MOE GEF UNEP UNITAR

# កំរងពត៌មានជាតិ ស្តីពី ការគ្រប់គ្រងសារធាតុគីមីនៅកម្ពុជា




**រៀបចំដោយ** : គំរោងពង្រឹងសមត្ថភាពរៀបចំផែនការជាតិសំរាប់អនុវត្តន៍អនុសញ្ញា ស្តុកខូម ស្តីពីសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ

ក្រសួងបរិស្ថាន

ភ្នំពេញ ធ្នូ ២០០៤

MoE GEF UNEP UNITAR

# កំរងពត៌មានជាតិ

# ស្តីពី

# ការគ្រប់គ្រងសារធាតុគីមីនៅកម្ពុជា

រៀបចំដោយ : គំរោងពង្រឹងសមត្ថភាពរៀបចំផែនការជាតិអនុវត្តន៍អនុសញ្ញា ស្តុកខូម

ផ្តល់មូលនិធិដោយ : មូលនិធិបរិស្ថានពិភពលោក

ប្រឹក្សាបច្ចេកទេសដោយ : កម្មវិធីបរិស្ថានសហប្រជាជាតិ និងវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវសហប្រជាជាតិ

CAMBODIA: NIP PROJECT FOR
STOCKHOLM CONVENTION ON POPS
Project No: GF/2732-03-4642

ក្រសួងបរិស្ថាន

ធ្នូ ២០០៤

សៀវភៅ **កំរងពត៌មានជាតិស្តីពី ការគ្រប់គ្រងសារធាតុគីមី** គឺជាឯកសារដែលបានរៀបចំឡើងដោយលោក **កាន់ វិបុល** អ្នកឯកទេសជាតិ ដោយមានការជួយសំរបសំរួលផ្នែកបច្ចេកទេសពីកម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP) និងមានការផ្តល់ប្រឹក្សាបច្ចេកទេសផ្ទាល់ពីវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវសហប្រជាជាតិ (UNITAR) ក្រោមការឧបត្ថម្ភថវិកាពីមូលនិធិបរិស្ថានពិភពលោក (GEF) តាមរយៈគំរោងពង្រឹងសមត្ថភាពរៀបចំផែនការជាតិ (NIP) សំរាប់អនុវត្តអនុសញ្ញា ស្តុកខូម ស្តីពី សារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ជាមួយនឹងការរួមវិភាគទានរបស់រាជរដ្ឋាភិបាលកម្ពុជា ។

សៀវភៅកំរងពត៌មានជាតិនេះបានបោះពុម្ពជាពីរភាសា ខ្មែរនិងអង់គ្លេស ដោយគំរោង NIP ក្រសួងបរិស្ថាននៃរាជរដ្ឋាភិបាលកម្ពុជា ហើយឯកសារនេះបានផ្តល់នូវពត៌មានដែលទាក់ទងទៅនឹងការគ្រប់គ្រងសារធាតុគីមី និងបញ្ហានានារបស់វា ដោយរួមបញ្ចូលនូវផ្នែកដ៏សំខាន់មួយទៀត គឺសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ (Persistent Organic Pollutants, POPs) ។ សៀវភៅកំរងពត៌មានជាតិនេះ នឹងត្រូវបានចាត់ទុកថាជាសមិទ្ធិផលលើកដំបូងនៃការប្រមូលផ្តុំចងក្រងនូវពត៌មាន និងទិន្នន័យសារធាតុគីមីដែលមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

សៀវភៅកំរងពត៌មានជាតិនេះ នឹងធ្វើការផ្តល់ដោយឥតគិតថ្លៃទៅរាល់អ្នកពាក់ព័ន្ធផលប្រយោជន៍រួម ដូចជា មន្ត្រីរដ្ឋាភិបាល ស្ថាប័នពាក់ព័ន្ធ អង្គការសង្គមស៊ីវិល បណ្ណាល័យ សាកលវិទ្យាល័យ អាជ្ញាធរដែនដី អង្គការអន្តរជាតិពាក់ព័ន្ធនានា និងប្រព័ន្ធផ្សព្វផ្សាយ ហើយអត្ថបទកំរងពត៌មានជាតិនេះក៏អាចអានបានតាមរយៈគេហ៍ទំព័រខាងក្រោមដោយឥតគិតថ្លៃ ។ សំរាប់ពត៌មានលំអិតទាក់ទងនឹងកំរងពត៌មាននេះ ឬករណីមានបំណងផ្តល់យោបល់កែតំរូវ សូមមេត្តាទំនាក់ទំនងតាមអាស័យដ្ឋានខាងក្រោម ។


គំរោងពង្រឹងសមត្ថភាពរៀបចំផែនការជាតិសំរាប់អនុវត្តអនុសញ្ញា ស្តុកខូម

នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន នៃក្រសួងបរិស្ថាន

អាគារលេខ ៤៨ វិថីសម្តេចព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ

ទូរស័ព្ទ : (៨៥៥) ២៣ ២១០ ៤៩២ / ២៣ ២២០ ៣៩២

**អ៊ីម៉ែល : moepcd@online.com.kh**

**nip_pops@online.com.kh**

**គេហ៍ទំព័រ : www.moe.gov.kh/cambodia-sc**


## សមាសភាពអ្នកចូលរួមរៀបចំកំរងពត៌មានជាតិ

| | | |
|---|---|---|
| ១- លោក ជា ស៊ីណា | មន្ត្រីសំរបសំរួលគំរោង | ក្រសួងបរិស្ថាន |
| ២- លោក កាន់ វិបុល | អ្នកឯកទេសជាតិ | ក្រសួងបរិស្ថាន |
| ៣- លោក ភត់ ស៊ិទ | មន្ត្រីជំនួយការគំរោង | ក្រសួងបរិស្ថាន |
| ៤- លោក ម៉ូយ វឌ្ឍនា | មន្ត្រីជំនួយការគំរោង | ក្រសួងបរិស្ថាន |
| ៥- លោក សារឿន កេសរា | មន្ត្រីសមភាគីគំរោង | ក្រសួងពាណិជ្ជកម្ម |
| ៦- លោក អ៊ិន ចាន់ថា | មន្ត្រីសមភាគីគំរោង | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៧- លោក សួ វាសនា | មន្ត្រីសមភាគីគំរោង | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| ៨- លោក អៀង សុខគី | មន្ត្រីសមភាគីគំរោង | ក្រសួងសុខាភិបាល |
| ៩- លោក ប៊ុណ្ណ ខ្លា | មន្ត្រីសមភាគីគំរោង | ក្រសួងបរិស្ថាន |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សារលិខិត

## របស់សម្ដេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា
## ការប្តេជ្ញាចិត្តផ្នែកនយោបាយក្នុងការគាំទ្រចំពោះការគ្រប់គ្រងសារធាតុគីមី

នេះជាកិត្តិយសដ៏ថ្លៃថ្លា និងមោទនភាពបំផុតរបស់កម្ពុជា ដោយបានបង្ហាញនូវកំរងពត៌មានជាតិ ស្តីពី "ការគ្រប់គ្រងសារធាតុគីមីនៅកម្ពុជា " នៅចំពោះជាតិ និងសហគមន៍អន្តរជាតិ ។ រាជរដ្ឋាភិបាលកម្ពុជាសូមស្វាគមន៍យ៉ាងកក់ក្តៅបំផុតចំពោះការបោះពុម្ពផ្សាយជាលើកទីមួយនូវកំរងពត៌មានជាតិដ៏ពេញលេញរបស់កម្ពុជាយើងក្នុង "ការគ្រប់គ្រងសារធាតុគីមីនៅកម្ពុជា" ។

ខ្ញុំមានជំនឿថា អ្នករៀបចំឯកសាររបស់យើងបានរៀបរាប់យ៉ាងច្រើនហើយនូវវិស័យនានា ដូចជា កសិកម្ម ឧស្សាហកម្ម សុខាភិបាល បរិស្ថាន ពាណិជ្ជកម្ម ។ល។ ថាកម្ពុជាយើងបានយកចិត្តទុកដាក់យ៉ាងខ្លាំងដល់កិច្ចការពារបរិស្ថាន ការលើកស្ទួយសុខុមាលភាពរបស់ប្រជាពលរដ្ឋ ឱ្យជៀសផុតពីឥទ្ធិពលគ្រោះថ្នាក់ដែលបង្កដោយសារធាតុគីមី ហើយកំពុងបន្តនូវគំនិតនិងសកម្មភាពការងារជាច្រើនទៀតដែលទាក់ទងជាពិសេសដល់បញ្ហាសារធាតុគីមី ។ ខ្ញុំសូមបញ្ជាក់ថែមទៀតថា នាពេលបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាមិនបានចាត់ទុកថាសារធាតុគីមីទូទៅ ក៏ដូចជាសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ គឺជាប្រភពដែលត្រូវចាយវាយជាដុំកំភួននោះទេ ផ្ទុយទៅវិញយើងបានបង្កើនការចំណាយរបស់យើងជារៀងរាល់ឆ្នាំទៅលើផ្នែកគាំពារសុខភាពសាធារណៈ ដែលមួយផ្នែកអាចទទួលរងនូវផលប៉ះពាល់បង្កដោយការគ្រប់គ្រងសារធាតុគីមីមិនទាន់បានល្អ ដូចជា ការប្រើប្រាស់ពុំបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងភាពខ្វះខាតនូវចំណេះដឹងរបស់ពលរដ្ឋយើងពីគ្រោះថ្នាក់នៃសារធាតុគីមី ។

ជាសក្ខីភាពនៃជំហររបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការចូលរួមជាមួយសហគមន៍អន្តរជាតិ សំដៅទប់ស្កាត់គ្រោះថ្នាក់ទៅលើសុខភាពនិងបរិស្ថានដែលបង្កដោយសារធាតុគីមី កម្ពុជាមានក្តីសោមនស្សរីករាយបានចុះហត្ថលេខាគាំទ្រអនុសញ្ញា ស្តុកខូម ស្តីពីសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ នាថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០០១ ។ ខ្ញុំសូមអះអាងជាថ្មីម្តងទៀតថា រាជរដ្ឋាភិបាលកម្ពុជាមានឆន្ទៈយ៉ាងពេញលេញក្នុងការផ្តល់សច្ចាប័នលើអនុសញ្ញា ស្តុកខូម នាពេលឆាប់ៗខាងមុខនេះ ។

ជាការពិតណាស់ថា កំរងពត៌មានជាតិនេះជាជំហានដ៏សំខាន់មួយឆ្ពោះទៅរកការគ្រប់គ្រងសារធាតុគីមីប្រកបដោយសុវត្ថិភាពបរិស្ថាន ប៉ុន្តែ យើងនៅមានជំហានបន្ទាប់ទៀតដែលត្រូវបំពេញ គឺការរៀបចំផែនការគ្រប់គ្រងសារធាតុគីមី និងការអនុវត្តផែនការនោះឱ្យទទួលបានជោគជ័យ ។ ទន្ទឹមនោះ រាជរដ្ឋាភិបាលក៏នឹងពិនិត្យមើលឡើងវិញនូវគ្រប់ទិដ្ឋភាពផ្នែកច្បាប់បរិស្ថានកម្ពុជា រួមទឹង

ទស្សនៈវិស័យផ្នែកច្បាប់ពាក់ព័ន្ធការគ្រប់គ្រងសារធាតុគីមីនានា ដើម្បីធានានូវការអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាព និងឆ្លើយតបជាមួយកិច្ចព្រមព្រៀងអន្តរជាតិនានា និងតាមការតំរូវរបស់អនុសញ្ញា ស្តុកខូម ស្តីពីសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ។

ខ្ញុំមានភាពប្រាកដក្នុងចិត្តថាកំរងពត៌មានជាតិនេះ នឹងជួយធ្វើឱ្យការប្តេជ្ញាចិត្តរបស់កម្ពុជាឈានដល់គោលដៅនៃការគ្រប់គ្រងសារធាតុគីមីប្រកបដោយភាពល្អប្រសើរ ។ កំរងពត៌មានជាតិនេះនឹងផ្តល់នូវពត៌មាន និងទិន្នន័យសំខាន់ៗដល់អ្នកពាក់ព័ន្ធផលប្រយោជន៍នានាឱ្យយល់ និងប្រើប្រាស់ជាឧបករណ៍សំរាប់គ្រប់គ្រងសារធាតុគីមី និងធ្វើឱ្យប្រសើរឡើងដល់សុខភាពប្រជាពលរដ្ឋ ព្រមទាំងលើកស្ទួយគុណភាពបរិស្ថានទាំងបច្ចុប្បន្នកាល និងអនាគតសំរាប់កូនចៅជំនាន់ក្រោយ ។ រាជរដ្ឋាភិបាលចាត់ទុកថា កំរងពត៌មានជាតិនេះគឺជាឯកសារមួយអាចរួមចំណែកយ៉ាងសំខាន់ដល់ភាពល្អប្រសើរនៃសុខភាព និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។

ជូនមុខឱ្យប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមសំដែងនូវការដឹងគុណដ៏ជ្រាលជ្រៅចំពោះមូលនិធិបរិស្ថានពិភពលោក (GEF) កម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP) និងវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវសហប្រជាជាតិ (UNITAR) ដែលបានផ្តល់ការគាំទ្រទាំងជំនួយបច្ចេកទេសនិងហិរញ្ញវត្ថុ ព្រមទាំងការសំរបសំរួលផ្សេងៗក្នុងការរៀបចំឯកសារកំរងពត៌មានជាតិនេះ។ ទន្ទឹមនេះ ខ្ញុំសូមធ្វើការកោតសរសើរដោយស្មោះនិងប្រកបដោយក្តីមោទនភាពជាតិ ចំពោះក្រសួងបរិស្ថាន អនុគណៈកម្មការអន្តរក្រសួងសំរបសំរួលការអនុវត្តអនុសញ្ញា ស្តុកខូម ក្រុមសំរបសំរួលគំរោង ព្រមទាំងស្ថាប័នរដ្ឋនានា បណ្តាអង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធទាំងអស់ និងចំពោះអ្នកឯកទេសជាតិរៀបរៀងឯកសារនេះ ដោយបានបំពេញនូវការងារដ៏ធំធេងជូនជាតិនិងប្រជាពលរដ្ឋ និងសំរេចនូវសមិទ្ធិផលដ៏មានសារៈសំខាន់នេះ គឺសៀវភៅកំរងពត៌មានជាភាសាជាតិ និងភាសាអង់គ្លេស ។

រាជរដ្ឋាភិបាលកម្ពុជាសូមប្រកាសយ៉ាងឱឡារិកថា គាំទ្រយ៉ាងពេញទំហឹងចំពោះកំរងពត៌មានជាតិស្តីពី **ការគ្រប់គ្រងសារធាតុគីមីនៅកម្ពុជា** នេះ និងគាំទ្រដល់នយោបាយគ្រប់គ្រងសារធាតុគីមីប្រកបដោយសុវត្ថិភាព ពិសេសសកម្មភាពនានាដទៃទៀតដែលជាការឆ្លើយតបទៅនឹងការបំពេញកាតព្វកិច្ចរបស់កម្ពុជាក្រោមអនុសញ្ញា ស្តុកខូម ហើយបន្តការអនុវត្ត និងប្រើប្រាស់គ្រប់មធ្យោបាយដែលអាចមាន ធ្វើយ៉ាងណាសំរេចឱ្យបាននូវគោលដៅដែលកំណត់ដោយអនុសញ្ញា ។

ភ្នំពេញ ថ្ងៃទី ១៧ ខែមករា ឆ្នាំ២០០៥

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

ហ៊ុន សែន

# សារថ្លែងអំណរគុណ



កំរងពត៌មានជាតិស្តីពី ការគ្រប់គ្រងសារធាតុគីមីនៅកម្ពុជា ដែលបានរៀបចំឡើងនេះ គឺជាការឆ្លើយតបទៅនឹងក្តីកង្វល់នានារបស់កម្ពុជាក្នុងបរិបទនៃការគ្រប់គ្រងសារធាតុគីមី ពិសេសក្នុងការបំពេញកាតព្វកិច្ចអនុវត្តអនុសញ្ញា ស្តុកខូម ស្តីពីសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ។ កំរងពត៌មានជាតិនេះ មិនមែនជាឯកសារសំរាប់ការបង្រៀនដល់សិស្ស និស្សិត ឬសាធារណជនជាទូទៅឡើយ តែវាជាឯកសារដែលផ្តល់នូវពត៌មានដ៏ទូលំទូលាយ ដែលទាក់ទងដល់ប្រធានបទនៃការគ្រប់គ្រងនិងត្រួតពិនិត្យសារធាតុគីមី ហើយដែលវាជាទុនមូលដ្ឋានសំរាប់ឈានទៅរៀបចំផែនការអនុវត្តជាតិលើការគ្រប់គ្រងសារធាតុគីមី ប្រកបដោយសុវត្ថិភាពបរិស្ថាន ។ ទន្ទឹមនោះ វាក៏ជាការបញ្ជាក់ពីលទ្ធភាពនិងសមត្ថភាពរបស់កម្ពុជា ក្នុងការចងក្រងកំរងពត៌មានជាតិនេះដែរ ។

កំរងពត៌មានជាតិនេះមានអត្ថប្រយោជន៏សំរាប់ប្រជាពលរដ្ឋ រាជរដ្ឋាភិបាលកម្ពុជា អ្នកប្រើប្រាស់សារធាតុគីមី អ្នកត្រួតពិនិត្យ អ្នកគ្រប់គ្រង និងសាធារណជន ព្រមទាំងអង្គការសង្គមស៊ីវិលនានា ក្នុងការកំណត់ចក្ខុវិស័យសំរាប់គ្រប់គ្រងសារធាតុគីមីក្នុងបរិបទកម្ពុជានាពេលអនាគត ។ ចំពោះវិធីសាស្ត្រ និងទស្សនាទានដែលបានយកមកប្រើក្នុងការរៀបចំ គឺមានលក្ខណៈទូទៅដែលអាចអនុវត្តបាន និងអាចប្រើប្រាស់បានក្នុងស្ថានភាពគ្រប់គ្រងសារធាតុគីមីនៅកម្ពុជានាពេលបច្ចុប្បន្ន ។ កំរងពត៌មានជាតិនេះនឹងផ្តល់ដល់អ្នកអាននូវគំនិតជាមូលដ្ឋានក្នុងការអនុវត្តឱ្យបានម៉ត់ចត់ ដោយផ្អែកលើទំរង់គោលការណ៍ណែនាំដែលបានផ្តល់ឱ្យដោយកម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP) និងវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវសហប្រជាជាតិ (UNITAR) សំរាប់ការរៀបចំកំរងពត៌មានជាតិនេះ ។ ការពិភាក្សា និងការពិគ្រោះយោបល់ដែលមានក្នុងឯកសារនេះ គឺមានលក្ខណៈជាទស្សនាទានបរិស្ថានសេដ្ឋកិច្ច និងការគ្រប់គ្រង ដែលសំដៅលើសារធាតុគីមីទូទៅដែលមានវត្តមាននៅកម្ពុជា។ កំរងពត៌មានជាតិនេះ មានគោលបំណងផ្តល់ជាអត្ថបទជំនួយស្មារតី និងជាឯកសារពិគ្រោះសំរាប់រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផលប្រយោជន៏នានាក្នុងការងារកសិកម្ម ពាណិជ្ជកម្ម សេដ្ឋកិច្ច បរិស្ថាន ព្រៃឈើ ជលផល ឧស្សាហកម្ម សុខភាព អភិវឌ្ឍន៏ជនបទ វិជ្ជាជីវៈ ការទប់ស្កាត់ថ្នាំញៀន ការរៀបចំផែនការនិងការរៀបចំវាយតំលៃ និងការគ្រប់គ្រងគំរោង ។ល។ ទន្ទឹមគ្នានេះ កំរងពត៌មានជាតិ នឹងផ្តល់ជាប្រយោជន៏ដល់អ្នកគ្រប់គ្រងសារធាតុគីមីដែលមិនមានឱកាសក្នុងការប្រមូលនិងស្រាវជ្រាវពីទិន្នន័យគីមីសំខាន់ៗ ក្នុងគោលបំណងគ្រប់គ្រង ។

តាងនាមថ្នាក់ដឹកនាំក្រសួងបរិស្ថាននិងក្នុងនាមខ្ញុំផ្ទាល់ សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់កម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP) និងមូលនិធិបរិស្ថានពិភពលោក (GEF) ដែលបានផ្តល់ការគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដើម្បីរៀបចំចងក្រងកំរងពត៌មានជាតិស្តីពី ការគ្រប់គ្រងសារធាតុគីមីនៅកម្ពុជា នេះឡើង ។ ខ្ញុំក៏សូមសំដែងនូវអំណរគុណចំពោះវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវសហប្រជាជាតិ (UNITAR) ដែលបានចូលរួមវិភាគទានដ៏មានតំលៃ និងជួយសំរបសំរួលក្នុងរៀបចំចងក្រងកំរងពត៌មានជាតិនេះរហូតបានសំរេចនាពេលនេះ ។

ជាពិសេសបំផុត ខ្ញុំសូមគោរពសំដែងនូវការដឹងគុណដ៏ជ្រាលជ្រៅចំពោះសម្តេច **ហ៊ុន សែន** ជាប្រមុខដឹកនាំដ៏ឈ្លាសវៃនៃរាជរដ្ឋាភិបាលកម្ពុជា ដែលជានិច្ចកាលតែងបានផ្តល់ការគាំទ្រយ៉ាងពេញទំហឹងដល់សកម្មភាពបរិស្ថាននានា រួមមានកិច្ចការពារគុណភាពបរិស្ថាន និងការអភិរក្សធនធានធម្មជាតិ ហើយថ្មីៗនេះបានផ្តល់នូវការគាំទ្រដល់ដំណើរការរៀបចំចងក្រងកំរងពត៌មានជាតិនេះ ឱ្យទទួលបានជោគជ័យគួរជាទីមោទនៈរបស់ជាតិ ។ ទន្ទឹមនេះ ខ្ញុំសូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំស្ថាប័នពាក់ព័ន្ធនានា

ដែលបានផ្តល់ការគាំទ្រយ៉ាងកក់ក្តៅ និងដោយយកចិត្តទុកដាក់ តាមរយៈការផ្តល់មន្ត្រីជំនាញបច្ចេកទេសចូលរួមជាសមភាគីក្នុងការជួយរៀបចំ និងចូលរួមពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងនៃកំរងពតិមានជាតិនេះ ។ ជាមួយគ្នានេះ ខ្ញុំក៏សូមសំដែងនូវការកោតសរសើរ និងអំណរគុណ ដល់អនុគណៈកម្មការអន្តរក្រសួងសំរបសំរួលការអនុវត្តអនុសញ្ញា ស្តុកខូម ក្រុមសំរបសំរួលគំរោងរៀបចំផែនការជាតិសំរាប់អនុវត្តន៍អនុសញ្ញា ស្តុកខូម និងជំនាញការជាតិ ដែលបានខិតខំប្រឹងប្រែងក្នុងការប្រមូលទិន្នន័យ រៀបចំពិនិត្យ និងកែសំរួលឯកសារកំរងពតិមានជាតិ ទាំងភាសាខ្មែរ និងភាសាអង់គ្លេស ឱ្យសំរេចបានតាមផែនការដែលបានគ្រោងទុក ។

ជាចុងក្រោយនេះ តាងនាមថ្នាក់ដឹកនាំក្រសួងបរិស្ថាន ខ្ញុំសូមបញ្ជាក់ថាក្រសួងបរិស្ថាននឹងខិតខំបង្កើនកិច្ចសហប្រតិបត្តិការជាមួយក្រសួងពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិនានាដើម្បីសំរេចឱ្យបាននូវការរៀបចំផែនការជាតិ សំរាប់អនុវត្តអនុសញ្ញា ស្តុកខូម ស្តីពី សារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ហើយក៏មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា កំរងពតិមានជាតិនេះ នឹងជួយបំពេញនូវកង្វះខាតក្នុងការគ្រប់គ្រងសារធាតុគីមីដែលជាសេចក្តីត្រូវការរបស់រាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងអ្នកប្រើប្រាស់សារធាតុគីមី ហើយនឹងនាំមកឱ្យប្រជាពលរដ្ឋកម្ពុជានូវសុខុមាលភាព និងភាពសំបូរសប្បាយ ។

ក្រសួងបរិស្ថានសូមការអភ័យទោសចំពោះអ្នកអានទាំងឡាយប្រសិនបើមានការខុសឆ្គង និងភាន់ច្រឡំនូវប្រការណាមួយដោយអចេតនា និងសូមទទួលយកនូវការរិះគន់ស្ថាបនាពីគ្រប់មជ្ឈដ្ឋានដោយក្តីសោមនស្សរីករាយបំផុត ។

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែធ្នូ ឆ្នាំ២០០៤

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ម៉ុក_ម៉ារ៉េត**

បណ្ឌិត.ជីវវិទ្យា

# មាតិកា

**មាតិកា** ---------- i

**បញ្ជីតារាង** ---------- v

**អក្សរកាត់** ---------- viii

**មូលបទសង្ខេប** ---------- x

**សេចក្តីផ្តើម** ---------- xi

**ជំពូកទី ១ : ពត៌មានមូលដ្ឋានជាតិ** ---------- ១

១.១ បរិបទរូបសាស្ត្រ និងប្រជាសាស្ត្រ ---------- ១

១.២ រចនាសម្ព័ន្ធនយោបាយ និងភូមិសាស្ត្រ ---------- ៩

១.៣ វិស័យកសិកម្ម និងឧស្សាហកម្មនៅកម្ពុជា ---------- ១០

*១.៣.១ វិស័យកសិកម្ម ---------- ១០*

*១.៣.២ វិស័យឧស្សាហកម្ម ---------- ១៥*

*១.៣.៣ សង្ខេបវិស័យកសិកម្ម និងឧស្សាហកម្ម ---------- ១៨*

**ជំពូកទី ២ : ការផលិត នាំចូល នាំចេញ និងការប្រើប្រាស់សារធាតុគីមី** ---------- ២១

២.១ ជីគីមី ---------- ២២

២.២ ថ្នាំកសិកម្ម ---------- ២៣

*២.២.១ ការនាំចូលថ្នាំសំលាប់សត្វល្អិតសំរាប់គោលបំណងសុខភាពសាធារណៈ ---------- ៣៧*

*២.២.២ បញ្ជីថ្នាំកសិកម្មដែលអនុញ្ញាតឲ្យប្រើ និងដែលមានល័ក្ខខ័ណ្ឌ ---------- ៣៨*

២.៣ សារធាតុគីមីសំរាប់វិស័យឱសថ ---------- ៤២

២.៤ សារធាតុគីមីសំរាប់វិស័យឧស្សាហកម្ម ---------- ៤៥

២.៥ ផលិតផលលោហធាតុ និងសមាសធាតុរបស់វា ---------- ៦៦

២.៦ ឥន្ធនៈរ៉ែ និងផលិតផលប្រេងឥន្ធនៈ ---------- ៦៦

២.៧ ផលិតផលគីមីសំរាប់ប្រើតាមលំនៅឋាន ---------- ៦៨

២.៨ សារធាតុគីមីសំរាប់មន្ទីរពិសោធន៍ ---------- ៦៨

២.៩ សំណល់សារធាតុគីមី ---------- ៧៨

២.១០ សារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ---------- ៧៩

*២.១០.១ ថ្នាំកសិកម្មប្រភេទសរីរាង្គមិនងាយបំបែកធាតុ ---------- ៧៩*

*២.១០.២ សារធាតុគីមី ភីស៊ីប៊ី (Polychlorinated Biphenyls, PCBs) ---------- ៧៩*

*២.១០.៣ សារធាតុថ្នាំ ដេដេតេ សំរាប់ការត្រួតពិនិត្យសុខភាពសាធារណៈ ---------- ៨០*

*២.១០.៤ អនុផលមិនបានការប្រកេទសរីរាង្គមិនងាយបំបែកធាតុ ------------------------------ ៨២*

២.១១ សារធាតុគីមីប្រើប្រាស់តាមចំណាត់ថ្នាក់ ------------------------------ ៨៥

**ជំពូកទី ៣ : បញ្ហាជាអាទិភាពដែលទាក់ទងទៅនឹងការផលិត នាំចូល នាំចេញ និងការប្រើប្រាស់សារធាតុគីមី ............................ ៨៧**

៣.១ ទិដ្ឋភាពរួមនៃបញ្ហាទាក់ទងនឹងសារធាតុគីមី ------------------------------ ៨៧

៣.២ បញ្ហាជាអាទិភាពទាក់ទងនឹងសារធាតុគីមី ------------------------------ ៨៩

៣.៣ យោបល់ និងការវិភាគ ------------------------------ ៩០

**ជំពូកទី ៤ : បរិធានច្បាប់ និងយន្តការដែលមិនស្ថិតក្នុងក្របខ័ណ្ឌច្បាប់សំរាប់គ្រប់គ្រងសារធាតុគីមី..... ៩១**

៤.១ ទិដ្ឋភាពរួមនៃបរិធានច្បាប់ជាតិដែលទាក់ទងការគ្រប់គ្រងសារធាតុគីមី ------------------------------ ៩១

៤.២ បទបញ្ញត្តិសំខាន់ៗ នៃបរិធានច្បាប់ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសារធាតុគីមី ------------------------------ ៩៥

៤.៣ បទបញ្ញត្តិនៃបរិធានច្បាប់លើវដ្តនៃសារធាតុគីមី ------------------------------ ១០២

៤.៤ ដំណោះស្រាយ និងនិតិវិធីក្នុងការគ្រប់គ្រងសារធាតុគីមី ------------------------------ ១០២

*៤.៤.១ និតិវិធីនៃការនាំចូលសារធាតុគីមី (លិខិតប្រតិវេទនៃការនាំចូលទាក់ទងទៅនឹងបញ្ហាគុណភាពនិងសុវត្ថិភាព) ---- ១០២*

*៤.៤.២ និតិវិធីនៃការធ្វើអាជីវកម្មជីគីមី និងថ្នាំកសិកម្ម ------------------------------ ១០៤*

*៤.៤.៣ បញ្ជីថ្នាំកសិកម្មដែលហាមឃាត់មិនឱ្យប្រើប្រាស់នៅកម្ពុជា ------------------------------ ១០៥*

*៤.៤.៤ បញ្ជីសារធាតុគីមីដែលស្ថិតក្រោមការដាក់កំរិតតឹងតែង ------------------------------ ១០៨*

៤.៥ យន្តការដែលមិនស្ថិតក្នុងក្របខ័ណ្ឌច្បាប់ (Non-regulatory mechanism) ------------------------------ ១០៨

៤.៦ យោបល់ និងការវិភាគ ------------------------------ ១០៩

**ជំពូកទី ៥ : ស្ថាប័នរដ្ឋពាក់ព័ន្ធក្នុងការគ្រប់គ្រងសារធាតុគីមី ............................ ១១១**

៥.១ ស្ថាប័នរដ្ឋ និងការទទួលខុសត្រូវលើការគ្រប់គ្រងសារធាតុគីមី ------------------------------ ១១១

៥.២ ភារកិច្ចរបស់ស្ថាប័នរដ្ឋទាក់ទងនឹងការគ្រប់គ្រងសារធាតុគីមី ------------------------------ ១១២

*៥.២.១ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ------------------------------ ១១២*

*៥.២.២ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ------------------------------ ១១២*

*៥.២.៣ ក្រសួងពាណិជ្ជកម្ម ------------------------------ ១១៣*

*៥.២.៤ ក្រសួងបរិស្ថាន ------------------------------ ១១៣*

*៥.២.៥ ក្រសួងសុខាភិបាល ------------------------------ ១១៣*

*៥.២.៦ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ------------------------------ ១១៣*

*៥.២.៧ ក្រសួងមហាផ្ទៃ ------------------------------ ១១៣*

៥.៣ កម្មវិធីការងារពាក់ព័ន្ធការគ្រប់គ្រងសារធាតុគីមីរបស់ស្ថាប័នរដ្ឋ ------------------------------ ១១៤

៥.៤ យោបល់ និងការវិភាគ ------------------------------ ១១៧

**ជំពូកទី ៦ : សកម្មភាពពាក់ព័ន្ធរបស់ផ្នែកឯកជន អង្គការមិនមែនរដ្ឋាភិបាលនិងក្រុមស្រាវជ្រាវ ~~~ ១១៩**

៦.១ ការចូលរួមរបស់សង្គមស៊ីវិលក្នុងសកម្មភាពគ្រប់គ្រងសារធាតុគីមី ------------------------------- ១១៩

*៦.១.១ កម្មវិធីការងាររបស់ផ្នែកឯកជនដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសារធាតុគីមី ---------------------- ១១៩*

*៦.១.២ កម្មវិធីការងាររបស់អង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធការគ្រប់គ្រងសារធាតុគីមី ---------------------- ១២០*

*៦.១.៣ សេវាកម្មជំនាញនៅក្រៅស្ថាប័នរដ្ឋ ---------------------------------------------- ១២១*

៦.២ យោបល់ និងការវិភាគ ---------------------------------------------------- ១២២

**ជំពូកទី ៧ : គណៈកម្មការអន្តរក្រសួង ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ១២៣**

៧.១ គណៈកម្មការអន្តរក្រសួង ---------------------------------------------------- ១២៣

៧.២ យន្តការសំរាប់ទទួលមតិយោបល់ពីសង្គមស៊ីវិល ------------------------------------- ១២៧

*៧.២.១ ការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាល ------------------------------------------- ១២៧*

*៧.២.២ ការចូលរួមរបស់សាធារណជន ------------------------------------------------ ១២៨*

៧.៣ យោបល់ និងការវិភាគ ---------------------------------------------------- ១២៨

**ជំពូកទី ៨ : ការទទួលបាន និងការប្រើប្រាស់ទិន្នន័យ ~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ១២៩**

៨.១ ទិន្នន័យដែលមានសំរាប់ការគ្រប់គ្រងសារធាតុគីមី ------------------------------------- ១២៩

៨.២ ទីកន្លែងទិន្នន័យជាតិ -------------------------------------------------------- ១៣០

៨.៣ នីតិវិធីសំរាប់ប្រមូល និងចែកចាយទិន្នន័យជាតិ ------------------------------------- ១៣៤

៨.៤ លទ្ធភាពរកឯកសារពត៌មានអន្តរជាតិ --------------------------------------------- ១៣៤

៨.៥ លទ្ធភាពរកទិន្នន័យមូលដ្ឋានអន្តរជាតិ --------------------------------------------- ១៣៦

៨.៦ ប្រព័ន្ធផ្លាស់ប្តូរពត៌មានជាតិ ------------------------------------------------------ ១៣៦

៨.៧ យោបល់ និងការវិភាគ ---------------------------------------------------- ១៣៧

**ជំពូកទី ៩ : រចនាសម្ព័ន្ធបច្ចេកទេស ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ១៣៩**

៩.១ រចនាសម្ព័ន្ធមន្ទីរពិសោធន៍សារធាតុគីមី -------------------------------------------- ១៣៩

*៩.១.១ មន្ទីរពិសោធន៍នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ----------------------------- ១៣៩*

*៩.១.២ មន្ទីរពិសោធន៍នៃក្រសួងពាណិជ្ជកម្ម --------------------------------------------- ១៤០*

*៩.១.៣ មន្ទីរពិសោធន៍នៃក្រសួងបរិស្ថាន ---------------------------------------------- ១៤០*

*៩.១.៤ មន្ទីរពិសោធន៍នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ---------------------------------- ១៤០*

*៩.១.៥ មន្ទីរពិសោធន៍ជាតិត្រួតពិនិត្យគុណភាពឱសថនៃក្រសួងសុខាភិបាល ------------------------- ១៤០*

*៩.១.៦ មន្ទីរពិសោធន៍នៃក្រសួងធនធានទឹកនិងឧតុនិយម ------------------------------------ ១៤០*

៩.២ ប្រព័ន្ធពត៌មាន និងសមត្ថភាពកុំព្យូទ័រ ------------------------------------------- ១៤២

៩.៣ កម្មវិធីអប់រំ និងការបណ្តុះបណ្តាលបច្ចេកទេស ---------- ១៤៣

៩.៤ យោបល់ និងការវិភាគ ---------- ១៤៤

**ជំពូកទី ១០ : ការយល់ដឹងរបស់កម្មករ កសិករ និងសាធារណជន ~~~~~~~~~~ ១៤៥**

១០.១ ពត៌មានសំរាប់កម្មករ និងកសិករ ---------- ១៤៥

១០.២ ពត៌មានសំរាប់សាធារណជន ---------- ១៤៥

១០.៣ ការលើកកំពស់ចំណេះដឹងរបស់សាធារណជន ---------- ១៤៦

១០.៤ សកម្មភាពអប់រំពីសារធាតុគីមីនាពេលអនាគត ---------- ១៤៧

១០.៥ យោបល់ និងការវិភាគ ---------- ១៤៨

**ជំពូកទី ១១ : ទំនាក់ទំនងអន្តរជាតិ ~~~~~~~~~~ ១៤៩**

១១.១ កិច្ចសហប្រតិបត្តិការ និងការចូលរួមជាមួយអង្គការអន្តរជាតិ និងកិច្ចព្រមព្រៀងនានា ---------- ១៤៩

១១.២ ការចូលរួមក្នុងគំរោងជំនួយបច្ចេកទេសដែលពាក់ព័ន្ធ ---------- ១៥២

១១.៣ យោបល់ និងការវិភាគ ---------- ១៥៩

**ឯកសារយោង ~~~~~~~~~~ ១៦១**

# បញ្ជីតារាង

តារាង ១-១ : ផលិតកម្មដំណាំ និងផ្ទៃដីដាំដុះ ( ឆ្នាំ២០០០-២០០២) ---------- ១០

តារាង ១-២ : របនាសម្ព័ន្ធផ្នែកក្សេត្រសាស្ត្រ ( ឆ្នាំ២០០២) ---------- ១១

តារាង ១-៣ : ផលិតកម្មបសុបក្សី និងបសុសត្វ ( ឆ្នាំ២០០០-២០០២) ---------- ១២

តារាង ១-៤ : របនាសម្ព័ន្ធផលិតកម្មបសុបក្សី និងបសុសត្វ ( ឆ្នាំ២០០២) ---------- ១២

តារាង ១-៥ : ផលិតកម្មជលផល ( ឆ្នាំ២០០០-២០០២) ---------- ១៣

តារាង ១-៦ : របនាសម្ព័ន្ធផ្នែកជលផល ( ឆ្នាំ២០០២) ---------- ១៣

តារាង ១-៧ : ផលិតកម្មរុក្ខកម្ម ( ឆ្នាំ២០០០-២០០២) ---------- ១៣

តារាង ១-៨ : របនាសម្ព័ន្ធផលិតកម្មរុក្ខកម្ម ( ឆ្នាំ២០០២) ---------- ១៤

តារាង ១-៩ : ផលិតកម្មកៅស៊ូ និងផ្ទៃដីដាំដុះ ( ឆ្នាំ២០០០-២០០២) ---------- ១៤

តារាង ១-១០ : ការប្រើប្រាស់ដីក្នុងវិស័យកសិកម្ម ( ឆ្នាំ២០០២) ---------- ១៤

តារាង ១-១១ : របនាសម្ព័ន្ធនៃឧស្សាហកម្ម និងសហគ្រាស ( ឆ្នាំ២០០០-២០០១) ---------- ១៥

តារាង ១-១២ : ទស្សនៈវិស័យទូទៅនៃផ្នែកសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា ( ឆ្នាំ២០០១) ---------- ១៨

តារាង ១-១៣ : និយោជិកនិងផលិតផលនៃផ្នែកសំខាន់ៗនៃវិស័យកសិកម្ម ( ឆ្នាំ២០០១) ---------- ១៩

តារាង ១-១៤ : និយោជិកនិងផលិតផលនៃផ្នែកសំខាន់ៗនៃវិស័យឧស្សាហកម្ម ( ឆ្នាំ២០០១) ---------- ១៩

តារាង ២-១ : បញ្ជីឈ្មោះនិងបរិមាណជីគីមីដែលបាននាំចូលមកកម្ពុជា ( ឆ្នាំ២០០២) ---------- ២២

តារាង ២-២ : ថ្នាំកសិកម្មដែលបាននាំចូលមកកម្ពុជាសំរាប់វិស័យកសិកម្ម ( ឆ្នាំ ២០០២) ---------- ២៣

តារាង ២-៣ : បញ្ជីថ្នាំកសិកម្មដែលមានវត្តមាននៅទីផ្សារកម្ពុជា ( ឆ្នាំ២០០៤) ---------- ២៤

តារាង ២-៤ : ថ្នាំសំលាប់សត្វល្អិតនាំចូលមកកម្ពុជាសំរាប់ត្រួតពិនិត្យភ្នាក់ងារចំលងជំងឺ ---------- ៣៨

តារាង ២-៥ : បញ្ជីឈ្មោះថ្នាំកសិកម្មអនុញ្ញាតឱ្យប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ---------- ៣៨

តារាង ២-៦ : បញ្ជីឈ្មោះថ្នាំកសិកម្មអនុញ្ញាតឱ្យប្រើប្រាស់ជាបណ្តោះអាសន្នដោយមានល័ក្ខខ័ណ្ឌនៅកម្ពុជា ---------- ៤១

តារាង ២-៧ : ប្រភេទនិងបរិមាណសារធាតុគីមីដែលនាំចូលជាវត្ថុធាតុដើមសំរាប់ផលិតឱសថ ( ឆ្នាំ២០០៣) ---------- ៤២

តារាង ២-៨ : ប្រភេទសារធាតុគីមីសរីរាង្គដែលបាននាំចូលសំរាប់វិស័យឧស្សាហកម្ម ( ឆ្នាំ២០០២) ---------- ៤៦

តារាង ២-៩ : ប្រភេទសារធាតុគីមីអសរីរាង្គដែលបាននាំចូលសំរាប់វិស័យឧស្សាហកម្ម ( ឆ្នាំ២០០២) ---------- ៤៦

តារាង ២-១០: ប្រភេទសារធាតុគីមីដែលនាំចូលសំរាប់ឧស្សាហកម្មជ្រលក់ពណ៌ ( ឆ្នាំ២០០២) ---------- ៤៧

តារាង ២-១១: ប្រភេទសារធាតុគីមីផ្សេងៗដែលនាំចូលសំរាប់បំរើវិស័យឧស្សាហកម្ម ( ឆ្នាំ២០០២) ---------- ៤៨

តារាង ២-១២: ប្រភេទសារធាតុគីមីដែលបាននាំចូលសំរាប់វិស័យឧស្សាហកម្ម ( ឆ្នាំ២០០៣) ---------- ៤៨

តារាង ២-១៣: ប្រភេទសារធាតុគីមីដែលបាននាំចូលសំរាប់វិស័យឧស្សាហកម្ម ( ឆ្នាំ២០០៤) ---------- ៥៧

តារាង ២-១៤: ផលិតផលលោហធាតុ និងសមាសធាតុរបស់វាដែលនាំចូល ( ឆ្នាំ២០០២) ---------- ៦៦

តារាង ២-១៥: ផលិតផលថាមពលចំហេះ និងប្រេងឥន្ធនៈដែលនាំចូល ( ឆ្នាំ២០០២) ---------- ៦៧
តារាង ២-១៦: ផលិតផលគីមីសំរាប់ប្រើតាមលំនៅឋានដែលនាំចូល ( ឆ្នាំ២០០២) ---------- ៦៨
តារាង ២-១៧: សារធាតុគីមីដែលមានប្រើនៅក្នុងមន្ទីរពិសោធន៍ ---------- ៦៨
តារាង ២-១៨: ប្រភេទនិងបរិមាណសំណល់សារធាតុគីមី ---------- ៧៨
តារាង ២-១៩: បរិមាណនៃការចែកចាយថ្នាំដេដេតេ និងកាលបរិច្ឆេទប្រគល់ទៅតាមខេត្ត-ក្រុង ---------- ៨១
តារាង ២-២០: បរិមាណសាយភាយប្រចាំឆ្នាំនៃឌីអុកស៊ីន និងហ្វូរ៉ាន់ ពីប្រភពសំខាន់ៗនៅកម្ពុជា ( ឆ្នាំ២០០៤) ---------- ៨៣
តារាង ២-២១: សង្ខេបសរុបផលិតផល និងការធ្វើពាណិជ្ជកម្មសារធាតុគីមី ---------- ៨៥

តារាង ៣-១ : ប្រភេទនៃបញ្ហាទាក់ទងនឹងសារធាតុគីមីនៅកម្ពុជា ---------- ៨៨
តារាង ៣-២ : លំដាប់អាទិភាពបញ្ហា និងកង្វល់ទាក់ទងនឹងសារធាតុគីមីនៅកម្ពុជា ---------- ៨៩

តារាង ៤-១ : បរិធានច្បាប់ដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសារធាតុគីមី ---------- ៩២
តារាង ៤-២ : បទបញ្ញត្តិសំខាន់ៗនៃបរិធានច្បាប់ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសារធាតុគីមី ---------- ៩៦
តារាង ៤-៣ : បរិធានច្បាប់សំរាប់គ្រប់គ្រងសារធាតុគីមី តាមប្រភេទនៃការប្រើប្រាស់ ---------- ១០២
តារាង ៤-៤ : បញ្ជីថ្នាំកសិកម្មដែលហាមឃាត់មិនឱ្យប្រើប្រាស់នៅកម្ពុជា ---------- ១០៥
តារាង ៤-៥ : បញ្ជីសារធាតុគីមីឧស្សាហកម្មដែលស្ថិតក្រោមការត្រួតពិនិត្យតឹងតែងក្នុងការនាំចេញ នាំចូលនិងចែកចាយ - ១០៨

តារាង ៥-១ : ការទទួលខុសត្រូវរបស់ស្ថាប័នរដ្ឋក្នុងដំណាក់កាលនៃវដ្តសារធាតុគីមី ---------- ១១២
តារាង ៥-២ : កម្មវិធីការងារដែលអនុវត្តដោយរដ្ឋាភិបាលក្នុងការគ្រប់គ្រងសារធាតុគីមី ---------- ១១៤

តារាង ៦-១ : កម្មវិធីការងាររបស់ផ្នែកឯកជនដែលទាក់ទងនឹងការគ្រប់គ្រងសារធាតុគីមី ---------- ១២០
តារាង ៦-២ : កម្មវិធីការងាររបស់អង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធការគ្រប់គ្រងសារធាតុគីមី ---------- ១២០
តារាង ៦-៣ : សេវាកម្មជំនាញនៅក្រៅស្ថាប័នរដ្ឋ ---------- ១២២

តារាង ៧-១ : គណៈកម្មការអន្តរក្រសួងពាក់ព័ន្ធនឹងការគ្រប់គ្រងសារធាតុគីមី ---------- ១២៤

តារាង ៨-១ : គុណភាព និងបរិមាណពត៌មានដែលអាចរកបាន ---------- ១២៩
តារាង ៨-២ : ទីកន្លែងពត៌មាន និងទិន្នន័យជាតិ ---------- ១៣១
តារាង ៨-៣ : លទ្ធភាពចូលរកសារពត៌មានអន្តរជាតិ ---------- ១៣៥
តារាង ៨-៤ : លទ្ធភាពរកទិន្នន័យមូលដ្ឋានអន្តរជាតិ ---------- ១៣៦

តារាង ៩-១ : រចនាសម្ព័ន្ធមន្ទីរពិសោធន៍សំរាប់វិភាគសារធាតុគីមី------------------------------------ ១៤១
តារាង ៩-២ : សមត្ថភាពប្រើប្រាស់កុំព្យូទ័រ ------------------------------------------------ ១៤២

តារាង ១០-១ : សកម្មភាពអប់រំពីសារធាតុគីមីក្នុងពេលអនាគត ------------------------------------ ១៤៧

តារាង ១១-១ : សមាជិកភាពក្នុងអង្គការអន្តរជាតិ និងកម្មវិធីនានាពាក់ព័ន្ធនឹងការគ្រប់គ្រងសារធាតុគីមី ---------- ១៤៩
តារាង ១១-២ : អនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិទាក់ទងនឹងសារធាតុគីមី -------------------- ១៥១
តារាង ១១-៣ : សកម្មភាពគំរោងរបស់កម្ពុជាពាក់ព័ន្ធសារធាតុគីមី ផ្នែកកសិកម្ម និងផ្នែកឧស្សាហកម្មក្រោម
គំរោងជំនួយរបស់អង្គការអន្តរជាតិ ---------------------------------------------- ១៥៣

# អក្សរកាត់

| | |
|---|---|
| AAS | Atomic Absorption Spectro-Photometer |
| ADB | Asian Development Bank<br>ធនាគារអភិវឌ្ឍន៍អាស៊ី |
| APIP | Agricultural Productive Improvement Project<br>គំរោងបង្កើនផលិតកម្មកសិកម្ម |
| ASEAN | Association of South East Asia Nations<br>សមាគមប្រជាជាតិអាស៊ីអគ្នេយ៍ |
| CAAEP | Cambodia-Australia Agricultural Extension Project<br>គំរោងការផ្សព្វផ្សាយកសិកម្មកម្ពុជា-អូស្ត្រាលី |
| CEDAC | Centre Étude et de Development Agricole Cambodgien<br>មជ្ឈមណ្ឌលអប់រំ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា |
| CIDA | Canadian International Development Agency<br>ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិកាណាដា |
| CSARO | Community Sanitation and Recycling Organization<br>អង្គការសមាគមអនាម័យ និងកែច្នៃសំណល់ |
| DANIDA | Danish International Development Agent<br>ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិដាណឺម៉ាក |
| ESCAP | Economic and Social Commission for Asia and the Pacific<br>គណៈកម្មការសេដ្ឋកិច្ចនិងសង្គមសំរាប់តំបន់អាស៊ីប៉ាស៊ីហ្វិក |
| ETAP | Environmental Technical Advisory Programme<br>កម្មវិធីប្រឹក្សាបច្ចេកទេសបរិស្ថាន |
| FAO | Food and Agriculture Organization<br>អង្គការស្បៀង និងកសិកម្ម |
| FP | Flame Photometer |
| GATT | General Agreement on Tariffs and Trade<br>កិច្ចព្រមព្រៀងទូទៅស្តីពីតារាងពន្ធគយនិងពាណិជ្ជកម្ម |
| GC | Gas Chromatography |
| GEF | Global Environmental Fund<br>មូលនិធិបរិស្ថានពិភពលោក |
| GINC | Global Information Network on Chemicals<br>បណ្តាញពត៌មានពិភពលោកស្តីពីសារធាតុគីមី |
| GLP | Good Laboratory Practice<br>កិច្ចប្រតិបត្តិមន្ទីរពិសោធន៍ល្អ |
| GSP | Generalized System of Preference<br>ប្រព័ន្ធអនុគ្រោះពន្ធ |
| HPLC | High Performance Liquid Chromatography |
| ICSDC | International Chemical Safety Data Cards<br>ប័ណ្ណទិន្នន័យសុវត្ថិភាពគីមីអន្តរជាតិ |
| IFCS | Inter-governmental Forum on Chemical Safety<br>វេទិការអន្តររដ្ឋាភិបាលស្តីពីសុវត្ថិភាពគីមី |
| ILO | International Labor Office<br>ការិយាល័យពលកម្មអន្តរជាតិ |
| INTOX | Information on Toxic<br>ពត៌មានពីភាពពុល |

| | |
|---|---|
| IPCS | International Programme on Chemical Safety<br>កម្មវិធីអន្តរជាតិស្តីពីសុវត្ថិភាពគីមី |
| IPM | Integrated Pest Management<br>ការគ្រប់គ្រងកត្តាចង្រៃដោយវិធានការចំរុះ |
| MoE | Ministry of Environment<br>ក្រសួងបរិស្ថាន |
| NAPA | Formulation of the National Adaptation Program of Action to Climate Change<br>គំរោងការរៀបចំកម្មវិធីសកម្មភាពជាតិដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ |
| NIP | National Implementation Plan<br>ផែនការអនុវត្តន៍ជាតិ (សំរាប់អនុវត្តន៍អនុសញ្ញា ស្តុកខូម) |
| OECD | Organization for Economic Co-operation and Development<br>អង្គការសំរាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ |
| PIC | Prior Informed Consent<br>ការព្រមព្រៀងផ្តល់ដំណឹងជាមុន |
| POPs | Persistent Organic Pollutants<br>សារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ |
| PTS | Persistent Toxic Substances<br>សារធាតុពុលមិនងាយបំបែកធាតុ |
| RDI | Resource Development International<br>អង្គការអភិវឌ្ឍន៍ធនធានអន្តរជាតិ |
| SP | Spectro-Photometer |
| STN | Scientific and Technical Information Network<br>បណ្តាញពត៌មានវិទ្យាសាស្ត្រ និងបច្ចេកទេស |
| TLC | Thin Layer Chromatography |
| UN | United Nations<br>អង្គការសហប្រជាជាតិ |
| UNDP | United Nations Development Programme<br>កម្មវិធីសហប្រជាជាតិសំរាប់ការអភិវឌ្ឍន៍ |
| UNEP | United Nations Environment Programme<br>កម្មវិធីសហប្រជាជាតិសំរាប់បរិស្ថាន |
| UNHCR | United Nations High Commission for Refugee<br>គណៈកម្មការជាន់ខ្ពស់នៃអង្គការសហប្រជាជាតិសំរាប់ជនភៀសខ្លួន |
| UNICEF | United Nations Children's Fund<br>មូលនិធិសហប្រជាជាតិសំរាប់កុមារ |
| UNIDO | United Nations Industrial Development Organization<br>អង្គការអភិវឌ្ឍន៍ឧស្សាហកម្មសហប្រជាជាតិ |
| UNITAR | United Nations Institute for Training and Research<br>វិទ្យាស្ថាននៃអង្គការសហប្រជាជាតិសំរាប់បណ្តុះបណ្តាលនិងស្រាវជ្រាវ |
| UV | Ultra-Violet Light |
| WB | World Bank<br>ធនាគារពិភពលោក |
| WHO | World Health Organization<br>អង្គការសុខភាពពិភពលោក |
| WTO | World Trade Organization<br>អង្គការពាណិជ្ជកម្មពិភពលោក |

# មូលបទសង្ខេប

ដូចគ្នាទៅនឹងប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀតដែរ ដើម្បីជំរុញភាពរីកចំរើននៃសង្គម កម្ពុជាបានធ្វើការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ចជាតិសំខាន់ៗ ដូចជា វិស័យកសិកម្ម ឧស្សាហកម្ម និងសុខាភិបាល ដែលនៅក្នុងសកម្មភាពនៃវិស័យទាំងនោះ គឺមានតំរូវការប្រើប្រាស់សារធាតុគីមីច្រើនប្រភេទ និងមានបរិមាណកើនឡើងជាលំដាប់ ពិសេសក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ។ សារធាតុគីមីដែលជាតំរូវការប្រើប្រាស់ទាំងនោះ ត្រូវបាននាំចូលទាំងស្រុងពីបរទេស និងបានចែកចាយទៅទីកន្លែងនិងផ្នែកដែលត្រូវការប្រើប្រាស់សារធាតុគីមីទាំងនោះ ។ ដូចនេះហើយ ទើបពត៌មានឬទិន្នន័យដែលទាក់ទងនឹងការនាំចូល ចែកចាយ ឬប្រើប្រាស់សារធាតុគីមីនៅកម្ពុជា គឺអាចមាននៅដោយឡែកៗពីគ្នាតាមស្ថាប័នទទួលខុសត្រូវ ឬអង្គភាពដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់សារធាតុគីមី ពោលគឺ ពត៌មានឬទិន្នន័យទាំងនោះពុំទាន់មានការប្រមូលផ្តុំចងក្រងជាឯកសារជាតិនៅឡើយទេសំរាប់កម្ពុជា ។ ការខ្វះនូវការប្រមូលចងក្រងជាឯកសារជាតិនៃពត៌មានឬទិន្នន័យសារធាតុគីមី គឺបានធ្វើឱ្យមានការលំបាកក្នុងការសិក្សាស្វែងយល់ពីស្ថានភាពនៃការគ្រប់គ្រងសារធាតុគីមីនៅក្នុងប្រទេស ពិសេសក្នុងការឈានទៅកំណត់ពីវិធានការគ្រប់គ្រងប្រកបដោយលក្ខណៈបច្ចេកទេស ដែលធានាមិនប៉ះពាល់ដល់សុខភាពសាធារណៈ និងបរិស្ថាន ។

ក្រោយការចុះហត្ថលេខារបស់កម្ពុជានាថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០០១ លើការអនុម័តអនុសញ្ញា **ស្តុកខូម ស្តីពីសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ** ហៅកាត់ជាភាសាអង់គ្លេសថា "**POPs**" ក្នុងចូលរួមជាមួយសហគមន៍អន្តរជាតិ ធាតុវិធានការអនុវត្តការកាត់បន្ថយនិងលុបបំបាត់សារធាតុ POPs កម្ពុជាបានទទួលការឧបត្ថម្ភគាំទ្រជាថវិកាពីមូលនិធិបរិស្ថានពិភពលោក (GEF) តាមរយៈកម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP) ដើម្បីរៀបចំផែនការជាតិសំរាប់អនុវត្តអនុសញ្ញា ស្តុកខូម (NIP) ដែលនឹងត្រូវធ្វើក្នុងរយៈពេល ២ ឆ្នាំ (ខែសីហាឆ្នាំ២០០៣ ដល់ខែកក្កដាឆ្នាំ២០០៥)។ នៅក្នុងដំណើរការរៀបចំផែនការជាតិនេះ ដោយសារកម្ពុជាពុំទាន់មានកំរងពត៌មានជាតិស្តីពី **ការគ្រប់គ្រងសារធាតុគីមី** ទើបអង្គការកម្មវិធីបរិស្ថានសហប្រជាជាតិបានស្នើដល់កម្ពុជា ឱ្យធ្វើការរៀបចំកំរងពត៌មានជាតិដោយបញ្ចូលជាផ្នែកមួយនៃគំរោង NIP ។

យោងទៅលើសេចក្តីស្នើរបស់អង្គការ UNEP និងដោយមានការឯកភាពគាំទ្រពីស្ថាប័នពាក់ព័ន្ធសំខាន់ៗក្នុងការងារគ្រប់គ្រងសារធាតុគីមី ពីតំរូវការចាំបាច់ក្នុងការប្រមូលចងក្រងឯកសារទាក់ទងសារធាតុគីមី ទើបក្រសួងបរិស្ថានសំរេចបញ្ចូលការងាររៀបចំកំរងពត៌មានជាតិស្តីពី **ការគ្រប់គ្រងសារធាតុគីមី** ជាផ្នែកមួយនៃគំរោង NIP ។ ការងាររៀបចំកំរងពត៌មាននេះ ត្រូវបានអនុវត្តន៏ដោយក្រុមការងារ ដែលចូលរួមដោយមន្ត្រីសមភាគីមកពីស្ថាប័នពាក់ព័ន្ធ និងដឹកនាំការងាររៀបចំសេចក្តីព្រាងដោយអ្នកឯកទេសជាតិ ដោយមានការផ្តល់ប្រឹក្សាបច្ចេកទេសផ្ទាល់ពីវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវសហប្រជាជាតិ (UNITAR) ព្រមទាំងមានការពិគ្រោះផ្តល់យោបល់ពីអនុគណៈកម្មការអន្តរក្រសួងសំរបសំរួលការអនុវត្តអនុសញ្ញា **ស្តុកខូម** ស្ថាប័នពាក់ព័ន្ធ និងបណ្តាអ្នកពាក់ព័ន្ធដែលមានផលប្រយោជន៏ផងដែរ ។

ឯកសារ " **កំរងពត៌មានជាតិ ស្តីពី ការគ្រប់គ្រងសារធាតុគីមី** " គឺជាការបរិយាយពីស្ថានភាពនៃការគ្រប់គ្រងសារធាតុគីមី លើទិដ្ឋភាពការងាររដ្ឋបាលនិងក្នុងក្របខ័ណ្ឌច្បាប់ នៅរាល់ដំណាក់កាលនៃវដ្តរបស់វាគិតចាប់តាំងពីការផលិត នាំចូល នាំចេញ ដឹកជញ្ជូន ទុកដាក់ ប្រើប្រាស់ និងការបោះបង់ចោល ។ល។ ទន្ទឹមនោះ កំរងពត៌មានជាតិបានប្រមូលផ្តុំនូវរាល់បណ្តាទិន្នន័យពីប្រភេទ និងបរិមាណនៃសារធាតុគីមីដែលនាំចូល និងប្រើប្រាស់នៅតាមផ្នែកឬវិស័យនិមួយៗផងដែរ ។ ដោយឡែក

ការវិភាគទៅលើចំនុចខ្លាំងនិងចំនុចខ្សោយ រួមបញ្ចូលទាំងភាពខ្វះចន្លោះក្នុងការងារគ្រប់គ្រងសារធាតុគីមី ក៏ត្រូវបានបញ្ចូលនៅក្នុងកំរងពត៌មានជាតិនេះដែរ ។ ពត៌មាននិងទិន្នន័យក្នុងកំរងពត៌មានជាតិនេះ មួយផ្នែកត្រូវបានប្រមូលពីស្ថាប័នរដ្ឋនិងអង្គការសង្គមស៊ីវិលដែលមានការពាក់ព័ន្ធទៅនឹងការគ្រប់គ្រងការប្រើប្រាស់សារធាតុគីមី ហើយមួយចំនួនត្រូវបានដកស្រង់ពីសៀវភៅ ឬឯកសារបោះពុម្ភ លើកលែងតែពត៌មានស្តីពីសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ដែលទទួលបានពីការធ្វើសារពើភ័ណ្ឌ ។

ទាក់ទងទៅនឹងពត៌មាននិងទិន្នន័យពីការនាំចូលសារធាតុគីមី គឺអាចមានច្រើន ប៉ុន្តែ ក្នុងលក្ខណៈជាក្រុមនៃសារធាតុគីមីទៅតាមប្រភេទតំរូវការប្រើប្រាស់ ដោយមិនមានលំអិតទៅលើសារធាតុគីមីនិមួយៗទេ ដូចជា ក្រុមជីគីមី ក្រុមថ្នាំកសិកម្ម ក្រុមគីមីវត្ថុធាតុដើមឧស្សាហកម្ម ។ល ។ ដោយឡែក ចំពោះពត៌មាននិងទិន្នន័យពីការប្រើប្រាស់សារធាតុគីមី គឺមានតិចតួចណាស់ និងមិនច្បាស់លាស់ពីប្រភេទ ឬបរិមាណដែលប្រើក្នុងវិស័យនិមួយៗ ឬតំបន់នៃខេត្ត-ក្រុងឡើយ ។ ចំណែកឯពត៌មាននិងទិន្នន័យពីការផលិត និងនាំចេញសារធាតុគីមី គឺមិនមានទេដោយសារសកម្មភាពនេះពុំមាននៅកម្ពុជា លើកលែងតែពត៌មានពីការបង្កើតសំណល់គីមី ដែលរួមមានសំណល់គីមីឧស្សាហកម្ម និងសំណល់មន្ទីរពេទ្យ ដែលមានបង្ហាញក្នុងកំរងពត៌មាននេះ ។ ទន្ទឹមនេះ ពត៌មាននិងទិន្នន័យពីសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ POPs គឺមានតិចតួចណាស់ ដែលទទួលបានតាមរយៈលទ្ធផលសារពើភ័ណ្ឌលើកតំបូង ហើយដែលបានបង្ហាញថា កម្ពុជាក៏មានសក្តានុពលខ្ពស់ក្នុងការបង្កើត ឬសាយភាយអនុផលមិនបានការ (Unintentional by-products) ដែលជាប្រភេទសារធាតុឌីអុកស៊ីន និងហ្វូរ៉ាន់ ។

ទាក់ទងទៅនឹងយន្តការច្បាប់សំរាប់គ្រប់គ្រងសារធាតុគីមី គឺកម្ពុជាមានលិខិតបទដ្ឋានមួយចំនួន ដូចជា ច្បាប់ អនុក្រឹត្យ ស្តង់ដារនិងប្រកាស ដែលបានដាក់ចេញសំរាប់ការត្រួតពិនិត្យលើសកម្មភាពដែលពាក់ព័ន្ធទៅនឹងការនាំចូល ផលិត កែច្នៃ ប្រើប្រាស់ ឬបោះបង់ចោលសារធាតុគីមី ដោយរួមបញ្ចូលទាំងការចេញបញ្ជីហាមឃាត់ និងបញ្ជីដាក់កំរិតតឹងតែងលើការនាំចូល និងប្រើប្រាស់សារធាតុគីមីដែលអាចបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាព និងបរិស្ថាន ដូចជា ពពួកថ្នាំកសិកម្ម គីមីឧស្សាហកម្ម និងគីមីផលិតគ្រឿងញៀនជាដើម ។ បន្ថែមលើនេះ សំរាប់ពង្រឹងដល់ការត្រួតពិនិត្យ ភាគច្រើននៃសារធាតុគីមីត្រូវបានតំរូវឱ្យធ្វើការចុះបញ្ជី និងសុំលិខិតអនុញ្ញាតក្នុងការនាំចូល ផលិត កែច្នៃ ចែកចាយ និងបោះបង់ចោល នៅក្រោមបទបញ្ញត្តិនៃច្បាប់ដែលមាន ។ ប៉ុន្តែ ពិនិត្យទៅលើក្របខ័ណ្ឌច្បាប់ទាក់ទងការគ្រប់គ្រងសារធាតុគីមី គឺកម្ពុជានៅមានការខ្វះចន្លោះចំនុចមួយចំនួន ឧទាហរណ៍ លិខិតបទដ្ឋានទាំងនោះច្រើនចែងវិធានរួមៗ ដោយមិនបានលំអិតច្បាស់លាស់សំរាប់ប្រភេទឬក្រុមនៃសារធាតុគីមី ហើយគោលការណ៍ណែនាំអនុវត្តន៍ក៏ពុំសូវមានដែរ ដែលជាលទ្ធផលធ្វើឱ្យការអនុវត្តច្បាប់នៅមានការខ្វះចន្លោះ និងពុំសូវមានប្រសិទ្ធិភាព ។

ទាក់ទងទៅនឹងយន្តការគ្រប់គ្រងសារធាតុគីមី កម្ពុជាមានស្ថាប័នរដ្ឋសំខាន់ៗចំនួន ៧ ដែលមានភារកិច្ចនិងការទទួលខុសត្រូវដោយឡែកៗពីគ្នាលើការងារត្រួតពិនិត្យសារធាតុគីមី ដែលកំណត់ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល ។ ស្ថាប័នរដ្ឋទាំងនោះរួមមាន : ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងពាណិជ្ជកម្ម (នាយកដ្ឋានកាំកុងត្រូល) ក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល ក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ទីចាត់ការគយនិងរដ្ឋាករ) ក្រសួងបរិស្ថាន និងក្រសួងមហាផ្ទៃ (អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន) ។ ថ្វីត្បិតតែស្ថាប័នច្រើនពាក់ព័ន្ធក្នុងការគ្រប់គ្រងសារធាតុគីមី ប៉ុន្តែ មានការជាន់ភារកិច្ចគ្នាតិចតួចប៉ុណ្ណោះ ហើយដែលបញ្ហានេះត្រូវបានសំរបសំរួលតាមរយៈការបង្កើតគណៈកម្មការអន្តរក្រសួង រួមមាន :

- គណៈកម្មការអន្តរក្រសួងសំរបសំរួលការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពផលិតផល និងសេវាកម្ម
- គណៈកម្មការបច្ចេកទេសសំរាប់ស្តង់ដារឧស្សាហកម្ម

- ក្រុមប្រឹក្សាភិបាលអន្តរក្រសួងទទួលបន្ទុកសំរបសំរួលការអនុវត្តអនុសញ្ញា បាសែល អនុសញ្ញារ៉ូតែរដាំ និងអនុសញ្ញាស្តុកខុម ។

ទន្ទឹមនោះគណៈកម្មការក៏មានភារកិច្ចផងដែរ ក្នុងការកំណត់និងលើកស្នើនូវគោលនយោបាយជាតិគ្រប់គ្រងសារធាតុគីមី និងសំរបសំរួលដល់ការអនុវត្តអនុសញ្ញានិងពិធីសារអន្តរជាតិដែលទាក់ទងនឹងសារធាតុគីមីផងដែរ ។ ប៉ុន្តែ ភាពខ្វះចន្លោះក្នុងការគ្រប់គ្រង និងសមត្ថភាពស្ថាប័ននៅមានកំរិតទាំងធនធានមនុស្ស និងសំភារៈ ពិសេសសមត្ថភាពវិភាគសារធាតុគីមី គឺជាបញ្ហាចំពោះមុខរបស់កម្ពុជា ដែលធ្វើឱ្យពត៌មាននិងទិន្នន័យសារធាតុគីមីមានតិចតួច និងមិនបានលំអិត ។

ក្រៅពីស្ថាប័នរដ្ឋសំខាន់ៗខាងលើដែលមានតួនាទីនិងភារកិច្ចគ្រប់គ្រងសារធាតុគីមី ក៏មានសកម្មភាពការងាររបស់អង្គការសង្គមស៊ីវិលនានា ដូចជា ផ្នែកឯកជន អង្គការមិនមែនរដ្ឋាភិបាល និងក្រុមស្រាវជ្រាវ ដែលគាំទ្រសកម្មភាព ឬកម្មវិធីជាតិក្នុងការគ្រប់គ្រងសារធាតុគីមីឱ្យមានភាពប្រសើរ និងប្រកបដោយសុវត្ថិភាពក្នុងការប្រើប្រាស់ និងបោះបង់ចោល ។ ប៉ុន្តែ សកម្មភាពទាំងនោះនៅមានកំរិត និងមិនទាន់បានទូលំទូលាយនៅឡើយ ដោយភាគច្រើនជាការងារអប់រំនិងផ្សព្វផ្សាយតែប៉ុណ្ណោះ ។

យោងទៅលើការខ្វះនូវបទពិសោធន៍ ធនធានមនុស្ស ច្បាប់ មធ្យោបាយសំភារៈបំពេញការងារគ្រប់គ្រងសារធាតុគីមី និងយន្តការប្រមូលផ្តុំនិងចែកចាយពត៌មានទាក់ទងនឹងសារធាតុគីមី បញ្ហាកង្វល់មួយចំនួនបានស្ថិតនៅចំពោះមុខកម្ពុជា រួមមានៈ

- ការយល់ដឹងរបស់កម្មករ និងកសិករដែលប្រើប្រាស់ផ្ទាល់ជាមួយសារធាតុគីមី និងសាធារណៈជនទូទៅ គឺនៅមានកំរិតទាប ដោយសារការផ្តល់នូវការអប់រំផ្សព្វផ្សាយគឺមានតិចតួច ។
- ភាពពេញនិយមប្រើប្រាស់សារធាតុគីមី គឺមានការកើនឡើងនិងមាននៅពាសពេញប្រទេស ដោយការប្រើប្រាស់មួយចំនួនខុសលក្ខណៈបច្ចេកទេស ដែលនាំឱ្យមានការប៉ះពាល់ដល់សុខភាពអ្នកប្រើផ្ទាល់និងអ្នកដទៃ និងបរិស្ថាន។
- កម្ពុជាមិនមានតួលេខ និងមិនបានចងក្រងពីករណីគ្រោះថ្នាក់ដោយសារធាតុគីមីទេ ក្នុងនោះរាប់បញ្ចូលទាំងគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់ខុសបច្ចេកទេស និងខុសទិសដៅផងដែរ។
- ស្ថាប័ននានារបស់កម្ពុជាមិនទាន់បានគិតគូពីការវាយតំលៃ និងការកំណត់អាទិភាពនៃបញ្ហាដែលទាក់ទងទៅនឹងការគ្រប់គ្រងសារធាតុគីមី រួមមានការផលិត ការធ្វើពាណិជ្ជកម្ម ការទុកដាក់ ការប្រើប្រាស់ និងការបោះបង់ចោល។ មូលហេតុចំបងនៃការខកខានមិនបានគិតគូរនេះ គឺបណ្តាលមកពីការខ្វះនូវសមត្ថភាពជំនាញ និងមធ្យោបាយក្នុងការវាយតំលៃ និងការកំណត់អត្តសញ្ញាណនៃផលប៉ះពាល់ដោយសារធាតុគីមី។
- កិច្ចសហប្រតិបត្តិការរវាងមន្ទីរពិសោធន៍និងមន្ទីរពិសោធន៍ និងជាមួយភាគីពាក់ព័ន្ធផលប្រយោជន៍រួម ដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងប្រភពសាយភាយនៃសារធាតុគីមីទូទៅ និងជាពិសេសសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុនៅមានកំរិតនៅឡើយ ហើយធនធានមនុស្សក្នុងដំណើរការមន្ទីរពិសោធន៍ ឧបករណ៍និងបរិក្ខារវិភាគ និងជំនាញបច្ចេកទេសក្នុងការវិភាគក៏នៅមានការខ្វះខាត។
- យន្តការផ្លាស់ប្តូរពត៌មានដែលទាក់ទងនឹងការគ្រប់គ្រងសារធាតុគីមី ក្នុងចំណោមស្ថានប័នរដ្ឋ និងបណ្តាអង្គការពាក់ព័ន្ធ គឺមិនបានដំណើរឱ្យបានទូលំទូលាយស្របតាមតំរូវការនាពេលបច្ចុប្បន្ន ។

# សេចក្តីផ្តើម

កំណើននៃការប្រើប្រាស់សារធាតុគីមី គឺមានភាពស្របគ្នាទៅនឹងកំណើននៃការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ពិសេសចាប់ពីទសវត្សឆ្នាំ ១៩៦០ ដែលតម្រូវការប្រើក្នុងវិស័យកសិកម្ម ឧស្សាហកម្ម និងផ្នែកដទៃទៀតមានសំទុះកើនឡើងជាលំដាប់។ ទន្ទឹមនឹងការផ្តល់សារៈប្រយោជន៍នៃការប្រើប្រាស់ សារធាតុគីមីមួយចំនួនធំបានផ្តល់នូវផលប៉ះពាល់អវិជ្ជមានទៅលើសុខភាពសាធារណៈ និងបរិស្ថាន ហើយជាលទ្ធផលបានធ្វើឱ្យមានការខាតបង់ថវិកាយ៉ាងច្រើនក្នុងការលុបបំបាត់នូវបញ្ហាទាំងនោះ។ ផ្តើមចេញពីបទពិសោធន៍នេះ នៅក្នុងសន្និសីទអង្គការសហប្រជាជាតិ ស្តីពី **ការអភិវឌ្ឍន៍និងបរិស្ថាន** នៅក្រុងរីយ៉ូ ប្រទេសប្រេស៊ីល ឆ្នាំ១៩៩២ សហគមន៍អន្តរជាតិបានសំរេចបញ្ចូលនៅក្នុងរបៀបវារៈ ២១ ជំពូកទី ១៩ នូវយុទ្ធសាស្ត្រនិងផែនការសកម្មភាពសំរាប់ " **ការគ្រប់គ្រងសារធាតុគីមីពុលប្រកបដោយសុវត្ថិភាពបរិស្ថាន ដែលរួមបញ្ចូលទាំងការទប់ស្កាត់ចរាចរឆ្លងដែនខុសច្បាប់នូវផលិតផលពុល និងគ្រោះថ្នាក់** " ហើយត្រូវបានអនុម័តដាក់ឱ្យអនុវត្តន៍សំរាប់ប្រទេសជាសមាជិក ក្នុងការសំរេចឱ្យបាននូវការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ។

ដើម្បីជំរុញការអនុវត្តរបៀបវារៈ ២១ ជំពូកទី ១៩ នៅឆ្នាំ១៩៩៤ សន្និសីទអន្តរជាតិ ស្តីពី សុវត្ថិភាពសារធាតុគីមី ត្រូវបានប្រព្រឹត្តនៅទីក្រុង ស្តុកខូម ប្រទេសស៊ុយអែត ដែលមានតំណាងប្រទេសជាង ១០០ ចូលរួម ដើម្បីកំណត់នូវអាទិភាពពាក់ព័ន្ធនឹងការគ្រប់គ្រងសារធាតុគីមី និងបង្កើតនូវយន្តការរួមមួយសំរាប់សំរបសំរួលការអនុវត្តសេចក្តីសំរេចរបស់គេ ដែលយន្តការនោះមានឈ្មោះថា " **វេទិកាអន្តររដ្ឋាភិបាល ស្តីពី សុវត្ថិភាពសារធាតុគីមី** " ហើយតាមរយៈនេះ ប្រទេសទាំងអស់ត្រូវធ្វើការកំណត់នូវអាទិភាពជាតិក្នុងការគ្រប់គ្រងសារធាតុគីមីដែលមានលក្ខណៈត្រឹមត្រូវ និងរៀបចំផែនការជាតិសំរាប់អនុវត្តន៍នូវអនុសាសន៍ដែលបានកំណត់ក្នុងសន្និសីទ រួមបញ្ចូលទាំងការរៀបចំកំរងពត៌មានជាតិ ស្តីពី ការគ្រប់គ្រងសារធាតុគីមី ។ ជាលទ្ធផលមកទល់ត្រឹមចុងឆ្នាំ ២០០៣ គឺមានប្រទេសចំនួន ៩២ បានរៀបចំកំរងពត៌មានជាតិរួចរាល់ ។

ក្រោយការចុះហត្ថលេខាលើអនុសញ្ញា ស្តុកខូម ស្តីពី សារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ (POPs) នាថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០០១ កម្ពុជាបានទទួលគំរោងជំនួយពីមូលនិធិបរិស្ថានពិភពលោក (GEF) ដើម្បីពង្រឹងសមត្ថភាពរៀបចំផែនការជាតិសំរាប់អនុវត្តន៍អនុសញ្ញា ស្តុកខូម (NIP) ក្នុងរយៈពេល ២ ឆ្នាំ ក្រោមកិច្ចសំរបសំរួលបច្ចេកទេសពីអង្គការកម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP) ។ យោងទៅតាមតំរូវការចាំបាច់ នៅក្នុងជំហានឆ្ពោះទៅធ្វើការគ្រប់គ្រងសារធាតុគីមីឱ្យមានលក្ខណៈល្អប្រសើរ ក្រសួងបរិស្ថាន ដោយមានការឯកភាពគាំទ្រពីស្ថាប័នពាក់ព័ន្ធ បានសំរេចបញ្ចូលការងាររៀបចំកំរងពត៌មានជាតិ ស្តីពី **ការគ្រប់គ្រងសារធាតុគីមី** ជាផ្នែកមួយនៃគំរោង NIP របស់កម្ពុជា ក្រោមការណែនាំនិងសំរបសំរួលបច្ចេកទេសផ្ទាល់ពីវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវសហប្រជាជាតិ (UNITAR) ។

នៅក្នុងដំណើរការរៀបចំកំរងពត៌មានជាតិ ក្រុមការងារបច្ចេកទេសមួយត្រូវបានបង្កើត ដែលដឹកនាំការងារដោយអ្នកឯកទេសជាតិ ១ រូប និងមានការចូលរួមដោយមន្ត្រីសមភាគីចំនួន ៥ រូប មកពីស្ថាប័នពាក់ព័ន្ធសំខាន់ៗ រួមមាន : ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងសុខាភិបាល ក្រសួងបរិស្ថាន និងក្រសួងពាណិជ្ជកម្ម ដែលក្រុមការងារបច្ចេកទេសនេះមានភារកិច្ចប្រមូលពត៌មាននិងទិន្នន័យពាក់ព័ន្ធនឹងសារធាតុគីមី សំរាប់ចងក្រងជាសេចក្តីព្រាងកំរងពត៌មានជាតិ ស្តីពី ការគ្រប់គ្រងសារធាតុគីមី ដែលជាការទទួលខុសត្រូវរបស់អ្នកឯកទេសជាតិ ។ បន្ថែមលើនេះ

ពតិមានទាក់ទងនឹងសារធាតុ POPs ក៏ត្រូវបានផ្តល់ដោយក្រុមការងារធ្វើសារពើភ័ណ្ឌផងដែរ សំរាប់បញ្ចូលទៅក្នុងសេចក្តីព្រាងកំរងពតិមានជាតិ។ ទន្ទឹមនេះ ដំណើរការរៀបចំកំរងពតិមានជាតិ ត្រូវបានទទួលការណែនាំនិងផ្តល់យោបល់ពីអនុគណៈកម្មការអន្តរក្រសួងសំរបសំរួលការអនុវត្តអនុសញ្ញា ស្តុកខូម ដែលមានសមាសភាពមកពីស្ថាប័នពាក់ព័ន្ធចំនួន ១១ ។

ជាលទ្ធផល សេចក្តីព្រាងកំរងពតិមានជាតិត្រូវបានដាក់ក្នុងកិច្ចប្រជុំពិនិត្យ និងពិគ្រោះយោបល់អន្តរក្រសួងចំនួន ៤ លើក ដើម្បីធ្វើឱ្យសេចក្តីព្រាងមានលក្ខណៈកាន់តែសុក្រិត្យ ដែលអាចទទួលយកបានពីគ្រប់ស្ថាប័ននិងអង្គភាពពាក់ព័ន្ធ ។ ទន្ទឹមនោះ ការជួយជាយោបល់បច្ចេកទេស និងទំរង់បែបបទនៃការរៀបចំ ក៏ត្រូវបានផ្តល់ជាបន្តបន្ទាប់ពីអង្គការ UNITAR និង UNEP ដែលធ្វើឱ្យសេចក្តីព្រាងមានលក្ខណៈកាន់តែប្រសើរ នឹងត្រូវបានពិនិត្យឆ្លងជាស្ថាពរក្នុងសិក្ខាសាលាជាតិនាថ្ងៃទី ២២-២៣ ខែកញ្ញា ឆ្នាំ២០០៤ ដោយមានមន្ត្រីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញមកពីស្ថាប័នពាក់ព័ន្ធចំនួន ៧៥ រូបចូលរួម ។

លទ្ធផលដែលសំរេចបានជាសៀវភៅកំរងពតិមានជាតិនេះ គឺជាមោទនៈភាពរបស់កម្ពុជា ដែលបង្ហាញពីឆន្ទៈរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការចូលរួមជាមួយសហគមន៏អន្តរជាតិ ដើម្បីធ្វើឱ្យសំរេចបាននូវការគ្រប់គ្រងសារធាតុគីមីប្រកបដោយលក្ខណៈបច្ចេកទេសត្រឹមត្រូវនិងសមស្រប ដែលអាចធានាបាននូវការកាត់បន្ថយគ្រោះថ្នាក់ទៅលើសុខភាពនិងបរិស្ថាន។ ទន្ទឹមនេះ នៅក្នុងក្របខ័ណ្ឌនៃផលប្រយោជន៏ជាតិ ក្រៅពីការផ្តល់ជាពតិមាននិងទិន្នន័យដែលទាក់ទងនឹងសារធាតុគីមី សៀវភៅកំរងពតិមានជាតិនេះ នឹងជួយទៅដល់ស្ថាប័នរដ្ឋាភិបាល ផ្នែកសាធារណៈ ផ្នែកឯកជននិងផ្នែកពាក់ព័ន្ធនានា ឱ្យយល់ដឹងកាន់តែច្បាស់ពីចំនុចខ្វះខាត និងការងារចាំបាច់ដើម្បីធ្វើឱ្យការគ្រប់គ្រងសារធាតុគីមីមានប្រសិទ្ធិភាពនិងកាន់តែប្រសើរ ហើយជាលទ្ធផលនឹងជួយឱ្យរាជរដ្ឋាភិបាលកម្ពុជាសំរេចបាននូវគោលដៅជាយុទ្ធសាស្ត្ររបស់ជាតិ គឺការកាត់បន្ថយនូវភាពក្រីក្រ តាមរយៈការលើកកំពស់ការការពារសុខភាពសាធារណៈ និងគុណភាពបរិស្ថាន ។

# ជំពូកទី ១
# ពត៌មានមូលដ្ឋានជាតិ

ជំពូកនេះរៀបរាប់អំពីពត៌មានមូលដ្ឋានទូទៅនៃព្រះរាជាណាចក្រកម្ពុជា ដែលស្តែងនូវស្ថានភាពនៃការគ្រប់គ្រងសារធាតុគីមី នៅក្នុងបរិបទទូទៅនៃលក្ខណៈរូបសាស្ត្រ នយោបាយ ប្រជាសាស្ត្រ សេដ្ឋកិច្ចសង្គម ឧស្សាហកម្ម និងកសិកម្មរបស់ប្រទេស ។

## ១.១ បរិបទរូបសាស្ត្រ និងប្រជាសាស្ត្រ

### ភូមិវិទ្យារូប

- ទំហំប្រទេស
  - ផ្ទៃក្រឡាសរុប : ១៨១.០៣៥ គម[២]
  - ផ្ទៃទឹកសរុប : ៤.៥២០ គម[២]
  - ប្រវែងបណ្តោយពីកើតទៅលិច : ៥៥០ គម
  - ប្រវែងទទឹងពីជើងទៅត្បូង : ៤៤០ គម
  - ប្រវែងឆ្នេរសមុទ្រ : ៤៣៥ គម ( ស្ថិតនៅទិសនិរតីតាមបណ្តោយឈូងសមុទ្រថៃ)

- អាកាសធាតុ

ប្រទេសកម្ពុជាស្ថិតនៅតំបន់ត្រូពិចមានអាកាសធាតុក្តៅហើយសើម ដែលចែកចេញជា ២ រដូវ គឺរដូវវស្សា និងរដូវប្រាំង ។ រដូវវស្សាចាប់ផ្តើមពីខែឧសភា ដល់ខែតុលា មានភ្លៀងធ្លាក់ខ្លាំងដោយសារខ្យល់មូសុងនិរតីបក់មកពីមហាសមុទ្រឥណ្ឌា។ រដូវប្រាំងចាប់ផ្តើមពីខែវិច្ឆិកា ដល់ខែមេសា ដែលទាក់ទងទៅនឹងខ្យល់មូសុងឦសានបក់នាំមកនូវខ្យល់ត្រជាក់ដើមរដូវ ។

- ទឹកភ្លៀង

របាយទឹកភ្លៀងនៅកម្ពុជាមិនមានភាពស្មើគ្នាទេ គឺវាអាស្រ័យទៅតាមតំបន់ ( ទំនាបកណ្តាល ប្រជុំភ្នំ និងខ្ពង់រាប) និងមានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ។ នៅរដូវវស្សា គឺមានភ្លៀងធ្លាក់ប្រមាណ ៨០% ជាប្រចាំឆ្នាំ។ កំពស់ទឹកភ្លៀងប្រចាំឆ្នាំមានជាមធ្យមលើផ្ទៃប្រទេសពី ១.០០០មម ទៅ ២.៥០០មម ។ កំពស់ទឹកភ្លៀងនៅតំបន់ទំនាបកណ្តាលដែលគ្របដណ្តប់លើបឹងទន្លេសាប និងអាងទន្លេមេគង្គក្រោមមានជាមធ្យមពី ១.២០០មម ទៅ ៣.០០០មម។ កំពស់ទឹកភ្លៀងដែលខ្ពស់លើសពី ៣.០០០មម ក្នុងមួយឆ្នាំ គឺមាននៅតែទំនាបតំបន់ឆ្នេរសមុទ្រផ្នែកខាងលិចប្រទេស។ នៅចុងខែកក្កដា និងដើមខែសីហា មានកូនរដូវប្រាំងមួយដែលមានរយៈពេលពី ១០ ទៅ ១៥ ថ្ងៃ។

- ខ្យល់

នៅកម្ពុជា ល្បឿនខ្យល់មធ្យមគឺប្រមាណជា ២ ម៉ែត្រក្នុង ១ វិនាទី ។ ពីខែកុម្ភៈដល់ខែមេសា ខ្យល់បក់មកពីទិសអាគ្នេយ៍មានល្បឿនខ្លាំងជាហេតុនាំឱ្យមានខ្យល់បក់ខ្លាំងនៅភាគខាងត្បូងប្រទេស ។ ចាប់ពីខែសីហាដល់ខែតុលា ជាទូទៅអាចមានខ្យល់កួច

ផ្អែកស្រទាប់លើអាកាស ហើយអាចបណ្តាលឱ្យស្ថានភាពខ្យល់ប្រែប្រួលមិនទៀងទាត់នៅតំបន់អាស៊ីអាគ្នេយ៍ ។ ដោយឡែក ពីខែវិច្ឆិកាដល់ខែមករា ខ្យល់បក់មកពីទិសឦសានហើយពេលខ្លះកើតមានខ្យល់បក់ខ្លាំងៗ ទៀតផង ។

✦ សីតុណ្ហភាព

សីតុណ្ហភាពមធ្យមប្រចាំខែប្រែប្រួលពីអប្បបរមា ២៥ អង្សាសេក្នុងខែមករា ទៅអតិបរមា ២៩ អង្សាសេក្នុងខែមេសា គឺមានការប្រែប្រួលតិចតួចប៉ុណ្ណោះ ។ ជាទូទៅសីតុណ្ហភាពខ្ពស់ជាង ៣២ អង្សាសេ តែងកើតមានមុនពេលចាប់ផ្តើមរដូវភ្លៀង ហើយជួនកាលសីតុណ្ហភាពនេះអាចឡើងខ្ពស់ជាង ៣៨ អង្សាសេ ហើយក៏កម្រចុះទាបជាង ១០ អង្សាសេដែរ ។ ទាក់ទងទៅនឹងសំណើម គឺមានការប្រែប្រួលពី ៦៥-៧០% ក្នុងខែមករានិងខែកុម្ភៈ ទៅដល់ ៨៥-៩០% ក្នុងខែសីហានិងខែកញ្ញា ។ ចំណែករំហួតជាមធ្យមប្រចាំឆ្នាំ គឺមានពី ២.០០០មម ទៅ ២.២០០មម ។ ដោយឡែករំហួតខ្ពស់បំផុត គឺមាននៅក្នុងខែមិនា និងក្នុងខែមេសា ក្នុងកំរិតពី ២០០មម ទៅ ២៤០មម ហើយទាបបំផុតនៅក្នុងខែកញ្ញា និងក្នុងខែតុលា គឺពី ១២០មម ទៅ ១៥០មម ។

## របបនយោបាយសង្គម

ប្រទេសកម្ពុជាប្រកាន់របបរាជានិយមអាស្រ័យធម្មនុញ្ញ ដោយមានស្ថាប័នកំពូលចំនួន ៣ គឺ សភា រាជរដ្ឋាភិបាល និងតុលាការ ។ សភារបស់កម្ពុជាមាន ២ គឺព្រឹទ្ធសភា និងរដ្ឋសភា ។ រាល់សេចក្តីព្រាងច្បាប់ ត្រូវតែមានការអនុម័តពីសភាទាំង ២ មុននឹងក្លាយទៅជាច្បាប់ ។

✦ ព្រឹទ្ធសភា

ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញក្រោយការបោះឆ្នោតជាសកលនៅឆ្នាំ ១៩៩៨ បាននាំឱ្យឈានទៅការបង្កើតព្រឹទ្ធសភា ដែលជាស្ថាប័នពង្រឹងអំណាចនីតិបញ្ញត្តិ។ ក្នុងរយៈពេល ១ ខែ ព្រឹទ្ធសភាត្រូវធ្វើការពិនិត្យនិងផ្តល់យោបល់ផ្សេងៗ លើសេចក្តីព្រាងច្បាប់ ឬនីតិកម្មផ្សេងៗទៀត ដែលបានអនុម័តជាជំហានដំបូងដោយរដ្ឋសភា។ នៅពេលដែលសេចក្តីព្រាងច្បាប់ណាមួយស្ថិតក្នុងការប្រញាប់ នោះរយៈពេលនៃការពិនិត្យច្បាប់ត្រូវកាត់បន្ថយមកត្រឹម ៥ ថ្ងៃ បន្ទាប់ពីរដ្ឋសភាបានអនុម័តជាជំហានដំបូង។ ទន្ទឹមនោះ សមាជិកព្រឹទ្ធសភាក៏មានសិទ្ធិក្នុងការផ្តួចផ្តើមបង្កើតច្បាប់ផងដែរ។ ក្រៅពីតួនាទីខាងលើ ព្រឹទ្ធសភាក៏មានភារកិច្ចក្នុងការសំរបសំរួលរវាងរដ្ឋសភា និងរាជរដ្ឋាភិបាល។

ព្រឹទ្ធសភាមានសមាជិកចំនួន ៦១ នាក់។ ប្រធានព្រឹទ្ធសភា ១ រូបត្រូវបានជួយជ្រោមជ្រែងការងារដោយអនុប្រធាន ២ រូប។ ព្រឹទ្ធសភាជួបប្រជុំគ្នា ២ ដងក្នុងមួយឆ្នាំដោយក្នុងការប្រជុំនិមួយៗមានរយៈពេល ៣ ខែ ។ ក្នុងករណីចាំបាច់ ព្រឹទ្ធសភាអាចកោះអញ្ជើញប្រជុំវិសាមញ្ញ។ នីតិកាលព្រឹទ្ធសភានឹងត្រូវផុតកំណត់នូវឆ្នាំ ២០០៤ បន្ទាប់មកទៀត សមាជិកព្រឹទ្ធសភានឹងត្រូវជ្រើសរើសម្តងទៀតសំរាប់អាណត្តិរយៈពេល ៦ ឆ្នាំ ។

✦ រដ្ឋសភា

ដោយយោងលើរដ្ឋធម្មនុញ្ញ រដ្ឋសភាត្រូវបានជ្រើសរើសសំរាប់រយៈពេល ៥ ឆ្នាំ ហើយអាចរំលាយខ្លួនក្នុងកាលៈទេសៈណាមួយ ឧទាហរណ៍ ប្រសិនបើមានអប្បភាព ២ ដងក្នុងរយៈពេល ១២ ខែ នៃរាជរដ្ឋាភិបាល ។ រដ្ឋសភាមានចំនួនសមាជិក ១២៣ រូប (អាណត្តិទី ៣) ដែលត្រូវជ្រើសរើសតាមរយៈការបោះឆ្នោតជាសកល ដោយសេរី ស្មើភាព និងដោយសំងាត់ ។ សមាជិកសភាចាស់អាចឈរឈ្មោះសំរាប់ការបោះឆ្នោតអាណត្តិក្រោយទៀតបាន ។

ការប្រជុំសាមញ្ញរបស់រដ្ឋសភាធ្វើឡើង ២ ដងក្នុង ១ឆ្នាំ ហើយការប្រជុំនីមួយៗ មានរយៈពេលយ៉ាងហោចណាស់ ៣ ខែ ។ ប្រសិនបើមានសំណើពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬមួយភាគបីនៃសមាជិកសភា គណៈកម្មការអចិន្ត្រៃយ៍រដ្ឋសភាអាចកោះប្រជុំវិសាមញ្ញបាន។ ក្នុងចន្លោះពេលនៃការអវត្តមានការប្រជុំ គណៈកម្មការអចិន្ត្រៃយ៍ គឺជាអ្នកចាត់ចែងការងាររបស់រដ្ឋសភា ។

រដ្ឋសភាធ្វើការអនុម័តថវិកាជាតិ ផែនការរដ្ឋ អនុញ្ញាតឱ្យរដ្ឋាភិបាលធ្វើការខ្ចីបុលប្រាក់ ឬឱ្យប្រាក់គេខ្ចី និងមានអំណាចបង្កើត ឬធ្វើវិសោធនកម្មច្បាប់ រឺធ្វើមោឃៈភាពទាក់ទងពន្ធអាករប្រចាំឆ្នាំ ។ រដ្ឋសភាមានអំណាចអនុម័តផ្តល់សច្ចាប័ន ឬលុបចោលនៃសច្ចានុម័តលើអនុសញ្ញា ឬពិធីសារអន្តរជាតិ។ ការអនុម័តនូវច្បាប់ទាំងឡាយដែលរៀបរាប់ខាងលើ ត្រូវតែមានការយល់ព្រមដោយមតិភាគច្រើននៃសមាជិកទាំងអស់ ។

✦ រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលកម្ពុជា គឺជាស្ថាប័ននីតិប្រតិបត្តិដែលដឹកនាំដោយនាយករដ្ឋមន្ត្រី។ រាជរដ្ឋាភិបាល មានភារកិច្ចដឹកនាំការងាររដ្ឋដោយទទួលខុសត្រូវលើគោលនយោបាយជាតិទាំងមូល និងការអនុវត្តកម្មវិធីការងារនានា និងទទួលខុសត្រូវចំពោះរដ្ឋសភា។ នាយករដ្ឋមន្ត្រី ត្រូវបានជ្រោមជ្រែងការងារដោយឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការដែលទទួលបន្ទុកការងារតាមក្រសួងស្ថាប័នដោយឡែកពីគ្នា ។ ខាងក្រោមនេះ គឺជាស្ថាប័នដែលស្ថិតក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាល ។

១- ទីស្តីការគណៈរដ្ឋមន្ត្រី
២- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
៣- ក្រសួងពាណិជ្ជកម្ម
៤- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
៥- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
៦- ក្រសួងអប់រំ យុវជន និងកីឡា
៧- ក្រសួងបរិស្ថាន
៨- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
៩- ក្រសួងសុខាភិបាល
១០- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
១១- ក្រសួងពត៌មាន
១២- ក្រសួងមហាផ្ទៃ
១៣- ក្រសួងយុត្តិធម៌
១៤- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
១៥- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
១៦- ក្រសួងការពារជាតិ
១៧- ក្រសួងទំនាក់ទំនងសភា និងអធិការកិច្ច
១៨- ក្រសួងផែនការ
១៩- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
២០- ក្រសួងសាធារណការ និងដឹកជញ្ជូន
២១- ក្រសួងធម្មការ និងកិច្ចការសាសនា
២២- ក្រសួងអភិវឌ្ឍន៍ជនបទ
២៣- ក្រសួងសង្គមកិច្ច និងយុវៈនីតិសម្បទា
២៤- ក្រសួងទេសចរណ៍
២៥- ក្រសួងធនធានទឹក និងឧតុនិយម
២៦- ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន
២៧- រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ
២៨- រដ្ឋលេខាធិការដ្ឋាន អាកាសចរណ៍ស៊ីវិល

✦ តុលាការ

អំណាចតុលាការ គឺឯករាជ្យហើយត្រូវបានធានាដោយព្រះមហាក្សត្រ និងមានការគាំទ្រពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ គ្មានអំណាចណាមួយអាចត្រួតត្រាទៅលើអំណាចតុលាការបានទេ ហើយមានតែចៅក្រមទេដែលអាចសំរេចចិត្ត ឬធ្វើការវិនិច្ឆ័យ។ អំណាចនេះកាន់កាប់ដោយតុលាការកំពូលនិងលំដាប់នៃតុលាការ ដែលត្រូវពិនិត្យរាល់សំណុំរឿងទាំងអស់ រួមបញ្ចូលទាំងសំណុំរឿងក្តីរដ្ឋបាលផងដែរ ។ ស្ថិតនៅក្រោមច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គឺមានតែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមួយគត់ ដែលអាចធ្វើការសំរេចដាក់ពិន័យទោសចំពោះចៅក្រមដែលប្រព្រឹត្តផ្ទុយ ឬខុសនឹងគតិច្បាប់។ ឯករាជ្យភាពរបស់ស្ថាប័នតុលាការ គឺចៅក្រមត្រូវសំរេចក្តីដោយគ្មានលំអៀង ដោយយកច្បាប់ជាមូលដ្ឋាន គ្មានការគាបសង្កត់ គំរាមកំហែងឬបំភិតបំភ័យ ទោះដោយផ្ទាល់ឬដោយប្រយោលក្តីពីជនណាឬគណៈបក្សណាឡើយ ។

## ជាតិសាសន៍ ភាសា និងសាសនា

ប្រជាជនកម្ពុជារួមមាន ៩០% ជាជនជាតិខ្មែរ និង ១០% ជាជនជាតិចិន វៀតណាម និងមួយចំនួនតូចជាចាម ភូមា ឡាវ និងជនជាតិភ្នង ឬកុលសម្ព័ន្ធភ្នំ ។ ប្រជាជនកម្ពុជាដែលជាខ្មែរ ភាគច្រើនរស់នៅយ៉ាងសមរម្យ និងអចិន្ត្រៃយ៍នៅតាមភូមិទាំងឡាយក្បែរប្រភពទឹក ជាពិសេសក្នុងតំបន់ដីទំនាបបឹងទន្លេសាបនិងអាងទន្លេមេគង្គ ដែលនៅទីនោះពួកគេប្រកបរបរចិញ្ចឹមជីវិតដោយការធ្វើស្រែ ធ្វើចំការ នេសាទ និងរបរការងារនៅតាមទីប្រជុំជន ដូចជាការលក់ដូរនៅតាមទីផ្សារ ជាកម្មករសំណង់ កម្មកររោងចក្រជាដើម ។

ជនជាតិចាមច្រើនរស់នៅតាមដងទន្លេ ឬប្រភពទឹកផ្សេងៗទៀត ដែលនៅទីនោះពួកគេច្រើនប្រកបរបរនេសាទត្រីសំរាប់ជួញដូរជាមួយផលិតផលឧបភោគ និងបរិភោគ រីឯស្ត្រីក្នុងភូមិអាចរកទទួលទានដោយការងារតម្បាញ ។ ជនជាតិចាមដែលរស់នៅលើដីគោកចិញ្ចឹមជីវិតតាមមធ្យោបាយផ្សេងៗ អាស្រ័យតាមភូមិនីមួយៗខ្លួនដូចជា ភូមិខ្លះប្រកបរបរជាជាងដែក ដាំដំណាំហូបផ្លែ ឬដាំបន្លែ របរសត្តឃាត គេចិញ្ចឹមក្របី និងបង្កាត់ពូជសត្វ ។

ចិននៅស្រុកខ្មែរ គឺជាជនជាតិភាគតិចដែលមានចំនួនច្រើនជាងគេនៅក្នុងចំណោមជនជាតិភាគតិច ។ ៦០% នៃចិនទាំងនោះជាអ្នករស់នៅតាមទីក្រុងដែលប្រកបរបរជំនួញជាចំបង ហើយ ៤០% ទៀតរស់នៅជនបទ ជាម្ចាស់ហាង ជាឈ្មួញ និងជាអ្នកទិញស្រូវ ស្ករត្នោត ផ្លែឈើ ត្រី និងជាអ្នកឱ្យប្រាក់គេខ្ចី ។ ចិននៅស្រុកខ្មែរបច្ចុប្បន្ននេះមានភាសាធំៗ ៥ ហើយក្រុមធំបំផុត គឺទាជីវ បន្ទាប់មកមានតាំងតុង ហុកកៀន ហាក់កា និងហៃណាន់ ។

សហគមន៍វៀតណាមរស់នៅរាយប៉ាយពាសពេញភាគនិរតី និងភាគកណ្តាលនៃប្រទេសកម្ពុជា។ ជនជាតិវៀតណាមភាគច្រើនរស់នៅជាពិសេសក្នុងរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តព្រៃវែង និងខេត្តកំពង់ចាម និងមួយចំនួនទៀតរស់នៅតាមដងទន្លេមេគង្គក្រោម ទន្លេបាសាក់ និងតាមដងទន្លេសាបជាកន្លែងដែលពួកគេធ្វើការនេសាទត្រី ។ ជនជាតិនេះមិនមានទំនាក់ទំនងជិតស្និទ្ធខាងផ្នែកវប្បធម៌និងសាសនាជាមួយខ្មែរទេ ។

ខ្មែរលើមានរស់នៅយ៉ាងច្រើននៅខេត្តភាគឦសាននៃប្រទេស ដូចជា : ខេត្តរតនគិរី ខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគិរី និងខេត្តក្រចេះ ។ ខ្មែរលើភាគច្រើនរស់នៅរាយប៉ាយក្នុងភូមិបណ្តោះអាសន្នដែលមានអ្នករស់នៅប្រមាណពី ២០០-៣០០ នាក់ប៉ុណ្ណោះ ។ ជាធម្មតា ភូមិទាំងនោះគ្រប់គ្រងដោយក្រុមប្រឹក្សាចាស់ទុំក្នុងភូមិ ឬក៏គ្រប់គ្រងដោយមេភូមិណាម្នាក់ ។ ខ្មែរលើដាំដុះដំណាំផ្សេងៗ ប៉ុន្តែ ដំណាំចំបងគឺស្រូវតំបន់ដីស្ងួត ឬដីទួល ដែលដាំដុះតាមវិធីដុតព្រៃ ឬហៅថាកសិកម្មព្រៃដុត ។ ក្រៅពីនោះ

ខ្មែរលើបានប្រកបរបរប្រមាញ់ នេសាទត្រី និងប្រមូលអនុផលព្រៃឈើផ្សេងៗទៀតសំរាប់អាហារប្រចាំថ្ងៃ ។ លំនៅឋានរបស់ពួកគេមានទំហំតូចធំអាស្រ័យតាមចំនួនសមាជិកគ្រួសារ ហើយដែលភាគច្រើនគឺសង់ផ្ទាល់នឹងដី ឬនៅលើធ្នើរ ។ ក្រុមខ្មែរលើភាគច្រើននៅកម្ពុជា រួមមាន កួយ ភ្នង ស្ទៀង ព្រៅ ព្នៅ ចារ៉ាយ និងរ៉ាដែ ដែលនៅក្នុងចំណោមនោះ គឺមានតែ ២ ក្រុមទេ (ចារ៉ាយនិងរ៉ាដែ) ដែលចេះនិយាយភាសាខ្មែរមន ។ បច្ចុប្បន្ននេះ មានជនជាតិតួយប្រហែល ១៦០.០០០ នាក់ រស់នៅខេត្តភាគឧត្តរនៃប្រទេស ដូចជា : ខេត្តកំពង់ធំ ខេត្តព្រះវិហារ និងខេត្តស្ទឹងត្រែង ហើយក៏មានខ្លះរស់នៅក្នុងខេត្តជាប់នឹងប្រទេសថៃ ។

ព្រះពុទ្ធសាសនា គឺជាសាសនារបស់រដ្ឋហើយដែលមានខ្មែរយ៉ាងលើសលប់ជាអ្នកកាន់ព្រះពុទ្ធសាសនា។ រាជរដ្ឋាភិបាលកម្ពុជាបានអនុញ្ញាតឱ្យមានសាសនាផ្សេងទៀតនៅក្នុងប្រទេស ហើយសាសនាទាំងនោះត្រូវបានគេគោរពយ៉ាងទូលំទូលាយផងដែរ ។ គ្រឹះស្តសាសនាត្រូវបានគេគោរពដោយក្រុមភាគតិច ជាពិសេសជនជាតិវៀតណាម ហើយសាសនាអ៊ីស្លាមជាសាសនាចំបងរបស់ជនជាតិចាម ។

ភាសាខ្មែរគឺជាភាសាជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ហើយដែលមានប្រជាជនច្រើនជាង ៩៥% និយាយភាសានេះ ។ ភាសាបារាំងត្រូវបាននិយាយដោយមនុស្សជំនាន់មុន រីឯភាសាអង់គ្លេសត្រូវបានគេប្រើប្រាស់ជាទូទៅដោយមនុស្សជំនាន់ក្រោយ ។ ភាគច្រើននៃប្រជាជនកម្ពុជា ទោះបីមិនមែនជាខ្មែរក្តីក៏ពួកគេអាចនិយាយភាសាខ្មែរបានដែរ ។ ខ្មែររស់នៅប្រទេសថៃ វៀតណាម និងឡាវ និយាយគ្រាមភាសាខ្មែរទោះតិចឬច្រើន ហើយពួកគេមានការឆ្លាតវៃក្នុងការនិយាយភាសាខ្មែរមិនចាញ់ខ្មែរដែលរស់នៅក្នុងប្រទេសឡើយ។ ភាសានៃជនជាតិភាគតិច រួមមាន វៀតណាម ចាម និងគ្រាមភាសាចិន ព្រមទាំងភាសាកុលសម្ព័ន្ធជាច្រើនទៀត។ ជាទូទៅ ភាសាខ្មែរមាននាម គុណនាម កិរិយាសព្ទ កិរិយាវិសេស និងពាក្យច្រើនប្រភេទទៀត ដែលហៅថាបរិវាស័ព្ទ។ លំដាប់ទំរង់ពាក្យធម្មតា គឺមានប្រធាន-កិរិយាសព្ទ-កម្មបទ ។ ភាសាខ្មែរប្រើភាសាសំស្ក្រឹត និងភាសាបាលីជាឫសគល់ ដូចគ្នានឹងភាសាអង់គ្លេស និងភាសាអឺរ៉ុបផ្សេងទៀតប្រើភាសាឡាតាំងនិងភាសាក្រិចដើម្បីបំបែកជាពាក្យថ្មី ពិសេសពាក្យវិទ្យាសាស្ត្រ ។ ភាសាខ្មែរក៏មានខ្ចីពាក្យចិន បារាំង អង់គ្លេសមកប្រើប្រាស់ដែរ ពិសេសពាក្យហិរញ្ញវត្ថុ ពាក្យពាណិជ្ជកម្ម និងក្នុងមុខអាហារជាដើម។ បន្ទាប់មក ពាក្យខ្ចីទាំងនោះក៏បានក្លាយជាវប្បធម៌នៃអាណាចក្រទៅវិញ ពិសេសឈ្មោះសំភារៈបច្ចេកវិជ្ជាលោកខាងលិចដ៏ទំនើប។ ភាសាខ្មែរ មានព្យញ្ជនៈ ៣៣ (អឃោសៈ ២០ និងឃោសៈ ១៣) ស្រៈ ២៤ ស្រៈពេញតួ ១២ (មិនសូវនិយមប្រើទេនៅយុគសម័យថ្មីនេះ) និងសញ្ញាសំគាល់មួយចំនួនទៀត ។

## ប្រជាសាស្ត្រ

យោងតាមសៀវភៅស្ថិតិជាតិឆ្នាំ ២០០៣ ដែលរៀបចំឡើងដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ នៅឆ្នាំ ២០០៣ ប្រជាជនកម្ពុជាមានចំនួនប្រមាណ ១៣.៨ លាននាក់ ក្នុងនោះ ៥២% ជាស្ត្រី និងមានអត្រាកំណើនប្រមាណ ២.៥% ក្នុងមួយឆ្នាំ ។ ប្រជាជនប្រមាណជា ៨៤% រស់នៅតាមជនបទ និង ១៦% រស់នៅក្នុងតំបន់ទីក្រុង និងទីប្រជុំជន។ នៅក្នុងរាជធានីភ្នំពេញត្រូវបានគេប៉ាន់ប្រមាណថាមានប្រជាជនចំនួន ១.២ លាននាក់ និងមានអត្រាកំណើនខ្ពស់រហូតដល់ ៣.៥% ក្នុង ១ ឆ្នាំ។ ដោយឡែកអាស្រ័យទៅតាមតំបន់នៃប្រទេស ចំនួនប្រជាជនខ្ពស់គឺមាននៅក្នុងខេត្តចំនួន ៦ ដែលស្ថិតនៅតំបន់ទំនាបកណ្តាលជុំវិញរាជធានីភ្នំពេញ ហើយមានប្រជាជនប្រមាណ ៦០% នៃចំនួនសរុប ។

| *ចំនួនប្រជាជន* | *ទាំងពីរភេទ* | *បុរស* | *ស្ត្រី* |
|---|---|---|---|
| **សរុប** | ១៣,០៩៩,៤៧២ | ៦,៣៤៨,១១២ | ៦,៧៥១,៣៦០ |
| ទីក្រុង | ២.០៩៥.១៣៥ | ១.០២៩.៤០៥ | ១.០៦៥.៧៣០ |
| ជនបទ | ១១.០០៤.៣៣៧ | ៥.៣១៨.៧០៧ | ៥.៦៨៥.៦៣០ |
| ភាគរយ | | ៤៨.២ % | ៥១.៨ % |

- អត្រាកំនើនប្រជាជនប្រចាំឆ្នាំ ២.៥ %
- អត្រាកំណើត ៣៨ នាក់ក្នុង ១០០០ នាក់
- អត្រាមរណៈ ១២ នាក់ក្នុង ១០០០ នាក់
- ចំនួនលំនៅឋានសរុប ២.១៨៨.៦៦៣
  - ទីក្រុង ៣២២.២៤៦
  - ជនបទ ១.៨៦៦.៤១៧
- ចំនួនលំនៅឋានធម្មតា ២.១៦២.០៨៦
- ភាគរយស្ត្រីជាមេគ្រួសារ ២៥.៧ %
- ដង់ស៊ីតេប្រជាជន ៧៦ នាក់ / គម²

✦ *ចំនួនប្រជាជននៅភ្នំពេញ :* ៩ %

✦ *ចំនួនប្រជាជននៅទីក្រុង :* ៧ %

✦ *ចំនួនប្រជាជននៅជនបទ :* ៨៤ %

✦ *អាយុជាមធ្យមនៃប្រជាជន :*

- ៥៨.៦ ឆ្នាំសំរាប់ស្ត្រី
- ៥០.៣ ឆ្នាំសំរាប់បុរស

✦ *អត្រាប្រជាជនតាមអាយុ*

- កុមារ ( ០-១៤ ឆ្នាំ) ៤២.៨ %
- ពលរដ្ឋដែលមានលទ្ធភាពចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច ( ១៥-៦៤ ឆ្នាំ) ៥៣.៧ %
- ប្រជាជនមានអាយុលើសពី ៦៥ ឆ្នាំ ៣.៥ %

✦ *ស្ថានភាពគ្រួសារពីអាយុ ១៥ ឆ្នាំឡើងទៅ (% )*

| ភេទ | មិនបានរៀបការ | បានរៀបការ | មេម៉ាយ / ពោះម៉ាយ | លះលែង | បែកគ្នា |
|---|---|---|---|---|---|
| ទាំងពីរភេទ | ២៩.៤ | ៦១.៣ | ៦.៥ | ២.៤ | ០.៤ |
| បុរស | ៣២.៨ | ៦៤.៦ | ១.៦ | ០.៨ | ០.២ |
| ស្ត្រី | ២៦.៦ | ៥៨.៤ | ១០.៨ | ៣.៧ | ០.៥ |

✦ *អាយុរៀបការជាមធ្យម*

| | |
|---|---|
| បុរស | ២៤.២ ឆ្នាំ |
| ស្ត្រី | ២២.៥ ឆ្នាំ |

✦ *អាយុកាលជាមធ្យម :* ៥៣.៤ ឆ្នាំ

✦ *អត្រាអក្ខរភាព :* ៦៥ % ( ឆ្នាំ១៩៩៨ )

✦ *អត្រាអក្ខរភាពមនុស្សចាស់ (ភាគរយនៃអក្ខរជនអាយុពី ១៥ ឆ្នាំឡើងទៅ)*

| សរុប ទីក្រុង ជនបទ | ទាំងពីរភេទ | បុរស | ស្ត្រី |
|---|---|---|---|
| សរុប | ៦៧.៣ | ៧៩.៥ | ៥៧.០ |
| ទីក្រុង | ៧៩.១ | ៨៨.២ | ៧០.៨ |
| ជនបទ | ៦៤.៩ | ៧៧.៦ | ៥៤.៣ |

✦ *កំរិតមានការអប់រំជាមធ្យមនៃចំនួនប្រជាជន : (ភាគរយនៃកំរិតអប់រំគិតពីអាយុពី ២៥ ឆ្នាំឡើងទៅ)*

| កំរិតនៃការអប់រំ | ទាំងពីរភេទ | បុរស | ស្ត្រី |
|---|---|---|---|
| គ្មានការអប់រំ | ២.១ | ២.០ | ២.២ |
| មិនចប់មធ្យមសិក្សា | ៥៦.៦ | ៤៩.០ | ៦៦.១ |
| ក្រោមមធ្យមសិក្សា | ១១.៨ | ១៣.៩ | ៩.២ |
| លើសពីមធ្យមសិក្សា | ០.៨ | ១.១ | ០.៤ |

✦ *អត្រាគ្មានការងារធ្វើ :*

- អត្រាស្ត្រីគ្មានការងារធ្វើ : ៥.៩ %
- អត្រាបុរសគ្មានការងារធ្វើ : ៤.៧ %

✦ *ចំនួនសរុបនៃមនុស្សមានការងារ :* ៦.៤ លាននាក់ ( ឆ្នាំ២០០២ បានចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច )

អត្រាសកម្មភាពសេដ្ឋកិច្ចស្តូចស្តើង ( មធ្យមភាគនៃសកម្មភាពសេដ្ឋកិច្ចក្នុងចំណោមប្រជាជនមានអាយុពី ៧ ឆ្នាំឡើងទៅ )

- ទាំងពីរភេទ ៥៥.៥ %
- បុរស ៥៦.៥ %
- ស្ត្រី ៥៤.៦ %
- ភាគរយនៃប្រជាជនបំរើការក្នុងវិស័យឧស្សាហកម្ម
  - ឧស្សាហកម្មខ្នាតតូច ៧៧.៥ %
  - ឧស្សាហកម្មខ្នាតមធ្យម ៤.៣ %
  - ឧស្សាហកម្មខ្នាតធំ ១៨.២ %

## <u>សេដ្ឋកិច្ច</u>

| ឆ្នាំ | ២០០០ | ២០០១ | ២០០២ | ២០០៣ |
|---|---|---|---|---|
| ✦ *ផលិតផលក្នុងស្រុកសរុប (លានដុល្លា)* | ២.៤៨០ | ២.៥៩២ | ២.៧២១ | ២.៨៨៨ |
| ✦ *ផលិតផលក្នុងស្រុកសរុបក្នុងម្នាក់ (ដុល្លា)* | ២៦១ | ២៥៩ | ២៥៥ | ៣១៧ |
| ✦ *អត្រាកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ (ភាគរយ)* | ៧.៧ | ៦.៣ | ៥.០ | ៦.០ |

- អត្រាលំនៅឋានមានអគ្គិសនីសំរាប់បំភ្លឺ :
  - ចំនួនសរុប ១៥.១ %
  - ទីក្រុង ៥៣.៦ %
  - ជនបទ ៨.៦៥ %

- អត្រាលំនៅឋានប្រើប្រភេទថាមពលផ្សេងៗក្នុងការចំអិនអាហារ :
  - អុស ៩០.០ %
  - ធ្យូង ៥.៣ %
  - ប្រេងកាត ១.៨ %
  - ឧស្ម័ន ១.៧ %
  - ផ្សេងៗ ១.២ %

## ១.២ រចនាសម្ព័ន្ធនយោបាយ និងភូមិសាស្ត្រ

ប្រទេសកម្ពុជាស្ថិតក្នុងតំបន់អាស៊ីអាគ្នេយ៍មានទីតាំងស្ថិតនៅចន្លោះខ្សែស្របទី ៨ និងទី ១២ នៃរយៈទទឹងខាងជើង និងនៅចន្លោះខ្សែបណ្ដោយទី ១០២ និងទី ១០៨ នៃរយៈបណ្ដោយខាងកើត ។ កម្ពុជាមានព្រំដែនដីគោកប្រវែង ២.៤២៨ គ.ម ជាប់ជាមួយប្រទេសថៃនៅប៉ែកខាងជើងនិងខាងលិច ជាប់ប្រទេសឡាវប៉ែកខាងជើង និងជាប់វៀតណាមប៉ែកខាងកើត និងខាងត្បូងប្រទេស ។




*ប្រភព*: គំរោង NAPA (ឆ្នាំ ២០០៣)

យោងតាមស្ថិតិរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៅក្នុងអាណត្តិបោះឆ្នោតសកលឆ្នាំ ២០០៣ រចនាសម្ព័ន្ធនយោបាយ និងរដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានចែកចេញជា : ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ ឃុំ-សង្កាត់ និងភូមិ គឺមានចំនួនដូចខាងក្រោម :

- ចំនួនខេត្ត-ក្រុង ២៤
- ចំនួនស្រុក-ខ័ណ្ឌ ១៨៥
- ចំនួនឃុំ-សង្កាត់ ១.៦២១
- ចំនួនភូមិ ១២.៧៣៨

# ១.៣ វិស័យកសិកម្ម និងឧស្សាហកម្មនៅកម្ពុជា

## ១.៣.១ វិស័យកសិកម្ម

កម្ពុជា គឺជាប្រទេសដែលមានសេដ្ឋកិច្ចពឹងផ្អែកលើវិស័យកសិកម្ម ហើយដែលមានប្រជាជនប្រមាណពី ៨០% ទៅ ៨៥% ប្រកបរបរកសិកម្ម និងផ្នែកពាក់ពន្ធ័ ដូចជា ដំណាំ ការចិញ្ចឹមសត្វ និងការបរបាញ់ជាដើម ហើយវិស័យនេះបានរួមចំណែកប្រមាណ ជិតពាក់កណ្តាលនៃផលទុនជាតិក្នុងស្រុកសរុប ។ ដំណាំស្រូវ គឺជាស្បៀងដ៏ចំបងបំផុតនៅកម្ពុជាដែលបានគ្របដណ្តប់លើផ្ទៃដី ប្រមាណជា ៩០% នៃផ្ទៃដីដាំដុះសរុប ។ បន្ទាប់ពីដំណាំស្រូវ គឺមានដំណាំជាច្រើនមុខទៀតដែលចូលរួមលើកកំពស់អភិវឌ្ឍន៍ សេដ្ឋកិច្ចជាតិរួមមាន : កៅស៊ូ ពោត សណ្តែកសៀង ម្រេច ថ្នាំជក់ ។ល។ ទាក់ទងទៅនឹងដំណាំស្រូវនៅកម្ពុជា ការដាំដុះ ត្រូវបានធ្វើតាមប្រព័ន្ធផ្សេងៗគ្នា រួមមាន : ដំណាំស្រូវវស្សាតាមដីទំនាប ដំណាំស្រូវប្រាំងប្រដេញទឹក ដំណាំស្រូវឡើងទឹក ដំណាំស្រូវ ប្រាំងដីទំនាបមានប្រភពស្រោចស្រព និងដំណាំស្រូវដីខ្ពង់រាប ។ រីឯប្រព័ន្ធដំណាំចំរុះវិញ គឺមានការដាំដុះច្រើននៅតំបន់ទំនាបទន្លេ មេគង្គ តំបន់ដីក្រហម ដីឥដ្ឋខ្មៅ និងកសិកម្មព្រៃដុត (កសិកម្មពនេចរ) ។

វិស័យកសិកម្មកម្ពុជាមានសក្តានុពលខ្ពស់ ហើយបានផ្តល់ជាមូលដ្ឋានគ្រឹះសំរាប់ការអភិវឌ្ឍន៍ប្រទេស ។ ទិសដៅចំបងរបស់ រាជរដ្ឋាភិបាលក្នុងវិស័យកសិកម្ម គឺធានាស្ថេរភាពស្បៀងទាំងកំរិតជាតិ និងទាំងកំរិតគ្រួសារ បង្កើនបរិមាណនាំចេញ ពង្រីក ផលិតកម្មកៅស៊ូសំរាប់បង្កើនចំណូលរូបិយវត្ថុអន្តរជាតិ លើកស្ទួយវត្ថុធាតុដើមក្នុងស្រុកសំរាប់កសិឧស្សាហកម្ម និងបង្កើនចំណូល សំរាប់ប្រជាពលរដ្ឋតាមជនបទ ។

យោងតាមការសិក្សាស្រាវជ្រាវផ្សេងៗធ្វើឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គការមិនមែន រដ្ឋាភិបាលបានបង្ហាញថាផលិតកម្មនិងបសុព្យាបាល គឺមានប្រមាណ ៥.១% ហើយផលត្រីមានប្រមាណ ២០% នៃផលិតកម្មកសិកម្ម សរុប ។ សំរាប់ពត៌មានពិស្តារគឺអាចរកបាននៅក្នុងព្រឹត្តិបត្រស្ថិតិកសិកម្មប្រចាំឆ្នាំ និងព្រឹត្តិបត្រស្ថិតិផលនេសាទប្រចាំឆ្នាំ ។

<u>ផលិតកម្មស្បៀង</u>

កសិករភាគច្រើននៅកម្ពុជាប្រកបរបរដាំដុះដំណាំកសិកម្មសំរាប់ចិញ្ចឹមជីវិត ។ ទំរង់ផលិតកម្មកសិកម្មបែបនេះអាចផ្តល់ផល ជាស្បៀងអាហារចិញ្ចឹមជីវិតសំរាប់តែបុគ្គលម្នាក់ ឬគ្រួសារនីមួយៗ និងមានសេសសល់តិចតួចសំរាប់លក់ជាចំណូល ឬរក្សាទុកសំរាប់ ទ្រទ្រង់ពេលផលដំណាំទទួលរងការខូចខាត ។ ស្រូវជាផលិតផលចំបងដោយមាន ៨៨% នៃតំលៃផលិតផលដំណាំសរុបក្នុងឆ្នាំ ២០០២ (យោងតាមតារាង ១-២ ) ។ ដោយឡែកផលិតផលកៅស៊ូ ពោត ដំឡូងឈើ គឺបានដើរតួនាទីដ៏សំខាន់ក្នុងការធានានូវ សុវត្ថិភាពស្បៀងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ។ ទាក់ទងទៅនឹងផ្ទៃដីផលិតកម្ម និងផលដំណាំកសិកម្ម គឺមានការប្រែ ប្រួលទៅតាមឆ្នាំ ដូចដែលមានបង្ហាញនៅក្នុងតារាងខាងក្រោម ។

តារាង ១-១ : ផលិតកម្មដំណាំ និងផ្ទៃដីដាំដុះ (ឆ្នាំ២០០០-២០០២)

| ផលិតផល | ផ្ទៃដីដាំដុះ (ហិកតា) | | | បរិមាណ (តោន) | | |
|---|---|---|---|---|---|---|
| | ២០០០ | ២០០១ | ២០០២ | ២០០០ | ២០០១ | ២០០២ |
| ស្រូវ | ២.៣១៨.៤៥៩ | ២.២៤០.៩១៧ | ២.១៣៧.១២៥ | ៤.០២៦.០៩២ | ៤.០៩៩.០១៦ | ៣.៨២២.៥០៩ |
| ពោត | ៧១.៤៦២ | ៨០.២១៥ | ៨០.៤៧០ | ១៥៦.៩៧២ | ១៨៥.៩៨៩ | ១៤៨.៨៩៧ |

| ផលិតផល | ផ្ទៃដីដាំដុះ (ហិកតា) | | | បរិមាណ (តោន) | | |
|---|---|---|---|---|---|---|
| | ២០០០ | ២០០១ | ២០០២ | ២០០០ | ២០០១ | ២០០២ |
| ពោតលឿង | ៤៤.៣៤៧ | ៥៥.១៤៧ | ៥៤.៦៥៧ | ១២១.៧៤១ | ១៥៧.៦៥២ | ១១៧.៣៤៤ |
| ដំឡូងឈើ | ១៦.២៧៩ | ១៤.២៣៩ | ១៩.៥៦៣ | ១៤៧.៧៦៣ | ១៤២.២៦២ | ១២២.០១៤ |
| ដំឡូងជ្វា | ៧.៤៣៥ | ៧.២២៥ | ៨.១៣៦ | ២៨.១៧៨ | ២៦.២៥២ | ៣១.៥៣០ |
| បន្លែ | ៣២.៧៥៥ | ៣៥.៣១១ | ៣៤.៤៣៣ | ១៩៥.៨៩៤ | ១៨៤.៦៤០ | ១៤៣.១៧៥ |
| សណ្តែកបាយ | ២៤.៩៩១ | ២៩.៤៣១ | ៣៩.៨០២ | ១៥.១០០ | ១៧.១៥៣ | ២៣.៩២៥ |
| សណ្តែកដី | ១០.៣៧០ | ១១.៩១៣ | ១៣.៨៤០ | ៧.៤៩០ | ៨.៩១៣ | ៩.៧៣៨ |
| សណ្តែកសៀង | ៣៣.២៥៦ | ៣១.៩៩៧ | ៣៣.៦១៣ | ២៨.១១១ | ២៤.៦៥៨ | ៣៨.៨០១ |
| អំពៅ | ៧.៧២៣ | ៧.៨៥៤ | ៩.៤៧៣ | ១៦៤.១៧៦ | ១៦៩.៣០២ | ២០៨.៨១៩ |
| ល្ង | ១៩.២២២ | ២០.១៥៨ | ២០.៨៥២ | ៩.៨៥៥ | ៨.៩៥៧ | ១០.១៥៧ |
| ថ្នាំជក់ | ៩.៦៧៨ | ៨.៥៥៤ | ៤.០៧៨ | ៧.៦៦៥ | ៤.៦៦២ | ២.៥០១ |
| ក្រចៅ | ២០៨ | ២០៣ | ៤៨៥ | ១៨០ | ២០៣ | ៦៣៦ |
| **សរុប** | **២.៥៩៦.២២១** | **២.៥៤៣.១៦៤** | **២.៤៥៦.៥២៧** | **៤.៩០៩.២១៧** | **៥.០២៩.២៥៩** | **៤.៦៨០.០៤៦** |

*ប្រភព* : របាយការណ៍សន្និបាតបូកសរុបការងារកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ ២០០៣

តារាង ១-២: របនាសម្ព័ន្ធផ្នែកក្សេត្រសាស្ត្រ (ឆ្នាំ២០០២)

| ផលិតផល | បរិមាណ (តោន) | តំលៃប៉ាន់ស្មាន (ដុល្លារ) | ភាគរយនៃផលតំលៃសរុប(%) |
|---|---|---|---|
| ស្រូវ | *៣.៨២២.៥០៩.០០* | *១.៦៦៦.២២១.៨៧២.០០* | *៨៧.៥៦* |
| ដំណាំផ្សេងៗ | *៥៤៣.២៨៥.០០* | *២៩២.៥៣៨.០៧៦.៩០* | *១២.៤៤* |
| **សរុប** | **៤.៣៦៥.៧៩៤,០០** | **១.៩៥៨.៧៥៩.៩៤៨,៩០** | **១០០,០០** |

*ប្រភព* : របាយការណ៍សន្និបាតបូកសរុបការងារកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ ២០០៣

## ផលិតកម្មបសុបក្សី និងបសុសត្វ

បច្ចុប្បន្ន ប្រភេទកសិដ្ឋានចិញ្ចឹមសត្វក្នុងទ្រង់ទ្រាយធំគឺមានតិចតួចនៅក្នុងប្រទេសកម្ពុជា ។ ភាគច្រើនផលិតកម្មបសុបក្សី និងបសុសត្វធ្វើឡើងជាលក្ខណៈគ្រួសារតែប៉ុណ្ណោះ ។ គោលបំណងនៃផលិតកម្មបែបនេះ គឺដើម្បីលើកស្ទួយការផ្គត់ផ្គង់ក្នុងស្រុកជាអាហារ និងមានបន្តិចបន្តួចសំរាប់លក់ជាកំរៃគ្រួសារ ។ រីឯប្រព័ន្ធបសុវប្បកម្ម គឺបានបង្កើតឡើងតែក្នុងគោលបំណងសំរាប់ការស្រាវជ្រាវ និងជាកម្មវិធីសាកល្បង ឬកម្មវិធីបង្ហាញនានា ។

តារាង ១-៣ :  ផលិតកម្មបសុបក្សី និងបសុសត្វ (ឆ្នាំ២០០០-២០០២)

| ផលិតផល | បរិមាណ (ក្បាល) | | |
|---|---|---|---|
| | ២០០០ | ២០០១ | ២០០២ |
| គោ | ២.៩៩២.៦៤០ | ២.៨៦៨.៨២៧ | ២.៩២៤.៤៥៧ |
| ក្របី | ៦៥៣.៦៣១ | ៦២៦.០១៦ | ៦២៥.៩១២ |
| ជ្រូក | ១.៩៣៣.៩៣០ | ២.១១៤.៥២៤ | ២.១០៥.៤៣៩ |
| បសុបក្សី | ១៥.២៤៩.២០១ | ១៥.២៤៩.៤៤៧ | ១៦.៦៧៧.៨៦៤ |
| សរុប | **២០.៨៦៩.៤០២** | **២០.៨៥៨.៨១៤** | **២២.៣៣៣.៦៦៨** |

*ប្រភព* :  របាយការណ៍សន្និបាតបូកសរុបការងារកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ ២០០៣

តារាង ១-៤ :  រចនាសម្ព័ន្ធផលិតកម្មបសុបក្សី និងបសុសត្វ (ឆ្នាំ២០០២)

| ផលិតផល | បរិមាណ (ក្បាល) | តំលៃប៉ាន់ស្មាន (ដុល្លារ) | ភាគរយនៃផលតំលៃសរុប(%) |
|---|---|---|---|
| គោ | ២.៩២៤.៤៥៧ | ៥៨៤.៨៩១.៤០០.០០ | ៧៥.៧២ |
| ក្របី | ៦២៥.៩១២ | ៩៣.៨៨៦.៨០០.០០ | ១២.១៥ |
| ជ្រូក | ២.១០៥.៤៣៩ | ៧៣.៦៩០.២២៥.០០ | ៩.៥៤ |
| បសុបក្សី | ១៦.៦៧៧.៨៦៤ | ២០.០១៣.៤៣៦.៨០ | ២.៥៩ |
| សរុប | **២២.៣៣៣.៦៦៨** | ***៧៧២.៤៨១.៨៦១.៨០*** | ១០០.០០ |

*ប្រភព* : របាយការណ៍សន្និបាតបូកសរុបការងារកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ ២០០៣

ត្រី និងផលិតកម្មត្រី

យោងតាមការប៉ាន់ស្មានផលនេសាទត្រីទឹកសាបបានបង្ហាញថា ការចាប់ត្រីបានថយចុះពី ៤៤៤.៥ ពាន់តោនក្នុងឆ្នាំ ២០០០ មកត្រឹម ៤២៤.៤ ពាន់តោនក្នុងឆ្នាំ២០០២ ។ ការនេសាទត្រីទឹកសាបសរុបក្នុងឆ្នាំ ២០០២ គឺមានចំនួន ៣៦០.៣ ពាន់តោន ដែលវាបានថយចុះប្រមាណជា ៦.៤% បើប្រៀបធៀបទៅផលនេសាទក្នុងឆ្នាំ ២០០០ ដែលមានចំនួន ៣៨៥.០ ពាន់តោន ។ ពិនិត្យជារួមចាប់តាំងពីឆ្នាំ ១៩៩៩ មក ផលនេសាទទឹកសាបគឺមានការថយចុះយ៉ាងខ្លាំង ហើយដែលការថយចុះនេះបណ្តាលមកពីកត្តាជាច្រើនដូចជា ការចាប់ច្រើនហួសកំណត់ ការនេសាទខុសលក្ខណៈបច្ចេកទេស ការប្រែប្រួលគុណភាពបរិស្ថាន ។ល។ ដោយឡែកការនេសាទត្រីទឹកប្រៃនៅកម្ពុជា មានការកើនឡើងចំនួន ៩.២ % គឺពីចំនួន ៤២.០ ពាន់តោនក្នុងឆ្នាំ២០០០ ដល់ ៤៥.៨៥ ពាន់តោនក្នុងឆ្នាំ២០០២ ហើយការនេសាទត្រីទឹកប្រៃ គឺមានសកម្មភាពច្រើននៅក្នុងបរិវេណក្រុងព្រះសីហនុ និងខេត្តកោះកុង ។

នៅក្នុងគោលបំណងរក្សាពូជត្រី និងដើម្បីបង្កើនផលស្តុកធម្មជាតិសំរាប់ការនេសាទរបស់ប្រជាពលរដ្ឋ រាជរដ្ឋាភិបាលកម្ពុជាបានសំរេចកាត់រំសាយចំនួនឡូត៍នេសាទសម្បទានពីចំនួន ២៧០ មកត្រឹមចំនួន ១៦៤ ឡូត៍ ។

វារីវប្បកម្មនៅកម្ពុជាបានកើនឡើងក្នុងកំរិតតិចតួចពី ១៧.៥ ពាន់តោននៅក្នុងឆ្នាំ ២០០០ ទៅដល់ ១៨.២៥ តោនក្នុងឆ្នាំ ២០០២ ។ រីឯផលិតកម្មត្រីកែច្នៃ តាមការប៉ាន់ស្មានបានថយចុះ ១៦.០% គឺពី ៦៣.០០ ពាន់តោនក្នុងឆ្នាំ ២០០០ មកនៅត្រឹម ៥២.៥០ ពាន់តោនក្នុងឆ្នាំ ២០០២ ។

តារាង ១-៥ : ផលិតកម្មជលផល (ឆ្នាំ២០០០-២០០២)

| ផលិតផល | បរិមាណ (តោន) | | |
|---|---|---|---|
| | ២០០០ | ២០០១ | ២០០២ |
| នេសាទទឹកសាប | ៣៨៥.០០០.០០ | ៣៨៥.០០០.០០ | ៣៦០.៣០០.០០ |
| នេសាទទឹកប្រៃ | ៤២.០០០.០០ | ៤០.០០០.០០ | ៤៥.៨៥០.០០ |
| វារីវប្បកម្ម | ១៧.៥០០.០០ | ៣០.៥០០.០០ | ១៨.២៥០.០០ |
| សរុប | ៤៤៤.៥០០.០០ | ៤១៥.៥០០.០០ | ៤២៤.៤០០.០០ |

ប្រភព : របាយការណ៍សន្និបាតបូកសរុបការងារកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ ២០០៣

តារាង ១-៦ : រចនាសម្ព័ន្ធផ្នែកជលផល (ឆ្នាំ២០០២)

| ផលិតផល | បរិមាណ (តោន) | តំលៃប៉ាន់ស្មាន (ដុល្លារ) | ភាគរយនៃផលតំលៃសរុប(%) |
|---|---|---|---|
| នេសាទទឹកសាប | ៣៦០.៣០០.០០ | ៥៧៦.៤៨០.០០០.០០ | ៨២.៨៨ |
| នេសាទទឹកប្រៃ | ៤៥.៨៥០.០០ | ៩១.៧០០.០០០.០០ | ១៣.១៨ |
| វារីវប្បកម្ម | ១៨.២៥០.០០ | ២៧.៣៧៥.០០០.០០ | ៣.៩៤ |
| សរុប | ៤២៤.៤០០.០០ | ៦៩៥.៥៥៥.០០០.០០ | ១០០.០០ |

ប្រភព : របាយការណ៍សន្និបាតបូកសរុបការងារកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ ២០០៣

## ព្រៃឈើ និងផលិតផលព្រៃឈើ

យោងតាមរបាយការណ៍ផលិតកម្មព្រៃឈើរបស់រដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបញ្ជាក់ថាពុំមានការកាប់ព្រៃឈើទេ គឺមានតែឈើអារចំនួន ១២.៧៣៥ ម៉ែត្រគូបប៉ុណ្ណោះ ដែលបានផលិតក្នុងឆ្នាំ ២០០២ (សន្និបាតប្រចាំឆ្នាំ២០០៣) ហើយបើប្រៀបធៀបទៅនឹងឆ្នាំ ២០០១ គឺមានការផលិតឈើមូលចំនួន ១២៣.០០០ម៉ែត្រគូប និងឈើអារ ១៦.១៧៤ ម៉ែត្រគូប ។

តារាង ១-៧ : ផលិតកម្មរុក្ខកម្ម (ឆ្នាំ២០០០-២០០២)

| ផលិតផល | បរិមាណ | | |
|---|---|---|---|
| | ២០០០ | ២០០១ | ២០០២ |
| ឈើកែច្នៃ (ម៉ែត្រគូប) | ១៥.៧៨៥.០០ | ១៦.១៧៤.០០ | ១២.៧៣៥.០០ |
| អនុផលព្រៃឈើ (តោន) | ៥១.៣១០.០០ | ៣៧.៥៧៤.០០ | ៨.១២៧.០០ |

ប្រភព : របាយការណ៍សន្និបាតបូកសរុបការងារកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ ២០០៣

តារាង ១-៨ : រចនាសម្ព័ន្ធផលិតកម្មរុក្ខកម្ម (ឆ្នាំ២០០២)

| ផលិតផល | បរិមាណ | តំលៃ (ដុល្លារ) |
|---|---|---|
| ឈើអារ/ឈើកែច្នៃ (ម៉ែត្រគូប) | ១២.៧៣៥.០០ | ៤.៧៥៤.៣៥៥.៥៥ |
| អនុផលព្រៃឈើ (តោន) | ៨.១២៧.០០ | គ្មាន |

*ប្រភព* : របាយការណ៍សន្និបាតបូកសរុបការងារកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ ២០០៣

## ផលិតកម្មកៅស៊ូ

ផលិតផលកៅស៊ូសរុបមធ្យមប្រចាំឆ្នាំ គឺមានប្រមាណជា ៤០.០០០ តោនក្នុងមួយឆ្នាំ ដែលចំនួននេះគឺស្មើនឹង ៨០% នៃផលិតផលកៅស៊ូនាចុងទសវត្សទី ៦០ ។ ដើម្បីធានាឱ្យមានការកែប្រែរចនាសម្ព័ន្ធផលិតកម្ម និងការធ្វើឱ្យប្រសើរឡើងក្នុងវិស័យផលិតកម្មកៅស៊ូ រាជរដ្ឋាភិបាលកម្ពុជាបានផ្លាស់ប្តូរគោលនយោបាយអាជីវកម្មផលិតកម្មកៅស៊ូ ពីការគ្រប់គ្រងដោយរដ្ឋទៅឯកជន ។

តារាង ១-៩ : ផលិតកម្មកៅស៊ូ និងផ្ទៃដីដាំដុះ (ឆ្នាំ២០០០-២០០២)

| *ផលិតផល* | *ផ្ទៃដី (ហិកតា)* | | | *បរិមាណ (តោន)* | | |
|---|---|---|---|---|---|---|
| | ២០០០ | ២០០១ | ២០០២ | ២០០០ | ២០០១ | ២០០២ |
| កៅស៊ូ | ១.៧២៥.៩៧ | ២.១៦៥.៣៥ | ២៩.១១៨.៦១ | ៧៦.៤៦៤.៦៧ | ៤៣.០៥៤.០០ | ៣២.៧៧៤.០០ |

*ប្រភព* : របាយការណ៍សន្និបាតបូកសរុបការងារកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ ២០០៣

## ការប្រើប្រាស់ដីក្នុងវិស័យកសិកម្ម

ការកើនឡើងយ៉ាងរហ័សនូវចំនួនប្រជាពលរដ្ឋ បានធ្វើឱ្យមានតំរូវការកាន់តែច្រើននូវទីអាស្រ័យ និងផ្ទៃដីផលិតកម្មកសិកម្មរបស់ប្រទេស ។ តារាង ១-១០ បានបង្ហាញឱ្យឃើញនូវព័ត៌មានស្តីពីការប្រើប្រាស់ដីសំរាប់វិស័យកសិកម្មក្នុងឆ្នាំ ២០០២ ដែលរៀបចំដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

តារាង ១-១០ : ការប្រើប្រាស់ដីក្នុងវិស័យកសិកម្ម (ឆ្នាំ២០០២)

| *ចំណាត់ថ្នាក់* | *ផ្ទៃដី (លានហិកតា)* | *ភាគរយ (%)* |
|---|---|---|
| ដីព្រៃ (តំបន់ការពារ ព្រៃសម្បទាន ព្រៃការពារ និងព្រៃផ្សេងទៀត) | ១១.១០ | ៦១.៣០ |
| ដីព្រៃគុម្ពោត | ១.២៩ | ៧.៧០ |
| ដីដាំដុះ | ២.៧០ | ១៥.០០ |
| ដីឡូត៍នេសាទសម្បទាន | ១.០០ | ៥.៣០ |
| ដីទីក្រុងតូចៗ | ១.០០ | ៥.៣០ |

| ចំណាត់ថ្នាក់ | ផ្ទៃដី (លានហិកតា) | ភាគរយ (%) |
|---|---|---|
| ដីសម្បទានកសិកម្ម | ០.៨១ | ៤.០០ |
| ដីចំការមីន ឬគ្រាប់មិនទាន់ផ្ទុះ | ០.១០ | ០.៦០ |
| សរុប | ១៨ | ៩៩,២០ |

*ប្រភព* : ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០០៣

យោងតាមការបង្ហាញខាងលើ ផ្ទៃដីដាំដុះគឺមានពី ២.៧ ទៅ ៣.១ លានហិកតា ក្នុងនោះដីដាំដុះស្រូវគឺមានប្រមាណពី ២.១ ទៅ ២.៣ លានហិកតា ប្រមាណជា ១០% នៃផ្ទៃដីប្រទេស ។ ផ្ទៃដីនៅសល់ប្រមាណពី ៦ ទៅ ៩ លានហិកតា គឺជាផ្ទៃដីដាំដំណាំផ្សេងៗ ។

## ១.៣.២ ទិសំយឧស្សាហកម្ម

មុនឆ្នាំ ១៩៩៣ មានការវិនិយោគលើវិស័យឧស្សាហកម្មក្នុងកំរិតទាបនៅកម្ពុជា ។ ការវិនិយោគលើវិស័យនេះមានភាពប្រសើរឡើងចាប់ពីឆ្នាំ ១៩៩៣ ដែលអាចចាត់ទុកថាជាឆ្នាំគោលនៃការអភិវឌ្ឍន៍វិស័យឧស្សាហកម្មនៅកម្ពុជា ។ យោងទៅលើស្ថេរភាពនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមនៅកម្ពុជា ភាពសមស្របនៃបទបញ្ញត្តិនានា ជាពិសេសច្បាប់វិនិយោគនិងការផ្តល់ប្រព័ន្ធអនុគ្រោះពន្ធ (GSP) ដោយបណ្តាប្រទេសឧស្សាហកម្មជឿនលឿនបានធ្វើឱ្យការអភិវឌ្ឍន៍វិស័យឧស្សាហកម្មមានសន្ទុះកើនឡើងយ៉ាងរហ័ស ពិសេសវិស័យឧស្សាហកម្មវាយនភ័ណ្ឌកាត់ដេរ ។ ឧស្សាហកម្មវាយនភ័ណ្ឌកាត់ដេរ ជ្រលក់ពណ៌ អាហារ និងភេសជ្ជៈ ... ដណ្តើមបានប្រមាណជា ២៤% នៃផលិតផលក្នុងស្រុកសរុបរបស់ជាតិនាឆ្នាំ ២០០១ ។ តែទោះជាយ៉ាងណាក៏ដោយវិស័យឧស្សាហកម្មកម្ពុជាគឺស្ថិតក្នុងទ្រង់ទ្រាយតូច ហើយបច្ចុប្បន្ននេះកម្ពុជាកំពុងសំឡឹងឆ្ពោះទៅរកការអភិវឌ្ឍន៍វិស័យឧស្សាហកម្មទ្រង់ទ្រាយធំសំរាប់អនាគត ។

<u>សហគ្រាសឧស្សាហកម្ម</u>

ផ្អែកតាមទិន្នន័យនៃការចុះបញ្ជីរបស់ក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល កម្ពុជាមានសហគ្រាសឧស្សាហកម្មចំនួន ២៧.៤៧៥ មូលដ្ឋាន (តូច មធ្យម និងធំ) ដែលដំណើរការក្នុងឆ្នាំ ២០០១។ ក្នុងចំណោមសហគ្រាសឧស្សាហកម្មទាំងនោះមាន ២៧៤ ជាសហគ្រាសឧស្សាហកម្មខ្នាតធំ ៤៦ ជាសហគ្រាសឧស្សាហកម្មខ្នាតមធ្យម និងចំនួន ២៧.១៥៥ ជាសហគ្រាសឧស្សាហកម្មខ្នាតតូច។

តារាង ១-១១ : របនាសម្ព័ន្ធនៃឧស្សាហកម្ម និងសហគ្រាស (ឆ្នាំ២០០០-២០០១)

| ឆ្នាំ | សហគ្រាសឧស្សាហកម្មខ្នាតតូច ឬសិប្បកម្ម | សហគ្រាសឧស្សាហកម្ម ខ្នាតធំ និងមធ្យម | សរុប |
|---|---|---|---|
| ២០០១ | ២៧.១៥៥ | ៣២០ | ២៧.៤៧៥ |
| ២០០០ | ២៥.៤០៦ | ៣៤០ | ២៥.៧៤៦ |
| អត្រាធៀប ២០០១ / ២០០០ | ១០៧% | ៩៤% | ១០៧% |

*ប្រភព* : របាយការណ៍ការងារប្រចាំឆ្នាំ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឆ្នាំ២០០៣

តំលៃប៉ាន់ស្មាននៃផលិតផលពីសហគ្រាសឧស្សាហកម្មដែលបានចុះបញ្ជីក្នុងឆ្នាំ ២០០១ មានប្រមាណជា ១.៤៦៦លានដុល្លាអាមេរិក ក្នុងនោះតំលៃផលិតផលវាយនភ័ណ្ឌសំលៀកបំពាក់ និងស្បែកជើងមានប្រមាណជា ៩៧.៥% បន្ទាប់មកគឺផលិតផលម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់មានតំលៃប្រមាណជា ២.២% ។

ធនធានរ៉ែ

ការពិនិត្យឡើងវិញនាពេលថ្មីៗពីការស្រាវជ្រាវរ៉ែនៅកម្ពុជាដែលអនុវត្តដោយ ESCAP ក្នុងឆ្នាំ១៩៩៣ និងលទ្ធផលនៃការសិក្សាក្នុងទសវត្សឆ្នាំ ១៩៥០ បានបង្ហាញពីវត្តមាននៃសន្ទស្សន៍រ៉ែសំខាន់ៗក្នុងប្រទេសកម្ពុជា រួមមាន : ត្បូងកណ្តៀង ត្បូងទទឹម សំណ មាស សំណប៉ាហាំង កាស៊ីដេរីត ស៊ីលីកា បុកស៊ីត ម៉ាញេស្យូម ស្ពូក កៅឡាំង ថ្មបូងថ្ម ថ្មបូងកូក លីញីត ប៉ាហ្គូឌីត និងហ្វូសហ្វាត ។

ធនធានរ៉ែអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេស ។ ឧស្សាហកម្មរ៉ែនៅកម្ពុជាពេលបច្ចុប្បន្ននេះមិនទាន់មានការអភិវឌ្ឍន៍នៅឡើយទេ ពោលគឺមានតែការធ្វើអាជីវកម្មរ៉ែបន្តិចបន្តួចប៉ុណ្ណោះ លើកលែងតែរ៉ែត្បូងដែលមានការធ្វើអាជីវកម្មច្រើននិងមិនអាចគ្រប់គ្រងបាន ដែលស្ថិតនៅភាគទិសពាយ័ព្យនៃប្រទេស ។ ការជីកយករ៉ែហ្វូសហ្វាតនៅប៉ៃលិនបានធ្វើឱ្យខូចខាតដី ហើយចាត់ទុកថាជាមូលហេតុចំបងនៃការកើនឡើងល្បាប់ភក់នៅតាមដងស្ទឹងសង្កែក្នុងខេត្តបាត់ដំបង ។

ជារួម ទោះបីកម្ពុជាមានភោគទ្រព្យរ៉ែជាទាយជ្ជទានពីធម្មជាតិច្រើនក៏ដោយ តែវាអាចនឹងត្រូវហិនហោចប្រសិនបើមិនមានការគ្រប់គ្រងច្បាស់លាស់លើអាជីវកម្មធនធានរ៉ែទាំងនោះ ។ ដូចនេះ ចាំបាច់ត្រូវតែមានការរៀបចំគោលនយោបាយគ្រប់គ្រង និងការផ្ចួចផ្តើមត្រួតពិនិត្យដ៏ម៉ត់ចត់ ទើបអាចឈានទៅដល់ការធ្វើឱ្យប្រសើរឡើងនូវការធ្វើអាជីវកម្មដែលមានលក្ខណៈសេដ្ឋកិច្ច និងធ្វើឱ្យបរិស្ថានមានភាពល្អប្រសើរឡើងវិញ ។ ការរៀបចំនូវគោលនយោបាយសំរាប់អនុវត្តច្បាប់គ្រប់គ្រងធនធានរ៉ែ គឺជាជំហានដ៏សំខាន់ក្នុងការអភិវឌ្ឍន៍ធនធានរ៉ែនៅកម្ពុជា ។ ច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែលើកទី ១ បានអនុម័តក្នុងឆ្នាំ ១៩៦៨ រីឯច្បាប់ថ្មីត្រូវបានអនុម័តដាក់ឱ្យប្រើប្រាស់នាឆ្នាំ ២០០១ ។

ថាមពល

ប្រភពថាមពលសំខាន់ៗនៅកម្ពុជា រួមមាន : ផលិតផលប្រេងឥន្ធនៈ ឧស្ម័ន ឱស សំណល់រុក្ខជាតិ សំណល់លាមកសត្វ (ជីវម៉ាស) ។ ចំណែកឯការប្រើប្រាស់ធ្យូងថ្មជាប្រភពថាមពល គឺមានតិចតួចណាស់នៅកម្ពុជាក្នុងវិស័យឧស្សាហកម្ម ។ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ តំរូវការថាមពលនៅកម្ពុជាមានការកើនឡើងយ៉ាងខ្លាំង ដោយសារកំណើននៃការអភិវឌ្ឍន៍សេដ្ឋកិច្ចមានកំរិតខ្ពស់ ដូចជា សកម្មភាពផលិតកម្មឧស្សាហកម្ម ការដឹកជញ្ជូន សេវាកម្ម និងការផលិតថាមពលអគ្គិសនី ។ ប្រភពថាមពលខាងដើមពីរ (ផលិតផលប្រេងឥន្ធនៈ និងឧស្ម័ន) ពុំមែនជាផលិតផលក្នុងស្រុកទេ គឺត្រូវបាននាំចូលទាំងស្រុងពីបរទេស ។

នៅកម្ពុជា ផលិតផលប្រេងឥន្ធនៈត្រូវបានប្រើប្រាស់ក្នុងបរិមាណដ៏ច្រើននៅក្នុងការផលិតថាមពលអគ្គិសនី ដំណើរការផលិតកម្មឧស្សាហកម្ម និងមធ្យោបាយដឹកជញ្ជូន ។ ក្រៅពីនោះ គឺមានការប្រើប្រាស់តិចតួចនៅក្នុងការចំអិនអាហារ និងសំរាប់ការដុតបំភ្លឺលំនៅឋានភាគច្រើននៅទីជនបទ ។ ចំពោះទិន្នន័យនៃការប្រើប្រាស់ផលិតផលប្រេងតាមផ្នែកដែលបានរៀបរាប់ខាងលើ គឺពុំទាន់មាននៅឡើយទេ ។ នៅក្នុងឆ្នាំ ២០០២ បរិមាណផលិតផលប្រេងឥន្ធនៈដែលបាននាំចូលសរុប គឺមានប្រមាណ ៦៨៨.០០០

តោន ដែលក្នុងបរិមាណនោះប្រេងម៉ាស៊ូតស្ថិតក្នុងលំដាប់ទី ១ មាន ៥៣.៤% ប្រេងសាំងលំដាប់ទី ២ មាន ១៤.៦% និងប្រេងខ្មៅលំដាប់ទី ៣ មាន ១៣.៩% នៃបរិមាណនាំចូលសរុប ។

ការប្រើប្រាស់ឧស្ម័នជាប្រភពថាមពលនៅកម្ពុជា ពិសេសនៅក្នុងការចំអិនអាហារ គឺបានចាប់ផ្តើមពីឆ្នាំ ១៩៩២ ហើយដែលត្រូវបាននាំចូលពីបរទេស ។ បរិមាណនាំចូលនៃឧស្ម័ននៅក្នុងឆ្នាំ ២០០២ គឺមានប្រមាណ ២៧ ពាន់តោន ។ ចំពោះការប្រើប្រាស់ប្រភពថាមពលនេះ គឺមានច្រើនតែក្នុងតំបន់ទីក្រុង និងក្នុងទីប្រជុំជនតែប៉ុណ្ណោះ ពីព្រោះវាមានតំលៃខ្ពស់ដែលធ្វើឱ្យប្រជាពលរដ្ឋនៅជនបទមិនអាចប្រើប្រាស់បាន ។

ឧសគឺជាប្រភពថាមពលដ៏សំខាន់របស់ប្រជាពលរដ្ឋកម្ពុជាទូទៅ ។ ឧសបានផ្តល់ជាប្រភពថាមពលសំរាប់ការចំអិនអាហារដែលមានប្រមាណ ៩០% នៃថាមពលប្រើសំរាប់ចំអិនអាហារតាមលំនៅឋាន ។ ក្រៅពីនោះ ឧសក៏ជាប្រភពថាមពលសំរាប់ទ្រទ្រង់ដំណើរការផលិតកម្មជាលក្ខណៈគ្រួសារផងដែរ ដូចជា ការដុតរំងាស់ស្ករ បិទស្រា សំងួតផលិតផលកសិកម្ម និងការផលិតឥដ្ឋក្បឿងសំណង់ជាដើម ។ ទន្ទឹមនឹងការផ្តល់អត្ថប្រយោជន៍ជាប្រភពថាមពល និន្នាការនៃកំណើនការប្រើប្រាស់ឧសនៅកម្ពុជាបានបង្កជាក្តីកង្វល់របស់ជាតិទៅលើការថយចុះនូវបរិមាណព្រៃឈើ ដែលជាគំរបផ្ទៃផែនដីប្រកបដោយសារៈប្រយោជន៍ច្រើនយ៉ាងសំរាប់មនុស្សជាតិនាពេលបច្ចុប្បន្ន និងកូនចៅជំនាន់ក្រោយ ។

ក្រៅពីប្រភពថាមពលខាងលើ សំណល់រុក្ខជាតិ និងសំណល់លាមកសត្វ (ជីវម៉ាស) ក៏ត្រូវបានប្រើប្រាស់ជាប្រភពថាមពលនៅតាមទីជនបទ ដើម្បីជួយកាត់បន្ថយការប្រើប្រាស់ឧស ។ សំណល់រុក្ខជាតិ និងសំណល់លាមកសត្វត្រូវបានប្រើប្រាស់ក្នុងការចំអិនអាហារ និងតិចតួចក្នុងផលិតកម្មជាលក្ខណៈគ្រួសារ ដូចជា ដុតរំងាស់ស្ករនិងបិទស្រាជាដើម ។

នៅកម្ពុជា ថាមពលអគ្គិសនីត្រូវបានផលិតចេញពីរោងចក្រប្រើប្រាស់ថាមពលប្រេងឥន្ធនៈ ពីទំនប់វារីអគ្គិសនី និងពីថាមពលពន្លឺព្រះអាទិត្យ ។ រោងចក្រផលិតអគ្គិសនីភាគច្រើនដំណើរការដោយប្រើប្រេងម៉ាស៊ូត និងប្រេងខ្មៅ ហើយដែលបានផ្តល់ជាថាមពលអគ្គិសនីប្រមាណ ១៦៨ មេហ្គាវ៉ាត់ ដែលស្មើនឹង ៨៣% នៃថាមពលអគ្គិសនីសរុប ។ ចំពោះថាមពលដែលអាចទទួលបានពីទំនប់វារីអគ្គិសនី គឺមានចំនួនត្រឹមតែ ១១ មេហ្គាវ៉ាត់តែប៉ុណ្ណោះ ។ ចំណែកឯការផលិតអគ្គិសនីពីថាមពលព្រះអាទិត្យគឺមានតិចតួចណាស់នៅកម្ពុជា ហើយដែលសំរាប់ប្រើជាការបំភ្លឺតិចតួចនៅទីសាធារណៈ និងលំនៅឋាននៅជនបទ ។

ទាក់ទងទៅនឹងការផ្គត់ផ្គង់អគ្គិសនីសំរាប់លំនៅឋាន គឺមានប្រមាណតែ ១៥ % នៃចំនួនលំនៅឋានសរុបទូទាំងប្រទេស (២.១៨៨.៦៦៣ លំនៅឋាន) ដែលទទួលបានការផ្គត់ផ្គង់ ក្នុងនោះ ៩៣.៦ % ស្ថិតក្នុងតំបន់ទីក្រុងនិងទីប្រជុំជន និង ៨.៦% ស្ថិតក្នុងតំបន់ជនបទ ។ នៅក្នុងឆ្នាំ ២០០២ ថាមពលអគ្គិសនីដែលផ្គត់ផ្គង់ការប្រើប្រាស់ក្នុងរាជធានីភ្នំពេញ គឺមានចំនួន ១២៩.២ មេហ្គាវ៉ាត់ ហើយដែលបរិមាណតំរូវការនឹងកើនដល់ ២០០ មេហ្គាវ៉ាត់ នៅឆ្នាំ ២០០៦ ។ ដោយឡែក ការផ្គត់ផ្គង់ថាមពលអគ្គិសនីនៅតាមទីប្រជុំជនខេត្តក្រុងគឺមានប្រមាណជា ៥០ មេហ្គាវ៉ាត់ ហើយដែលបរិមាណតំរូវការនឹងកើនដល់ ១៧៣ មេហ្គាវ៉ាត់ នៅឆ្នាំ ២០១០ ។

## ១.៣.៣ សង្ខេបវិស័យកសិកម្ម និងឧស្សាហកម្ម

យោងតាមការប៉ាន់ប្រមាណពីរបរការងារបានបង្ហាញថា ក្នុងឆ្នាំ ១៩៩៣ ចំនួនរបរការងារគឺមាន ៣.៩ លាន ដែលក្នុងនោះផ្នែកកសិកម្មបានផ្តល់របរការងារចំនួន ៨១% ផ្នែកឧស្សាហកម្មមាន ៣% និងផ្នែកសេវាកម្មមាន ១៦% ។ នៅក្នុងឆ្នាំ ២០០១ ចំនួនរបរការងារបានកើនដល់ ៦.២ លាន ក្នុងនោះផ្នែកកសិកម្មមានចំនួនប្រមាណ ៧០.៤៩% ផ្នែកឧស្សាហកម្មមាន ១០.១៣% និងផ្នែកសេវាកម្មមាន ១៩.៣៨% នៃរបរការងារសរុប ។ នៅក្នុងវិស័យកសិកម្ម របរការងារក្នុងផ្នែកដាំដុះគឺមានចំនួនច្រើនរហូតដល់ ៩៣% រីឯរបរការងារក្នុងផ្នែកជលផលគឺមាន ៥.៧៣% និងផ្នែកបរបាញ់ ១.២៧% នៃរបរការងារកសិកម្មសរុប ។

តារាង ១-១២ : ទស្សនៈវិស័យទូទៅនៃផ្នែកសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា (ឆ្នាំ២០០១)

| វិស័យ | អត្រាធៀប ផលិតផលក្នុងស្រុកសរុប (% ) | ចំនួននិយោជិក | ផលិតផលសំខាន់ក្នុងវិស័យនីមួយៗ |
|---|---|---|---|
| *ឧស្សាហកម្ម/សហគ្រាស* | ២៤.០០ | ៦២៨.៤៣៧ | រ៉ែ និងរ៉ែត្បូង ម្ហូបអាហារ និងភេសជ្ជៈ ថ្នាំជក់ វាយនភ័ណ្ឌ កាត់ដេរសំលៀកបំពាក់ ជ្រលក់ពណ៌ រោមសត្វប្រដាប់ប្រដាស្បែក កាតាប កាបូបស្រ្តី ស្បែកជើង ឈើនិងផលិតផលឈើ ក្រដាស និងផលិតផលក្រដាស ការបោះពុម្ពគីមីនិង ផលិតផលគីមី កៅស៊ូនិងផលិតផលប្លាស្ទិច ផលិតផលរ៉ែមិនមែនលោហៈ លោហៈ សំណោហៈ គ្រឿងម៉ាស៊ីន បរិក្ខារអេឡិចត្រូនិច បរិក្ខារពេទ្យ សង្ហារឹម និងការផ្គត់ផ្គង់ទឹកស្អាត សំភារៈសំណង់ ។ល។ |
| *កសិកម្ម* | ៣៩.៦០ | ៤.៣៧២.៣០៨ | ស្រូវ ដំឡូងឈើ ដំឡូងជ្វា បន្លែ សណ្តែកខៀវ សណ្តែកបាយ សណ្តែកសៀង ស្ពៃអំពៅ ល្ង ថ្នាំជក់ ក្រចៅ ប្រេងល្ហុង រុក្ខឈើ ដំណាំអចិន្ត្រៃយ៍ ការចិញ្ចឹមសត្វ ផលិតផលត្រី ផលិតផលឈើ កៅស៊ូ កាហ្វេ តែ ។ល។ |
| *សេវាកម្ម* | ៣១.៥០ | ១.២០២.៨៥០ | សណ្ឋាគារ ភោជនីយដ្ឋាន ការដឹកជញ្ជូន គមនាគមន៍ អន្តរកម្មសាច់ប្រាក់ និងការជួល-លក់ផ្ទះ ។ |
| *ពន្ធបន្ថែម* | ៥.៨០ | | |
| *កំរៃធនាគារ* | ០.៥០ | | |
| សរុប | **១០០%** | **៦.២០៣.៥៩៥** | |

*ប្រភព* : កម្មវិធីវិនិយោគសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា ២០០៣-២០០៥ និងសៀវភៅស្ថិតិជាតិ ឆ្នាំ២០០៣

### និយោជិកតាមផ្នែកសំខាន់ៗនៃវិស័យកសិកម្ម

នៅក្នុងវិស័យកសិកម្ម ផ្នែកដាំដុះ បរបាញ់ និងផ្នែកដទៃទៀតមានអត្រាពលកម្មប្រមាណ ៩៣% ធៀបនឹងពលកម្មសរុបនៅក្នុងវិស័យកសិកម្ម ។ ចំណែកឯ ៧% ទៀតបានរួមចំណែកយ៉ាងសំខាន់ក្នុងផ្នែករុក្ខកម្មនិងអាជីវកម្មឈើ និងផ្នែកនេសាទត្រីនិងការធ្វើវារីវប្បកម្ម ។

តារាង ១-១៣ : និយោជិកនិងផលិតផលនៃផ្នែកសំខាន់ៗនៃវិស័យកសិកម្ម (ឆ្នាំ២០០១)

| ផ្នែកផលិត | ចំនួនទីកន្លែង | ចំនួនពលកម្ម | | តំលៃផលិតផល | |
|---|---|---|---|---|---|
| | | ចំនួន(នាក់) | ភាគរយ | តំលៃ(១,០០០ដុល្លារ) | ភាគរយ |
| ការដាំដុះ ការបរបាញ់ និងសកម្មភាពពាក់ព័ន្ធ | គ្មាន | ៤.០៦៣.០៨៨ | ៩២.៩២ | ១.៦៦៦.២២២.០០ | ៩៩.៥៥ |
| រុក្ខកម្ម និងអាជីវកម្មឈើ | គ្មាន | ៥៥.៥១២ | ១.២៦ | ៤.៧៥៤.៤០ | ០.២៨ |
| នេសាទ និងវារីវប្បកម្ម | ១៦៤ | ២៥៣.៧០៨ | ៥.៨២ | ២.៦៩៤.៣០ | ០.១៧ |
| *សរុប* | ១៦៤ | ៤.៣៧២.៣០៨ | ១០០.០០ | ១.៦៧៣.៦៧០.៧០ | ១០០.០០ |

*ប្រភព* : សៀវភៅស្ថិតិជាតិ ឆ្នាំ២០០៣

## និយោជិកតាមផ្នែកសំខាន់ៗនៃវិស័យឧស្សាហកម្ម

នៅក្នុងវិស័យឧស្សាហកម្ម ផ្នែកវាយនភណ្ឌនិងកាត់ដេរសំលៀកបំពាក់ មានអត្រាពលកម្មខ្ពស់ជាងផ្នែកដទៃ គឺរហូតដល់ ៥១.២៥% ធៀបនឹងពលកម្មសរុបនៃវិស័យនេះ ក្រៅពីនេះមានផ្នែកធំចំនួន ២ គឺផ្នែកផលិតម្ហូបអាហារ ១៨% និងផ្នែកសំណង់ចំនួន ១៤% ។

តារាង ១-១៤ : និយោជិកនិងផលិតផលនៃផ្នែកសំខាន់ៗនៃវិស័យឧស្សាហកម្ម (ឆ្នាំ២០០១)

| ផ្នែកនៃវិស័យឧស្សាហកម្ម | ចំនួនពលកម្ម | | តំលៃផលិតផល | |
|---|---|---|---|---|
| | ចំនួន(នាក់) | ភាគរយ | តំលៃ(១,០០០ដុល្លារ) | ភាគរយ |
| រ៉ែ និងរ៉ែត្បូង | ១១.៨២៨ | ១.៨៨ | ១.០៧៨.៩៧៤.៣៦ | ០.០៤ |
| ម្ហូបអាហារ និងភេសជ្ជៈ | ១១២.២២៥ | ១៧.៨៦ | ៣២៨.០៦៣.០៧៦.៩២ | ១១.០៤ |
| ថ្នាំជក់ | ៧.២០៨ | ១.១៥ | ៥៣.១៤៥.១២៨.២១ | ១.៧៩ |
| វាយនភ័ណ្ឌ | ៧៩.៧១៥ | ១២.៦៩ | ១.០៧៤.៨៦២.៨២០.៥១ | ៣៦.១៦ |
| កាត់ដេរសំលៀកបំពាក់ | ២៤២.៥៨៤ | ៣៨.៦០ | ១.១៧៦.៨៣៩.៤៨៧.១៨ | ៣៩.៥៩ |
| រោមសត្វ និងសំភារៈស្បែក | ១១.៧០៩ | ១.៨៦ | ១៣៦.៣១២.៥៦៤.១០ | ៤.៥៩ |
| ឈើ និងផលិតផលឈើ | ២០.៧៧៥ | ៣.៣១ | ១១.៣៨១.៥៣៨.៤៦ | ០.៣៨ |
| ក្រដាស និងផលិតផលក្រដាស | ០ | ០.០០ | ៣៨៦.៤១០.២៦ | ០.០១ |
| ការបោះពុម្ព និងការផលិតពត៌មានបោះពុម្ព | ១.១៥២ | ០.១៨ | ៣៣៦.៩២៣.០៨ | ០.០១ |
| គីមីនិង ផលិតផលគីមី | ៥១០ | ០.០៨ | ២.៩៣៣.៥៨៩.៧៤ | ០.១០ |
| កៅស៊ូ និងផលិតផលប្លាស្ទិច | ១៣១ | ០.០២ | ៨៩.៦៩២.០៥១.២៨ | ៣.០២ |
| ផលិតផលរ៉ែមិនមែនលោហៈ | ១១.៤១៧ | ១.៨២ | ៧.៤៤៣.៣៣៣.៣៣ | ០.២៥ |
| លោហៈ | ៥.៦៦៥ | ០.៩០ | ៧៣.៨៤៦.១៩ | ០.០០ |

| ផ្នែកនៃវិស័យឧស្សាហកម្ម | *ចំនួនពលកម្ម* | | *តំលៃផលិតផល* | |
|---|---|---|---|---|
| | *ចំនួន(នាក់)* | *ភាគរយ* | *តំលៃ(១,០០០ដុល្លារ)* | *ភាគរយ* |
| សំណោហ: | ១១.០៤៨ | ១,៧៦ | ១៦៨.៤៦១,៥៤ | ០.០១ |
| គ្រឿងម៉ាស៊ីន និងបរិក្ខារគ្រឿងចក្រ | ២.១៣២ | ០,៣៤ | ២២.៨០៨.៧១៧,៩៥ | ០.៧៧ |
| បរិក្ខារម៉ាស៊ីនអេឡិចត្រូនិច | ២.១៤៧ | ០,៣៤ | ១៥.៨៩៧.៤៤ | ០.០០ |
| វិទ្យុ ទូរទស្សន៍ បរិក្ខារគ្រឿងទំនាក់ទំនង | ៦៧២ | ០,១១ | ០ | ០ |
| បរិក្ខារពេទ្យ និងសំភារៈភ្នែក | ២.៣៨៨ | ០,៣៨ | ០ | ០ |
| រថយន្តសណ្តោង និងរថយន្តពាក់កណ្តាលសណ្តោងគ្រឿងដឹកជញ្ជូន | ៣.៤៨៨ | ០,៥៦ | ៤.៦២៧.១៧៩.៤៩ | ០,១៦ |
| សង្ហារឹម | ៩.៦៨៤ | ១,៥៤ | ៤.៧៤៤.៨៧១.៧៩ | ០,១៦ |
| អគ្គិសនី ឧស្ម័ន ការចំហុយ និងការផ្គត់ផ្គង់ទឹក | ២.០៩៣ | ០,៣៣ | ៥៦.៥១៦.៩២៣.០៨ | ១,៩០ |
| ទឹកបរិសុទ្ធ និងការចែកចាយទឹកបរិសុទ្ធ | ១.៦៩២ | ០,២៧ | ១.៤៣៨.៩៧៤.៣៦ | ០,០៥ |
| សំភារៈសំណង់ | ៨៨.១៧០ | ១៤,០៣ | ០ | ០ |
| *សរុប* | ៦២៨.៤៣៧ | ១០០,០០ | ២.៩៧២.៨៨០.៧៦៩,២៣ | ១០០,០០ |

*ប្រភព* : សៀវភៅស្ថិតិជាតិ ឆ្នាំ២០០៣

# ជំពូកទី ២

# ការផលិត នាំចូល នាំចេញ និងការប្រើប្រាស់សារធាតុគីមី

ជំពូកនេះផ្តល់ឱ្យនូវព័តិមាននិងទិន្នន័យទូទៅ ដែលទាក់ទងទៅនឹងការនាំចូល និងប្រើប្រាស់សារធាតុគីមីដោយរួមបញ្ចូលទាំងផលិតផលនៃសារធាតុគីមី ព្រមទាំងអធិប្បាយពីអាទិភាពនៃការប្រើប្រាស់ប្រភេទសារធាតុគីមីនិមួយៗនៅកម្ពុជា ក្នុងគោលបំណងបំរើបំរាស់ផ្សេងៗគ្នា ។

ដើម្បីមានភាពងាយស្រួលក្នុងការបរិយាយបង្ហាញនៅក្នុង " **កំរងពតិមានជាតិ ស្តីពី ការគ្រប់គ្រងសារធាតុគីមី** " យើងបានធ្វើចំណាត់ថ្នាក់សារធាតុគីមី និងផលិតផលនៃសារធាតុគីមីទាំងនោះ ជា ១០ ប្រភេទ ដូចខាងក្រោម:

១- ជីគីមី

២- ថ្នាំកសិកម្ម

៣- សារធាតុគីមីសំរាប់វិស័យឱសថ

៤- សារធាតុគីមីសំរាប់វិស័យឧស្សាហកម្ម

៥- ផលិតផលលោហធាតុ និងសមាសធាតុរបស់វា

៦- ឥន្ទនៈរ៉ែ និងផលិតផលប្រេងឥន្ទនៈ

៧- ផលិតផលគីមីសំរាប់ប្រើតាមលំនៅឋាន

៨- សារធាតុគីមីសំរាប់មន្ទីរពិសោធន៍

៩- សំណល់សារធាតុគីមី

១០- សារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ (Persistent Organic Pollutants, POPs)

ដោយសារតែកម្ពុជា គឺជាប្រទេសដែលមានការអភិវឌ្ឍន៍តិច និងមិនមែនជាប្រទេសឧស្សាហកម្ម ដូច្នេះហើយការផលិតនិងនាំចេញនូវសារធាតុគីមី គឺមិនមានទេ។ ជាទូទៅ សារធាតុគីមីដែលបានធ្វើចំណាត់ថ្នាក់ខាងលើ គឺត្រូវបាននាំចូលនិងប្រើប្រាស់តាមវិស័យនានានៅកម្ពុជា។ ការនាំចូលសារធាតុគីមីទាំងនោះ ត្រូវបានគេធ្វើតាមរយៈក្រុមហ៊ុនឯកជនដែលនាំចូលសំរាប់ចែកចាយឬលក់ និងតាមរូបភាពសំរាប់បំរើការផលិត ឬប្រើប្រាស់ក្នុងសកម្មភាពអាជីវកម្មផ្ទាល់របស់គេ។ ដោយឡែកមានការនាំចូលតិចតួចប៉ុណ្ណោះក្នុងរូបភាពជាស្ថាប័នរដ្ឋសំរាប់បំរើការងារដែលពាក់ព័ន្ធនឹងសមត្ថកិច្ចទទួលខុសត្រូវរបស់គេ ដូចជា សំរាប់បំរើការពិសោធន៍ឬវិភាគ សំរាប់កម្មវិធីជាតិប្រឆាំងជំងឺឆ្លង ឬសំរាប់ធ្វើអន្តរាគមន៍ក្នុងពេលសមាសភាពចង្រៃរាតត្បាត ។ល។ ការនាំចូលសារធាតុគីមីទាំងនោះ ត្រូវបានតំរូវឱ្យអនុវត្តន៍តាមនិតិវិធីនិងបែបបទដែលមានចែងក្នុងបទបញ្ញត្តិច្បាប់ ដែលមានលំអិតក្នុងជំពូក ៤ ខាងក្រោយ។ ក្រៅពីការនាំចូលដែលស្ថិតនៅក្រោមការត្រួតពិនិត្យ សារធាតុគីមីមួយចំនួនត្រូវបាននាំចូលដោយគេចពន្ធនៅតាមច្រកព្រំដែនតូចៗផងដែរ។

ទិន្នន័យស្ថិតិដែលទាក់ទងទៅនឹងការនាំចូលនិងប្រើប្រាស់សារធាតុគីមី គឺនៅមានការខ្វះខាតច្រើន ហើយមួយចំនួនដែលមានគឺពុំទាន់បានចងក្រងជាឯកសារដែលមានលក្ខណៈជាប្រព័ន្ធនៅឡើយទេ។ ទិន្នន័យស្ថិតិសារធាតុគីមីដែលរៀបរាប់បង្ហាញនៅក្នុងកំរង

ឯកសារជាតិនេះ ត្រូវបានប្រមែប្រមូលមកពីស្ថាប័នរដ្ឋនានា សង្គមស៊ីវិលនិងផ្នែកឯកជន ដោយភាគច្រើនផ្អែកទៅលើប្រភពទិន្នន័យពីឆ្នាំ២០០០ ដល់ឆ្នាំ២០០២។

## ២.១ ជីគីមី

យោងតាមតួលេខរបស់នាយកដ្ឋានកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម នៅក្នុងឆ្នាំ ២០០២ កម្ពុជាបាននាំចូលជីគីមីប្រមាណ ៤៥.៣៣៤ តោន ហើយដែលប្រភេទនិងបរិមាណនៃជីគីមីដែលនាំចូល គឺមានសង្ខេបបង្ហាញនៅក្នុងតារាង ២-១ ខាងក្រោម។ គួរបញ្ជាក់ថា ប្រភេទជីគីមីដែលនាំចូលមកកម្ពុជា គឺអាចមានច្រើនប្រភេទជាងអ្វីដែលមានបង្ហាញក្នុងតារាងខាងក្រោម ពីព្រោះសំរង់ទិន្នន័យក្នុងពេលនាំចូល ភាគច្រើនគឺពុំបានធ្វើចំណាត់ថ្នាក់លំអិតពីឈ្មោះជីគីមី ពោលគឺករណីភាគច្រើនត្រូវកត់ត្រាតាម Harmoniged System ជាក្រុមតែម្តង ដូចជាករណី (31.02.29.00) ដែលដាក់ថា " ជីគីមីដទៃទៀត " ដោយពុំបានបញ្ជាក់ពីឈ្មោះពិតប្រាកដនៃជីគីមីទាំងនោះឡើយ។ អនុលោមទៅតាមបទបញ្ញត្តិច្បាប់ ជីគីមីដែលនាំចូលនិងដែលធ្វើចរាចរនៅកម្ពុជា ត្រូវមានបិទស្លាកសញ្ញាលើសំភារៈវេចខ្ចប់ និងសរសេរជាភាសាខ្មែរ។ ប៉ុន្តែ នៅក្នុងការអនុវត្ត គឺមានតែជីគីមីមួយចំនួនប៉ុណ្ណោះដែលមានបិទស្លាកសញ្ញាមានសរសេរពន្យល់ពីការប្រើប្រាស់ជាភាសាជាតិ។

តារាង ២-១ : បញ្ជីឈ្មោះនិងបរិមាណជីគីមីដែលបាននាំចូលមកកម្ពុជា ( ឆ្នាំ២០០២)

| លរ. | ឈ្មោះជីគីមី | បរិមាណ ( តោន) | ប្រទេសនាំចូល |
|---|---|---|---|
| 1 | *ជី Ammonium Nitrate* | *១៥០.៥០* | *សិង្ហបុរី* |
| 2 | *ជី Diammunium phosphate* | *៥.៦១៦.០០* | *ថៃ* |
| 3 | *ជីគីមីសំរាប់ដំណាំដូងប្រេង (Fertilizer for Oil Palm Tree)* | *១.៦៧០.០០* | *ម៉ាឡេស៊ី* |
| 4 | *ជីNP (Multiple Nutrient Fertilizer)* | *២.៧៣៥.០០* | *ថៃ* |
| 5 | *ជី NPK (Multiple Nutrient Fertilizer)* | *១.៣៤៨.០០* | *ថៃ* |
| 6 | *ជីអ៊ុយរ៉េ (Urea )* | *៣.៤៨២.៥០* | *ចិន វៀតណាម* |
| 7 | *ជីគីមីដទៃទៀត (Other Fertilizers )* | *២៦.៣៣២.០០* | *ថៃ វៀតណាម និងអាមេរិក* |
| | សរុប | *៤៥.៣៣៥.០០* | |

*ប្រភព* : សៀវភៅស្ថិតិនាំចូលក្នុងឆ្នាំ ២០០២ នាយកដ្ឋានកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម

ជីគីមីដែលនាំចូលត្រូវបានប្រើប្រាស់ភាគច្រើនទៅលើដំណាំស្រូវ ដំណាំកសិឧស្សាហកម្មសំខាន់ៗ ដូចជា ថ្នាំជក់ សណ្តែកកៅស៊ូ ដូងប្រេង និងដំណាំបន្លែ ។ ប៉ុន្តែ រហូតមកទល់ពេលនេះ គឺពុំទាន់មានតួលេខពីបរិមាណជីគីមីដែលប្រើប្រាស់ទៅលើប្រភេទដំណាំទាំងនោះនៅឡើយទេ ។ ក្នុងចំណោមកសិករកម្ពុជាដែលជាអ្នកប្រើប្រាស់ផ្ទាល់នឹងជីគីមី គឺមានចំនួនតិចតួចណាស់ដែលមានចំណេះដឹងក្នុងការប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាព ដែលទទួលបានតាមរយៈការអប់រំផ្សព្វផ្សាយរបស់ភ្នាក់ងារកសិកម្ម។ មានន័យថា កសិករកម្ពុជាភាគច្រើនមានការយល់ដឹងតិចតួចពីការប្រើប្រាស់ជីគីមី ហើយគួបផ្សំនឹងការពុំមានការពន្យល់ជាភាសាជាតិលើស្លាកសញ្ញា បានបង្កឱ្យមានការខាតបង់ទាំងថវិកា និងពុំទទួលបានប្រសិទ្ធិភាពក្នុងរបរការងាររបស់ពួកគេ ។

## ២.២ ថ្នាំកសិកម្ម

កម្ពុជាពុំមែនជាប្រទេសផលិត ឬនាំចេញថ្នាំកសិកម្មទេ ។ ដូចនេះហើយ ទើបរាល់តំរូវការប្រើប្រាស់នៅក្នុងស្រុកត្រូវបាននាំចូលទាំងស្រុងពីក្រៅប្រទេស ។ យោងតាមស្ថិតិនាំចូលរបស់នាយកដ្ឋានកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម ថ្នាំកសិកម្មដែលនាំចូលមកកម្ពុជា ត្រូវបានធ្វើចំណាត់ថ្នាក់ជា ៤ ក្រុមធំៗ គឺថ្នាំសំលាប់សត្វល្អិត ថ្នាំសំលាប់ស្មៅ ថ្នាំសំលាប់ផ្សិត និងថ្នាំសំលាប់កណ្តុរ ហើយបរិមាណដែលនាំចូលសរុបនៅក្នុងឆ្នាំ ២០០២ ដែលមានការសុំច្បាប់ត្រឹមត្រូវ គឺមានប្រមាណជា ២០០ តោនតែប៉ុណ្ណោះ ដូចមានបង្ហាញនៅក្នុងតារាង ២-២ ខាងក្រោម ។ ដោយឡែក ក្រៅពីការនាំចូលដោយស្របច្បាប់ ការនាំចូលថ្នាំកសិកម្មដោយគេចពន្ធ គឺបានកើតមានមួយចំនួននៅតាមច្រកព្រំដែនតូចៗជាប់នឹងប្រទេសជិតខាង ។

តារាង ២-២: ថ្នាំកសិកម្មដែលបាននាំចូលមកកម្ពុជាសំរាប់វិស័យកសិកម្ម (ឆ្នាំ ២០០២)

| ល.រ | ប្រភេទ | បរិមាណ (តោន) | តំលៃ (US$) | ប្រភពនាំចូល |
|---|---|---|---|---|
| ១ | ថ្នាំសំលាប់សត្វល្អិត | ១៤៥.៤២ | ១២៧.៣៣៧.០០ | ប្រទេសថៃ វៀតណាម ចិន ម៉ាឡេស៊ី បារាំង សិង្ហបុរី និងកោះតៃវ៉ាន់ |
| ២ | ថ្នាំសំលាប់ស្មៅ | ១៦.១៤ | ៦៥.៧៣១.០០ | |
| ៣ | ថ្នាំសំលាប់ផ្សិត | ៧.០២ | ១០.២៦២.០០ | |
| ៤ | ថ្នាំសំលាប់កណ្តុរ | ២៩.៨៨ | ១៨.៥២៦.០០ | |
| | សរុប | ១៩៨.៤៦ | ២២៥.៨៥៦.០០ | |

*ប្រភព* : សៀវភៅស្ថិតិនាំចូលក្នុងឆ្នាំ ២០០២ នាយកដ្ឋានកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម

អនុលោមទៅតាមបទបញ្ញត្តិច្បាប់ ការនាំចូលថ្នាំកសិកម្មគឺតំរូវឱ្យមានការសុំលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាមុន និងបានតំរូវឱ្យមានបិទស្លាកសញ្ញាពន្យល់ពីការប្រើប្រាស់និងភាពគ្រោះថ្នាក់របស់វាទៅលើសុខភាព និងបរិស្ថាន ដោយមានសរសេរជាភាសាជាតិ ដូចមានលំអិតជាពតិមាននៅក្នុងជំពូក ៤ ខាងក្រោយ ។ ប៉ុន្តែ នៅលើទីផ្សារគឺមានថ្នាំកសិកម្មតិចតួចប៉ុណ្ណោះដែលមានស្លាកសញ្ញាផ្តល់ពតិមានជាភាសាជាតិ ហើយបញ្ជីថ្នាំកសិកម្មទាំងនោះលើទីផ្សារត្រូវបានរៀបចំដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានបង្ហាញថានៅឆ្នាំ ២០០៤ គឺមានចំនួន ៤១៥ មុខ ដូចមានបង្ហាញនៅក្នុងតារាង ២-៣ ខាងក្រោម ។

តារាង ២-៣: បញ្ជីថ្នាំកសិកម្មដែលមានវត្តមាននៅទីផ្សារកម្ពុជា (ឆ្នាំ២០០៤)

| លរ | ឈ្មោះពាណិជ្ជកម្ម | ឈ្មោះទូទៅនៃសារធាតុគីមី | ចំណុះកុង ១ ដប ឬ កញ្ចប់ | កំហាប់ (%) | ប្រទេស/ទីតាំង ផលិត | ភាសាលើ ស្លាកសញ្ញា | ក្រុមសារធាតុគីមី | ល័ក្ខខ័ណ្ឌ | ប្រភេទ ប្រើ | ចំណាត់ថ្នាក់ WHO | PIC |
|---|---|---|---|---|---|---|---|---|---|---|---|
| 1 | 558 | dichlorvos+fenvalerate | 2 ml | 2.5 | China | Chinese | pyrethroid | Per | I | II | |
| 2 | -MAGAZIN | mancozeb | 500 g | 80.0 | Thailand | Thai | dithiocarbamate | Per | F | U | |
| 3 | -Mi shell | zinc phosphide | 10 g | 80.0 | Thailand | Thai | inorganic rodenticide | Res | R | Ib | |
| 4 | 95% Carbaril power | carbaryl | 100 g | 95.0 | China | English | carbamate | Per | I | II | |
| 5 | Abamet | abamectin | 100, 4000ml | 1.8 | 8973042 | Thai | Biopesticide | Unc | I | III | |
| 6 | Actara 25 WG | thiamethoxam | 1 g | 25.0 | Vietnam | Vietnamese | neonicotinoid | Per | I | III | |
| 7 | Actellic 50 EC | pirimiphos-ethyl | 1000 ml | 50.0 | France | English | organophosphorus | Res | I | Ib | |
| 8 | Almix 20 WP | metsulfuron methyl+ chlorimuron ethyl | 100 ml | 20.0 | Vietnam | Vietnamese | sulfonylurea + chloroacetanilide | Unc | H | U | |
| 9 | ANCO 720 DD | 2, 4-D | 480 ml | 72.0 | An Giang | Vietnamese | phenoxyacetic acid | Per | H | II | |
| 10 | Andoril 250EC | cypermethrin | 1L | 25.0 | Vietnam | Vietnamese | pyrethroid | Per | I | II | |
| 11 | Ankoun.V | parathion methyl | 500 ml | 50.0 | Thailand | Thai | organophosphorus | Ban | I | Ia | * |
| 12 | Annogvin 45SC | hexaconazole | 480 ml | 4.5 | Vietnam | Vietnamese | | Per | F | U | |
| 13 | Antibac | streptomycin sulphate+ oxytetracycline hydrochloride | 1000 ml | | Thailand | Thai | antibiotic | Unc | B | III | |
| 14 | Antracol 70 WP | propineb | 100 g | 70.0 | Agritech.VN | Vietnamese | dithiocarbamate | Per | F | U | |
| 15 | Anvil 5 SC | hexaconazole | 1000 ml | 5.0 | Vietnam | Vietnamese | | Per | F | U | |
| 16 | Apadrin | monocrotophos | 480 ml | 60.0 | Vietnam | Vietnamese | organophosphorus | Ban | I | Ib | * |
| 17 | Appencarb super 50FL | carbendazim | 480 ml | 50.0 | Vietnam | Vietnamese | systemic fungicide | Per | F | U | |
| 18 | APPLAUD 10 WP | buprofezin | 100 g | 10.0 | 8244946 | Vietnamese | | Per | I | III | |
| 19 | Arrivo 25 EC | cypermethrin | 250 ml | 25.0 | Vietnam | Vietnamese | pyrethroid | Per | I | II | |
| 20 | Aswin | azamethiphos | 10 g | 0.75 | Thailand | Thai | organophosphorus | Unc | I | III | |
| 21 | Atabron 5EC | chlorfluazuron | 100, 500 ml | 5.0 | Sang Yo Kaisha | Vietnamese | benzoylurea | Unc | I | U | |
| 22 | ATHEN-M | mancozeb | 500 g | 16+2+62 | Thailand | Thai | dithiocarbamate | Per | F | U | |
| 23 | Atonik 1.8 EC | sodium ortho-nitrophenolate+ sodium para-nitrophenolerate +nigroguaiacplae | 100 ml | 1.8 | | Vietnamese | | Unc | PGR | III | |
| 24 | Atrazine 80 WP | atrazine | 5 L | 80.0 | Thailand | Thai | chloroacetamide | Per | H | U | |
| 25 | Avidon-V | parathion methyl | 100 g | 3.0 | Thailand | Thai | organophosphorus | Ban | I | Ia | * |
| 26 | AZINMAG | mancozeb | 100 g | 80.0 | Thailand | Thai | dithiocarbamate | Per | F | U | |
| 27 | AZODRIN | monocrotophos | 500 ml | 50.0 | Thailand | Thai | organophosphorus | Ban | I | Ib | * |
| 28 | AZODRIN 50 DD | monocrotophos | 100, 480 ml | 50.0 | VIPESCO | Vietnamese | organophosphorus | Ban | I | Ib | * |
| 29 | Aztron | bacillus thuringiensis | 10 g | 16.0 | Vietnam | Vietnamese | Biopesticide | Per | I | III | |
| 30 | B.L Tachlor 60 EC | butachlor | 100 ml | 60.0 | Vietnam | Vietnamese | chloroacetamide | Per | H | U | |

| លរ | ឈ្មោះពាណិជ្ជកម្ម | ឈ្មោះទូទៅនៃសារធាតុគីមី | ចំណុះក្នុង ១ ដប ឬ កញ្ចប់ | កំហាប់ (%) | ប្រទេស/ទីតាំងផលិត | ភាសាលើស្លាកសញ្ញា | ក្រុមសារធាតុគីមី | ល័ក្ខខ័ណ្ឌ | ប្រភេទប្រើ | ចំណាត់ថ្នាក់ WHO | PIC |
|---|---|---|---|---|---|---|---|---|---|---|---|
| 31 | Bai 58 | dimethoate | 100 ml | 40.0 | Vietnam | Vietnamese | organophosphorus | Per | I | II | |
| 32 | Bamate | methamidophos | 500 ml | 60.0 | Thailand | Thai | organophosphorus | Ban | I | Ib | * |
| 33 | Bambin | abamectin | 500 ml | 1.8 | 8973042 | Thai | Biopesticide | Unc | I | III | |
| 34 | Bascide 50 EC | fenobucarb | 480 ml | 50.0 | Vietnam | Vietnamese | carbamate | Per | I | II | |
| 35 | Basoca | dimethoate | 100, 500 ml | 40.0 | Thailand | Thai | organophosphorus | Per | I | II | |
| 36 | Bassa 50EC | fenobucarb | 480 ml | 50.0 | Vietnam | Vietnamese | carbamate | Per | I | II | |
| 37 | Bassa tigi 50 ND | fenobucarb | 100 ml | 50.0 | Vietnam | Vietnamese | carbamate | Per | I | II | |
| 38 | BASSAN 50 EC | fenobucarb | 480 ml | 50.0 | An Giang | Vietnamese | carbamate | Per | I | II | |
| 39 | Basudin 10 H | diazinon | 1000 g | 50.0 | Vietnam | Vietnamese | organophosphorus | Per | I | II | |
| 40 | Basudin 50ND | diazinon | 480 ml | 50.0 | Vietnam | Vietnamese | organophosphorus | Per | I | II | |
| 41 | Bavistin FL | carbendazim | 10 ml | 50.0 | Vietnam | Vietnamese | systemic fungicide | Per | F | U | |
| 42 | BB-tigi 5 H | dimethoate+fenobucarb | 1 kg | 3+2 | Vietnam | Vietnamese | OP+CA | Unc | I | II | |
| 43 | Bek kham | zinc phosphide | 6 g | 80.0 | Thailand | Thai | inorganic rodenticide | Res | R | Ib | |
| 44 | Benben 50 EC | carbendazim | 500 ml | 50.0 | Thailand | Thai | systemic fungicide | Per | F | U | |
| 45 | Bent 600 | methamidophos | 1000 ml | 60.0 | Thailand | Thai | organophosphorus | Ban | I | Ib | * |
| 46 | BI 58 | dimethoate | 100, 240 ml | 50.0 | Vietnam | Vietnamese | organophosphorus | Per | I | II | |
| 47 | BiAN 40EC | dimethoate | 100, 480, 1000 ml | 40.0 | An Giang | Vietnamese | organophosphorus | Per | I | II | |
| 48 | Bilux 752 | tetradifon | 1000 ml | 75.2 | | Thai | | Unc | AC | U | |
| 49 | Binhnavil 50SC | carbendazim | 1L | 50.0 | Vietnam | Vietnamese | systemic fungicide | Per | F | U | |
| 50 | Binhsin 70 WP | thiophanate methyl | 100 g | 70.0 | Vietnam | Vietnamese | Benzimidazole | Per | F | U | |
| 51 | Bini 58 40EC | dimethoate | 480 ml | 40.0 | Vietnam | Vietnamese | organophosphorus | Per | I | II | |
| 52 | Biobit 52BFC | bacillus thuringiensis | 100 g | 32.0 | Vietnam | Vietnamese | Biopesticide | Per | I | III | |
| 53 | Bio-D | 2, 4-D | 500 ml | 80.0 | Thailand | Thai | phenoxyacetic acid | Per | H | II | |
| 54 | BI-TONIC | | | | Viva chemicals Pesticide Co. | Thai | | | | | |
| 55 | Bonanza | cyproconazole | 100 ml | | | Vietnamese | | Unc | F | III | |
| 56 | Bos | mancozeb | 100, 500, 1000 g | 80.0 | Thailand | Thai | dithiocarbamate | Per | F | U | |
| 57 | Bosdin | dichlorvos | 100, 500, 1000 ml | 50.0 | Kemocraf | Thai | organophosphorus | Res | I | Ib | |
| 58 | Brodifa | brodifacoum | 100 ml | 0.05 | Vietnam | Vietnamese | coumarin derivative | Res | R | Ia | |
| 59 | Buthyl | buprofezin | 100 g | 10.0 | Sai Gon | Vietnamese | | Per | I | III | |
| 60 | Cadazim 500 FL | carbendazim | 100 ml | 50.0 | Vietnam | Vietnamese | systemic fungicide | Per | F | U | |
| 61 | Calidan 262.5 | carbendazim | 100 ml | 50.0 | Vietnam | Vietnamese | systemic fungicide | Per | F | U | |
| 62 | Cantop-M 72 WP | thiophanate methyl | 100 g | 72.0 | Vietnam | Vietnamese | Benzimidazole | Per | F | U | |
| 63 | Cantosin 720 DD | 2, 4-D | 480 ml | 72.0 | Vietnam | Vietnamese | phenoxyacetic acid | Per | H | II | |
| 64 | Cantox -D50WP | iprodione | 500 g | 50.0 | Vietnam | Vietnamese | Dicarboximide | Per | F | U | |

| លរ | ឈ្មោះពាណិជ្ជកម្ម | ឈ្មោះទូទៅនៃសារធាតុគីមី | ចំណុះក្នុង ១ ដប ឬ កញ្ចប់ | កំហាប់ (%) | ប្រទេស/ទីតាំងផលិត | ភាសាលើស្លាកសញ្ញា | ក្រុមសារធាតុគីមី | ល័ក្ខខ័ណ្ឌ | ប្រភេទប្រើ | ចំណាត់ថ្នាក់ WHO | PIC |
|---|---|---|---|---|---|---|---|---|---|---|---|
| 65 | Caradan 5H | carbofuran | 1000 g | 5.0 | Vietnam | Vietnamese | carbamate | Res | I | Ib | |
| 66 | Carbaryl 85BTN | carbaryl | 100 g | 85.0 | Vietnam | Vietnamese | carbamate | Per | I | II | |
| 67 | Carben 50 SC | carbendazim | 100 ml | 50.0 | China | Khmer | systemic fungicide | Per | F | U | |
| 68 | Carbenda 50SC | carbendazim | 1000 ml | 50.0 | Vietnam | Vietnamese | systemic fungicide | Per | F | U | |
| 69 | Carbenvil 50SC | carbendazim | 100, 480 ml | 50.0 | Vietnam | Vietnamese | systemic fungicide | Per | F | U | |
| 70 | Carbenzim 500 FL | carbendazim | 250 ml | 50.0 | Sai Gon | Vietnamese | systemic fungicide | Per | F | U | |
| 71 | Carmethrin 25 EC | cypermethrin | 100 ml | 25.0 | Vietnam | Vietnamese | pyrethroid | Per | I | II | |
| 72 | Carphosate 41DD | glyphosate | 480 ml | 41.0 | Vietnam | Vietnamese | glycin dervative | Per | H | U | |
| 73 | Carphosate 480 SC | glyphosate | 480 ml | 48.0 | Vietnam | Vietnamese | glycin dervative | Per | H | U | |
| 74 | Cascade 5 EC | flufenoxuron | 100 ml | 5.0 | Thailand | Thai | | Per | I | U | |
| 75 | Cavil 50 SC | carbendazim | 240 ml | 50.0 | Vietnam | Vietnamese | systemic fungicide | Per | F | U | |
| 76 | Cazim | carbendazim | 500 ml | 50.0 | Thailand | Thai | systemic fungicide | Per | F | U | |
| 77 | Cazinon 10H | diazinon | 1000 g | 10.0 | Vietnam | Vietnamese | organophosphorus | Per | I | II | |
| 78 | Chix | cypermethrin | 500 ml | 25.0 | Thailand | Thai | pyrethroid | Per | I | II | |
| 79 | CO 2,4-D 80BHN | 2, 4-D | 100 g | 72.0 | Vietnam | Vietnamese | phenoxyacetic acid | Per | H | II | |
| 80 | COC 85 WP | copper oxychloride | 25 g | 85.0 | 8729995 | Vietnamese | copper compound | Per | F | III | |
| 81 | Cocman 69 WP | oxyclorua+mancozeb | 25 g | | | Vietnamese | | Unc | F | U | |
| 82 | Comite 73 EC | propargite | 100 ml | 73.0 | Vietnam | Vietnamese | | Per | AC | III | |
| 83 | Confidor 100 SL | imidacloprid | 20 ml | 10.0 | Vietnam | Vietnamese | neonicotinoid | Per | I | II | |
| 84 | Cupravit | copper oxychloride | 1000 g | 85.0 | Thailand | Thai | copper compound | Per | F | U | |
| 85 | Curzate M-8 72WP | cymoxanil+mancozeb | 500 g | 8+64 | Vietnam | Vietnamese | dithiocarbamate | Unc | F | U+III | |
| 86 | Cyanamid | mevinphos | 1000 ml | 24.0 | Thailand | Thai | organophosphorus | Ban | I | Ia | |
| 87 | Cyclodan 35 EC | endosulfan | 100 ml | 35.0 | Vietnam | Vietnamese | organochlorine | Ban | I | II | |
| 88 | Cykker 10 | cypermethrin | 100 ml | 10.0 | Thailand | Thai | pyrethroid | Per | I | II | |
| 89 | Cyper 25 EC | cypermethrin | 480 ml | 25.0 | Vietnam | Vietnamese | pyrethroid | Per | I | II | |
| 90 | CYPER ALPHA 5 ND | alpha cypermethrin | 100 ml | 5.0 | Vietnam | Vietnamese | pyrethroid | Per | I | II | |
| 91 | Cyperan 10 EC | cypermethrin | 480 ml | 10.0 | Vietnam | Vietnamese | pyrethroid | Per | I | II | |
| 92 | Cyperan 25 EC | cypermethrin | 480 ml | 25.0 | Vietnam | Vietnamese | pyrethroid | Per | I | II | |
| 93 | Cyperin 10 EC | cypermethrin | 100, 480 ml | 10.0 | 8572765 | Vietnamese | pyrethroid | Per | I | II | |
| 94 | Cypermethrin 10 EC | cypermethrin | 500 ml | 10.0 | Thailand | Thai | pyrethroid | Per | I | II | |
| 95 | Cyperoid 10 EC | cypermethrin | 1000 ml | 10.0 | India | English | pyrethroid | Per | I | II | |
| 96 | Cyperoid 25 EC | cypermethrin | 1000 ml | 25.0 | Switzerland | English | pyrethroid | Per | I | II | |
| 97 | Cyrin 25 EC | cypermethrin | 100 ml | 25.0 | India | Vietnamese | pyrethroid | Per | I | II | |
| 98 | Cyrus 25 | cypermethrin | 100 ml | 25.0 | Vietnam | Vietnamese | pyrethroid | Per | I | II | |
| 99 | Daconil 75 WP | chlorothalonil | 100 g | 75.0 | SDS Biotech | Vietnamese | chloronitrile | Unc | F | U | |
| 100 | DA-FIGHT | glyphosate | 5 L | 48.0 | Thailand | Thai | glycin dervative | Per | H | U | |

| លរ | ឈ្មោះពាណិជ្ជកម្ម | ឈ្មោះទូទៅនៃសារធាតុគីមី | ចំណុះក្នុង ១ ដប ឬ កញ្ចប់ | កំហាប់ (%) | ប្រទេស/ទីតាំង ផលិត | ភាសាលើ ស្លាកសញ្ញា | ក្រុមសារធាតុគីមី | លក្ខខ័ណ្ឌ | ប្រភេទ ប្រើ | ចំណាត់ ថ្នាក់ WHO | PIC |
|---|---|---|---|---|---|---|---|---|---|---|---|
| 101 | Dazin 50 WP | carbendazim | 100 g | 50.0 | Vietnam | Thai | systemic fungicide | Per | F | U | |
| 102 | DDT | DDT | | | | | organochlorine | Ban | I | II | * |
| 103 | DDVP 50 ND | dichlorvos | 480 ml | 50.0 | TIGIPESCO | Vietnamese | organophosphorus | Res | I | Ib | |
| 104 | DDVP 80 EC | dichlorvos | 500 ml | 50.0 | Vietnam | Khmer | organophosphorus | Res | I | Ib | |
| 105 | DDVQuin 25EC | quinalphos | 1L | 25.0 | (0650)751485 | Vietnamese | | Per | I | II | |
| 106 | Decis 2.5 EC | delthamethrin | 100 ml | 2.5 | 8230751 | Vietnamese | pyrethroid | Per | I | II | |
| 107 | Delfin WG | bacillus thuringiensis | 10 g | 32.0 | Vietnam | Vietnamese | Biopesticide | Per | I | III | |
| 108 | Deltacide | delthamethrin | 1000 ml | 2.5 | Vietnam | Vietnamese | pyrethroid | Per | I | II | |
| 109 | Delthamethrin | delthamethrin | 1000 ml | 2.5 | Vietnam | Vietnamese | pyrethroid | Per | I | II | |
| 110 | Derosal 50 SC | carbendazim | 100 ml | 50.0 | Vietnam | Vietnamese | systemic fungicide | Per | F | U | |
| 111 | Diazinon 60EC | diazinon | 1000 ml | 60.0 | Singapore | English | organophosphorus | Per | I | II | |
| 112 | Dibadan | | 100 g | 95.0 | Vietnam | Vietnamese | | | | | |
| 113 | Dibathote 40 EC | dimethoate | 1000 ml | 40.0 | Vietnam | Vietnamese | organophosphorus | Per | I | II | |
| 114 | Dichlor | dichlorvos | 500 ml | 50.0 | Thailand | Thai | organophosphorus | Res | I | Ib | |
| 115 | Diji-one 40EC | isoprothiolane | 480 ml | 40.0 | Vietnam | Vietnamese | Phosphorothiolate | Per | F | III | |
| 116 | Dimethoate | dimethoate+fenobucarb | 1 kg | 3+2 | 8243077 | Vietnamese | organophosphorus | Unc | I | II | |
| 117 | Dimethoate 40 EC | dimethoate | 1000 ml | 40.0 | | English | organophosphorus | Per | I | II | |
| 118 | Dinear | dichlorvos | 100 ml | 50.0 | Thailand | Thai | organophosphorus | Res | I | Ib | |
| 119 | Dineb-D | mancozeb | 500 g | 80.0 | Thailand | Thai | dithiocarbamate | Per | F | U | |
| 120 | Dipel 6.4 DF | bacillus thuringiensis | 10 g | 16.0 | Vietnam | Vietnamese | Biopesticide | Per | I | III | |
| 121 | Dola 02X | thiourea | 1 kg | 97.0 | Vietnam | Vietnamese | plant growth regulator | Unc | PGR | | |
| 122 | Door | parathion methyl | 100 ml | 50.0 | Thailand | Thai | organophosphorus | Ban | I | Ia | * |
| 123 | DP 50 | dichlorvos | 100 ml | 50.0 | Thailand | Thai | organophosphorus | Res | I | Ib | |
| 124 | Dupont | diazinon | 100 ml | 50.0 | Thailand | Thai | organophosphorus | Per | I | II | |
| 125 | Elxydol-D | parathion methyl | 500 ml | 50.0 | Thailand | Thai | organophosphorus | Ban | I | Ia | * |
| 126 | Endel 35 ND | endosulfan | 500 ml | 35.0 | Thailand | Thai | organochlorine | Ban | I | II | |
| 127 | Endosol 35 EC | endosulfan | 100 ml | 35.0 | Vietnam | Vietnamese | organochlorine | Ban | I | II | |
| 128 | Endosulfen 35 EC | endosulfan | 1000 ml | 35.0 | | English | organochlorine | Ban | I | II | |
| 129 | Exonak | 2, 4-D | 5 L | 80.0 | Thailand | Thai | phenoxyacetic acid | Per | H | II | |
| 130 | Extra-tonic | | 500 ml | | Thailand | Thai | | | PGR | | |
| 131 | Famoso 240 | mevinphos | 500 ml | 24.0 | Thailand | Thai | organophosphorus | Ban | I | Ia | |
| 132 | FAMTOY 50 | dimethoate | 100 ml | 50.0 | ZHONGLI | Vietnamese | organophosphorus | Per | I | II | |
| 133 | FASTOCID 5 EC | alpha cypermethrin | 100 ml | 5.0 | TIGIPESCO | Vietnamese | pyrethroid | Per | I | II | |
| 134 | FASTOX 5 EC | alpha cypermethrin | 100 ml | 5.0 | 8760036 | Vietnamese | pyrethroid | Per | I | II | |
| 135 | Febkill 20EC | fenvalerate+dimethoate | 480 ml | 20.0 | Vietnam | Vietnamese | pyrethroid+op | Unc | I | II+III | |
| 136 | Fenbis 25 EC | fenvalerate+dimethoate | 100, 480 ml | 3.5+21.5 | Sai Gon | Vietnamese | pyrethroid+op | Unc | I | II | |

| លរ | ឈ្មោះពាណិជ្ជកម្ម | ឈ្មោះទូទៅនៃសារធាតុគីមី | ចំណុះក្នុង ១ ដប ឬ កញ្ចប់ | កំហាប់ (%) | ប្រទេស/ទីតាំង ផលិត | ភាសាលើ ស្លាកសញ្ញា | ក្រុមសារធាតុគីមី | ល័ក្ខខ័ណ្ឌ | ប្រភេទ ប្រើ | ចំណាត់ ថ្នាក់ WHO | PIC |
|---|---|---|---|---|---|---|---|---|---|---|---|
| 137 | Fencozeb | mancozeb | 100 g | 80.0 | Thailand | Thai | dithiocarbamate | Per | F | U | |
| 138 | Fenkill 20 EC | fenvalerate | 100, 480 ml | 20.0 | 8760036 | Vietnamese | pyrethroid | Per | I | II | |
| 139 | Filitox 50EC | methamidophos | 480 ml | 50.0 | 23 300489 | Khmer | organophosphorus | Ban | I | Ib | * |
| 140 | Filitox 60DD | methamidophos | 480 ml | 60.0 | Vietnam | Vietnamese | organophosphorus | Ban | I | Ib | * |
| 141 | Filitox 70 SC | methamidophos | 480 ml | 50.0 | Vietnam | Vietnamese | organophosphorus | Ban | I | Ib | * |
| 142 | First 20 EC | fenvalerate | 480 ml | 20.0 | Vietnam | Vietnamese | pyrethroid | Per | I | II | |
| 143 | Fitor | mevinphos | 250 ml | 24.0 | Thailand | Thai | organophosphorus | Ban | I | Ia | |
| 144 | Fokeba 20% | zinc phosphide | 50 g | 20.0 | VIPESCO | Vietnamese | inorganic rodenticide | Res | R | Ib | |
| 145 | Foldtool | omethoate | 100 ml | 40.0 | China | Khmer | organophosphorus | Res | I | Ib | |
| 146 | Folez-folez | parathion methyl | 100 ml | 50.0 | BAYER | Khmer | organophosphorus | Ban | I | Ia | * |
| 147 | Folidol | parathion methyl | 1000 ml | 50.0 | BAYER | Thai | organophosphorus | Ban | I | Ia | * |
| 148 | Folidol-E605 M50 | parathion methyl | 100, 250, 500, 1000, 2000ml | 50.0 | BAYER | Thai | organophosphorus | Ban | I | Ia | * |
| 149 | Folitec 025EC | beta-cyfluthrin | 500 ml | 2.5 | 2331440-50 | Thai | pyrethroid | Per | I | II | |
| 150 | Folpan | folpet | 20 g | | | Vietnamese | | Per | F | U | |
| 151 | FORWABIT 16.00 IU | bacillus thuringiensis | 100 g | 16.0 | FORWARD INT. LTD | English | Biopesticide | Per | I | III | |
| 152 | Fotor | mevinphos | 100 ml | 24.0 | Thailand | Thai | organophosphorus | Ban | I | Ia | |
នៅក្នុងផ្នែកនេះមានការរៀបរាប់ត្រួសៗជាពិសេសលើផលិតផលលោហធាតុ និងសមាសធាតុរបស់វា ដែលទាក់ទងទៅនឹងសំភារៈសំណង់ ហើយនិងផលិតផលសំរេចដទៃទៀត។ កម្ពុជា មិនមែនជាប្រទេសផលិតលោហធាតុ និងសមាសធាតុរបស់វាទេ។ សំរាប់ការអភិវឌ្ឍន៍ប្រទេស និងដើម្បីឆ្លើយតបការធ្វើឱ្យប្រសើរឡើងនូវសំណង់សាធារណៈ សំណង់ឯកជន គ្រឿងចក្រឧស្សាហកម្ម និងហេដ្ឋារចនាសម្ព័ន្ធដទៃទៀត កម្ពុជាចាំបាច់បាននាំចូលនូវផលិតផលលោហធាតុ និងសមាសធាតុរបស់វា ដូចជា ដែក ដែកថែប អាលុយមីញ៉ូម ស័ង្កសី សំណ ស្ពាន់ ព្រមទាំងផលិតផលសំរេចដទៃទៀត។ ទិន្នន័យ និងពត៌មាន ដែលផ្តល់ដោយនាយកដ្ឋានកាំកុងត្រូលទាក់ទងនឹងផលិតផលលោហធាតុនិងសមាសធាតុរបស់វា មានបង្ហាញនៅក្នុងតារាង ២-១៤ ខាងក្រោម។

តារាង ២-១៤: ផលតិផលលោហធាតុ និងសមាសធាតុរបស់វាដែលនាំចូល (ឆ្នាំ២០០២)

| ល.រ | សារធាតុគីមី | បរិមាណ (តោន) | តំលៃ (US$) | ប្រភពនាំចូល |
|---|---|---|---|---|
| ១ | ដែក និងដែកថែប (គ្រឿងសំណង់ និងផលិតផល) | ៨៥.៥៧៤.០០ | ១៧.០៣៨.៦៨២.០០ | ចិន វៀតណាម សឹង្ហបូរី អាមេរិក ថៃ តៃវ៉ាន់ ឥណ្ឌូនេស៊ី ជប៉ុន ហុងកុង អ៊ីតាលី ឥណ្ឌា និង ម៉ាឡេស៊ី |
| ២ | អាលុយមីញ៉ូម និងផលិតផល របស់វា | ៦.៣១៩.៨២ | ១១.១៨៨.៤២៨.០០ | ចិន វៀតណាម សឹង្ហបូរី អាមេរិក ថៃ តៃវ៉ាន់ ឥណ្ឌូនេស៊ី ហុងកុង អារ៉ាប់ ម៉ាឡេស៊ី អាល្លឺម៉ង់ នីការ៉ាហ្គ័រ បារាំង អូស្ត្រាលី អ៊ីតាលី ជប៉ុន ក្រិច និងស៊ុយអែត |
| ៣ | ស័ង្កសី និងផលិតផលរបស់វា | ១.៤៤០.៧២ | ១.៣០៨.២២៣.០០ | ចិន វៀតណាម សឹង្ហបូរី ថៃ តៃវ៉ាន់ ជប៉ុន និងហុងកុង |
| ៤ | សំណ | ២.៥៦ | ៩.០៥៥.០០ | ចិន វៀតណាម សឹង្ហបូរី ថៃ តៃវ៉ាន់ ជប៉ុន និងហុងកុង |
| ៥ | ស្ពាន់ | ៦៤.៦៥ | ២១៩.០៨៥.០០ | ចិន វៀតណាម សឹង្ហបូរី អាមេរិក ថៃ តៃវ៉ាន់ ឥណ្ឌូនេស៊ី ជប៉ុន ហុងកុង ឥណ្ឌា ម៉ាឡេស៊ី អាល្លឺម៉ង់ បែលហ្សិក កូរ៉េ អង់គ្លេស បារាំង អ៊ីតាលី អូស្ត្រាលី និងដាណឺម៉ាក |
| | **សរុប** | **៩៣.៤០១.៧៥** | **២៩.៧៦៣.៤៧៣.០០** | |

*ប្រភព*: ស្ថិតិនាំចូលទំនិញ ឆ្នាំ២០០២ នាយកដ្ឋានកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម

## ២.៦ ឥន្ធនៈរ៉ែ និងផលិតផលប្រេងឥន្ធនៈ

យោងតាមការរុករក និងស្រាវជ្រាវប្រេងកាតក្នុងឆ្នាំ ១៩៩២ បានបង្ហាញថា កម្ពុជាមានសក្តានុពលខ្ពស់លើឧស្ម័នធម្មជាតិ និងមានសក្តានុពលមធ្យមចំពោះប្រេងឆៅ។ ការសាកល្បងខួងអណ្តូងមួយបានបង្ហាញថា មានទិន្នផលឧស្ម័នប្រមាណ ១៣៣ ពាន់

ម៉ែត្រគូប និងមានប្រេងឆៅប្រមាណ ១៨០ បារ៉ែលក្នុងមួយថ្ងៃ (ទំព័រ ១៨០ របាយការណ៍បរិស្ថានជាតិលើកទី ១ ឆ្នាំ១៩៩៤)។ តាមការប៉ាន់ប្រមាណដំបូងបានបង្ហាញថា សក្តានុពលឥន្ធនៈរ៉ែនៅឯនាយសមុទ្រមានឧស្ម័នប្រមាណ ២៨.៣០០ ទៅ ១៤១.៥០០ លាន ម៉ែត្រគូប និងមានប្រេងឆៅប្រមាណពី ៣០ ទៅ ១៨០លានបារ៉ែល។ ប៉ុន្តែ មកទល់បច្ចុប្បន្ននេះ កម្ពុជាពុំទាន់បានធ្វើវិនិយោគក្នុងការទាញយកប្រេងឆៅនៅឡើយទេ។ មុនឆ្នាំ ១៩៧០ កម្ពុជាបានសាងសង់រោងចក្រនិងដំណើរការចំរាញ់ប្រេងឆៅ ប៉ុន្តែត្រូវបានបំផ្លាញដោយរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ហើយដែលពុំទាន់មានការស្តារជួសជុលនៅឡើយទេ ។ ហេតុដូចនេះហើយ ផលិតផលប្រេងឥន្ធនៈទាំងអស់ដែលជាតំរូវការប្រើប្រាស់ក្នុងស្រុក ត្រូវបាននាំចូលទាំងស្រុងពីបរទេស។ ផលិតផលប្រេងដែលនាំចូលត្រូវបានប្រើប្រាស់សំរាប់ផ្គត់ផ្គង់ការផលិតថាមពលអគ្គិសនី សំរាប់យានយន្ត សំរាប់បំរើវិស័យឧស្សាហកម្ម កសិកម្ម និងវិស័យផ្សេងៗ។ យោងតាមទិន្នន័យនិងពត៌មានស្តីពីការនាំចូលផលិតផលប្រេងឥន្ធនៈ ដែលផ្តល់ដោយនាយកដ្ឋានកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម បានបង្ហាញថា កម្ពុជាបាននាំចូលប្រេងពីបណ្តាប្រទេសអាស៊ាន ហើយមួយចំនួនទៀតបាននាំចូលពីសហគមអ៊ឺរ៉ុប ចិន ហុងកុង តៃវ៉ាន់ និងជប៉ុន ហើយដែលពត៌មានលំអិតមាននៅក្នុងតារាង ២-១៥ ខាងក្រោម។

តារាង ២-១៥: ផលិតផលថាមពលចំហេះ និងប្រេងឥន្ធនៈដែលនាំចូល (ឆ្នាំ២០០២)

| ល.រ | សារធាតុគីមី | បរិមាណ (តោន) | តំលៃ (US$) | ប្រភពនាំចូល |
|---|---|---|---|---|
| ១ | ធ្យូងថ្ម *(Coal)* | ៣៩.៥០ | ១.៣៧៤.០០ | សិង្ហបុរី ចិន ហុងកុង តៃវ៉ាន់ ម៉ាឡេស៊ី ជប៉ុន អាល្លឺម៉ង់ វៀតណាម និងបារាំង |
| ២ | ខ្លាញ់គោ *(Grease)* | ១៩៩.៦៨ | ១៧៩.៩១៣.០០ | |
| ៣ | ប្រេងម៉ាស៊ូត *(Diesel)* | ៣៦៧.២៩៩.៩៦ | ៨៤.៨៣៩.៩៤៥.០០ | |
| ៤ | ប្រេងខ្មៅ *(Fuel Oil)* | ៩៥.៨២៦.៩៦ | ១៣.១៧៣.០២៤.០០ | |
| ៥ | ប្រេងកាត *(Kerosene)* | ៤១.៤៤៧.៩០ | ៨.៥៨៦.៣១៥.០០ | |
| ៦ | ប្រេងកាតសំរាប់យន្តហោះ *(Kerosene for Airplane)* | ២២.៦៦១.៦៧ | ៣.៩៦០.៩៣៦,០០ | |
| ៧ | ប្រេងរំអិល *(Lubricant Oil)* | ៦០.៥២១.២៨ | ៧.៣១៦.៧២៥.០០ | |
| ៨ | ឧស្ម័នធម្មជាតិ *(Natural Gas)* | ២៧.០១៦.៦៩ | ៨.៣៨៧.៥៥០.០០ | |
| ៩ | ប្រេងសាំង *(Gasoline)* | ១០០.៤៤៨.៧១ | ៣៨.០១៧.២៨៦.០០ | |
| ១០ | វត្ថុធាតុដើមសំរាប់ផលិតប្រេងរំអិល *(Raw Material for Producing Lubricant)* | ២.១៨៣.៧៨ | ៦៤៨.៣៦៦.០០ | |
| | សរុប | ៧១៧.៦០៦,០៩ | ១៦៩.១០៧.០៤៤,០០ | |

*ប្រភព:* ស្ថិតិនាំចូលទំនិញ ឆ្នាំ២០០២ នាយកដ្ឋានកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម

## ២.៧ ផលិតផលគីមីសំរាប់ប្រើតាមលំនៅឋាន

ផលិតផលគីមីសំរាប់ប្រើតាមលំនៅឋាន គឺសំដៅទៅលើទំនិញឬផលិតផលសំរេចសំរាប់ការសំអាត ការបោកគក់ ការថែរក្សាសុខភាព ដែលប្រើប្រាស់នៅតាមលំនៅឋាន អាគារសាធារណៈ រោងចក្រ អាគារពាណិជ្ជកម្ម។ល។ នៅកម្ពុជា ផលិតផលគីមីសំរាប់ប្រើតាមលំនៅឋាន គឺមានតិចតួចណាស់ដែលត្រូវបានផលិតនៅក្នុងស្រុក ហើយភាគច្រើនត្រូវបាននាំចូលពីបរទេស។

យោងតាមទិន្នន័យនាំចូលរបស់នាយកដ្ឋានកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម បានបង្ហាញថាមានផលិតផលគីមីសំខាន់ ២ ប្រភេទ ដែលបាននាំចូលសំរាប់ការប្រើប្រាស់តាមលំនៅឋាន និងអាគារសាធារណៈ គឺផលិតផលសាប៊ូ (ម្សៅ ទឹក និងដុំ) និងផលិតផលថ្នាំសំលាប់សត្វល្អិតចង្រៃលំនៅស្ថាន ដូចជា ធូបមូស ថ្នាំបាញ់មូស ថ្នាំកន្លាតឬកណ្តៀរ។ល។ ហើយបរិមាណនៃការនាំចូលក្នុងឆ្នាំ ២០០២ គឺមានសង្ខេបបង្ហាញនៅក្នុងតារាង ២-១៦ ខាងក្រោម។

តារាង ២-១៦: ផលិតផលគីមីសំរាប់ប្រើតាមលំនៅឋានដែលនាំចូល (ឆ្នាំ២០០២)

| ល.រ | សារធាតុគីមី | បរិមាណ (តោន) | តំលៃ (US$) | ប្រភពនាំចូល |
|---|---|---|---|---|
| ១ | សារធាតុសំរាប់ការលាងសំអាត (សាប៊ូ ឬថ្នាំលាង) | ៥.៤២៦.៥៩ | ១.០៧៦.១០៩.០០ | វៀតណាម ថៃ ហុងកុង ម៉ាឡេស៊ី សឹង្ហបូរី បារាំង ចិន និងតៃវ៉ាន់ |
| ២ | សារធាតុគីមីសំរាប់ថែទាំសុខភាពតាមផ្ទះ | ៣.៦៤២.៧១ | ៥៤៦.០៨៣.០០ | |
| | សរុប | ៩.០៦៩.៣០ | ១.៦២២.១៩២.០០ | |

*ប្រភព:* ស្ថិតិនាំចូលទំនិញ ឆ្នាំ២០០២ នាយកដ្ឋានកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម

## ២.៨ សារធាតុគីមីសំរាប់មន្ទីរពិសោធន៍

បច្ចុប្បន្ន នៅកម្ពុជាមានមន្ទីរពិសោធន៍របស់រដ្ឋចំនួន ៦ រួមមាន : មន្ទីរពិសោធន៍ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរពិសោធន៍ក្រសួងពាណិជ្ជកម្ម មន្ទីរពិសោធន៍ក្រសួងសុខាភិបាល មន្ទីរពិសោធន៍ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មន្ទីរពិសោធន៍ក្រសួងបរិស្ថាន និងមន្ទីរពិសោធន៍ក្រសួងធនធានទឹក និងឧតុនិយម។ មន្ទីរពិសោធន៍ទាំងនោះ មានតួនាទីនិងការទទួលខុសត្រូវដោយឡែកពីគ្នា ដែលនឹងមានរៀបរាប់លំអិតនៅជំពូកទី ៩ នៃកំរងឯកសារនេះ។ ក្រៅពីមន្ទីរពិសោធន៍របស់រដ្ឋ នៅមានមន្ទីរពិសោធន៍ឯកជនមួយចំនួនទៀត ដែលភាគច្រើនពាក់ព័ន្ធទៅនឹងការវិភាគផ្នែកវេជ្ជសាស្ត្រនិងមានទំហំតូច ហើយដែលនឹងមិនបញ្ចូលពតិមាននៅក្នុងឯកសារនេះទេ ។

ចំពោះសារធាតុគីមីដែលជាតំរូវការសំរាប់ដំណើរការនៃមន្ទីរពិសោធន៍រដ្ឋទាំង ៦ នៅក្នុងការវិភាគ គឺត្រូវបាននាំចូលទាំងស្រុងពីបរទេស។ ប្រភេទសារធាតុគីមីដែលប្រើប្រាស់នៅក្នុងមន្ទីរពិសោធន៍ទាំង ៦ មានបង្ហាញនៅក្នុងតារាង ២-១៧ ខាងក្រោម ។

តារាង ២-១៧: សារធាតុគីមីដែលមានប្រើនៅក្នុងមន្ទីរពិសោធន៍

| លរ | សារធាតុគីមី (Reagent) | មន្ទីរពិសោធន៍នៃក្រសួង | | | | | |
|---|---|---|---|---|---|---|---|
| | | កសិកម្ម | ពាណិជ្ជកម្ម | សុខាភិបាល | ឧស្សាហកម្ម | បរិស្ថាន | ធនធានទឹក |
| 1. | *1,10 Phénanthroline Hydrate* | x | | | | | |
| 2. | *1-butanol* | | x | | | | |
| 3. | *1-propanol* | | x | | | | |
| 4. | *2-propanol* | | x | | | | |
| 5. | *Acacia* | | | | | x | |

| លរ | សារធាតុគីមី (Reagent) | មន្ទីរពិសោធន៍នៃក្រសួង | | | | | |
|---|---|---|---|---|---|---|---|
| | | កសិកម្ម | ពាណិជ្ជកម្ម | សុខាភិបាល | ឧស្សាហកម្ម | បរិស្ថាន | ធនធានទឹក |
| 6. | Acetaldehyde | | | x | | x | |
| 7. | Acetic Acid | x | x | x | x | x | x |
| 8. | Acetic Anhydride | x | | x | | | |
| 9. | Acetone | x | x | x | x | x | |
| 10. | Acetonitrile | x | x | x | | | |
| 11. | Acid Acetylsalicylic | | | x | | | |
| 12. | Acid Benzoic | | x | x | x | | |
| 13. | Acid Boric | x | x | x | x | x | |
| 14. | Acid Nitric | x | x | x | x | | |
| 15. | Acid Phosphoric, 85% Analar | x | x | x | x | | |
| 16. | Acid Trichloracetique | | | x | | | |
| 17. | Alkaline Pepetone Water | | x | | | | |
| 18. | Allylthiourea | | | | | x | |
| 19. | Alpha Amylase Liquicolor | | | x | | | |
| 20. | Aluminum Potassium Sulphate, 12-Hydrate | | | x | x | x | |
| 21. | Aluminum sulfate octadecahydrate | | x | | | | |
| 22. | Aluminon | | | x | x | x | |
| 23. | Aluminum Ammonium (Sulfate Al ) | | | x | | | x |
| 24. | Aluminum Hydroxide Al $(OH)_3$ | | | x | | | x |
| 25. | Amberlite IR-120(Na), Particle Size 0.30-1.18mm | | | | | x | |
| 26. | Aminoantipyrin ; 4-[4-Aminophenazone] | | | | x | x | |
| 27. | Ammonia Solution | x | | | x | x | |
| 28. | Ammonium Acetate | x | x | | x | x | x |
| 29. | Ammonium Chloride | x | x | | x | x | x |
| 30. | Ammonium Citrate (Di-Ammonium Hydrogencocitrate) | | | x | | | |
| 31. | Ammonium Dihydrogenphosphate | x | | | x | x | |
| 32. | Ammonium Hydroxide | | | | | | x |
| 33. | Ammonium Iron Sulphate | x | x | | x | x | x |
| 34. | Ammonium Iron(III) Sulfate 12-Hydrate | | x | | | x | |
| 35. | Ammonium Metavanadate | x | | x | | x | |
| 36. | Ammonium Molydate | x | x | | x | x | x |
| 37. | Ammonium Nitrate | | | | | x | |
| 38. | Ammonium Peroxide Sulphate | | | | | x | |
| 39. | Ammonium Sulphamate, [Ammonium Amidosulfate] | | | | | x | |
| 40. | Ammonium Sulphate | x | | | x | | |
| 41. | Amoxicillin 25ug(AMX) | | | x | | | |
| 42. | Amoxilline-Clavulenic Acid (Amc) | | | x | | | |
| 43. | Ampicilline (AM) 10ug | | | x | | | |
| 44. | Anti-Bumping Granules | | | | | x | |
| 45. | Antimony Potassium Oxide, (+) Tartrate | | | | | x | |
| 46. | Antimony(III) Potassium Oxide, (+) Tartrate 0.5 Hydrate | | | | | x | |
| 47. | Arsenic Standard Solution | | | | x | | |
| 48. | Ascarite | | | | | | x |
| 49. | Ascorbic Acid | | | x | x | x | x |
| 50. | Aslo-Latex | | | x | | | |
| 51. | Bacitracin | | | x | | | |
| 52. | Barbituric Acid | | | | | x | |
| 53. | Barium Chloride | | x | | x | x | |
| 54. | Barium Chromate | | | | x | | |
| 55. | Barium hydroxide | | x | | x | | |
| 56. | barium sulfate | | x | | x | | |
| 57. | Bilirubine D+T | | | x | | | |

| លរ | សារធាតុគីមី (Reagent) | មន្ទីរពិសោធន៍នៃក្រសួង | | | | | |
|---|---|---|---|---|---|---|---|
| | | កសិកម្ម | ពាណិជ្ជកម្ម | សុខាភិបាល | ឧស្សាហកម្ម | បរិស្ថាន | ធនធានទឹក |
| 58. | *Billiary Salts* | | | x | | | |
| 59. | *Bispyrazolon* | | | | | x | |
| 60. | *Bouillon Lactose Bile Green* | | | | | | x |
| 61. | *Bouillon Lactose Poupre Bromocresol* | | | | | | x |
| 62. | *BPA (Baird Parker Agar)* | | x | | | | |
| 63. | *Brain Heart Agar* | | x | x | | | |
| 64. | *Brain Heart Infusion Broth (Dehydrate)* | | x | x | | | |
| 65. | *Brilliant Cresyl Bleu* | | | x | | | |
| 66. | *Bromocresol Green* | x | | | x | x | x |
| 67. | *Bromophenol Blue* | | | | | x | |
| 68. | *Brucine Hydrate* | | | | x | | |
| 69. | *Buffer Mixture Ph 4.0±0.02* | x | x | x | | | |
| 70. | *Buffer Mixture Ph 7.0±0.02* | x | x | x | | | |
| 71. | *Buffer Mixture Ph 9.0±0.02* | x | | x | | | |
| 72. | *Butyl Acetate* | | x | x | x | x | |
| 73. | *C, L, E, D Agar* | | | x | | | |
| 74. | *Cadmium Coarse Powder, 0.3-1.6mm* | | | | | x | x |
| 75. | *Cadmium Granulated GPR, 3-6mm* | | | | x | x | |
| 76. | *Cadmium Standard Solution* | | x | | x | | |
| 77. | *Calcium C.P.C* | | | x | | | |
| 78. | *Calcium Carbonate* | x | x | | x | x | x |
| 79. | *Calcium Chloride* | x | x | | | x | |
| 80. | *Calcium Hydroxide* | | | | x | x | |
| 81. | *Calcium Hypochlorite, (Bleaching Powder)* | | | | | x | |
| 82. | *Calcium Liquicolor* | | | x | | | |
| 83. | *Calcium Sulphate Dehydrate Precipitated* | x | x | | | x | |
| 84. | *Calibration Standard For Ba* | | | | | | x |
| 85 | *Calibration Standard For Ca* | x | | | | | x |
| 86. | *Calibration Standard For K* | x | | | | | x |
| 87. | *Calibration Standard For Li* | x | | | | | x |
| 88. | *Calibration Standard For Na* | x | | | | | x |
| 89. | *Carbon Tetrachloride* | | | | x | | |
| 90. | *Cefotaxime (CTX) 30ug* | | | x | | | |
| 91. | *Ceftriaxone 30mcg* | | | x | | | |
| 92. | *Charcoal Granular Activated* | | | | | x | |
| 93. | *Chloramines* | | | | x | x | |
| 94. | *Chloramphenicol 3ug* | | | x | | | |
| 95. | *Chlorhydric Acid* | x | x | | x | | |
| 96. | *Chloroform* | x | | x | | x | |
| 97. | *Chlorophenicol ; 4-* | | | | | x | |
| 98. | *Cholesterol CHOD-PAP Lliquicolor* | | | x | | | |
| 99. | *Ciprofloxacin 5mcg* | | | x | | | |
| 100. | *Citric Acid (Monohydrate), Powder* | x | x | | x | x | |
| 101. | *Ck-Nac Act* | | | x | | | |
| 102. | *Cobalt Standard Solution* | | x | | x | | |
| 103. | *Cobalt(II) Chloride 6-Hydrate* | | | | | x | |
| 104. | *Colistine 10mcg* | | | x | | | |
| 105. | *Commercial Sodium Hypochlorite Solution* | | | | x | | x |
| 106. | *Copper (Turning Cu)* | | | x | x | x | |
| 107. | *Copper Powder, Precipitated* | | | | | x | |
| 108. | *Copper standard solution, 1000 mg/L* | | x | | | | |
| 109. | *Copper Sulphate* | x | x | | x | x | x |
| 110. | *Creactinine* | | | x | | | |
| 111. | *Creatine* | | | x | | | |
| 112. | *Creatine monohydrate* | | x | | | | |
| 113. | *Chromium standard solution, 1000 mg/L* | | x | | | | |

| ល.រ | សារធាតុគីមី (Reagent) | មន្ទីរពិសោធន៍នៃក្រសួង | | | | | |
|---|---|---|---|---|---|---|---|
| | | កសិកម្ម | ពាណិជ្ជកម្ម | សុខាភិបាល | ឧស្សាហកម្ម | បរិស្ថាន | ធនធានទឹក |
| 114. | Cupferron GR [N-Nitroso-N-Phenylhydroxylamin Ammoniumsaiz] | | | | | x | |
| 115. | Curcumin Crystalline | | | | | x | |
| 116. | Cyanide Solution Standard | | | | x | | |
| 117. | Cyclohexanone | | | x | | x | |
| 118. | D(+) Galactose | | | x | | | |
| 119. | D(+) Glucose Anhydride | | | x | | | |
| 120. | Decaboxylase Medium Base | | x | | | | |
| 121. | Detergent( MA 03 Sans Phosphate) | | | | | | x |
| 122. | Determine Hbs For Ag | | | x | | | |
| 123. | Determine HIV 1+2 | | | x | | | |
| 124. | Determine Tm Syphilis Tp | | | x | | | |
| 125. | Dextrin | | | | | x | |
| 126. | Diammonium Hydrogen Citrate, [Ammonium Citrate Dibasic] | | | | | x | |
| 127. | Diammonium Iron(II) Sulphate 6-Hydrate | | | | | x | |
| 128. | Dichloroisocyanuric Acid Sodium Salt | | | | | x | |
| 129. | Diethyldithiocarbamic Acid, Sodium Salt Trihydrate | | | | | x | |
| 130. | Diethy ether | | x | | x | | |
| 131. | Diluents | | | x | | | |
| 132. | Dimethylaminobenzaldehyde ; 4 | | | | | x | |
| 133. | Diphenylcarbazide ; 1,5 | | | | x | x | x |
| 134. | Di-Potassium Hydrogen, Orthophosphate 3-Hydrate, Anhydrous | | | | x | x | |
| 135 | Di-Potassium Hydrogen Phosphate | | | x | | | |
| 136 | Di-Sodium Hydrogen Orthophosphate, 2-Hydrate, Anhydrous | | | | | x | |
| 137. | Di-sodium Hydrogen Phosphate, Dodecahydrate | x | x | | | | |
| 138. | Di-Sodium Peroxodisulphate | | | | | x | |
| 139. | Di-Sodium Tetraborate Anhydrous, [Sodium Tetraborate Anhydrous] | | x | | | x | |
| 140. | Dithizone | | | x | x | x | |
| 141. | Doxycycline 30ug | | | x | | | |
| 142. | D. Mannitol | | x | | | | |
| 143. | EC broth | | x | | | | |
| 144. | Egg Yoke Emulsion 50% | | x | | | | |
| 145. | Egg Yoke Telluride | | x | | | | |
| 146. | Elisa Hbsag | | | x | | | |
| 147. | Elisa Hcv | | | x | | | |
| 148. | Elisa Hiv 1+2 Genscreen Version 2 | | | x | | | |
| 149. | Eosin Methylen Blue Agar | | x | x | | | |
| 150. | Eriochromcyanin R | | | | x | x | |
| 151. | Eriochrome Black T | | | | | | x |
| 152. | Erythromycin 15ug | | | x | | | |
| 153. | Ethanol | x | x | x | x | x | x |
| 154. | Ethanolamine | | | x | | x | |
| 155. | Ethyl Acetate Gpr | x | x | x | | | |
| 156. | Ethylenediamine Tetra-Acetic Acide Disodium Salt [EDTA] | | x | x | x | x | |
| 157. | Ethylenediaminetetraacetic Acid Disodium Salt Dehydrate | x | x | x | | | x |
| 158. | Ethylenedianinetetraacetic Acid Magnesium Disodium Sal | | x | | | | x |
| 159. | Exatrol N, P | | | x | | | |

| លរ | សារធាតុគីមី (Reagent) | មន្ទីរពិសោធន៍នៃក្រសួង | | | | | |
|---|---|---|---|---|---|---|---|
| | | កសិកម្ម | ពាណិជ្ជកម្ម | សុខាភិបាល | ឧស្សាហកម្ម | បរិស្ថាន | ធនធានទឹក |
| 160. | *Ferric chloride anhydrous 98%* | | *x* | | | | |
| 161. | *Fluorescein Sodium [Uranin]* | | | | | *x* | |
| 162. | *Fluoride Standard Solution* | | | | *x* | | |
| 163. | *Formaldehyde* | | *x* | | | | |
| 164. | *Formic Acid* | | | | *x* | | *x* |
| 165. | *Fuchsine acid* | | *x* | | | | |
| 166. | *Fuchsine basic* | | *x* | | *x* | | |
| 167. | *Gamma GT* | | | *x* | | | |
| 168. | *Gentamycine 10ug* | | | *x* | | | |
| 169. | *Giemsa* | | | *x* | | | |
| 170. | *Giolitti Cantoni Broth* | | *x* | | | | |
| 171. | *Glucose* | | | | | | *x* |
| 172. | *Glucose Anhydrous ; D(+)-* | | | *x* | | *x* | |
| 173. | *Glucose Bile Esculine, Sodium Azide* | | | | | | *x* |
| 174. | *Glucose Film* | | | *x* | | | |
| 175. | *Glucose GOD-PAP* | | | *x* | | | |
| 176. | *Glucose Liquicolor* | | | *x* | | | |
| 177. | *Glucose Presion Electrode* | | | *x* | | | |
| 178. | *Glutamic Acid ; (S)-(+)-* | | | | | *x* | |
| 179. | *Glutaraldehyde Solution 50%* | | | | | *x* | |
| 180. | *Glycerol GPR* | | | *x* | | | |
| 181. | *Got Liquid Uv* | | | *x* | | | |
| 182. | *Gpt* | | | *x* | | | |
| 183. | *Gram Stain Kit* | | | *x* | | | |
| 184. | *Hektoen (Gelose)* | | | *x* | | | |
| 185. | *Hektoen Enteric Agar* | | | *x* | | | |
| 186. | *Hexamine [Hexamethylenetetramine]* | | | | | *x* | |
| 187. | *Hexane ; N-* | | | | *x* | *x* | |
| 188. | *Hydrazinesulphate* | | | | | | *x* |
| 189. | *Hydrazinium Sulphate, (Hydrazine Sulfate)* | | | | | *x* | |
| 190. | *Hydrochloric Acid* | *x* | *x* | *x* | *x* | *x* | *x* |
| 191. | *Hydrofluoric Acid* | | | *x* | | *x* | *x* |
| 192. | *Hydrogen Peroxide Solution 30%, and 6%* | *x* | | *x* | | *x* | |
| 193. | *Hydroxylamine hydrochloride* | | | | *x* | | *x* |
| 194. | *Hydroxyl ammonium Chloride* | | *x* | | *x* | *x* | |
| 195. | *Hydroxyl ammonium Sulfate* | | | | *x* | *x* | |
| 196. | *Imidazol* | | | *x* | | | |
| 197. | *Imipenem (IPM) 10ug* | | | *x* | | | |
| 198. | *Immersion Oil* | | | *x* | | | |
| 199. | *Immunofluorescence For Phneumocystis Carinii* | | | *x* | | | |
| 200. | *Indian Ink* | | | *x* | | | |
| 201. | *Indol Medium* | | | *x* | | | |
| 202. | *Iodine Indicator (Yodo Indicator)* | *x* | *x* | | | *x* | |
| 203. | *Ion Exchange Powder (Mixed-Bed, For Cations & Anions)* | | | | | | *x* |
| 204. | *Iron III Chloride 6 Hydrate* | | *x* | | *x* | | |
| 205. | *Iron III Nitrate* | | | | *x* | | |
| 206. | *Iron(II) Sulphate 7-Hydrate* | *x* | | | | *x* | |
| 207. | *Iron(III) Chloride 6-Hydrate, [Ferric Chloride Hexahydrate]* | | | | *x* | *x* | |
| 208. | *Iron standard solution, 1000 mg/L* | | *x* | | | | |
| 209. | *Isobutyl Alcohol* | | | | *x* | | *x* |
| 210. | *Kanamycine 10ug* | | | *x* | | | |
| 211. | *King A and B Agar* | | | *x* | | | |
| 212. | *Kliggle Hassan* | | | *x* | | | |

| ល.រ | សារធាតុគីមី (Reagent) | មន្ទីរពិសោធន៍នៃក្រសួង | | | | | |
|---|---|---|---|---|---|---|---|
| | | កសិកម្ម | ពាណិជ្ជកម្ម | សុខាភិបាល | ឧស្សាហកម្ម | បរិស្ថាន | ធនធានទឹក |
| 213. | L-Agrinine Hydrochloride | | x | | | | |
| 214. | L(+) Lysine Hydrochloride | | | x | | | |
| 215. | L+ Ornithine chlohydrate | | x | | | | |
| 216. | Lactose | | | x | | | |
| 217. | Lanthanum Chloride Heptahydrate and Solution | | x | | | x | |
| 218. | Lanthanum Oxide | | | | | x | x |
| 219. | Larryl Sulphate Tryptose Broth | | | x | | | |
| 220. | Latan chloride 7-hydrate | | x | | | | |
| 221. | Lauryl Sulphate Broth | | x | | | | |
| 222. | Lead Dithizone Reagent | | | x | | x | |
| 223. | Lead Standard Solution | | | | x | | |
| 224. | Lead(II) Acetate 3hydrate | | x | x | x | x | |
| 225. | Lead(II) Carbonate | | | | | x | |
| 226. | Lead(II) Nitrate | | | | | x | |
| 227. | Lead IV oxide | | x | | | | |
| 228. | Lincomycine 15mcg | | | x | | | |
| 229. | Lithium Chloride Anhydrous | x | | | | x | |
| 230. | Lugol Solution For Microbiology, [Iodine Potassium Iodide] | | | x | | x | |
| 231. | Lyse | | | x | | | |
| 232. | Lysine Desoxycholatebroth | | | x | | | |
| 233. | L. Lysine | | x | | | | |
| 234. | Macconkey-Broth | | | x | | | |
| 235. | Manganese Standard Solution | | | | x | | |
| 236. | Magnesium Chloride Anhydrous and Hexahydrate | | | | | x | |
| 237. | Magnesium chloride 6-hydrate | | x | | x | | |
| 238. | Magnesium Citrate | | | x | | | |
| 239. | Magnesium Nitrate Hexahydrate | | | | | x | |
| 240. | Magnésium Nitrate Solution, (10mg-Mg/Ml, 15%-Nitrate) | | | | | x | |
| 241. | Magnesium Oxide | | | | x | x | |
| 242. | Magnesium Sulphate 7-Hydrate | | x | | x | x | |
| 243. | Malachite Green | | | x | | | |
| 244. | Malachite Green Oxalate | | x | | | | |
| 245. | Manganese(II) Chloride 4-Hydrate | | | | | x | |
| 246. | Manganese(II) Sulphate Monohydrate | | | | x | x | |
| 247. | Manitol Mobilite | | | x | | | |
| 248. | Manitol Salt Agar | | | x | | | |
| 249. | Manitol Selective Broth Base | | x | | | | |
| 250. | Mecilinam (MC) 10ug | | | x | | | |
| 251. | Mercaptoacetic Acid | | | | | x | |
| 252. | Mercury | | | | | x | |
| 253. | Mercury Nitrate | | | | | | x |
| 254. | Mercury standard solution, 1000 mg/L | | x | | | | |
| 255. | Mercury(II) Chloride, Fine Crystals | | x | | | x | |
| 256. | Mercury(II) iodide | | x | | | | |
| 257. | Mercury(II) oxide red | | x | | | | |
| 258. | Mercury(II) Sulphate | | | | | x | |
| 259. | Metacresol Purple | | | | | x | |
| 260. | Metal-Free Triethanolamine, | | | | | | x |
| 261. | Methanol 99% | x | x | x | | x | |
| 262. | Methyl Orange | | x | x | x | x | |
| 263. | Methyl Red (Ph Indicator) | x | x | | | | x |

| លរ | សារធាតុគីមី (Reagent) | មន្ទីរពិសោធន៍នៃក្រសួង | | | | | |
|---|---|---|---|---|---|---|---|
| | | កសិកម្ម | ពាណិជ្ជកម្ម | សុខាភិបាល | ឧស្សាហកម្ម | បរិស្ថាន | ធនធានទឹក |
| 264. | *Methyl-1-Phenyl-2-Pyrazolin-5-One ; 3-[3-Methyl-1-Phenol- 5-Pyrazolon]* | | | | | *x* | |
| 265. | *Methylene blue chloride double salt* | | *x* | | | | |
| 266. | *Methylene Blue Powder and Trihydrate* | | | *x* | | | |
| 267. | *Methylpentan 2-One ; 4-* | | | | | *x* | *x* |
| 268. | *Miniclean* | | | *x* | | | |
| 269. | *Minidil LMG* | | | *x* | | | |
| 270. | *Minoclaire* | | | *x* | | | |
| 271. | *Monopotassium Phosphate* | | | *x* | | | |
| 272. | *Morpholine* | | | | | *x* | |
| 273. | *MRVP broth* | | *x* | | | | |
| 274. | *Mueller Hinton Agar* | | | *x* | | | |
| 275. | *Murexide* | | | | | | *x* |
| 276. | *Murexide [Ammonium Purpurate]* | | | | | *x* | |
| 277. | *MYP (Bacillus cereus agar)* | | *x* | | | | |
| 278. | *N-1-Naphthylethylenediamine Dihydrochloride* | | | | | *x* | |
| 279. | *Nalidixic (NA) 30ug* | | | *x* | | | |
| 280. | *Nickel standard solution, 1000 mg/L* | | *x* | | | | |
| 281. | *Nickel(II) Nitrate Hexahydrate* | | | | | *x* | |
| 282. | *Nickel (II) Nitrate Solution (10mg-Ni/Ml, 15%-Nitrate)* | | | | | *x* | |
| 283. | *Nicotinic Acid* | | | | | *x* | |
| 284. | *Nitrate Solution Standard 100ppm* | | *x* | | *x* | | |
| 285. | *Nitric Acid 98%, 68%, 65%* | | *x* | *x* | *x* | | *x* |
| 286. | *Nitrophenol ; 4- [Or P-]* | | | | *x* | *x* | |
| 287. | *Nitrosor Salt* | | | | *x* | | |
| 288. | *N-Naphtylethylenediamine Dihydrochloride* | | | | | | *x* |
| 289. | *n-butyl acetate* | | *x* | | | | |
| 290. | *n-propanol* | | *x* | | | | |
| 291. | *NNN'N'-Tetramethyl-P-Phenylenedlamlne Dlhydrochlorlbe* | | | | | *x* | |
| 292. | *Norfloxacine 10mcg* | | | *x* | | | |
| 293. | *Novobiocin* | | | *x* | | | |
| 294. | *Nutrient Agar* | | *x* | *x* | | | |
| 295. | *O.X (Oxidasee)* | | | *x* | | | |
| 296. | *O.Nitriphenyl B.D. Galatopyranoside* | | *x* | | | | |
| 297. | *Ofloxacine 5ug* | | | *x* | | | |
| 298. | *Optochin* | | | *x* | | | |
| 299. | *Orthoboric Acid Crystals[Boric Acid]* | *x* | | | | *x* | |
| 300. | *Orthophosphoric Acid 85%* | *x* | | | *x* | *x* | |
| 301. | *Oxacilline 5ug* | | | *x* | | | |
| 302. | *Oxalic Acid* | | | | *x* | *x* | *x* |
| 303. | *Oxalyldihydrazide* | | | | | *x* | |
| 304. | *Pancreatic Peptone Of Casein* | | | *x* | | | |
| 305. | *Pararosaniline Hydrochloride* | | | | | *x* | |
| 306. | *Pasorex Crypto Plus* | | | *x* | | | |
| 307. | *Pastorex Meningtis Meningo A* | | | *x* | | | |
| 308. | *PCA (Plate Count Agar)* | | *x* | | | | |
| 309. | *Penicillin 10 Unit* | | | *x* | | | |
| 310. | *Pentyl Acetate* | | | | | *x* | |
| 311. | *Peptone Bacteriological and Water* | | | *x* | | | |
| 312. | *Petroleum Ether, 30-60°c* | | | *x* | | *x* | |
| 313. | *Petroleum Spirit, 40-60°c* | | | *x* | *x* | *x* | |
| 314. | *Ph Electrode Soaker Bottle Solution* | | | | | *x* | |

| ល.រ | សារធាតុគីមី (Reagent) | មន្ទីរពិសោធន៍នៃក្រសួង | | | | | |
|---|---|---|---|---|---|---|---|
| | | កសិកម្ម | ពាណិជ្ជកម្ម | សុខាភិបាល | ឧស្សាហកម្ម | បរិស្ថាន | ធនធានទឹក |
| 315. | *Ph Standard Buffer Solution (pH4.01) Solution (pH7.00) and (pH9.0)* | | | | x | x | |
| 316. | *Phenanthroline Hydrate ; 1,10-* | | x | | x | x | |
| 317. | *Phenanthrolinium Chloride, Monohydrate; 1-10 phenantroline hydrate* | | x | | | x | |
| 318. | *Phenol* | | | x | x | x | x |
| 319. | *Phenol Standard Solution* | | | x | x | | |
| 320. | *Phosphate Buffered Saline PBS* | | | x | x | | |
| 321. | *Phosphoric Acid* | x | x | | x | | x |
| 322. | *Phosphotungstic Acid* | | | x | x | | |
| 323. | *Polymycine 300 unit* | | | x | | | |
| 324. | *Polymysin B Sulphate* | | x | | | | |
| 325. | *Polyvinylpyrrolidone* | | | x | | x | |
| 326. | *Potassium Dehydrogenate Phosphate* | | | x | | | |
| 327. | *Potassium Liquicolor* | | | x | | | |
| 328. | *Potassium Antimony (III) Oxide Tartrate* | | | | | | x |
| 329. | *Potassium Bicarbonate* | | | x | | | |
| 330. | *Potassium Bromate* | | x | | x | x | |
| 331. | *Potassium Bromide* | | x | | x | x | |
| 332. | *Potassium Carbonate Anhydrous* | | | x | | x | |
| 333. | *Potassium Chloride* | x | | | x | x | x |
| 334. | *Potassium Chromate* | | | | | x | x |
| 335. | *Potassium Cyanide 'Analar '* | | | | | x | x |
| 336. | *Potassium Dichromate* | x | x | | x | x | |
| 337. | *Potassium Dehydrogenate Orthophosphate* | | x | | | | |
| 338. | *Potassium Dehydrogenate Phosphate* | x | | x | | | x |
| 339. | *PotassiumDisulfite* | | x | | | | |
| 340. | *Potassium Fluoride Anhydrous* | | | | x | x | |
| 341. | *Potassium Hexachloroplatinate(IV)* | | | | x | x | |
| 342. | *Potassium Hexacyanoferrate* | | x | | x | x | |
| 343. | *Potassium Hydrogen Di-Iodate* | | | | | x | |
| 344. | *Potassium Hydrogen Phthalate* | | x | x | | x | x |
| 345. | *Potassium Hydrogen Phthalate, Primary Standard P.A.* | | | | | x | |
| 346. | *Potassium Hydroxide* | | x | x | x | x | |
| 347. | *Potassium Iodide* | | x | | x | x | x |
| 348. | *Potassium Iodine 98.5%* | | x | | | | |
| 349. | *Potassium Nitrate* | x | x | | x | x | x |
| 350. | *Potassium Periodate* | | | | x | | |
| 351. | *Potassium Permanganate (Not & low Hg)* | | x | x | x | x | x |
| 352. | *Potassium Peroxodisulphate* | | x | | x | | x |
| 353. | *Potassium Sodium (+)-Tartrare Crystalsand Powder* | | | | x | x | |
| 354. | *Potassium Sulphate* | | x | x | x | x | |
| 355. | *Pregnancy Test (25lu/HCG)* | | | x | | | |
| 356. | *Propan-2-Ol* | | | x | | x | |
| 357. | *Pyridine* | | | | x | x | |
| 358. | *Pyrrolidine-1-Dithiocarboxylic Acid {* Store At +2°c To +8°c }* | | | | | x | |
| 359. | *Pyruvic Acid Sodium Salt* | | | x | | | |
| 360. | *Rabbit plasma with EDTA* | | x | | | | |
| 361. | *Rapparot Vassiliadis Broth* | | x | | | | |
| 362. | *Rheumatoid Factor-Latex* | | | x | | | |
| 363. | *Ringer Solution* | | | | | | x |
| 364. | *Rosalic Acid* | | | | x | | |
| 365. | *Rpr (Vdrl)* | | | x | | | |

| លរ | សារធាតុគីមី (Reagent) | មន្ទីរពិសោធន៍នៃក្រសួង | | | | | |
|---|---|---|---|---|---|---|---|
| | | កសិកម្ម | ពាណិជ្ជកម្ម | សុខាភិបាល | ឧស្សាហកម្ម | បរិស្ថាន | ធនធានទឹក |
| 366. | *Sabouraud + Chloramphenicol* | | | *x* | | | |
| 367. | *Safranine* | | | *x* | | | |
| 368. | *Safranine O* | | *x* | | | | |
| 369. | *Salicylic Acid* | | | | | *x* | |
| 370. | *Secondary Antibody* | | | *x* | | | |
| 371. | *Selective Supplement* | | *x* | | | | |
| 372. | *Selenite Broth* | | | *x* | | | |
| 373. | *Selenium powder* | | *x* | | | | |
| 374. | *Silica Gel* | | | | *x* | *x* | *x* |
| 375. | *Silver Chloride* | | | | | *x* | |
| 376. | *Silver Diethyldithiocarbamate* | | | | | *x* | |
| 377. | *Silver Nitrate* | *x* | *x* | | *x* | *x* | *x* |
| 378. | *Silver Sulphate* | | | | | *x* | |
| 379. | *Sodium Acetate* | *x* | *x* | *x* | *x* | *x* | |
| 380. | *Sodium Arsenate 7-Hydrate* | | | | | *x* | |
| 381. | *Sodium Arsenate Solution, 0.05mol/L (0.1N), Volumetric Solution* | | | | | *x* | |
| 382. | *Sodium Azide* | | | | | *x* | *x* |
| 383. | *Sodium Bicarbonate* | *x* | | *x* | | | |
| 384. | *Sodium Borohydride* | | | | | *x* | |
| 385. | *Sodium Carbonate Anhydrous* | *x* | *x* | *x* | *x* | *x* | |
| 386. | *Sodium Chloride* | *x* | | *x* | *x* | *x* | *x* |
| 387. | *Sodium Cyanide 95%* | | *x* | | | | |
| 388. | *Sodium Dihydrogen Orthophosphate monohydrate* | | *x* | | | | |
| 389. | *Sodium Dihydrogen Orthophosphate 2 Hydrate* | | | | *x* | | |
| 390. | *Sodium Disulfide* | | *x* | | | | |
| 391. | *Sodium Dodecyl Sulphate* | | | | | *x* | |
| 392. | *Sodium Fluoride* | *x* | | | *x* | *x* | |
| 393. | *Sodium Fluorosilicate* | | | *x* | | | *x* |
| 394. | *Sodium Glutamate* | | | *x* | | | |
| 395. | *Sodium Hydrogen Carbonate* | *x* | *x* | | | *x* | *x* |
| 396. | *Sodium Hydroxide* | | *x* | *x* | *x* | *x* | |
| 397. | *Sodium Hypochlorite (See Teepol Bleach)* | | | | *x* | | |
| 398. | *Sodium Iodide* | | | | | *x* | *x* |
| 399. | *Sodium Linear-Dodecylbenzene, Sulfonate Standard* | | | | | *x* | |
| 400. | *Sodium Metasilicate* | | | | | *x* | |
| 401. | *Sodium N,N-Diethyldithiocarbamate , Trihydrate* | | | | *x* | *x* | |
| 402. | *Sodium Nitrate* | *x* | *x* | | *x* | *x* | *x* |
| 403. | *Sodium Nitroprussode* | | | | | | *x* |
| 404. | *Sodium Oxalate* | | *x* | | *x* | *x* | |
| 405. | *Sodium Salicylate* | | | | | *x* | |
| 406. | *Sodium Starch Glycolate,* | | | | | | *x* |
| 407. | *Sodium Sulfate, Anhydrous* | | *x* | *x* | *x* | | |
| 408. | *Sodium Sulphite Anhydrous* | | *x* | | *x* | *x* | |
| 409. | *Sodium Thiocyanate* | | *x* | | | | |
| 410. | *Sodium Thiosulphate 5-Hydrate* | | *x* | | | *x* | *x* |
| 411. | *Solochrome Black* | | *x* | | *x* | *x* | |
| 412. | *Sorbic Acid* | | *x* | | | | |
| 413. | *Spiramycine 100ug* | | | *x* | | | |
| 414. | *Standard Solution - Cadmium 1000ppm* | | *x* | | *x* | *x* | |
| 415. | *Standard Solution - Calcium 1000ppm* | *x* | | | | *x* | |
| 416. | *Standard Solution - Cesium 1000ppm* | | | | | *x* | |

| លរ | សារធាតុគីមី (Reagent) | មន្ទីរពិសោធន៍នៃក្រសួង | | | | | |
|---|---|---|---|---|---|---|---|
| | | កសិកម្ម | ពាណិជ្ជកម្ម | សុខាភិបាល | ឧស្សាហកម្ម | បរិស្ថាន | ធនធានទឹក |
| 417. | *Standard Solution - Chromium 1000ppm* | | x | | | x | |
| 418. | *Standard Solution - Cobalt 1000ppm* | | x | | x | x | |
| 419. | *Standard Solution - Copper 1000ppm* | | x | | x | x | |
| 420. | *Standard Solution - Fluoride1000ppm* | | | | x | x | |
| 421. | *Standard Solution - Iron 1000ppm* | | x | | | x | |
| 422. | *Standard Solution - Lead 1000ppm* | | x | | x | x | |
| 423. | *Standard Solution - Lithium 1000ppm* | | | | | x | |
| 424. | *Standard Solution - Magnesium 1000ppm* | x | | | | x | |
| 425. | *Standard Solution - Mercury 1000ppm* | | x | | | x | |
| 426. | *Standard Solution - Nickel 1000ppm* | x | x | | | x | |
| 427. | *Standard Solution - Potassium 1000ppm* | x | | | | x | |
| 428. | *Standard Solution - Sodium 1000ppm* | x | | | | x | |
| 429. | *Standard Solution - Zinc 1000ppm* | | | | x | x | |
| 430. | *Streptomycin 10ug* | | | x | | | |
| 431. | *Sucrose* | | x | | | | |
| 432. | *Sulfanilic Acid, [ 4-Aminobenzenesulfonic Acid]* | | | | | x | |
| 433. | *Sulfate Solution Standard* | | | | x | | |
| 434. | *Sulphanilamide* | | | | x | | |
| 435. | *Sulphuric Acid* | | | | x | | x |
| 436. | *Tartaric Acid;Dextro-Rotatory* | | x | | x | x | |
| 437. | *Tb Niacin Test Strip* | | | | x | x | |
| 438. | *Tetrahydrofuranne* | | | x | | | |
| 439. | *Tetrationate Broth* | | | x | | | |
| 440. | *Tetracycline 30ug* | | | x | | | |
| 441. | *Thioglycolate With Rezasurin Broth* | | | x | | | |
| 442. | *Thiourea* | | | | | x | |
| 443. | *Thymol* | | | | | x | |
| 444. | *Tin(II) Chloride Dehydrate* | | | | x | x | |
| 445. | *Tin(II) Chloride, 'Spectrosol L' (Low Mercury)* | | | | | x | |
| 446. | *Tin-Granulated* | | | | x | x | |
| 447. | *Titan Yellow GR* | | | | | x | |
| 448. | *Tri Sodium Phosphate* | | | x | | x | |
| 449. | *Triethanolamine* | x | | | | x | |
| 450. | *Triglyceride GPO* | | | x | | | |
| 451. | *Trimetoprine 1.25x23,75* | | | x | | | |
| 452. | *Tri-Sodium orthophosphate* | | x | | | | |
| 453. | *Tri-Sodium Citrate* | | | x | | x | |
| 454. | *Triton X-100* | | | x | | x | |
| 455. | *Tryptone Water* | | x | | | | |
| 456. | *Trypetone Soya Agar* | | x | | | | |
| 457. | *Tryptone* | | | | | | x |
| 458. | *Tryptophane* | | | x | | | |
| 459. | *Umatrol N and P* | | | x | | | |
| 460. | *Urea* | | | x | | | |
| 461. | *Urea Liquicolor* | | | x | | | |
| 462. | *Uric Acid* | | | x | | | |
| 463. | *Uric Acid Liquicolor* | | | x | | | |
| 464. | *Urine Strip* | | | x | | | |
| 465. | *Vibrio Cholerae Inaba* | | x | | | | |
| 466. | *Vibrio Cholelae O1 Polyvalent* | | x | | | | |
| 467. | *Xylene Cyanol* | | | | | | x |
| 468. | *Zielh Neelsen, Staining Set* | | | x | | | |
| 469. | *Zinc Granules / Pellets(3-8mm) /Powder* | x | | | | x | |
| 470. | *Zinc Sulphate* | | | | | x | |

| លរ | សារធាតុគីមី (Reagent) | មន្ទីរពិសោធន៍នៃក្រសួង | | | | | |
|---|---|---|---|---|---|---|---|
| | | កសិកម្ម | ពាណិជ្ជកម្ម | សុខាភិបាល | ឧស្សាហកម្ម | បរិស្ថាន | ធនធានទឹក |
| 471. | *Zincon* | | | | | *x* | |
| 472. | *Zirconium(IV) Oxide Chloride Octahydrate* | | | | | *x* | |
| 473. | *Zirconyl Chloride Octahydrate* | | | | | *x* | |

*ប្រភព :* មន្ទីរពិសោធន៍ក្រសួងសុខាភិបាល ក្រសួងបរិស្ថាន ក្រសួងពាណិជ្ជកម្ម ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## ២.៩ សំណល់សារធាតុគីមី

ជាទូទៅ ឧស្សាហកម្មនៃប្រទេសកម្ពុជាជាប្រភេទឧស្សាហកម្មធុនស្រាល ដូចជា ផលិតកម្មអាហារ និងផលិតកម្មសំលៀកបំពាក់ ហើយដែលពុំទាន់មានជាប្រភេទឧស្សាហកម្មគីមី ឬលោហៈកម្មនៅឡើយ។ ដូចនេះ ទាក់ទងទៅនឹងការបង្កើតសំណល់គីមី គឺមានក្នុងបរិមាណតិចតួច ហើយដែលបានកំណត់ទៅលើប្រភេទសំណល់ភក់នៃអាងប្រព្រឹត្តកម្មសំណល់រាវរោងចក្រ ដែលប្រើប្រាស់សារធាតុគីមីច្រើនប្រភេទនៅក្នុងដំណើរការផលិតកម្ម ពិសេស គឺឧស្សាហកម្មបោកគក់និងជ្រលក់ពណ៌។ ក្រៅពីសំណល់ភក់នៃអាងប្រព្រឹត្តកម្មសំណល់រាវរោងចក្រ សំណល់សារធាតុគីមីត្រូវបានចាត់បញ្ចូលផងដែរនូវសំណល់គ្រោះថ្នាក់មួយចំនួន រួមបញ្ចូលទាំងសំណល់មន្ទីរពេទ្យ។ ទិន្នន័យពីបរិមាណសំណល់សារធាតុគីមីដែលមាននៅក្នុងប្រទេស ត្រូវបានផ្តល់ឱ្យដោយក្រសួងបរិស្ថាន និងក្រសួងសុខាភិបាល ដូចមានសង្ខេបបង្ហាញក្នុងតារាង ២-១៨ ខាងក្រោម។

តារាង ២-១៨: ប្រភេទនិងបរិមាណសំណល់សារធាតុគីមី

| លរ | ប្រភេទនៃសំណល់សារធាតុគីមី | បរិមាណបញ្ចេញមធ្យម (តោន/ឆ្នាំ) | ការនាំចេញ (តោន/ឆ្នាំ) | ការនាំចូល (តោន/ឆ្នាំ) |
|---|---|---|---|---|
| ១ | សំណល់គ្រោះថ្នាក់ឧស្សាហកម្ម | ៦.៩៣៩.០០ | - | - |
| ២ | សំណល់ពាណិជ្ជកម្ម និងសេវាកម្ម | - | - | - |
| ៣ | សំណល់មន្ទីរពេទ្យ | ៨០១.៨២ | - | - |
| ៤ | សំណល់មន្ទីរពិសោធន៍ | - | - | - |
| ៥ | សំណល់កំពង់ផែ និងការដឹកជញ្ជូនតាមនាវា | - | - | - |
| ៦ | សំណល់សហគមន៍ | - | - | - |
| ៧ | សំណល់កសិកម្ម | - | - | - |
| | សរុប | ៧.៧៤០.៨២ | - | - |

*ប្រភព :* ក្រសួងបរិស្ថាន នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន ឆ្នាំ២០០៣

## ២.១០ សារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ

### ២.១០.១ ថ្នាំកសិកម្មប្រភេទសរីរាង្គមិនងាយបំបែកធាតុ

នៅក្នុងចំណោមថ្នាំកសិកម្មប្រភេទសរីរាង្គមិនងាយបំបែកធាតុទាំង ៩ មុខ ដែលត្រូវបានហាមឃាត់ជាអន្តរជាតិដោយអនុសញ្ញា ស្តុកខូម (Aldrin, Chlordane, DDT, Dieldrin, Endrin, Heptachlor, Hexachlorobenzene, Mirex និង Toxaphene) គឺមាន ២ មុខដែលពេញនិយមខ្លាំងសំរាប់ប្រជាពលរដ្ឋកម្ពុជារហូតមកទល់សព្វថ្ងៃនេះ គឺដេដេតេ និងអង់ឌ្រីន។ ភាពពេញនិយមនេះបានធ្វើឱ្យកសិករកម្ពុជាមានការយល់ច្រឡំថា រាល់ថ្នាំកសិកម្មដែលជាម្សៅគឺដេដេតេ ហើយថ្នាំកសិកម្មដែលជាទឹក គឺអង់ឌ្រីន។ ក្រៅពីដេដេតេ និងអង់ឌ្រីន នៅកម្ពុជាក៏ធ្លាប់មានប្រើប្រាស់ថ្នាំកសិកម្មប្រភេទសរីរាង្គមិនងាយបំបែកធាតុដទៃផ្សេងទៀតដែរ ប៉ុន្តែពុំមានរបាយការណ៍ឬពត៌មានបញ្ជាក់ឡើយ។

យោងតាមទិន្នន័យ និងពត៌មានដែលផ្តល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបញ្ជាក់ថា ចាប់ពីឆ្នាំ១៩៨៥ ដល់ឆ្នាំ១៩៩០ ក្រុមហ៊ុនរដ្ឋដែលទទួលខុសត្រូវលើការនាំចូលនិងចែកចាយថ្នាំកសិកម្មនៅទូទាំងប្រទេស ធ្លាប់បានធ្វើការនាំចូលថ្នាំកសិកម្មប្រភេទសរីរាង្គមិនងាយបំបែកធាតុក្នុងបរិមាណតិចតួចប៉ុណ្ណោះ គឺដេដេតេ ១.២ តោន និងអង់ឌ្រីន ១៩០០ លីត្រ។

ដោយការទទួលស្គាល់ពីភាពគ្រោះថ្នាក់នៃសារធាតុគីមីប្រភេទថ្នាំកសិកម្ម រាជរដ្ឋាភិបាលកម្ពុជាបានចេញបទបញ្ជាធ្វើការហាមឃាត់ថ្នាំកសិកម្មចំនួន ១១៦ មុខ ដែលក្នុងនោះមានប្រភេទថ្នាំកសិកម្មដែលស្ថិតក្នុងអនុសញ្ញា ស្តុកខូម ទាំង ៩ មុខផងដែរ។

យោងតាមលទ្ធផលនៃការធ្វើសារពើភ័ណ្ឌសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុនាដើមឆ្នាំ ២០០៤ គឺបានរកឃើញថា នៅលើទីផ្សារមួយចំនួននៅកម្ពុជា គឺមានការលក់ដូរថ្នាំកសិកម្មប្រភេទសារធាតុសរីរាង្គមិនងាយបំបែកធាតុចំនួន ២ មុខ គឺ ដេដេតេ ៣៥០ គីឡូក្រាម និងក្លរដែន ៥៥ គីឡូក្រាម ប៉ុន្តែ ពុំបានរកឃើញស្តុកនៃថ្នាំទាំងនោះទេ ដែលនេះគឺជាការបញ្ជាក់ថា ប្រភេទថ្នាំកសិកម្មទាំងនោះ ត្រូវបាននាំចូលដោយលួចលាក់ក្នុងបរិមាណតិចតួច តាមរយៈការគេចពន្ធនៅតាមច្រកតូចៗនៃព្រំដែនជាប់ប្រទេសជិតខាង។

### ២.១០.២ សារធាតុគីមី ភីស៊ីប៊ី (Polychlorinated Biphenyls, PCBs)

សារធាតុគីមី ភីស៊ីប៊ី (Polychlorinated Biphenyls, PCBs) គឺជាសារធាតុមួយដែលស្ថិតនៅក្នុងចំណោមសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុទាំង ១២ មុខ ដែលមានចែងនៅក្នុងអនុសញ្ញា ស្តុកខូម។ ជាទូទៅ សារធាតុគីមី ភីស៊ីប៊ី ត្រូវបានប្រើប្រាស់ជាប្រេងមិនចំលងចរន្តនៅក្នុងបរិក្ខារចែកចាយថាមពលអគ្គិសនី ដូចជា ត្រង់ស្វូរ កាប៉ាស៊ីទ័រ កង់ដង់ ឧបករណ៍ផ្តាច់ចរន្ត ខ្សែកាបត្រាំប្រេង ។ល។

នៅកម្ពុជា ផ្អែកទៅលើពត៌មានពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងអគ្គិសនីកម្ពុជា បានបង្ហាញថា បរិក្ខារក្នុងបណ្តាញអគ្គិសនី ដូចជា ត្រង់ស្វូរ កាប៉ាស៊ីទ័រ ឧបករណ៍ផ្តាច់ចរន្ត និងខ្សែកាបត្រាំប្រេង ត្រូវបាននាំចូល និងប្រើប្រាស់តាំងពីឆ្នាំ ១៩០៦ នៅពេលដែលក្រុមហ៊ុនអគ្គិសនីរបស់បារាំងមកធ្វើវិនិយោគវិស័យអគ្គិសនីនៅកម្ពុជា ហើយក្នុងរយៈពេលបន្ទាប់ ការនាំចូលនិងប្រើប្រាស់ត្រូវបានធ្វើជាបន្តរហូតមកទល់បច្ចុប្បន្ននេះ ។ ប៉ុន្តែ ទិន្នន័យ ឬស្ថិតិពីការនាំចូល ឬប្រើប្រាស់គ្រឿងបរិក្ខារអគ្គិសនីទាំងនោះ គឺពិបាកនឹងរកបាន ពីព្រោះក្នុងរយៈកាលកន្លងមកពុំមានការចាប់អារម្មណ៍ទៅលើសារធាតុគីមី ភីស៊ីប៊ី នៅក្នុងឧបករណ៍ទាំងនោះទេ ។

ក្រោយការចុះហត្ថលេខាលើអនុសញ្ញា ស្តុកខូម (២៣ ឧសភា ២០០១) រដ្ឋាភិបាលកម្ពុជា ដោយមានការគាំទ្រពីមូលនិធិបរិស្ថានសហប្រជាជាតិ (GEF) និងការគាំទ្របច្ចេកទេសពីកម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP) បានធ្វើសារពើភ័ណ្ឌលើឧបករណ៍

អគ្គិសនីត្រង់ស្វូនៅទូទាំងប្រទេស ដើម្បីកំណត់វត្តមាននៃសារធាតុគីមី ភីស៊ីប៊ី ។ ជាលទ្ធផល គឺបានរកឃើញថា មានត្រង់ស្វូអគ្គិសនីប្រមាណ ១៦០០ គ្រឿង កំពុងត្រូវបានប្រើប្រាស់នៅទូទាំងប្រទេស ហើយដែលត្រូវបាននាំចូលមកប្រើប្រាស់តាមឆ្នាំដូចខាងក្រោម :

- **មុនឆ្នាំ ១៩៧០:** ត្រង់ស្វូភាគច្រើនត្រូវបាននាំចូលពីប្រទេសបារាំង ជប៉ុន ដែលមានចំនួនប្រហែល ៣០០គ្រឿង កំពុងបន្តប្រើប្រាស់ ។
- **ចន្លោះឆ្នាំ ១៩៧០-១៩៨៣ :** នៅក្នុងដំណាក់កាលនេះ ត្រង់ស្វូអគ្គិសនីភាគច្រើនត្រូវបាននាំចូលពីប្រទេសបារាំង កូរ៉េខាងត្បូង អាល្លឺម៉ង់ យូហ្គូស្លាវី និងអតីតសហភាពសូវៀត ដែលមានចំនួនប្រហែល ២០០គ្រឿង កំពុងបន្តប្រើប្រាស់ ។
- **ក្រោយឆ្នាំ ១៩៨៣ មកទល់បច្ចុប្បន្ន :** ភាគច្រើនមកពីអតីតសហភាពសូវៀត បណ្តាប្រទេសអឺរ៉ុបខាងលិច បារាំង កូរ៉េខាងត្បូង ថៃ ជប៉ុន រ៉ូម៉ានី អ៊ីតាលី និងវៀតណាម ដែលគេប៉ាន់ស្មានថាមានចំនួនប្រហែល ១១០០គ្រឿង ដែលត្រូវបានប្រើប្រាស់មកដល់បច្ចុប្បន្ន។

យោងតាមលទ្ធផលនៃការធ្វើសារពើភ័ណ្ឌលើកដំបូងនេះ បានបង្ហាញថា ក្នុងចំណោមត្រង់ស្វូ ១៦០០ គ្រឿង គឺមានប្រមាណជា ៥០% (ប្រមាណ ៨០០ គ្រឿង) ត្រូវបានសន្មតថាមានផ្ទុក ឬមានលាយឡំដោយសារធាតុគីមី ភីស៊ីប៊ី។ គួរបញ្ជាក់ថា សេចក្តីសន្មតពីវត្តមាននៃសារធាតុគីមី ភីស៊ីប៊ី ក្នុងប្រេងត្រង់ស្វូ គឺបានផ្អែកទៅលើអាយុរបស់ត្រង់ស្វូ ពីស្ថានភាពនៃការប្រើប្រាស់ និងដោយការធ្វើតេស្តដោយឧបករណ៍វិភាគនៅទីវាល ដូចនេះហើយទើបអ្វីដែលបានកំណត់ក្នុងការធ្វើសារពើភ័ណ្ឌត្រូវបានចាត់ថាជាការសន្មតលើកដំបូង។ មូលហេតុដែលយើងមិនទាន់អាចធ្វើការកំនត់ឱ្យបានច្បាស់លាស់ពីវត្តមានសារធាតុ ភីស៊ីប៊ី គឺដោយសារមន្ទីរពិសោធន៍គីមីទាំងអស់របស់កម្ពុជា គឺពុំទាន់មានសមត្ថភាពក្នុងការវិភាគរកសារធាតុ ភីស៊ីប៊ី នៅឡើយ។

នៅកម្ពុជា ទាក់ទងទៅនឹងការនាំចូល ប្រើប្រាស់ ឬបោះបង់ចោលសារធាតុគីមី ភីស៊ីប៊ី គឺពុំទាន់មានបរិធានច្បាប់ ឬបទបញ្ជាណាមួយដាក់បញ្ញត្តិ ឬហាមឃាត់នៅឡើយទេ។ ការប្រើប្រាស់ឡើងវិញនូវប្រេងត្រង់ស្វូចាស់ៗ សំរាប់ជាប្រេងបំពេញបន្ថែមទៅត្រង់ស្វូថ្មីៗ កំពុងបន្តអនុវត្តនី ពិសេសក្នុងពេលជួសជុលត្រង់ស្វូដែលឆេះ ឬខូច ។ ទន្ទឹមនោះ ការយកប្រេងត្រង់ស្វូចាស់ៗទៅប្រើប្រាស់នៅតាមលំនៅឋាន ជាប្រេងប៉ូលាឈើនិងគ្រឿងសង្ហារឹម ជាប្រេងម៉ាស៊ីនដេរ និងជាប្រេងលាយសំរាប់ដុតយកថាមពលក្នុងអាជីវកម្មតូចៗ គឺកំពុងមានសកម្មភាព ដោយពុំមានការចាប់អារម្មណ៍ពីគ្រោះថ្នាក់ដល់សុខភាពនិងបរិស្ថាន ដែលនឹងត្រូវប្រឈមនាពេលអនាគត។ ក្រៅពីការប្រើប្រាស់ឡើងវិញនូវប្រេងត្រង់ស្វូចាស់ៗ បច្ចុប្បន្ន ការបោះបង់ចោលសំណល់ត្រង់ស្វូចាស់ៗ គឺកំពុងចោទជាបញ្ហា ពីព្រោះកម្ពុជាពុំទាន់មានបរិក្ខារសំរាប់សំអាត ស្តុក ឬកំទេចចោលសំណល់ប្រេងភីស៊ីប៊ី ឬឧបករណ៍ដែលមានប្រឡាក់ភីស៊ីប៊ីនៅឡើយទេ ហើយសំណល់ទាំងនោះត្រូវបានគេទិញយកទៅលួយកលោហៈ ។

## ២.១០.៣ សារធាតុថ្មី ដេដេតេ សំរាប់ការត្រួតពិនិត្យសុខភាពសាធារណៈ

សារធាតុគីមីថ្នាំសំលាប់សត្វល្អិត ដេដេតេ ដែលជាសារធាតុមួយស្ថិតនៅក្នុងចំណោមសារធាតុគីមីបំពុលសរីរាង្គមិនងាយបំបែកធាតុទាំង ១២ មុខ ដែលមានចែងនៅក្នុងអនុសញ្ញា ស្តុកខូម ក្រៅពីការប្រើប្រាស់សំរាប់គោលបំណងផ្នែកកសិកម្ម គឺត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងគោលបំណងត្រួតពិនិត្យសុខភាពសាធារណៈ ពោលគឺសំរាប់ប្រឆាំងទៅនឹងជំងឺឆ្លងដែលបង្កដោយមូសជាភ្នាក់ងារ។

ទាក់ទងទៅនឹងការប្រើប្រាស់ថ្នាំសំលាប់សត្វល្អិតដេដេតេ សំរាប់គោលបំណងត្រួតពិនិត្យសុខភាពសាធារណៈ នៅកម្ពុជា គឺបានចាប់ផ្តើមនៅក្នុងឆ្នាំ១៩៥៣ ក្នុងលក្ខណៈជាការសិក្សាសាកល្បងនៅតំបន់ដែលមានជំងឺគ្រុនចាញ់ ហើយបន្ទាប់មកបានពង្រីកទៅ

កាន់តំបន់ដទៃទៀតក្នុងលក្ខណៈជាយុទ្ធនាការធំដើម្បីលុបបំបាត់ជំងឺគ្រុនចាញ់ ដែលបានអនុវត្តន៍នៅចន្លោះឆ្នាំ១៩៥៩ ទៅឆ្នាំ១៩៦៨ និងបានបន្តប្រើប្រាស់នៅក្នុងសម័យសង្គ្រាម ឆ្នាំ១៩៧០ ដល់១៩៧៥ ។ ប៉ុន្តែ ពុំមានទិន្នន័យពីតំបន់ និងបរិមាណថ្នាំដេដេតេ ដែលបានប្រើប្រាស់នោះទេ ។

នៅក្នុងសម័យខ្មែរក្រហមកាន់អំណាច ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ឯកសារឈ្មោះ "របបប៉ុលពត" ដែលសរសេរដោយលោក បែន គីយ៉ើណាន់ (ទំព័រ១៤៦) បានបញ្ជាក់ថា នៅក្នុងកំឡុងឆ្នាំ ១៩៧៥-១៩៧៩ របបខ្មែរក្រហមបាននាំចូលនូវថ្នាំដេដេតេចំនួន ៨៤០ តោនពីហុងកុង តែពុំមានពត៌មានលំអិតពីការចែកចាយ និងការប្រើប្រាស់នូវថ្នាំដេដេតេទាំងនេះទេ ។

ចាប់ពីឆ្នាំ ១៩៨០ កម្មវិធីប្រើប្រាស់ថ្នាំដេដេតេសំរាប់ការពារសុខភាពសាធារណៈត្រូវបានបន្ត ដើម្បីប្រឆាំងនិងភ្នាក់ងារចំលងជំងឺគ្រុនចាញ់និងគ្រុនឈាមទាំងនៅតំបន់ទីប្រជុំជន និងជនបទ ដោយបានប្រើថ្នាំដេដេតេសល់ក្នុងស្តុកនៃរបបខ្មែរក្រហមប្រមាណជា ២០ តោន។ នៅក្នុងអំឡុងឆ្នាំ ១៩៨១-៨៧ មានការនាំចូលថ្នាំដេដេតេប្រមាណ ១២០តោន ពីអតីតសហភាពសូវៀត និងពីប្រទេសហូឡង់ សំរាប់គាំទ្រដល់កម្មវិធីប្រឆាំងជំងឺគ្រុនចាញ់នៅប៉ែកខាងក្នុងប្រទេសកម្ពុជា។ ក្នុងពេលជាមួយគ្នានោះ ក៏មានការប្រើប្រាស់ថ្នាំដេដេតេសំរាប់ប្រឆាំងភ្នាក់ងារចំឡងជំងឺគ្រុនចាញ់នៅតាមជំរុំជនភៀសខ្លួនរបស់អង្គការជនភៀសខ្លួន (UNHCR) ដែលស្ថិតនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ផងដែរ ប៉ុន្តែពុំមានទិន្នន័យពីបរិមាណ និងទីកន្លែងប្រើប្រាស់ឡើយ ។

ចាប់តាំងពីឆ្នាំ ១៩៨៧ មក កម្ពុជាពុំបាននាំចូល និងបានបញ្ឈប់ការប្រើប្រាស់ថ្នាំដេដេតេ សំរាប់ការត្រួតពិនិត្យសុខភាពសាធារណៈ ពិសេស ជំងឺគ្រុនចាញ់ លើកលែងតែតំបន់ចំការកៅស៊ូដែលបានបញ្ឈប់ការប្រើប្រាស់នៅក្នុងឆ្នាំ១៩៩១ ។ ការបញ្ឈប់ការប្រើប្រាស់នេះ គឺពុំមែនស្ថិតនៅក្រោមបទបញ្ញត្តិច្បាប់ ឬបទបញ្ជាជាតិណាមួយទេ ប៉ុន្តែការបញ្ឈប់នេះគឺបានផ្អែកទៅលើអនុសាសន៍របស់អង្គការសុខភាពពិភពលោក (WHO) ក្នុងឆ្នាំ១៩៨៦ និងដោយសារមានវត្តមានសារធាតុគីមីជាថ្នាំសំលាប់សត្វល្អិតជំរើសជំនួសការប្រើថ្នាំដេដេតេ ដូចជា ថ្នាំដែលតាមីទ្រីន (Deltamethrin) ពែមីទ្រីន (Permethrin) និងពីរីត្រូយ (Pyritroil) ។ ដូច្នេះហើយ បច្ចុប្បន្ននេះ មិនមានថ្នាំដេដេតេកំពុងត្រូវបានប្រើប្រាស់សំរាប់ត្រួតពិនិត្យជំងឺគ្រុនចាញ់ទេ ហើយកម្ពុជាក៏គ្មានឆន្ទៈណាមួយក្នុងការប្រើប្រាស់វាឡើងវិញដែរនៅពេលអនាគត ។

ទាក់ទងទៅនឹងទិន្នន័យពីបរិមាណថ្នាំដេដេតេ ដែលបានបែងចែងសំរាប់ការប្រើប្រាស់នៅតាមខេត្តក្រុងនិមួយៗ គឺពុំមានកំណត់ត្រាជាឯកសារទេ។ ប៉ុន្តែ តាមរយៈការសម្ភាសន៏ក្នុងពេលធ្វើសារពើភ័ណ្ឌជាមួយអ្នកធ្លាប់គ្រប់គ្រងផ្ទាល់នឹងការងារជំងឺគ្រុនចាញ់ខេត្ត-ក្រុង បានបង្ហាញ គឺមានថ្នាំដេដេតេប្រមាណ ១៤៣ តោន ត្រូវបានបែងចែកសំរាប់ការប្រើប្រាស់នៅទូទាំងប្រទេសពីឆ្នាំ ១៩៨០ ដល់ឆ្នាំ១៩៨៧ ដូចមានសង្ខេបបង្ហាញក្នុងតារាង ២-១៩ ខាងក្រោម ។

តារាង ២-១៩: បរិមាណនៃការចែកចាយថ្នាំដេដេតេ និងកាលបរិច្ឆេទប្រគល់ទៅតាមខេត្ត-ក្រុង

| ល.រ | ខេត្ត-ក្រុង | ឆ្នាំប្រគល់ | ឆ្នាំប្រើអស់ | បរិមាណ (តោន) | គោលបំណងនៃការប្រើប្រាស់ |
|---|---|---|---|---|---|
| ១ | ខេត្តបន្ទាយមានជ័យ | ១៩៨០ | ១៩៨៧ | ១១ | ប្រឆាំងភ្នាក់ងារចំឡងជំងឺគ្រុនចាញ់ និងគ្រុនឈាម |
| ២ | ខេត្តបាត់ដំបង | ១៩៨០ | ១៩៨៧ | ១០ | ប្រឆាំងភ្នាក់ងារចំឡងជំងឺគ្រុនចាញ់ និងគ្រុនឈាម |
| ៣ | ខេត្តកំពត | ១៩៨០ | ១៩៨៦ | ១ | ប្រឆាំងភ្នាក់ងារចំឡងជំងឺគ្រុនចាញ់ |
| ៤ | ខេត្តកណ្តាល | ១៩៨១ | ១៩៨៧ | ៥ | ប្រឆាំងភ្នាក់ងារចំឡងជំងឺគ្រុនចាញ់ និងគ្រុនឈាម |
| ៥ | ក្រុងកែប (ក្នុងខេត្តកំពត) | ១៩៨០ | ១៩៨៦ | - | ប្រឆាំងភ្នាក់ងារចំឡងជំងឺគ្រុនចាញ់ |

| ល.រ | ខេត្ត-ក្រុង | ឆ្នាំប្រគល់ | ឆ្នាំប្រើអស់ | បរិមាណ (តោន) | គោលបំណងនៃការប្រើប្រាស់ |
|---|---|---|---|---|---|
| ៦ | ខេត្តកំពង់ចាម | ១៩៨១ | ១៩៩១ | ៥ | ប្រឆាំងភ្នាក់ងារចំឡងជំងឺគ្រុនចាញ់ និងគ្រុនឈាម |
| ៧ | ខេត្តកំពង់ឆ្នាំង | ១៩៨០ | ១៩៨៧ | ១៣ | ប្រឆាំងភ្នាក់ងារចំឡងជំងឺគ្រុនចាញ់ និងគ្រុនឈាម |
| ៨ | ខេត្តកំពង់ស្ពឺ | ១៩៨០ | ១៩៨៦ | ៥ | ប្រឆាំងភ្នាក់ងារចំឡងជំងឺគ្រុនចាញ់ និងគ្រុនឈាម |
| ៩ | ខេត្តកំពង់ធំ | ១៩៨១ | ១៩៨៦ | ៥ | ប្រឆាំងភ្នាក់ងារចំឡងជំងឺគ្រុនចាញ់ និងគ្រុនឈាម |
| ១០ | ខេត្តកោះកុង | ១៩៨០ | ១៩៨៦ | ៣ | ប្រឆាំងភ្នាក់ងារចំឡងជំងឺគ្រុនចាញ់ |
| ១១ | ខេត្តក្រចេះ | ១៩៨១ | ១៩៨៦ | ៥ | ប្រឆាំងភ្នាក់ងារចំឡងជំងឺគ្រុនចាញ់ |
| ១២ | ខេត្តមណ្ឌលគិរី | ១៩៨០ | ១៩៨៦ | ១ | ប្រឆាំងភ្នាក់ងារចំឡងជំងឺគ្រុនចាញ់ |
| ១៣ | ខេត្តឧត្តរមានជ័យ (ដូចសៀមរាប) | ១៩៨០ | ១៩៨៩ | - | ប្រឆាំងភ្នាក់ងារចំឡងជំងឺគ្រុនចាញ់ |
| ១៤ | ក្រុងប៉ៃលិន | ១៩៨០ | ១៩៩១ | ៤ | ប្រឆាំងភ្នាក់ងារចំឡងជំងឺគ្រុនចាញ់ និងរុយ |
| ១៥ | រាជធានីភ្នំពេញ | ១៩៨១ | ១៩៨៦ | ៣ | ប្រឆាំងភ្នាក់ងារចំឡងជំងឺគ្រុនចាញ់ និងគ្រុនឈាម |
| ១៦ | ខេត្តព្រះវិហារ | ១៩៨១ | ១៩៨៦ | ២ | ប្រឆាំងភ្នាក់ងារចំឡងជំងឺគ្រុនចាញ់ |
| ១៧ | ខេត្តព្រៃវែង | ១៩៨០ | ១៩៨៦ | ៥ | ប្រឆាំងភ្នាក់ងារចំឡងជំងឺគ្រុនចាញ់ និងគ្រុនឈាម |
| ១៨ | ខេត្តពោធិសាត់ | ១៩៨០ | ១៩៨៥ | ១១ | ប្រឆាំងភ្នាក់ងារចំឡងជំងឺគ្រុនចាញ់ និងគ្រុនឈាម |
| ១៩ | ខេត្តរតនៈគិរី | ១៩៨០ | ១៩៨៧ | ៣ | ប្រឆាំងភ្នាក់ងារចំឡងជំងឺគ្រុនចាញ់ |
| ២០ | ខេត្តសៀមរាប | ១៩៨០ | ១៩៨៥ | ១១ | ប្រឆាំងភ្នាក់ងារចំឡងជំងឺគ្រុនចាញ់ |
| ២១ | ក្រុងព្រះសីហនុ | ១៩៨១ | ១៩៨៦ | ០.៥ | ប្រឆាំងភ្នាក់ងារចំឡងជំងឺគ្រុនចាញ់ និងគ្រុនឈាម |
| ២២ | ខេត្តស្ទឹងត្រែង | ១៩៨០ | ១៩៨៦ | ៣ | ប្រឆាំងភ្នាក់ងារចំឡងជំងឺគ្រុនចាញ់ |
| ២៣ | ខេត្តស្វាយរៀង | ១៩៨១ | ១៩៨៧ | ៤ | ប្រឆាំងភ្នាក់ងារចំឡងជំងឺគ្រុនចាញ់ និងគ្រុនឈាម |
| ២៤ | ខេត្តតាកែវ | ១៩៨១ | ១៩៨៧ | ៤ | ប្រឆាំងភ្នាក់ងារចំឡងជំងឺគ្រុនចាញ់ |
| ២៥ | ចំការកៅស៊ូ * | ១៩៨១ | ១៩៨៦ | ២៨.៥ | ប្រឆាំងភ្នាក់ងារចំឡងជំងឺគ្រុនចាញ់ |
| | សរុប | | | ១៤៣ | |

ប្រភព : របាយការណ៍សារពើភ័ណ្ឌលើសារធាតុដេដេតេ ខែកក្កដា ឆ្នាំ២០០៤

សំគាល់ : * ចំការកៅស៊ូមិនមែនជាខេត្ត ឬក្រុងទេ

## ២.១០.៤ អនុផលមិនបានការប្រភេទសរីរាង្គមិនងាយបំបែកធាតុ

អនុផលមិនបានការ (Unintentional By-products) គឺសំដៅទៅលើសារធាតុគីមីសរីរាង្គ ២ ប្រភេទ ឌីអុកស៊ីន (Dioxins) និងហ្វូរ៉ាន់ (Furans) ហើយដែលសារធាតុគីមីទាំង ២ នេះ គឺស្ថិតនៅក្នុងចំណោមសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុទាំង ១២ មុខ ដែលមានចែងនៅក្នុងអនុសញ្ញា ស្តុកខូម ។ ជាទូទៅ សារធាតុគីមីឌីអុកស៊ីន និងហ្វូរ៉ាន់ គឺពុំមានប្រទេសណាមួយផលិត

ក្នុងគោលបំណងសំរាប់ការប្រើប្រាស់ឡើយ ។ ផ្ទុយទៅវិញ វាងាយនឹងកកើតនៅតាមដំណើរផលិតកម្មគីមីឧស្សាហកម្ម ឬចំហេះមួយចំនួនដែលគេមិនចង់បាន និងអាចបង្កបញ្ហាគ្រោះថ្នាក់ដល់សុខភាពនិងបរិស្ថានថែមទៀត ដូចនេះហើយទើបគេហៅវាថាជាអនុផលមិនបានការ ឬមិនចង់បាន (Unintentional By-products) ។

ថ្វីត្បិតតែប្រទេសកម្ពុជាពុំមែនជាប្រទេសឧស្សាហកម្មដែលជាប្រភពបង្កើត និងសាយភាយអនុផលមិនបានការ ឌីអុកស៊ីន និងហ្វូរ៉ាន់ក៏ពិតមែន ប៉ុន្តែ នៅក្នុងការធ្វើសារពើភ័ណ្ឌលើប្រភពបង្កើត និងសាយភាយសារធាតុគីមីឌីអុកស៊ីននិងហ្វូរ៉ាន់ នៅដើមឆ្នាំ ២០០៤ នេះ គឺបានរកឃើញថា មានប្រភពមួយចំនួនដែលមានសក្តានុពលខ្ពស់ក្នុងការបង្កើតនិងសាយភាយសារធាតុគីមីឌីអុកស៊ីន និងហ្វូរ៉ាន់នៅកម្ពុជា រួមមាន :

- ការឆេះដោយគ្មានការត្រួតពិនិត្យ ដែលរួមបញ្ចូលទាំងការដុតសំរាមនៅទីលានចាក់ ការដុតសំរាមតាមលំនៅឋាន ការឆេះព្រៃ ការដុតសំណល់កសិកម្មនៅតាមទីវាលក្រោយការប្រមូលផល ។
- ការដុតសំណល់មន្ទីរពេទ្យ ដោយប្រើឡបូរាណមិនមានបំពាក់ឧបករណ៍សំអាតផ្សែង ។
- រោងចក្រអគ្គិសនីដើរដោយការដុតប្រេង និងឡចំហាយដើរដោយការដុតសំណល់ ។
- សិប្បកម្មស្លដែកចាស់ៗ និងលោហៈកម្មមិនមែនដែក ( របស់អេតចាយ ) ។

ផ្អែកទៅលើគោលការណ៍ណែនាំរបស់អង្គការ UNEP សំរាប់គណនាប៉ាន់ប្រមាណបរិមាណសាយភាយឌីអុកស៊ីន និងហ្វូរ៉ាន់ កម្ពុជាបានអនុវត្តការធ្វើសារពើភ័ណ្ឌលើសារធាតុទាំង ២ ហើយដែលលទ្ធផលប៉ាន់ប្រមាណនៃការសាយភាយសរុបក្នុង ១ ឆ្នាំ គឺមានចំនួន ៦០៦.៦៦៤ ក្រាម នៃអេគីវ៉ាឡង់ភាពពុល ( g TEQ/a ) ដូចមានបង្ហាញលំអិតក្នុងតារាង ២-២០ ខាងក្រោម ។

តារាង ២-២០: បរិមាណសាយភាយប្រចាំឆ្នាំនៃឌីអុកស៊ីន និងហ្វូរ៉ាន់ ពីប្រភពសំខាន់ៗនៅកម្ពុជា (ឆ្នាំ២០០៤)

| ចំណាត់ថ្នាក់ | ប្រភពចំណាត់ថ្នាក់ | ការបញ្ចេញប្រចាំឆ្នាំ ( g TEQ/a[1] ) ទៅលើ/ក្នុង | | | | | |
|---|---|---|---|---|---|---|---|
| | | ខ្យល់ | ទឹក | ដី | ផលិតផល | សំណល់ | សរុប |
| ១ | ការឆេះដោយគ្មានការត្រួតពិនិត្យ | ២១៧.៨៧ | 0.00 | ១៤.៥៦ | 0.00 | ៣១៥.៦០ | ៥៤៨.០៣១ |
| ២ | ការដុតសំណល់មន្ទីរពេទ្យដោយឡបូរាណ មិនមានបំពាក់ឧបករណ៍សំអាតផ្សែង | ៤០.៧៣ | 0.00 | 0.00 | 0.00 | 0.៧៨១ | ៤១.៥១១ |
| ៣ | រោងចក្រអគ្គិសនីដើរដោយប្រេង និងឡចំហាយដើរដោយដុតសំណល់ | ១០.២៧៥ | 0.00 | 0.00 | 0.00 | ១.៦៩២ | ១១.៩៦៧ |
| ៤ | ផលិតផលដែក និងលោហៈកម្ម មិនមែនដែក | 0.៤១ | 0.00 | 0.00 | 0.00 | ១.0 | ១.៤១ |
| ៥ | ផលិតកម្មនៃផលិតផលរ៉ែ | 0.0៩៩ | 0.00 | 0.00 | 0.00 | 0.00 | 0.0៩៩ |
| ៦ | ការដឹកជញ្ជូន | 0.00៥ | 0.00 | 00 | 0.00 | 0.00 | 0.00៥ |

[1] g TEQ/a - Gram Toxic Equivalent per Annual

| ចំណាត់ថ្នាក់ | ប្រភពចំណាត់ថ្នាក់ | ការបញ្ចេញប្រចាំឆ្នាំ (g TEQ/a[1]) ទៅលើ/ក្នុង | | | | | |
|---|---|---|---|---|---|---|---|
| | | ខ្យល់ | ទឹក | ដី | ផលិតផល | សំណល់ | សរុប |
| ៧ | ផ្សេង១ | ៣.៦៤១ | 0.00 | 0.00 | 0.00 | 0.00 | ៣.៦៤១ |
| ១-៧ | សរុប | ២៧៣.០៣១ | 0.00 | ១៤.៥៦ | 0.00 | ៣១៩.០៧៣ | ៦០៦.៦៦៤ |

*ប្រភព* : របាយការណ៍សារពើភ័ណ្ឌលើសារធាតុឌីអុកស៊ីន និងហ្វូរ៉ាន់ ខែកក្កដា ឆ្នាំ២០០៤

## ២.១១ សារធាតុគីមីប្រើប្រាស់តាមចំណាត់ថ្នាក់

តារាង ២-២១: សង្ខេបសរុបផលិតផល និងការធ្វើពាណិជ្ជកម្មសារធាតុគីមី

| ប្រភេទសារធាតុគីមី | ការផលិត | | នាំចូល | | ការលាយផ្សំ/ការវេចខ្ចប់ | | នាំចេញ | |
|---|---|---|---|---|---|---|---|---|
| | បរិមាណ (តោន/ឆ្នាំ) | តំលៃ (US$) | បរិមាណ (តោន/ឆ្នាំ) | តំលៃ (US$) | បរិមាណ (តោន/ឆ្នាំ) | តំលៃ (US$) | បរិមាណ (តោន/ឆ្នាំ) | តំលៃ (US$) |
| ជីគីមី | - | - | ៤៥.៣៣៩.០០ | ៤.៦៩១.២៩៣.០០ | - | - | - | - |
| ថ្នាំកសិកម្ម | - | - | ១៩៨.៤៦ | ២២៥.៨៥៦.០០ | - | - | - | - |
| សារធាតុគីមីសំរាប់ការផលិតឱសថ | - | - | ៧៤.០៣២.០៣ | ៤១.២០៩.១៨៦.០០ | - | - | - | - |
| សារធាតុគីមីសំរាប់វិស័យឧស្សាហកម្ម | - | - | ៩៤.៨៩៥.៧៧ | ១០.៧០៩.២៩៤.០០ | - | - | - | - |
| ផលិតផលលោហធាតុ និងសមាសធាតុរបស់វា | - | - | ១៥១.២៧៩.៧៣ | ៣១.១២៧.២០៤.០០ | - | - | - | - |
| ឥន្ធនៈរ៉ែ និងផលិតផលប្រេងឥន្ធនៈ | - | - | ៩១៨.៤៥០.៥០ | ២៤១.១១០.៣៧២.០០ | - | - | - | - |
| ផលិតផលគីមីសំរាប់ប្រើតាមលំនៅឋាន | - | - | ៥.០៦៩.៣០ | ១.៦២២.១៩២.០០ | - | - | - | - |
| សារធាតុគីមីសំរាប់មន្ទីរពិសោធន៍ | - | - | - | - | - | - | - | - |
| សំណល់សារធាតុគីមី | ៧.៧៤០.៨២ | - | - | - | - | - | - | - |
| សារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ | - | - | - | - | - | - | - | - |
| សរុប | ៧.៧៤០.៨២ | - | ១.២៩៣.២៦១.១៩ | ៣៣០.៦៥៥.៣៥៧.០០ | - | - | - | - |

# ជំពូកទី ៣
# បញ្ហាជាអាទិភាពដែលទាក់ទងទៅនឹងការផលិត នាំចូល នាំចេញ និងការប្រើប្រាស់សារធាតុគីមី

ជំពូកនេះនឹងផ្តល់នូវទិដ្ឋភាពរួមនៃរាល់បញ្ហាដែលទាក់ទងទៅនឹងសកម្មភាពនៃការផលិត ការធ្វើពាណិជ្ជកម្ម ការប្រើប្រាស់សារធាតុគីមី និងការបោះបង់ចោលនូវសារធាតុគីមីទាំងនោះ ។ ជាមួយគ្នានេះដែរ ជំពូកនេះនឹងផ្តល់ការកំណត់បញ្ហាជាអាទិភាពដែលពាក់ព័ន្ធសារធាតុគីមី ដែលត្រូវបានចាត់ទុកថាបានបង្កជាក្តីកង្វល់ទៅដល់សង្គមជាតិ ដោយវាបានធ្វើឱ្យប៉ះពាល់ទៅលើសុខភាពសាធារណៈ និងគុណភាពបរិស្ថាននៅកម្ពុជា ។

## ៣.១ ទិដ្ឋភាពរួមនៃបញ្ហាទាក់ទងនឹងសារធាតុគីមី

នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដូចជាប្រទេសកម្ពុជា ការនាំចូល ការដឹកជញ្ជូន និងការប្រើប្រាស់សារធាតុគីមីបានបង្កនូវក្តីកង្វល់ជាច្រើន ពិសេសសារធាតុគីមីដែលជាប្រភេទថ្នាំកសិកម្ម សារធាតុគីមីសំរាប់វិស័យឱសថ សារធាតុគីមីសំរាប់ផលិតកម្មឧស្សាហកម្ម សារធាតុគីមីគ្រោះថ្នាក់ដែលមានផ្ទុកក្នុងឧបករណ៍ប្រើប្រាស់ ផលិតផលសារធាតុគីមីប្រើប្រាស់តាមលំនៅឋាន និងសំណល់គីមី ។ ប៉ុន្តែ សំរាប់ប្រទេសកម្ពុជារហូតមកទល់បច្ចុប្បន្ននេះ គឺពុំទាន់មានការសិក្សា ឬប៉ាន់ប្រមាណជាលក្ខណៈពេញលេញ និងច្បាស់លាស់ពីប្រភេទនៃបញ្ហាដែលទាក់ទងទៅនឹងការប្រើប្រាស់សារធាតុគីមីនៅឡើយទេ។ ទន្ទឹមនោះការកំណត់ពីតំបន់ដែលមានការប្រើប្រាស់សារធាតុគីមីច្រើន ឬទទួលរងនូវការបំពុលដោយសារធាតុគីមីក៏ពុំធ្លាប់បានធ្វើដែរ។ សូមបញ្ជាក់ថា ការវាយតំលៃ ឬកំនត់ពីបញ្ហាឬកង្វល់ដែលទាក់ទងទៅនឹងការប្រើប្រាស់សារធាតុគីមីនៅកម្ពុជាក្នុងរយៈពេលកន្លងមកគឺភាគច្រើនបានធ្វើតាមរយៈការពិនិត្យឃើញ និងការសន្និដ្ឋានដោយផ្អែកលើអត្ថបទ ឬឯកសារដែលពាក់ព័ន្ធតែប៉ុណ្ណោះ ពោលគឺពុំបានផ្អែកលើលទ្ធផលអង្កេតបែបវិទ្យាសាស្ត្រនៅឡើយទេ ។

ថ្វីត្បិតតែមានការខ្វះខាតមូលដ្ឋានសំរាប់ការវាយតំលៃពីបញ្ហាទាក់ទងសារធាតុគីមី ប៉ុន្តែមិនមានន័យថាកម្ពុជាគ្មានបញ្ហានោះទេ ។ ផ្ទុយទៅវិញ បច្ចុប្បន្ននេះ ពលរដ្ឋកម្ពុជាកំពុងប្រឈមទៅនឹងភាពគ្រោះថ្នាក់ដែលបង្កដោយការប្រើប្រាស់សារធាតុគីមីជាពិសេសពពួកសារធាតុគីមីពុល និងសារធាតុគីមីគ្រោះថ្នាក់នៅក្នុងមុខរបររបស់ពួកគេ និងនៅក្នុងសហគមន៍និងលំនៅឋានរបស់ពួកគេ ដោយគេមិនបានយល់ដឹងពីភាពគ្រោះថ្នាក់ដែលនឹងទទួលរងនាពេលអនាគត ។ ក្រៅពីភាពប្រឈមទៅនឹងគ្រោះថ្នាក់ដោយការប្រើប្រាស់សារធាតុគីមី ពលរដ្ឋកម្ពុជាក៏ប្រឈមទៅនឹងការទទួលរងនូវសំណល់ជាតិគីមីពុល តាមរយៈចំណីអាហារដែលមានផ្ទុកជាតិគីមីទាំងនោះ ។

នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការផលិតស្បៀងរបស់កម្ពុជា គឺទទួលបានលើសពីតំរូវការក្នុងស្រុកក្នុងកំរិតបរិមាណតិចតួចប៉ុណ្ណោះ ។ ដូចនេះ យុទ្ធសាស្ត្រដើម្បីសំរេចបាននូវការដាំដុះបែបប្រពលវប្បកម្មនិងមានគុណភាពខ្ពស់ រួមមានការកែលំអពូជស្រូវ ការកែលំអដីធ្លី និងប្រព័ន្ធស្រោចស្រពទឹក ត្រូវបានដាក់ចេញឱ្យអនុវត្តនៅទូទាំងប្រទេស ដោយរួមបញ្ចូលទាំងការប្រើប្រាស់នូវសារធាតុគីមីកសិកម្មសំរាប់ការពារដំណាំនិងជំរុញឱ្យមានទិន្នផលខ្ពស់ ។ ប៉ុន្តែ ការប្រើប្រាស់ថ្នាំកសិកម្មមិនបានត្រឹមត្រូវ និងខ្វះការយល់ដឹងផ្នែកបច្ចេកទេស បានផ្តល់នូវផលអាក្រក់ដោយផ្ទាល់ក្នុងបញ្ហាសុខភាពនៅកន្លែងដែលពីមុនមិនធ្លាប់

កើតមានបញ្ហានោះ ។ ទន្ទឹមនេះ វាក៏បានបណ្តាលឱ្យប៉ះពាល់ទៅដល់សុខភាពកសិករ និងគុណភាពបរិស្ថានផងដែរ ។ នៅកម្ពុជា មានប្រជាជនជាង ៨០% ជាកសិករ ហើយភាគច្រើនបំផុតនៃពួកគេ គឺកំពុងប្រើប្រាស់សារធាតុគីមីដ៏គ្រោះថ្នាក់ក្នុងរបរកសិកម្ម របស់ខ្លួន ដោយខ្វះការយល់ដឹងឬការធ្វើមិនដឹងមិនឮពីការគំរាមកំហែងដល់សុខភាពរបស់ពួកគេនិងបរិស្ថាន ។ ទន្ទឹមនេះ សារធាតុគីមីមួយចំនួនដែលលក់នៅលើទីផ្សារក្នុងស្រុក គឺត្រូវបានហាមឃាត់មិនឱ្យលក់ដូរ ឬប្រើប្រាស់នៅបណ្តាប្រទេសមួយចំនួន ពិសេសបណ្តាប្រទេសអ្នកផលិតសារធាតុគីមីនោះ ។

ទាក់ទងទៅនឹងសារធាតុគីមីជាវត្ថុធាតុដើមឧស្សាហកម្ម និងផលិតផលគីមីប្រើប្រាស់តាមលំនៅឋាន ក៏បានជះឥទ្ធិពលខ្លាំង ទៅលើសុខភាពសាធារណៈ ពិសេសកម្មកររោងចក្រ និងប្រជាពលរដ្ឋដែលប្រើសារធាតុគីមីនោះផ្ទាល់ ។ ការងាយទទួលរង គ្រោះថ្នាក់ គឺដោយសារពួកគេមិនបានយល់ដឹងពីភាពងាយរងគ្រោះថ្នាក់ដែលបង្កដោយសារធាតុគីមីទាំងនោះ ជាក់ស្តែងនៅក្នុង ការអនុវត្ត កម្មកររោងចក្រដែលធ្វើការផ្ទាល់នឹងសារធាតុគីមី គឺពុំមានសំលៀកបំពាក់ឬសំភារៈការពារខ្លួនឡើយ ។ ដោយឡែក សំរាប់ផលិតផលសារធាតុគីមីដែលប្រើប្រាស់តាមលំនៅឋាន ដូចជា គ្រឿងសំអាង ថ្នាំសំលាប់សត្វចង្រៃតាមលំនៅឋាន គឺត្រូវ បាននាំចូលនិងលក់ដូរសំរាប់ប្រើប្រាស់យ៉ាងសេរីដោយមិនមានការត្រួតពិនិត្យគុណភាពជាផ្លូវការ និងការណែនាំពីរបៀបប្រើប្រាស់ ប្រកបដោយសុវត្ថិភាពសុខភាព ដូចជាការប្រើប្រាស់លើកូនក្មេងដែលមិនទាន់គ្រប់អាយុដែលត្រូវប្រើ។ ក្រៅពីនោះ ផលិតផល សារធាតុគីមីមួយចំនួន ត្រូវបានគេយកទៅប្រើប្រាស់ដោយផ្ទាល់លើអាហារនិងផលិតផលចំណីអាហារ ក្នុងគោលបំណងលើក សោភ័ណ រក្សាទុកបានយូរ និងការពាររុយជាដើម។

ជារួម ទាក់ទងទៅនឹងសារធាតុគីមី កម្ពុជាកំពុងប្រឈមទៅនឹងភាពគ្រោះថ្នាក់ទាំងទៅលើសុខភាពមនុស្សនិងបរិស្ថាន ។ ប៉ុន្តែ បញ្ហាគ្រោះថ្នាក់ទាំងនោះគឺមិនទាន់មានការកំណត់អត្តសញ្ញាណឱ្យបានច្បាស់លាស់នៅឡើយ ពីព្រោះភាគច្រើនជាឥទ្ធិពលរ៉ាំរ៉ៃ ជួបផ្សំនឹងការខ្វះខាតនូវប្រព័ន្ធនិងមធ្យោបាយសំរាប់ធ្វើការវាយតំលៃ ហើយការវាយតំលៃនេះគឺផ្អែកទៅលើការសង្កេតជាទូទៅ តែប៉ុណ្ណោះ ។ ការសង្ខេបពីប្រភេទនៃបញ្ហាទាក់ទងនឹងសារធាតុគីមីនៅកម្ពុជា គឺមាននៅក្នុងតារាងខាងក្រោម :

តារាង ៣-១: ប្រភេទនៃបញ្ហាទាក់ទងនឹងសារធាតុគីមីនៅកម្ពុជា

| លរ | ប្រភេទនៃបញ្ហា | តំបន់ | ពិពណ៌នាពីបញ្ហា | សារធាតុគីមី ឬសារធាតបំពុល |
|---|---|---|---|---|
| ១ | ការប៉ះពាល់លើសុខភាពកសិករដែលប្រើប្រាស់ថ្នាំកសិកម្ម | ជនបទ (ស្រែ-ចំការ) | សុខភាពទ្រុឌទ្រោម មានកើតនូវជំងឺប្លែកៗ និងមានរោគស្បែក | ថ្នាំកសិកម្ម |
| ២ | ការប៉ះពាល់លើសុខភាពកម្មកររោងចក្រដែលអនុវត្តផ្ទាល់នឹងសារធាតុគីមី | ទីក្រុង និងទីរួមខេត្ត | សុខភាពចុះខ្សោយ រោគផ្លូវដង្ហើម និងរោគថ្លើម | ពពួកអាស៊ីត ពពួកបាស ពពួកសារធាតុរំលាយ |
| ៣ | ការប៉ះពាល់លើសុខភាពអ្នកប្រើផលិតផលគីមីជាគ្រឿងសំអាង | ទាំងទីក្រុង និងជនបទ | កើតរោគស្បែក ប៉ះពាល់សរសៃប្រសាទ | ពពួកអំបិលបារត អ៊ីដ្រូសែនពែរអុកស៊ីត ($H_2O_2$) |
| ៤ | ការប៉ះពាល់លើសុខភាពអ្នកប្រើផលិតផលគីមីជាថ្នាំសំលាប់សត្វល្អិតតាមលំនៅឋាន | ទីក្រុង និងទីប្រជុំជន | កើតរោគក្អក និងរលាកផ្លូវដង្ហើម | ថ្នាំកសិកម្ម |
| ៥ | ការប៉ះពាល់លើសុខភាពអ្នកប្រើប្រាស់ផលិតផលចំណីអាហារដែលប្រើសារធាតុគីមី | ទាំងទីក្រុង និងជនបទ | រោគខ្សោយក្រលៀន ជំងឺថ្លើម រោគក្រពះ ជម្ងឺមហារីក | ថ្នាំកសិកម្ម សារធាតុគីមីបន្ថែម |

## ៣.២ បញ្ហាប្រឈមអាទិភាពទាក់ទងនឹងសារធាតុគីមី

បច្ចុប្បន្ននេះ ប្រទេសកម្ពុជាមានការខ្វះខាតច្រើននូវពត៌មានទិន្នន័យនិងកំណត់ត្រាផ្សេងៗ សំរាប់ប្រើប្រាស់ជាមូលដ្ឋានក្នុងការវាយតំលៃ និងកំណត់អាទិភាពនៃបញ្ហាដែលទាក់ទងទៅនឹងសារធាតុគីមី ។ ប៉ុន្តែ យោងទៅតាមបទពិសោធន៏ការងាររបស់មន្ត្រីជំនាញនៃស្ថាប័នពាក់ព័ន្ធការងារគ្រប់គ្រងសារធាតុគីមី និងការសង្កេតនិងកត់សំគាល់ជារួម ការកំណត់អាទិភាពនៃបញ្ហាសារធាតុគីមីត្រូវបានកំណត់ និងសង្ខេបបង្ហាញនៅក្នុងតារាងខាងក្រោម ។

តារាង ៣-២: លំដាប់អាទិភាពបញ្ហា និងកង្វល់ទាក់ទងនឹងសារធាតុគីមីនៅកម្ពុជា

| ប្រភេទបញ្ហា | ទំហំបញ្ហា | កំរិតកង្វល់ | លទ្ធភាពត្រួតពិនិត្យបញ្ហា | ទិន្នន័យដែលអាចរកបាន | ប្រភេទគីមីដែលបង្កកង្វល់ | លំដាប់អាទិភាព |
|---|---|---|---|---|---|---|
| *ការបំពុលខ្យល់* | តំបន់ | ទាប | ទាប | គ្មាន | Pb, PM10 | ៤ |
| *ការបំពុលទឹកសាប* | តំបន់ | មធ្យម | មធ្យម | មិនគ្រប់គ្រាន់ | - | ៣ |
| *ការបំពុលទឹកប្រៃ* | មូលដ្ឋាន | ទាប | ទាប | គ្មាន | - | ៤ |
| *ការបំពុលទឹកក្រោមដី* | មូលដ្ឋាន | មធ្យម | ទាប | មិនគ្រប់គ្រាន់ | As, NO2 | ៣ |
| *ការបំពុលដី* | មូលដ្ឋាន | ទាប | ទាប | គ្មាន | - | ៤ |
| *ជាតិគីមីសល់ក្នុងអាហារ* | ជាតិ | ខ្ពស់ | ទាប | មិនគ្រប់គ្រាន់ | Pesticides residue | ២ |
| *ការបំពុលទឹកផឹក* | ជាតិ | មធ្យម | ទាប | មិនគ្រប់គ្រាន់ | As, NO2 | ៣ |
| *ការសំអាត/បោះបង់ចោលសំណល់គ្រោះថ្នាក់* | មូលដ្ឋាន | មធ្យម | ទាប | មិនគ្រប់គ្រាន់ | Lead battery | ៣ |
| *សុខភាពការងារផ្នែកកសិកម្ម* | តំបន់ | ខ្ពស់ | ទាប | គ្មាន | Pesticides | ២ |
| *សុខភាពការងារផ្នែកឧស្សាហកម្ម* | មូលដ្ឋាន | ខ្ពស់ | ទាប | គ្មាន | - | ២ |
| *សុខភាពសាធារណៈ* | ជាតិ | មធ្យម | មធ្យម | គ្មាន | ទូទៅ | ២ |
| *គ្រោះថ្នាក់សារធាតុគីមីក្នុងរោងចក្រ* | មូលដ្ឋាន | មធ្យម | ទាប | គ្មាន | - | ៣ |
| *គ្រោះថ្នាក់សារធាតុគីមីក្នុងពេលដឹកជញ្ជូន* | មូលដ្ឋាន | ខ្ពស់ | ទាប | គ្មាន | - | ៣ |
| *ការនាំចូលសារធាតុគីមីគ្មានការជូនដំណឹងជាមុន* ** | ជាតិ | ខ្ពស់ | ទាប | គ្មាន | Pesticides and Industrial Chemicals | ២ |
| *ស្តុក/បោះបង់ចោលសំណល់គីមី* | ជាតិ | មធ្យម | ទាប | មិនគ្រប់គ្រាន់ | - | ៣ |
| *ការពុលគីមី/ការធ្វើអត្តឃាតដោយប្រើសារធាតុគីមី* | មូលដ្ឋាន | ទាប | ទាប | គ្មាន | Pesticides | ៤ |
| *សារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ* | តំបន់ | មធ្យម | ទាប | មិនគ្រប់គ្រាន់ | PCBs, Endrin, DDT, By-products, | ៣ |

***កំណត់ពន្យល់*** : - មូលដ្ឋាន សំដៅកន្លែងកើតបញ្ហាដែលមិនធំ គឺស្ថិតក្នុងរង្វង់ភូមិ ឬឃុំ-សង្កាត់ទាំងមូល

- តំបន់ សំដៅកន្លែងដែលកើតបញ្ហាធំ គឺស្ថិតក្នុងរង្វង់ស្រុក ឬខេត្តទាំងមូល
- ជាតិ សំដៅកន្លែងដែលកើតបញ្ហាធំខ្លាំង គឺស្ថិតក្នុងរង្វង់ទូទាំងប្រទេស
- លេខ ១ បញ្ហាស្ថិតក្នុងលំដាប់ខ្លាំងក្លាណាស់
- លេខ ២ បញ្ហាស្ថិតក្នុងលំដាប់ខ្លាំងល្មម
- លេខ ៣ បញ្ហាស្ថិតក្នុងលំដាប់មធ្យម
- លេខ ៤ បញ្ហាស្ថិតក្នុងលំដាប់តិច
- លេខ ៥ បញ្ហាស្ថិតក្នុងលំដាប់តិចតួចណាស់
- * ត្រឹមតែជាសន្ទស្សចង្អុលបង្ហាញពីវត្តមាន
- ** សំដៅបញ្ជាក់ពីកិរិតអនុវត្តន៍ការព្រមព្រៀងជូនដំណឹងជាមុននៃអនុសញ្ញា PIC

## ៣.៣ យោបល់ និងការវិភាគ

រហូតមកទល់បច្ចុប្បន្ន ស្ថាប័ននានារបស់កម្ពុជាមិនទាន់មានលទ្ធភាពគ្រប់គ្រាន់ក្នុងការវាយតំលៃ និងការកំណត់អាទិភាពនៃបញ្ហា ដែលទាក់ទងទៅនឹងការគ្រប់គ្រងសារធាតុគីមី រួមមានការផលិត ការធ្វើពាណិជ្ជកម្ម ការទុកដាក់ ការប្រើប្រាស់ និងការបោះបង់ចោល។ មូលហេតុចំបងនៃការខកខានមិនបានពិតតួនេះ គឺបណ្តាលមកពីមិនមានទិសដៅច្បាស់លាស់សំរាប់វាយតំលៃឥទ្ធិពលគ្រោះថ្នាក់នៃការប្រើប្រាស់សារធាតុគីមី គួបផ្សំនឹងការខ្វះនូវសមត្ថភាពជំនាញក្នុងការវាយតំលៃ និងការកំណត់អត្តសញ្ញាណនៃផលប៉ះពាល់ដោយសារធាតុគីមី។

ចំពោះពត៌មាន និងទិន្នន័យសំរាប់ប្រើប្រាស់នៅក្នុងការធ្វើអត្តសញ្ញាណនៃបញ្ហា ក៏ដូចជាការកំណត់ពីអាទិភាពនៃបញ្ហាពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសារធាតុគីមី គឺនៅមានការខ្វះខាតស្ទើរតែទាំងស្រុង។ ដូច្នេះ ដើម្បីងាយស្រួល និងមានភាពច្បាស់លាស់ក្នុងការកំណត់បញ្ហាទាក់ទងនឹងសារធាតុគីមី យន្តការជាតិគ្រប់គ្រងពត៌មាន ទិន្នន័យ និងកំណត់ត្រាដែលពាក់ព័ន្ធនឹងចរាចរ និងការប្រើប្រាស់សារធាតុគីមី គួរត្រូវបានរៀបចំនិងបង្កើតឡើង។

ដោយឡែក ចំពោះបញ្ហាទាក់ទងនឹងសារធាតុគីមី ដែលកើតមាននៅកម្ពុជា គឺពុំបានជះឥទ្ធិពល ឬបង្កការកង្វល់ទៅដល់ប្រទេសជិតខាងទេ ពោលគឺវាបង្កការកង្វល់នៅក្នុងប្រទេសតែប៉ុណ្ណោះ ដោយសារតែកម្ពុជាពុំមែនជាប្រទេសផលិត និងនាំចេញសារធាតុគីមីទេ។ ម៉្យាងវិញទៀត ប្រភពបញ្ចេញឬសាយភាយសារធាតុបំពុល គឺមានទំហំតូចបើធៀបទៅនឹងប្រទេសជិតខាង។

លើសពីនេះទៀត កិច្ចសហការរវាងស្ថាប័នរដ្ឋនិងស្ថាប័នរដ្ឋនៅមានកំរិតនៅឡើយក្នុងការគ្រប់គ្រងបញ្ហាសារធាតុគីមី។ ទាំងនេះគឺដោយសារកម្ពុជាមិននិយមធ្វើអនុស្សារណៈយោគយល់រវាងស្ថាប័ននិងស្ថាប័ន ក្នុងការអនុវត្តរួមគ្នាលើការងារបច្ចេកទេស និងការអនុវត្តច្បាប់ ហើយក្នុងករណីដែលមានការធ្វើអនុស្សារណៈយោគយល់ ក៏ការអនុវត្តអនុស្សារណៈនោះមិនទទួលបានប្រសិទ្ធភាពខ្ពស់។ មូលហេតុចំបងនៃការអនុវត្តមិនបានប្រសិទ្ធភាពខ្ពស់ គឺដោយសារការកំណត់នូវទំហំការងារមិនច្បាស់លាស់ គួបផ្សំនឹងកង្វះខាតនូវធនធានសំរាប់អនុវត្ត។

# ជំពូកទី ៤

# បរិធានច្បាប់ និងយន្តការដែលមិនស្ថិតក្នុងក្របខ័ណ្ឌច្បាប់ សំរាប់គ្រប់គ្រងសារធាតុគីមី

ជំពូកនេះនឹងលើកមកបង្ហាញពីទិដ្ឋភាពរួមនៃបរិធានច្បាប់របស់កម្ពុជាដែលមាន ហើយដែលបញ្ញត្តិនៃច្បាប់ទាំងនោះមានការពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសារធាតុគីមី ។ ជំពូកនេះនឹងបង្ហាញផងដែរពីយន្តការដែលមិនស្ថិតក្នុងក្របខ័ណ្ឌច្បាប់ ហើយដែលមានសកម្មភាពពាក់ព័ន្ធទៅនឹងការធ្វើឱ្យប្រសើរនូវការគ្រប់គ្រងសារធាតុគីមីនៅកម្ពុជា ។ ជាមួយគ្នានេះ ការអនុវត្ត និងនីតិវិធី ឬដំណើរការប្រតិបត្តិបរិធានច្បាប់ទាំងនោះ ក៏ត្រូវបានលើកមកបង្ហាញនៅក្នុងជំពូកនេះផងដែរ ដែលជាមូលដ្ឋានដើម្បីកំណត់ពីភាពខ្លាំង ភាពខ្សោយ និងចំនុចខ្វះចន្លោះនៃបរិធានច្បាប់ ។

ជាទូទៅ សារធាតុគីមីគឺមានច្រើនប្រភេទ ឬក្រុម ហើយវដ្តនៃសារធាតុគីមី គឺវាមានដំណាក់បន្តបន្ទាប់យ៉ាងវែង ដូចជាការផលិត វេចខ្ចប់ ស្តុក ដឹកជញ្ជូន ចែកចាយ ឬលក់ដូរ ប្រើប្រាស់ និងចុងក្រោយគឺកំទេចឬបោះបង់ចោល ។ នេះគឺជាមូលហេតុដែលធ្វើឱ្យការគ្រប់គ្រងសារធាតុគីមីមានការពាក់ព័ន្ធគ្នាពីស្ថាប័នមួយទៅស្ថាប័នមួយ ហើយដែលអាចនិយាយបានថា សំរាប់ការគ្រប់គ្រងសារធាតុគីមីចាំបាច់ត្រូវមានច្បាប់ បទដ្ឋាន ឬស្តង់ដារច្រើន សំរាប់ដោះស្រាយឬគ្រប់គ្រងទៅតាមដំណាក់កាល ឬទៅតាមវិធីផ្សេងគ្នា ។ ហេតុដូចនេះហើយ ទើបច្បាប់ បទដ្ឋាន ឬស្តង់ដារមួយចំនួនអាចមានការពាក់ព័ន្ធគ្នានៅក្នុងទិសដៅជាក់លាក់ដូចគ្នា ឧទាហរណ៍ រវាងច្បាប់ដឹកជញ្ជូន និងច្បាប់ការពារសុខភាពនិងបរិស្ថាន គឺអាចនឹងមានបទបញ្ញត្តិមួយចំនួនដែលនិយាយពីការគ្រប់គ្រងសារធាតុគីមីគ្រោះថ្នាក់ដូចគ្នា តែសកម្មភាពអនុវត្តអាចផ្សេងគ្នា ។

## ៤.១ ទិដ្ឋភាពរួមនៃបរិធានច្បាប់ជាតិដែលទាក់ទងការគ្រប់គ្រងសារធាតុគីមី

ក្រោយការបោះឆ្នោតជាសកលលើកទី ១ ក្នុងឆ្នាំ ១៩៩៣ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកនយោបាយសេដ្ឋកិច្ចទីផ្សារ ហើយចាប់ពីពេលនោះមក ការអភិវឌ្ឍន៍ប្រទេសលើគ្រប់វិស័យមានការកើនឡើង ពិសេសវិស័យពាណិជ្ជកម្ម និងឧស្សាហកម្ម។ ជាលទ្ធផល តំរូវការសារធាតុគីមីសំរាប់បំរើវិស័យកសិកម្ម ឧស្សាហកម្ម និងប្រើប្រាស់ក្នុងលំនៅឋាន គឺមានការកើនឡើងយ៉ាងខ្លាំងក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ ។ យោងទៅតាមស្ថានភាពនៃការអភិវឌ្ឍន៍សង្គម និងដើម្បីធានាឱ្យមានការគ្រប់គ្រងសារធាតុគីមី ដែលមានលក្ខណៈបច្ចេកទេសត្រឹមត្រូវ និងមិនបង្កគ្រោះថ្នាក់ដល់សុខភាពនិងបរិស្ថាន រាជរដ្ឋាភិបាលកម្ពុជាបានខិតខំរៀបចំច្បាប់ ក្រឹត្យច្បាប់ បទបញ្ជា ស្តង់ដារ និងលិខិតបទដ្ឋានមួយចំនួនដែលទាក់ទងទៅនឹងការគ្រប់គ្រងសារធាតុគីមី ។ បរិធានច្បាប់ទាំងនោះបានកំណត់ចេញនូវវិធានការ សំដៅរារាំងភាពគ្រោះថ្នាក់ ឬផលប៉ះពាល់ជាអវិជ្ជមានដែលអាចកើតមាននៅក្នុងដំណើរការផលិត នាំចូល នាំចេញ ដឹកជញ្ជូន ចែកចាយ ប្រើប្រាស់សារធាតុគីមី និងបោះបង់ចោលនូវសំណល់របស់វា ។

ការរៀបចំបរិធានច្បាប់កន្លងមកមានរយៈពេលខ្លីសំរាប់ឆ្លើយតបទៅនឹងតំរូវការ គួបផ្សំនឹងការខ្វះនូវបទពិសោធន៍ទាំងផ្នែកច្បាប់ និងជំនាញគ្រប់គ្រងសារធាតុគីមី គឺជាមូលហេតុធ្វើឱ្យបរិធានច្បាប់ដែលមានស្រាប់នៅកម្ពុជា អាចមានការខ្វះចន្លោះ ឬចែងបទបញ្ញត្តិមិនបានលំអិតសំរាប់ការត្រួតពិនិត្យ ហើយជាលទ្ធផលធ្វើឱ្យមានការលំបាកក្នុងការអនុវត្ត ឬអនុវត្តពុំសូវមានប្រសិទ្ធិភាព ។ ខាងក្រោមនេះ គឺជាបរិធានច្បាប់ដែលកម្ពុជាមាន សំរាប់បញ្ញត្តិឬដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការគ្រប់គ្រងសារធាតុគីមី ដែលមានសង្ខេបបង្ហាញនៅក្នុងតារាង ៤-១ ខាងក្រោម ។

តារាង ៤-១: បរិធានច្បាប់ដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសារធាតុគីមី

| បរិធានច្បាប់ | ស្ថាប័នទទួលខុសត្រូវ | សារធាតុគីមីដែលស្ថិតក្រោមបទបញ្ញត្តិ | គោលបំណងច្បាប់និងបទបញ្ញត្តិ | មាត្រាពាក់ព័ន្ធ | លំដាប់ប្រសិទ្ធភាពអនុវត្តន៍ |
|---|---|---|---|---|---|
| ១. ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (២៤ ខែកញ្ញា ឆ្នាំ១៩៩៣) | រដ្ឋាភិបាល | សារធាតុគីមីជារ៉ែ និងសារធាតុគ្រឿងញៀន | - ការពារទ្រព្យសម្បត្តិរដ្ឋ ធនធានធម្មជាតិ និងបរិស្ថាន<br>- ទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន និងអាជីវកម្មទំនិញក្លែងក្លាយ សំដៅការពារសុខមាលភាពប្រជាពលរដ្ឋ ។ | មាត្រា ៥៩<br>មាត្រា ៦៤ | |
| ២. ក្រឹត្យច្បាប់លេខ ៣៣ ក្រ.ច របស់ក្រុមប្រឹក្សារដ្ឋ ស្តីពី ការគ្រប់គ្រងវិស័យជលផល (៩ ខែមិនា ឆ្នាំ១៩៨៧) | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | វ៉ាសេវ គ្រឿងផ្ទុះ ឬសារធាតុគីមីបំពុលគ្រប់ប្រភេទ | - ការពារធនធានជលផល ដោយធ្វើការហាមឃាត់ការប្រើគីមីពុល វ៉ាសេវ និងគ្រឿងផ្ទុះក្នុងការនេសាទ ។ | មាត្រា ១៧ | |
| ៣. បទបញ្ញត្តិ ស្តីពី ប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនិតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល (១០ ខែកញ្ញា ឆ្នាំ១៩៩២ ) | ក្រសួងយុត្តិធម៌ | សារធាតុគ្រឿងញៀន | - ហាមឃាត់ការផលិត នាំចូល លក់ និងប្រើប្រាស់សារធាតុគ្រឿងញៀន | មាត្រា ៣៩ វាក្យខ័ណ្ឌ ១<br>មាត្រា ៦៥ | |
| ៤. ច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (២៤ ខែធ្នូ ឆ្នាំ១៩៩៦) | ក្រសួងបរិស្ថាន | សារធាតុគីមីពុល និងសំណល់គ្រោះថ្នាក់ | - ការពារគុណភាពបរិស្ថាន<br>- ទប់ស្កាត់ការបំពុលបរិស្ថានតាមរយៈការវាយតំលៃហេតុប៉ះពាល់បរិស្ថានលើគំរោងអភិវឌ្ឍន៍<br>- គ្រប់គ្រងសារធាតុគីមី និងសំណល់គ្រោះថ្នាក់ | មាត្រា ៦ វាក្យខ័ណ្ឌ ១<br>មាត្រា ៨<br>មាត្រា ១២<br>មាត្រា ១៣ | |

| បរិធានច្បាប់ | ស្ថាប័នទទួលខុសត្រូវ | សារធាតុគីមីដែលស្ថិតក្រោមបទបញ្ញត្តិ | គោលបំណងច្បាប់និងបទបញ្ញត្តិ | មាត្រាពាក់ព័ន្ធ | លំដាប់ប្រសិទ្ធភាពអនុវត្តន៍ |
|---|---|---|---|---|---|
| ៥. ច្បាប់ ស្តីពី ការគ្រប់គ្រងឱសថ (២៤ ខែមករា ឆ្នាំ១៩៩៧) | ក្រសួងសុខាភិបាល | សារធាតុគីមីផលិតឱសថ និងផលិតផលឱសថ | - ត្រួតពិនិត្យការផលិត និងធ្វើអាជីវកម្មឱសថ សំដៅការពារសុខភាពអ្នកប្រើប្រាស់ឱ្យជៀសផុតពីឥទ្ធិពលឱសថខូចគុណភាព និងក្លែងបន្លំ | មាត្រា៥<br>មាត្រា៨<br>វាក្យខ័ណ្ឌ១និង២<br>មាត្រា១០ មាត្រា១២ | |
| ៦. ច្បាប់ ស្តីពី ការគ្រប់គ្រងគ្រឿងញៀន (២៤ ខែធ្នូ ឆ្នាំ១៩៩៧) | ក្រសួងមហាផ្ទៃ<br>ក្រសួងសុខាភិបាល | សារធាតុផលិតថ្នាំញៀន | - ហាមឃាត់ការផលិត នាំចូល លក់ និងប្រើប្រាស់គ្រឿងញៀន | មាត្រា៣ មាត្រា៨<br>មាត្រា៩ មាត្រា១២<br>មាត្រា១៣ | |
| ៧. ច្បាប់ ស្តីពី ការគ្រប់គ្រងគុណភាពសុវត្ថិភាពលើផលិតផល ទំនិញ និងសេវា (២១ ខែមិថុនា ឆ្នាំ២០០០) | ក្រសួងពាណិជ្ជកម្ម | រាល់ផលិតផល និងទំនិញ | - ធានាសុខមាលភាពសាធារណៈ ការពារអ្នកប្រើប្រាស់ និងធានាការអនុវត្តក្នុងពាណិជ្ជកម្មផលិតផល និងសេវាកម្ម ពិសេសម្ហូបអាហារ | មាត្រា ៦<br>មាត្រា ៧<br>មាត្រា ២៧ | |
| ៨. អនុក្រឹត្យលេខ ៦៩ ស្តីពី បមាណីយ និងការគ្រប់គ្រង សំភារៈកសិកម្ម (២៨ ខែតុលា ឆ្នាំ១៩៩៨) | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងបរិស្ថាន | ជីគីមី និងថ្នាំកសិកម្ម | - ត្រួតពិនិត្យលើរាល់សកម្មភាពទាក់ទងនឹងជីគីមី និងថ្នាំកសិកម្ម រួមមាន : ការផលិត នាំចូល នាំចេញ ដឹកជញ្ជូន ចែកចាយ លក់ដូរ ស្តុក និងបោះបង់ ឬកំទេចចោល | មាត្រា ៤ - មាត្រា ១៦<br>មាត្រា១៨ - មាត្រា ២៤ | |
| ៩. អនុក្រឹត្យលេខ ៧២ ស្តីពី កិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន (១១ ខែសីហា ឆ្នាំ១៩៩៩) | ក្រសួងបរិស្ថាន | សារធាតុគីមីគ្រប់ប្រភេទ | - កំណត់នូវវិធានការទប់ស្កាត់ការបំពុលបរិស្ថាន និងការប៉ះពាល់ទៅលើសុខភាពសាធារណៈ ដែលពាក់ព័ន្ធទៅនឹងគំរោងអភិវឌ្ឍន៍ | មាត្រា ៣<br>មាត្រា ៤ | |

| បរិធានច្បាប់ | ស្ថាប័នទទួលខុសត្រូវ | សារធាតុគីមី ដែលស្ថិតក្រោមបទបញ្ញត្តិ | គោលបំណងច្បាប់និងបទបញ្ញត្តិ | មាត្រាពាក់ព័ន្ធ | លំដាប់ប្រសិទ្ធភាពអនុវត្តន៍ |
|---|---|---|---|---|---|
| ១០. អនុក្រឹត្យលេខ ៣៦ ស្តីពី ការគ្រប់គ្រងសំណល់រឹង (២៧ ខែមេសា ឆ្នាំ១៩៩៩) | ក្រសួងបរិស្ថាន | សារធាតុគីមី សំណល់សារធាតុគីមី និងសំណល់គ្រោះថ្នាក់ ដែលចែងក្នុងអនុសញ្ញាបាសែល | - ត្រួតពិនិត្យលើសកម្មភាពទាក់ទងការបង្កើត និងបោះបង់ចោលសំណល់រឹង និងសំណល់គ្រោះថ្នាក់ | មាត្រា៣ មាត្រា១៥ មាត្រា១៧ មាត្រា២០ មាត្រា២១ មាត្រា២៤ មាត្រា២៥ មាត្រា២៦ | |
| ១១. អនុក្រឹត្យលេខ ២៧ ស្តីពី ការត្រួតពិនិត្យការបំពុលទឹក (០៦ ខែមេសា ឆ្នាំ១៩៩៩) | ក្រសួងបរិស្ថាន | សារធាតុគីមី សំណល់សារធាតុគីមី និងសំណល់គ្រោះថ្នាក់ | - ត្រួតពិនិត្យលើរាល់សកម្មភាពដែលអាចបង្កឱ្យមានការបំពុលទឹក និងការកំរិតការបញ្ចេញសារធាតុបំពុលទឹក | មាត្រា៦ មាត្រា៨ មាត្រា៩ មាត្រា១០ មាត្រា១១ | |
| ១២. អនុក្រឹត្យលេខ ៤២ ស្តីពី ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង (១០ ខែកក្កដា ឆ្នាំ២០០០) | ក្រសួងបរិស្ថាន | សារធាតុវិទ្យុសកម្ម សារធាតុផ្សេះ និងសារធាតុបំពុលខ្យល់ | - ត្រួតពិនិត្យលើរាល់សកម្មភាពដែលអាចបង្កឱ្យមានការបំពុលខ្យល់ និងការរំខានដោយសំលេង និងធ្វើការកំរិតការបញ្ចេញសារធាតុបំពុលខ្យល់ | មាត្រា៨ មាត្រា១០ មាត្រា១៤ | |
| ១៣. អនុក្រឹត្យលេខ ៤២ ស្តីពី ស្តង់ដារឧស្សាហកម្មកម្ពុជា (១៥ ខែឧសភា ឆ្នាំ២០០១) | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សារធាតុគីមីបំរើផលិតកម្មឧស្សាហកម្ម | - រៀបចំ និងត្រួតពិនិត្យការប្រើប្រាស់ស្តង់ដារផលិតផលឧស្សាហកម្ម<br>- បង្កើនគុណភាពផលិតផលឧស្សាហកម្ម និងសុវត្ថិភាពសាធារណៈ និងលើកទឹកចិត្តអ្នកវិនិយោគ ។ | មាត្រា ៥ | |

## ៤.២ បទបញ្ញត្តិសំខាន់ៗ នៃបរិធានច្បាប់ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសារធាតុគីមី

យោងតាមតារាង ៤-១ ខាងលើ បានបង្ហាញថា កម្ពុជាគឺពុំទាន់មានច្បាប់រួម ស្តីពី ការគ្រប់គ្រងសារធាតុគីមីនៅឡើយទេ។ ចំពោះបរិធានច្បាប់ដែលមាន (ដូចបានរៀបរាប់ខាងលើ) ភាគច្រើនបានចែងពីបទបញ្ញត្តិទាក់ទងទៅនឹងការគ្រប់គ្រងសារធាតុគីមីទៅតាមប្រភេទឬក្រុម ហើយដែលតារាងនៃសារធាតុគីមីទាំងនោះត្រូវបានបង្ហាញនៅក្នុងតារាង ២-៥ តារាង ២-៦ និងតារាង ៤-៤ ។ ចំពោះនិតិវិធី និងបទបញ្ជាដែលទាក់ទងទៅនឹងការគ្រប់គ្រងនិងត្រួតពិនិត្យសារធាតុគីមី ត្រូវបានចែងជាបទបញ្ញត្តិដោយឡែកៗនៃបរិធានច្បាប់ សំរាប់ប្រភេទឬក្រុមនៃសារធាតុគីមី ដូចមានសង្ខេបបង្ហាញនៅក្នុងតារាង ៤-២ ខាងក្រោម :

- <u>ការផ្សព្វផ្សាយបរិធានច្បាប់</u>

ជាទូទៅ ក្រោយទទួលបានការអនុម័ត បរិធានច្បាប់នឹងត្រូវបានប្រកាសឱ្យប្រើប្រាស់ដោយរាជរដ្ឋាភិបាល ឬស្ថាប័នទទួលបន្ទុកអនុវត្ត តាមរយៈសេចក្តីជូនដំណឹង សេចក្តីចំលងជូន និងការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងកាសែត ។ ប៉ុន្តែ នៅក្នុងការអនុវត្តយន្តការនៃការផ្សព្វផ្សាយបែបនេះ មិនបានធ្វើជាប្រចាំនិងមិនបានគ្រប់បរិធានច្បាប់ទេ ហើយការផ្សព្វផ្សាយក៏មិនបានទូលំទូលាយដែរ ភាគច្រើនគឺសំរាប់តែមន្ត្រីដែលពាក់ព័ន្ធក្នុងការអនុវត្តផ្ទាល់តាមរយៈសិក្ខាសាលា និងការប្រជុំបុណ្ណោះ។ ចំណែកឯស្ថាប័នពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធដែលមានផលប្រយោជន៍រួម គឺបានទទួលពត៌មានផ្សព្វផ្សាយនេះតិចតួចតាមរយៈសិក្ខាសាលា ឬការប្រជុំ និងឯកសារចំលងជូន ។

តារាង ៤-២: បទបញ្ញត្តិសំខាន់ៗនៃបរិធានច្បាប់ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសារធាតុគីមី

| នីតិវិធី និងបទបញ្ជា គ្រប់គ្រងនិងត្រួតពិនិត្យ | បទបញ្ញត្តិសំខាន់ៗដែលចែងពីនីតិវិធី និងបទបញ្ជា គ្រប់គ្រងនិងត្រួតពិនិត្យសារធាតុគីមី | សារធាតុគីមីដែលស្ថិតក្រោមបទបញ្ញត្តិ |
|---|---|---|
| *ការចុះបញ្ជី* | **មាត្រា ៤ អនុក្រឹត្យលេខ ៦៩ ស្តីពី បមាណី និងការគ្រប់គ្រងសំភារៈកសិកម្ម** : ជីគីមីគ្រប់ប្រភេទដែលនឹងអាចដាក់លក់នៅព្រះរាជាណាចក្រកម្ពុជា ត្រូវតែមានកិច្ចចុះបញ្ជីការនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទោះបីជីគីមីនោះបានមកពីការនាំចូល ឬការផលិតក្នុងស្រុកក៏ដោយ ។ | ជីគីមីគ្រប់ប្រភេទ តែពុំមានបញ្ជីទេ |
| | **មាត្រា ១២ អនុក្រឹត្យលេខ ៦៩ ស្តីពី បមាណី និងការគ្រប់គ្រងសំភារៈកសិកម្ម** : រូបវន្តបុគ្គល ឬនិតិបុគ្គល ដែលបាននឹងកំពុងឬមានបំណងធ្វើអាជីវកម្មថ្នាំកសិកម្ម ត្រូវចុះបញ្ជីការ និងមានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។ | បញ្ជីថ្នាំកសិកម្មដែលអនុញ្ញាតឱ្យប្រើមានបង្ហាញក្នុងតារាង ២.៥ ជំពូក ២ |
| | **មាត្រា ១៣ អនុក្រឹត្យលេខ ៦៩ ស្តីពី បមាណី និងការគ្រប់គ្រងសំភារៈកសិកម្ម** : ថ្នាំកសិកម្មដែលត្រូវចុះបញ្ជីការនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមាន :<br>១- ថ្នាំកសិកម្មដែលកំពុងត្រូវបានចរាចរលក់ដូរក្នុងទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា តែពុំបានចែងក្នុងប្រកាសអនុញ្ញាតឱ្យប្រើប្រាស់ជាបណ្តោះអាសន្នរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។<br>២- ថ្នាំកសិកម្មដែលមានចែងក្នុងបញ្ជីអនុញ្ញាតឱ្យប្រើប្រាស់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។<br>៣- ថ្នាំកសិកម្មថ្មី ដែលមិនស្ថិតក្នុងចំណាត់ថ្នាក់ទី១ អនុលោមតាមចំណាត់ថ្នាក់អង្គការ WHO ។<br>៤- ថ្នាំកសិកម្មដែលបានធ្វើការចុះបញ្ជីការរួច តែបានប្តូររូបមន្ត ឬឈ្មោះពាណិជ្ជកម្ម ។ | បញ្ជីថ្នាំកសិកម្មដែលអនុញ្ញាតឱ្យប្រើមានបង្ហាញក្នុងតារាង ២.៥ ជំពូក ២ |
| *ការសុំលិខិតអនុញ្ញាត* | **មាត្រា ៨ ច្បាប់ ស្តីពី ការគ្រប់គ្រងឱសថ** :<br>១. ត្រូវមានការអនុញ្ញាតពីក្រសួងសុខាភិបាលចំពោះ :<br>• ការបើក បិទ ឬប្តូរទីតាំងគ្រឹះស្ថានលក់ឱសថ គ្រឹះស្ថានអាហារ័ណ នីហារ័ណ ឱសថ និងគ្រឹះស្ថានផលិតឱសថ ។<br>• ការធ្វើអាជីវកម្ម អាហារ័ណ នីហារ័ណកម្មឱសថ ។<br>• ការនាំចូល នាំចេញ ស្តុកឱសថ និងវត្ថុធាតុដើមសម្រាប់ផលិតឱសថ ។<br>២. ........................................................... | ផលិតផលគីមីសំរាប់ផលិតឱសថ និងផលិតផលឱសថគ្រប់ប្រភេទ តែពុំមានជាបញ្ជីទេ |

| នីតិវិធី និងបទបញ្ជា គ្រប់គ្រងនិងត្រួតពិនិត្យ | បទបញ្ញត្តិសំខាន់ៗដែលចែងពីនីតិវិធី និងបទបញ្ជា គ្រប់គ្រងនិងត្រួតពិនិត្យសារធាតុគីមី | សារធាតុគីមីដែលស្ថិតក្រោមបទបញ្ញត្តិ |
|---|---|---|
| | មាត្រា ៦ ច្បាប់ ស្តីពី ការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងសេវាកម្ម : រាល់ផលិតផលទំនិញ ឬសេវាកម្មទាំងឡាយដែលអាចប៉ះពាល់ដល់សុវត្ថិភាព ឬសុខភាពនៃអ្នកប្រើផលិតកម្ម ឬពាណិជ្ជកម្មនៃផលិតផលទំនិញ និង សេវាកម្មទាំងនោះ តម្រូវឱ្យមានការធ្វើប្រតិវេទន៍ជាមុន ជូនដល់ស្ថាប័នមានសមត្ថកិច្ច និងមានការអនុញ្ញាតជាមុនពីស្ថាប័នមានសមត្ថកិច្ចក្រោយពីមានការពិនិត្យរួច ព្រមទាំងមានបញ្ជាក់បង្ហាញអំពីវិធីប្រើជាភាសាខ្មែរ ។ | ផលិតផលទំនិញគ្រប់ប្រភេទ តែពុំមានជាបញ្ជីឈ្មោះទេ |
| | មាត្រា ៩ អនុក្រឹត្យលេខ ៦៩ ស្តីពី បមាណី និងការគ្រប់គ្រងសំភារៈកសិកម្ម : រូបវន្តបុគ្គល ឬនិតិបុគ្គល ឬក្រុមហ៊ុនណាដែលមានបំណងផលិត ឬនាំចូល ឬនាំចេញជីគីមី ត្រូវមានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ | ជីគីមីគ្រប់ប្រភេទ តែពុំមានបញ្ជីទេ |
| | មាត្រា ១០ អនុក្រឹត្យលេខ ៦៩ ស្តីពី បមាណី និងការគ្រប់គ្រងសំភារៈកសិកម្ម : ការលក់ដូរជីគីមីក្រៅយថាប្រភេទ ឬជីគីមីអន់គុណភាព ត្រូវមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងត្រូវអនុវត្តតាមការណែនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អំពីការធ្វើអាជីវកម្មជីគីមីទាំងនោះ ។ | ជីគីមីគ្រប់ប្រភេទ តែពុំមានបញ្ជីទេ |
| | មាត្រា ២០ អនុក្រឹត្យលេខ ៦៩ ស្តីពី បមាណី និងការគ្រប់គ្រងសំភារៈកសិកម្ម : ការវេចខ្ចប់ថ្មីនូវថ្នាំកសិកម្មត្រូវហាមឃាត់ ។ ការវេចខ្ចប់ថ្មីអាចប្រព្រឹត្តទៅបានលុះត្រាតែមានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ការច្រក ឬរំលែក ថ្នាំកសិកម្មណាមួយទៅក្នុងដប ឬថង់ ឬសំភារៈវេចខ្ចប់ចំណីអាហារ ឬភេសជ្ជៈ ត្រូវហាមឃាត់ជាដាច់ខាត ។ | |
| | មាត្រា ២២ អនុក្រឹត្យលេខ ៦៩ ស្តីពី បមាណី និងការគ្រប់គ្រងសំភារៈកសិកម្ម : របៀប និងល័ក្ខខ័ណ្ឌទុកដាក់ថ្នាំកសិកម្ម ត្រូវកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ទីតាំងឃ្លាំងទុកដាក់ថ្នាំកសិកម្ម ត្រូវមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានការឯកភាពពីក្រសួងបរិស្ថាន។ | |
| | មាត្រា ២៣ អនុក្រឹត្យលេខ ៦៩ ស្តីពី បមាណី និងការគ្រប់គ្រងសំភារៈកសិកម្ម : រាល់ការបោះចោល ការបំផ្លាញចោលនូវសំណល់ ឬសំភារៈវេចខ្ចប់ថ្នាំកសិកម្មរបស់អាជីវករ ត្រូវមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានការឯកភាពពីក្រសួងបរិស្ថាន ។ | |
| | មាត្រា ២៤ អនុក្រឹត្យលេខ ៦៩ ស្តីពី បមាណី និងការគ្រប់គ្រងសំភារៈកសិកម្ម : រាល់ការផ្សព្វផ្សាយថ្នាំកសិកម្មទោះតាមមធ្យោបាយណាក៏ដោយ ត្រូវមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ អាចអនុញ្ញាតឱ្យធ្វើការផ្សាយពាណិជ្ជកម្មបានចំពោះតែថ្នាំកសិកម្មណាដែលបានចុះបញ្ជីការពេញលេញរួចហើយ ។ | បញ្ជីថ្នាំកសិកម្មដែលអនុញ្ញាតឱ្យប្រើមានបង្ហាញក្នុងតារាង ២.៥ ជំពូក ២ |

| និតិវិធី និងបទបញ្ញា គ្រប់គ្រងនិងត្រួតពិនិត្យ | បទបញ្ញត្តិសំខាន់ៗដែលចែងពីនិតិវិធី និងបទបញ្ញា គ្រប់គ្រងនិងត្រួតពិនិត្យសារធាតុគីមី | សារធាតុគីមីដែលស្ថិតក្រោមបទបញ្ញត្តិ |
|---|---|---|
| | មាត្រា ២០ អនុក្រឹត្យលេខ ៣៧ ស្តីពី ការគ្រប់គ្រងសំណល់រឹង : ការនាំចេញនូវសំណល់ប្រកបដោយគ្រោះថ្នាក់ពីព្រះរាជាណាចក្រកម្ពុជាទៅកាន់ប្រទេសក្រៅអាចនឹងប្រព្រឹត្តទៅបាន លុះត្រាណាមានការឯកភាពពីក្រសួងបរិស្ថាន និងមានអាជ្ញាប័ណ្ណនាំចេញរបស់ក្រសួងពាណិជ្ជកម្ម ព្រមទាំងលិខិតអនុញ្ញាតឱ្យនាំចូលរបស់សាមីប្រទេសជាមុនសិន ។ ការនាំចេញសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវអនុលោមតាមបទបញ្ញត្តិ និងគោលការណ៍នៃអនុសញ្ញាអន្តរជាតិបាសែល ស្តីពីការត្រួតពិនិត្យការដឹកជញ្ជូនអន្តរជាតិ និងការបោះបង់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ឆ្នាំ ១៩៨៩ ដែលចូលជាធរមាននៅថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ១៩៩២ ។ | បញ្ជីសំណល់គ្រោះថ្នាក់ គឺយោងទាំងស្រុងលើឧបសម្ព័ន្ធនៃអនុសញ្ញាបាសែល |
| | មាត្រា ១០ អនុក្រឹត្យលេខ ២៧ ស្តីពី ការត្រួតពិនិត្យការបំពុលទឹក : ការបញ្ចេញចោល ឬការដឹកចេញនូវសំណល់រាវពីប្រភពបំពុលទៅកន្លែងដទៃក្នុងគោលបំណងណាមួយ ត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថានជាមុនសិន និងត្រូវធ្វើសេចក្តីចំលងនៃពាក្យសុំនោះទៅក្រសួង និងស្ថាប័នពាក់ព័ន្ធ ។ | |
| | មាត្រា ១៤ អនុក្រឹត្យលេខ ៤២ ស្តីពី ការត្រួត ពិនិត្យការបំពុលខ្យល់ និងការរំខាន ដោយសំលេង : ការសុំអនុញ្ញាតនាំចូលនូវសារធាតុនេះត្រូវមានភ្ជាប់នូវលទ្ធផលវិភាគដែលបញ្ជាក់ពីបរិមាណជាតិស្ពាន់ធ័រ សំណ បង់សែន និងអ៊ីដ្រូកាប៊ូប្រហើរពីប្រភពដើមនៃការនាំចូល ឬការផលិត ។ | ស្ពាន់ធ័រ សំណ បង់សែន និងសារធាតុអ៊ីដ្រូកាប៊ូប្រហើរ |
| *ការបិទស្លាកសញ្ញា* | មាត្រា ៨ អនុក្រឹត្យលេខ ៦៩ ស្តីពី បមាណី និងការគ្រប់គ្រងសំភារៈកសិកម្ម : គ្រប់សំភារៈវេចខ្ចប់ជីគីមីទាំងអស់ត្រូវមានស្លាកសញ្ញាដើម្បីផ្តល់ពត៌មានគ្រប់គ្រាន់ និងច្បាស់លាស់ដល់អ្នកប្រើប្រាស់ជាភាសាខ្មែរ ស្របតាមការណែនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ | ជីគីមីគ្រប់ប្រភេទ តែពុំមានបញ្ជីទេ |
| | មាត្រា ១៨ អនុក្រឹត្យលេខ ៦៩ ស្តីពី បមាណី និងការគ្រប់គ្រងសំភារៈកសិកម្ម : គ្រប់សំភារៈវេចខ្ចប់ថ្នាំកសិកម្មដែលនឹងនាំចូល ស្តុកទុក លក់ដុំ និងលក់រាយ ត្រូវមានស្លាកសញ្ញាជាភាសាខ្មែរដែលងាយយល់ ។ ទំរង់និងលក្ខណៈនៃផ្លាកសញ្ញាត្រូវកំណត់ដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ | បញ្ជីថ្នាំកសិកម្មដែលអនុញ្ញាតឱ្យប្រើ មានបង្ហាញក្នុងតារាង ២.៥ ជំពូក ២ |
| *ការធ្វើសារពើភ័ណ្ឌ* | មាត្រា ១២ ច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ : ក្រសួងបរិស្ថានត្រូវសហការជាមួយក្រសួងពាក់ព័ន្ធដើម្បីចងក្រងបញ្ជីសារពើភ័ណ្ឌដែលបញ្ជាក់ពី :<br>- ប្រភព ប្រភេទ និងបរិមាណនៃសារធាតុបំពុលនិងសំណល់ដែលបាននាំចូល បង្កើតឡើង ដឹកជញ្ជូន កែឆ្នៃឡើងវិញ បានប្រព្រឹត្តកម្ម រក្សាទុក បោះបង់ចោល ឬបញ្ចេញចោលទៅក្នុងអាកាស ទឹក ដី ឬលើដី ។ | សារធាតុបំពុល សំណល់ សារធាតុពុល និងសារធាតុគ្រោះថ្នាក់ទូទៅ ដោយពុំមានបញ្ជីឈ្មោះ ឬប្រភេទ |

| និតិវិធី និងបទបញ្ជា គ្រប់គ្រងនិងត្រួតពិនិត្យ | បទបញ្ញត្តិសំខាន់ៗដែលចែងពីនិតិវិធី និងបទបញ្ជា គ្រប់គ្រងនិងត្រួតពិនិត្យសារធាតុគីមី | សារធាតុគីមីដែលស្ថិតក្រោមបទបញ្ញត្តិ |
| --- | --- | --- |
| | - ប្រភព ប្រភេទ និងបរិមាណនៃសារធាតុពុលនិងសារធាតុប្រកបដោយគ្រោះថ្នាក់ដែលបាននាំចូល ផលិត ដឹកជញ្ជូន រក្សាទុក ប្រើប្រាស់ បង្កើតឡើង បានប្រព្រឹត្តកម្មកែឆ្នៃឡើងវិញ បោះបង់ចោលឬដែលបានបញ្ចេញទៅក្នុងអាកាស ទឹក ឬទៅក្នុងដី ឬលើដី។<br>- ប្រភព ប្រភេទ និងទំហំនៃការរំខានដោយសម្លេង និងរំញ័រ ។ | |
| *ការហាមឃាត់* | **មាត្រា ១៧ ក្រឹត្យច្បាប់លេខ ៣៣ ស្តីពី ការគ្រប់គ្រងវិស័យជលផល :** ត្រូវហាមឃាត់ជាដាច់ខាត ចំពោះការធ្វើនេសាទគ្រប់ប្រភេទក្នុងដែននេសាទទឹកសាបដោយប្រើឧបករណ៍ហាមឃាត់ដូចខាងក្រោមនេះ :<br>ក. ខ្សែភ្លើងឆក់ វិសេវ គ្រឿងផ្ទុះ ឬថ្នាំបំពុលគ្រប់ប្រភេទ<br>ខ. .................................... | ថ្នាំបំពុលគ្រប់ប្រភេទ តែពុំមានបញ្ជីប្រភេទថ្នាំ |
| | **មាត្រា ២១ អនុក្រឹត្យលេខ ៣៦ ស្តីពី ការគ្រប់គ្រងសំណល់រឹង :** ហាមឃាត់ជាដាច់ខាតការនាំចូលសំណល់ប្រកបដោយគ្រោះថ្នាក់ពីប្រទេសក្រៅចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ។ | បញ្ជីសំណល់គ្រោះថ្នាក់ គឺយោងលើ ឧបសម្ព័ន្ធនៃអនុសញ្ញា បាសែល |
| | **មាត្រា ៦ អនុក្រឹត្យលេខ ២៧ ស្តីពី ការត្រួតពិនិត្យការបំពុលទឹក :** ហាមឃាត់ជាដាច់ខាតនូវរាល់ការចាក់ចោល ឬការបង្ហូរសំណល់រាវពីប្រភពបំពុលណាមួយដែលមិនអនុវត្តតាមកំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវ ដូចមានចែងក្នុងមាត្រា៤ និង មាត្រា៥ នៃអនុក្រឹត្យនេះ ។ | |
| | **មាត្រា ៨ អនុក្រឹត្យលេខ ២៧ ស្តីពី ការត្រួតពិនិត្យការបំពុលទឹក :** ហាមឃាត់ជាដាច់ខាតនូវរាល់ការចាក់សំរាម សំណល់រឹង ឬសារធាតុប្រកបដោយគ្រោះថ្នាក់ ទៅក្នុងតំបន់ទឹកសាធារណៈ ឬប្រព័ន្ធលូសាធារណៈ ។ ហាមឃាត់ជាដាច់ខាតនូវការទុកដាក់ ឬការចាក់ចោលសំរាម សំណល់រឹងឬ សារធាតុប្រកបដោយគ្រោះថ្នាក់ដែលនាំឱ្យមានការបំពុលទឹកតំបន់ទឹកសាធារណៈ។ | |
| | **មាត្រា ៨ អនុក្រឹត្យលេខ ៤២ ស្តីពី ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខាន ដោយសំលេង :** ហាមឃាត់ដាច់ខាតនូវការបញ្ចេញសារធាតុបំពុលទៅក្នុងបរិយាកាសដែលមិនឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៣ និង ៤ ។ | |
| | **មាត្រា ១០ អនុក្រឹត្យលេខ ៤២ ស្តីពី ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខាន ដោយសំលេង :** ការនាំចូល និងផលិតនូវសារធាតុនេះដែលមានជាតិស្ពាន់ធ័រ សំណ បង់សែន និងសារធាតុអ៊ីដ្រូកាប៊ូប្រហើរ ត្រូវឆ្លើយតបទៅនឹងការកំរិតកំណត់ស្តង់ដារ ដូចមានចែងនៅក្នុងតារាង ឧបសម្ព័ន្ធ ៨ ។ | ស្ពាន់ធ័រ សំណ បង់សែន និង សារធាតុអ៊ីដ្រូកាបូប្រហើរ |

| និតិវិធី និងបទបញ្ជា គ្រប់គ្រងនិងត្រួតពិនិត្យ | បទបញ្ញត្តិសំខាន់ៗដែលចែងពីនិតិវិធី និងបទបញ្ជា គ្រប់គ្រងនិងត្រួតពិនិត្យសារធាតុគីមី | សារធាតុគីមីដែលស្ថិតក្រោមបទបញ្ញត្តិ |
|---|---|---|
| *ការផ្តន្ទាទោសចំពោះការមិនអនុវត្ត* | **មាត្រា ៦៤ នៃរដ្ឋធម្មនុញ្ញ :** រដ្ឋហាមឃាត់ និងផ្តន្ទាទោសជាទម្ងន់ដល់ជនណាដែលនាំចូល ផលិត លក់ដូរ គ្រឿងញៀន ទំនិញ ក្លែងក្លាយ ហួសរយៈពេលប្រើដែលប៉ះពាល់ដល់សុខភាព អាយុជីវិតរបស់អ្នកប្រើប្រាស់ ។ | គ្រឿងញៀនទូទៅ តែមិនមានបញ្ជីឈ្មោះ |
| | **មាត្រា ១២ ច្បាប់ ស្តីពី ការគ្រប់គ្រងឱសថ :** ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០រៀល ( ម្ភៃលានរៀល ) ដល់ ៥០.០០០.០០០រៀល ( ហាសិបលានរៀល ) ឬផ្តន្ទាទោសដាក់ពន្ធនាគារពី ០៥ឆ្នាំ ដល់ ១០ឆ្នាំ ឬទោសទាំងពីរនេះ ចំពោះជនណាដែលបានធ្វើផលិតកម្មអាហារ៉ណ នីហរ៉ណ និងពាណិជ្ជកម្មដោយចេតនាឱសថមានសារជាតិញៀន ដោយគ្មានការអនុញ្ញាត ឱសថក្លែងក្លាយ ឱសថគ្មានគុណភាព ឱសថហួសរយៈពេលប្រើប្រាស់ដែលប៉ះពាល់ដល់សុខភាព អាយុជីវិតរបស់អ្នកប្រើប្រាស់ ។ | ផលិតផលឱសថទូទៅ |
| | **មាត្រា ៣៥ អនុក្រឹត្យលេខ ៦៩ ស្តីពី បមាណី និងការគ្រប់គ្រងសំភារៈកសិកម្ម :** ត្រូវផ្តន្ទាទោសពិន័យរដ្ឋបាលដូចខាងក្រោមនេះ :<br>១- ព្រមានជាលាយល័ក្ខអក្សរ និងឃាត់ទុកវត្ថុល្មើសជាបណ្តោះអាសន្ន រួចរៀបចំសំណុំរឿងបញ្ជូនទៅតុលាការ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានធ្វើអាជីវកម្មសំភារៈកសិកម្មដែលពុំបានចុះបញ្ជីការដូចមានចែងក្នុងមាត្រា ៤ មាត្រា ១១ មាត្រា ១២ និងមាត្រា ៣១ ។<br>២- ព្រមានជាលាយល័ក្ខអក្សរ និងបង្ខំឱ្យធ្វើកិច្ចសន្យាកែតម្រូវក្នុងរយៈពេល ៧ ថ្ងៃ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានធ្វើអាជីវកម្មសំភារៈកសិកម្មដោយពុំមានលិខិតអនុញ្ញាតធ្វើអាជីវកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចមានចែងក្នុងមាត្រា ៥ មាត្រា ៧ មាត្រា ១៣ និងមាត្រា ២១ ។ ឃាត់ទុកវត្ថុតាងជាបណ្តោះអាសន្ន រួចរៀបចំសំណុំរឿងបញ្ជូនទៅតុលាការក្នុងករណីប្រព្រឹត្តល្មើសលើកទី ២ ។<br>៣- ព្រមានជាលាយល័ក្ខអក្សរ និងឃាត់ទុកវត្ថុល្មើសជាបណ្តោះអាសន្ន រួចរៀបចំសំណុំរឿងបញ្ជូនទៅតុលាការ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលណាដែលធ្វើអាជីវកម្មសំភារៈកសិកម្ម ក្លែងបន្លំ ឬខូចគុណភាព ឬខុសពីការធានាគុណភាពដែលបានចុះបញ្ជីការ ដូចមានចែងក្នុងមាត្រា ៦ មាត្រា ៩ មាត្រា ២២ មាត្រា ២៩ មាត្រា ៣២ និងមាត្រា ៣៤ ។ ដកហូតលិខិតអនុញ្ញាតធ្វើអាជីវកម្មជាស្ថាពរក្នុងករណីប្រព្រឹត្តល្មើសលើកទី ២ ។<br>៤- ព្រមានជាលាយល័ក្ខអក្សរ ហើយបង្ខំឱ្យធ្វើកិច្ចសន្យាកែតម្រូវក្នុងរយៈពេល ១៥ ថ្ងៃ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើអាជីវកម្មសំភារៈកសិកម្មដោយបំពានលើបមាណីយ នៃការវេចខ្ចប់ដូចមានចែងក្នុងមាត្រា ៨ មាត្រា ១៩ មាត្រា ២០ មាត្រា ២៩ និងមាត្រា ៣៣ ។ ដកហូតលិខិតអនុញ្ញាតធ្វើអាជីវកម្មជាបណ្តោះអាសន្នក្នុងករណីប្រព្រឹត្តល្មើសលើកទី ២ ។ | សំភារៈកសិកម្មទូទៅ |

| និតិវិធី និងមធ្យោបាយ គ្រប់គ្រងនិងត្រួតពិនិត្យ | បទបញ្ញត្តិសំខាន់ៗដែលចែងពីនិតិវិធី និងមធ្យោបាយ គ្រប់គ្រងនិងត្រួតពិនិត្យសារធាតុគីមី | សារធាតុគីមីដែលស្ថិតក្រោមបទបញ្ញត្តិ |
|---|---|---|
| | ៥- ព្រមានជាលាយល័ក្ខអក្សរ ហើយបង្ខំឱ្យធ្វើកិច្ចសន្យាកែតម្រូវក្នុងរយៈពេល ៧ ថ្ងៃ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានធ្វើអាជីវកម្មថ្នាំកសិកម្មដោយមិនធានាសុវត្ថិភាពក្នុងការទុកដាក់ បោះចោលកាកសំណល់ ឬសំភារៈវេចខ្ចប់ ឬផ្សព្វផ្សាយថ្នាំកសិកម្មដោយពុំមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចមានចែងក្នុងមាត្រា ២៣ មាត្រា ២៤ និងមាត្រា ២៥ ។ ដកហូតលិខិតអនុញ្ញាតធ្វើអាជីវកម្មជាបណ្តោះអាសន្នក្នុងករណីប្រព្រឹត្តល្មើសលើកទី ២ ។<br>៦- ព្រមានជាលាយល័ក្ខអក្សរ ហើយបង្ខំឱ្យធ្វើកិច្ចសន្យាកែតម្រូវក្នុងរយៈពេល ៧ ថ្ងៃ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលបាននាំចូល ឬផលិតគ្រាប់ពូជមានវិញ្ញាបនប័ត្រ ឬបំរែកពូជដំណាំ ដោយពុំមានការអនុញ្ញាត ឬចុះបញ្ជីការនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចមានចែងក្នុងមាត្រា ២៧ និងមាត្រា ២៨ ។<br>ការផ្តន្ទាទោសពិន័យរដ្ឋបាល តាមការកំណត់ខាងលើនេះ ជាសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ | |

## ៤.៣ បទបញ្ញត្តិនៃបរិធានច្បាប់លើវដ្តនៃសារធាតុគីមី

បរិធានច្បាប់ដែលមានស្រាប់ដូចបានរៀបរាប់នៅក្នុងតារាង ៤-១ ខាងលើ គឺបានដោះស្រាយសំរាប់ដំណាក់កាល ឬវដ្តនៃសារធាតុគីមី ដែលគិតចាប់ពីការផលិត នាំចូល រក្សាទុក ដឹកជញ្ជូន ចែកចាយ ប្រើប្រាស់ និងបោះបង់ចោល ។ អនុលោមទៅតាមក្របខ័ណ្ឌច្បាប់ដែលមានស្រាប់ គឺបានឆ្លុះបញ្ចាំងឱ្យឃើញពីវិសាលភាពនៃបទបញ្ញត្តិច្បាប់ទាំងនោះ ដែលបានគ្របដណ្តប់លើរាល់សកម្មភាពទាក់ទងនឹងសារធាតុគីមី ឬវដ្តនៃសារធាតុគីមី ដូចមានបង្ហាញក្នុងតារាង ៤-៣ ខាងក្រោម ។

តារាង ៤-៣: បរិធានច្បាប់សំរាប់គ្រប់គ្រងសារធាតុគីមី តាមប្រភេទនៃការប្រើប្រាស់

| ចំណាត់ថ្នាក់សារធាតុគីមី | ដំណាក់កាល ឬវដ្តនៃសារធាតុគីមី ដែលស្ថិតក្រោមបទបញ្ញត្តិច្បាប់ | | | | | | |
|---|---|---|---|---|---|---|---|
| | នាំចូល | ផលិតផល | រក្សាទុក | ដឹកជញ្ជូន | ចែកចាយ | ប្រើប្រាស់ | បោះចោល |
| ថ្នាំសំលាប់សត្វល្អិត (សំរាប់វិស័យកសិកម្ម និងសំរាប់ការពារសុខភាពសាធារណ:) | x | x | x | x | x | x | x |
| ជីគីមី | x | x | x | x | x | x | x |
| សារធាតុគីមីឧស្សាហកម្ម | x | x | x | | | x | x |
| ផលិតផលប្រេងឥន្ធន: (តេល:សិលា) | x | | x | x | x | | |
| សារធាតុគីមីប្រើតាមលំនៅដ្ឋាន | x | x | | | | | |
| សំណល់គីមី | x | x | x | x | x | x | x |

## ៤.៤ ដំណោះស្រាយ និងនីតិវិធីក្នុងការគ្រប់គ្រងសារធាតុគីមី

នីតិវិធីនៃការគ្រប់គ្រងសារធាតុគីមីត្រូវបានបែងចែកជាបួនផ្នែកសំខាន់ៗ គឺ: នីតិវិធីនៃការនាំចូលសារធាតុគីមី នីតិវិធីនៃការធ្វើអាជីវកម្មជីគីមី និងថ្នាំកសិកម្ម នីតិវិធីហាមឃាត់មិនឱ្យប្រើប្រាស់សារធាតុគីមី និងនីតិវិធីប្រើប្រាស់ស្ថិតក្រោមការដាក់កំរិតតឹងតែង។ នីតិវិធីទាំងនេះ ត្រូវបានកំណត់ដោយច្បាប់/សេចក្តីប្រកាស សំដៅធានាគ្រប់គ្រងសារធាតុគីមីប្រកបដោយប្រសិទ្ធិភាព និងមិនបង្កឱ្យមានផលប៉ះពាល់ដល់សុខភាពសាធារណ: និងសុវត្ថិភាពបរិស្ថាន។ សេចក្តីបរិយាយពីនីតិវិធីនិមួយៗមានដូចតទៅ:

### ៤.៤.១ នីតិវិធីនៃការនាំចូលសារធាតុគីមី (លិខិតប្រតិវេទនៃការនាំចូលទាក់ទងទៅនឹងបញ្ហាគុណភាពនិងសុវត្ថិភាព)

ក្នុងការនាំចូលសារធាតុគីមី និងផលិតផលគ្រប់គ្រងដោយបញ្ញត្តិបច្ចេកទេសផ្សេងទៀត បែបបទត្រួតពិនិត្យគយជាសកលត្រូវបំពេញបន្ថែមទៀតដោយការត្រួតពិនិត្យភាពសមស្រប ពាក់ព័ន្ធនឹងគុណភាពនិងសុវត្ថិភាពផលិតផល ដែលធ្វើឡើងដោយស្ថាប័នទទួលបន្ទុកដោយឡែក គឺនាយកដ្ឋានកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម (ក្នុងពេលបច្ចុប្បន្ន) ។ ការត្រួតពិនិត្យបន្ថែមដោយស្ថាប័នចុងក្រោយនេះ ត្រូវបានអនុវត្តន៍តាមបែបបទដូចខាងក្រោម :

### ៤.៤.១.១ ការត្រួតពិនិត្យឯកសារនាំចូល

និតិវិធីនេះ គឺសំដៅលើការត្រួតពិនិត្យឯកសារសុំនាំចូលទំនិញ ដែលអ្នកនាំចូលត្រូវដាក់ពាក្យសុំការអនុញ្ញាតិនាំចូលទៅអាជ្ញាធរមានសមត្ថកិច្ចត្រួតពិនិត្យ ដើម្បីសុំការអនុញ្ញាតិនាំទំនិញឆ្លងកាត់ច្រកព្រំដែន ។ ពាក្យសុំអនុញ្ញាតនាំចូលសារធាតុគីមីឆ្លងកាត់ព្រំដែននិងឯកសារនានាដែលពាក់ព័ន្ធ ត្រូវផ្តល់ជូនសមត្ថកិច្ចត្រួតពិនិត្យយ៉ាងហោចណាស់ ១ សប្តាហ៍មុនពេលទំនិញត្រូវបានដឹកជញ្ជូនដល់ព្រំដែន ។ ឯកសារពាក់ព័ន្ធដែលអ្នកនាំចូលត្រូវផ្តល់ជូនសមត្ថកិច្ចត្រួតពិនិត្យ រួមមាន :

- វិញ្ញាបនប័ត្របញ្ជាក់គុណភាពយថាប្រភេទ ដែលផ្តល់ឱ្យដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសសាមីនាំចេញ ។
- អាជ្ញាប័ណ្ណនាំចេញ ។
- លិខិតអនុញ្ញាតនាំចូល ដែលចេញឱ្យដោយស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធចំពោះមុខទំនិញដែលស្ថិតក្រោមបញ្ញត្តិច្បាប់ ។
- ប័ណ្ណបញ្ជាក់សុវត្ថិភាពសារធាតុគីមីដែលត្រូវនាំចូល ។
- លិខិតផ្ទុកទំនិញ (នាវា ឬយន្តហោះ) ។
- វិក័យប័ត្រមុខទំនិញ ។
- បញ្ជីវេចខ្ចប់ទំនិញ
- លិខិតប្រកាសគោលបំណងសំរាប់ការប្រើប្រាស់នៅកម្ពុជា ។

ក្រោយពីបានទទួលពាក្យសុំការអនុញ្ញាតនាំចូល អាជ្ញាធរមានសមត្ថកិច្ចនឹងធ្វើការពិនិត្យលើឯកសារនាំចូល និងពិនិត្យលើប្រវត្តិក្រុមហ៊ុននាំចូល និងឈ្មោះនៃសារធាតុគីមី ឬផលិតផលដែលត្រូវនាំចូល ដោយផ្ទៀងផ្ទាត់ទៅនឹងស្តង់ដារឬបទបញ្ញត្តិបច្ចេកទេសជាតិ និងអន្តរជាតិ ។

### ៤.៤.១.២ ការត្រួតពិនិត្យសារធាតុគីមីនៅចំនុចត្រួតពិនិត្យព្រំដែន

នៅពេលបានទទួលអាជ្ញាប័ណ្ណនាំចូល ក្រុមហ៊ុនឬសេវាដឹកជញ្ជូនត្រូវយកឯកសារពាក់ព័ន្ធនឹងការនាំចូលទំនិញ អមជាមួយនឹងទំនិញ ដើម្បីឱ្យអាជ្ញាធរមានសមត្ថកិច្ចនៅតាមច្រកទ្វារព្រំដែនធ្វើការត្រួតពិនិត្យទំនិញ ។ ការត្រួតពិនិត្យទំនិញមុននឹងអនុញ្ញាតឱ្យនាំចូល គឺមានគោលបំណងធ្វើការត្រួតពិនិត្យលើទិដ្ឋភាពខាងក្រៅ រួមមានការត្រួតពិនិត្យលើឯកសារដែលបានផ្តល់ដោយក្រុមហ៊ុនស្នើសុំនាំចូលដោយផ្ទៀងផ្ទាត់នឹងច្បាប់ និងសេចក្តីតំរូវនានា ព្រមទាំងធ្វើការត្រួតពិនិត្យលើស្លាកសញ្ញាផលិតផល សំបកវេចខ្ចប់ លក្ខណៈរូបនៃសារធាតុដែលវេចខ្ចប់។

ក្នុងករណីខ្លះ ការនាំចូលទំនិញត្រូវបានអនុញ្ញាតដោយមានល័ក្ខខ័ណ្ឌដូចខាងក្រោម :

- ធ្វើការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពផលិតផលគីមី ដោយការយកសំណាកទៅវិភាគដើម្បីផ្ទៀងផ្ទាត់បញ្ញត្តិជាតិ និងអន្តរជាតិ ក្រោយពេលទំនិញអនុញ្ញាតឱ្យនាំចូលនិងស្តុក ។
- ការវិភាគពីគុណភាពនិងសុវត្ថិភាពផលិតផលគីមី អាចធ្វើទាំងនៅក្នុងប្រទេស ឬក្រៅប្រទេសទៅតាមលទ្ធភាព។
- នឹងត្រូវបញ្ជូនផលិតផលសារធាតុគីមីត្រឡប់ទៅប្រទេសដើមវិញ ក្នុងករណីដែលលទ្ធផលវិភាគនៃមន្ទីរពិសោធន៍បង្ហាញថា គុណភាពនិងសុវត្ថិភាពផលិតផលសារធាតុគីមីនោះ មិនឆ្លើយតបទៅនឹងបទបញ្ញត្តិជាតិ និងអន្តរជាតិ ។

- និងត្រូវផ្តល់សិទ្ធិនាំចូលស្របច្បាប់ដល់អ្នកនាំចូល ក្នុងករណីដែលគុណភាពនិងសុវត្ថិភាពសារធាតុគីមីនោះ ឆ្លើយតបទៅនឹងសេចក្តីតំរូវដោយបទបញ្ញត្តិជាតិនិងអន្តរជាតិ ដែលត្រូវបានបញ្ជាក់ដោយលទ្ធផលវិភាគ ។

## ៤.៤.២ និតិវិធីនៃការធ្វើអាជីវកម្មជីគីមី និងថ្នាំកសិកម្ម

គោលបំណងដ៏សំខាន់នៃនិតិវិធីនេះ គឺជំរុញការអនុវត្តបទបញ្ញត្តិច្បាប់ដែលទាក់ទងនឹងសារធាតុគីមីកសិកម្ម សំដៅធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងជីគីមីនិងថ្នាំកសិកម្មនៅកម្ពុជា និងលើកកំពស់សុខភាពប្រជាពលរដ្ឋ និងផ្នែកសេដ្ឋកិច្ច ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាអាជ្ញាធរមានសមត្ថកិច្ចរបស់កម្ពុជា ដែលទទួលបន្ទុកអនុវត្តនិតិវិធីនៃការធ្វើអាជីវកម្ម នាំចូលជីគីមី និងថ្នាំកសិកម្ម។ ដោយឡែក ក្រសួងបរិស្ថានមានភារកិច្ចសហការក្នុងការគ្រប់គ្រងលើការបោះបង់ចោលជីគីមី និងថ្នាំកសិកម្ម ដែលលែងត្រូវការប្រើប្រាស់តាមវិធីប្រកបដោយសុវត្ថិភាពបរិស្ថាន។

ដើម្បីទទួលបានសិទ្ធិក្នុងការនាំចូលជីគីមី និងថ្នាំកសិកម្ម អ្នកនាំចូលត្រូវដាក់ពាក្យសុំទៅកាន់អាជ្ញាធរមានសមត្ថកិច្ច។ រូបវន្តបុគ្គល ឬនិតិបុគ្គលដែលបាននឹងកំពុង ឬមានបំណងធ្វើអាជីវកម្មថ្នាំកសិកម្ម ត្រូវធ្វើការចុះបញ្ជី និងត្រូវសុំការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ។ ចំពោះថ្នាំកសិកម្មទាំងឡាយណា ដែលមិនបានចុះបញ្ជី ឬគ្មានការសំរេចឱ្យប្រើប្រាស់ជាបណ្តោះអាសន្នដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្នាំប្រភេទនោះនឹងត្រូវបានហាមឃាត់ដល់រាល់ការនាំចូល ផលិត លាយ វេចខ្ចប់ និងលក់ដុំ។ល។

### ៤.៤.២.១ ការចុះបញ្ជីការ

ការចុះបញ្ជីការថ្នាំកសិកម្មមាន ៤ ប្រភេទ រួមមាន :

- <u>ការចុះបញ្ជីការបណ្តោះអាសន្ន</u> : ការចុះបញ្ជីការនេះត្រូវធ្វើសំរាប់គ្រប់ប្រភេទនៃថ្នាំកសិកម្ម ដែលស្ថិតក្នុងការកំណត់អនុញ្ញាតឱ្យប្រើប្រាស់ជាបណ្តោះអាសន្នដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដែលកំពុងចរាចរនៅលើទីផ្សារ ។
- <u>ការចុះបញ្ជីការមានល័ក្ខខ័ណ្ឌ</u> : ការចុះបញ្ជីនេះត្រូវធ្វើចំពោះថ្នាំកសិកម្មណា ដែលការចុះបញ្ជីលើកដំបូងត្រូវបានតំរូវឱ្យបំពេញ ប៉ុន្តែ ទិន្នន័យឬល័ក្ខខ័ណ្ឌចាំបាច់ផ្សេងទៀតនឹងតំរូវឱ្យផ្តល់បន្ថែមទៅតាមផ្នែកបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។
- <u>ការចុះបញ្ជីការពេញលេញ</u> : ការចុះបញ្ជីនេះធ្វើចំពោះថ្នាំកសិកម្មណា ដែលអ្នកស្នើសុំចុះបញ្ជីបានបំពេញទាំងស្រុងតាមការតំរូវផ្នែកបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។
- <u>ការឱ្យសិទ្ធិប្រើប្រាស់សំរាប់ការពិសោធន៍</u> : គឺជាការសំរេចឱ្យសិទ្ធិនាំចូលនូវថ្នាំកសិកម្មទាំងឡាយណា ដែលមិនទាន់មានការសំរេចឱ្យប្រើប្រាស់នៅក្នុងស្រុក ហើយនាំចូលមកសំរាប់តែគោលបំណងស្រាវជ្រាវប៉ុណ្ណោះ ។

វិញ្ញាបនប័ត្រចុះបញ្ជីការនឹងមានសុពលភាពរយៈពេល ៣ ឆ្នាំ ក្នុងករណីដែលគ្មានការដកហូត ឬលប់ចោល ។ ការផ្តល់ឱ្យជាថ្មីនឹងមានរយៈពេលដូចគ្នា ។ ប្រសិនបើមានកំហុស ឬយឺតយ៉ាវក្នុងការសុំចុះបញ្ជីការជាថ្មី នោះសុពលភាពនឹងត្រូវផុតកំណត់ដោយស្វ័យប្រវត្តិ ។ ការស្នើសុំពន្យារសុពលភាពវិញ្ញាប័នប័ត្រចុះបញ្ជីការនឹងអាចផ្តល់បន្តរយៈពេល ១ ឆ្នាំ ក្នុងករណីដែលមានមូលហេតុសមរម្យ ។

### ៤.៤.២.២ ការអនុញ្ញាតឱ្យប្រើប្រាស់

- ចំពោះថ្នាំកសិកម្មដែលស្លាកសញ្ញាលើសំភារៈវេចខ្ចប់មានសរសេរជាភាសាខ្មែរ ។
- រាល់សំភារៈវេចខ្ចប់ថ្នាំកសិកម្មត្រូវតែឆ្លើយតបទៅនឹងស្តង់ដារ ដែលកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។
- វិធីសាស្ត្រ និងល័ក្ខខ័ណ្ឌរក្សាទុកឬស្តុកថ្នាំកសិកម្ម នឹងត្រូវបានកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។ ការបង្កើតឃ្លាំងសំរាប់ទុកដាក់ថ្នាំកសិកម្ម ត្រូវមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានការឯកភាពពីក្រសួងបរិស្ថាន ។
- ការបោះចោល និងការកំទេចចោលនូវសំណល់ ឬសំភារៈសំរាប់វេចខ្ចប់ថ្នាំកសិកម្មនៃអាជីវករ ត្រូវមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានការឯកភាពពីក្រសួងបរិស្ថាន ។
- រាល់ការផ្សាយឃោសនាពាណិជ្ជកម្ម ស្តីពីថ្នាំកសិកម្មតាមមធ្យោបាយនានា ត្រូវមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ការផ្សាយពាណិជ្ជកម្មអាចធ្វើទៅបានតែចំពោះថ្នាំកសិកម្មណា ដែលបានចុះបញ្ជីពេញលេញរួច ។

### ៤.៤.៣ បញ្ជីថ្នាំកសិកម្មដែលហាមឃាត់មិនឱ្យប្រើប្រាស់នៅកម្ពុជា

នៅក្នុងគោលបំណងការពារសុខភាពសាធារណៈ និងគុណភាពបរិស្ថាន ឱ្យជៀសផុតពីឥទ្ធិពលគ្រោះថ្នាក់នៃថ្នាំកសិកម្មដែលមានកំរិតពុលធ្ងន់ធ្ងរ និងដោយយោងទៅលើគោលការណ៍ណែនាំរបស់អង្គការសុខភាពពិភពលោកនិងអង្គការស្បៀងកសិកម្ម លើការធ្វើចំណាត់ថ្នាក់នៃភាពគ្រោះថ្នាក់របស់ថ្នាំកសិកម្ម រដ្ឋាភិបាលកម្ពុជាបានសំរេចហាមឃាត់ការប្រើប្រាស់សារធាតុគីមីប្រភេទថ្នាំកសិកម្មចំនួន ១១៦ មុខ ដែលក្នុងនោះមាន ៩ មុខជាសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ដូចមានបង្ហាញក្នុងតារាង ៤-៤ ខាងក្រោម ។

តារាង ៤-៤: បញ្ជីថ្នាំកសិកម្មដែលហាមឃាត់មិនឱ្យប្រើប្រាស់នៅកម្ពុជា

| លរ | ឈ្មោះសារធាតុគីមី | ប្រើប្រាស់ | ចំណាត់ថ្នាក់ភាពពុលរបស់អង្គការ WHO | ក្រុមគីមី | ផ្សេងៗ |
|---|---|---|---|---|---|
| 01 | 1,1,2,2-Tetrachloroethane | FM | | Org | |
| 02 | 2,4,5-T | H | O | OC | |
| 03 | 2,4,5-TP (Fenoprop) | H | O | OC | |
| 04 | Aldicarb | I | Ia | CA | |
| 05 | Aldoxycarb (Aldicarb sulfone) | I | O | | |
| 06 | Aldrin | I | O | OC | (POP) |
| 07 | Aminocarb | I | O | Org | |
| 08 | Amitraz | I | O | Triazapentadiene | |
| 09 | Antu | R | O | CA | |
| 10 | Aramite | I | O | OC | |
| 11 | Arsenic compound (AS) | F | | AS | |
| 12 | BHC / HCH, Lindane | I | II | OC | |
| 13 | Binapacryl | I,F | O | Org | |
| 14 | Bis (Tributyltin) oxide | | O | | |
| 15 | Bromophos | I | O | | |
| 16 | Bromophos ethyl | I | O | | |
| 17 | Cadmium Compound (Cd) | F | | Inorg | |
| 18 | Calcium arsenate | I | Ib | AS | |

| លរ | ឈ្មោះសារធាតុគីមី | ប្រើប្រាស់ | ចំណាត់ថ្នាក់ភាពពុល របស់អង្គការ WHO | ក្រុមគីមី | ផ្សេងៗ |
|---|---|---|---|---|---|
| 19 | Calcium cyanide | FM | Ib | Inorg | |
| 20 | Camphechlor (Toxaphene, Polychlorcamphene) | I | O | OC | (POP) |
| 21 | Captafol | F | Ia | OC | |
| 22 | Captan | F | Un | PD | |
| 23 | Carbophenothion | I | O | | |
| 24 | Chlordane | I | II | OC | (POP) |
| 25 | Chlordecone | I | O | OC | |
| 26 | Chlordimeform | I | O | Formami-dine | |
| 27 | Chlorfen vinphos / CVP | I | Ib | OP | |
| 28 | Chlormephos | I | Ia | OP | |
| 29 | Chlorthiophos | I | O | OP | |
| 30 | Coumaphos | AC | Ia | OP | |
| 31 | Crimidine | R | O | | |
| 32 | Crotoxyphos | I | O | | |
| 33 | Cytokinin (Zeatin) | PGR | | Antibiotic | |
| 34 | Cyanthoate / Tartan | I | O | OP | |
| 35 | Cyeloheximide | PGR | O | Org | |
| 36 | Cyhexatin | I | III | OT | |
| 37 | Daminozide | H | Un | Org | |
| 38 | DBCP(Dibromochloropropane) | FM | O | OC | |
| 39 | DDT | I | II | OC | (POP) |
| 40 | Demephion | I | O | OP | |
| 41 | Demeton | I | O | OP | |
| 42 | Demeton-S-methyl | I | Ib | OP | |
| 43 | Diamidafos | N | O | | |
| 44 | Dieldrin | I | O | OC | (POP) |
| 45 | Demefox | I | O | | |
| 46 | Dimetilan | I | O | | |
| 47 | Dinose /Dinosebacetate,Amine | H | O | Dinitroph-enol | |
| 48 | Dinoterb | H | Ib | NP | |
| 49 | Dioxathion | I | O | OP | |
| 50 | Disulfoton / Ethylthiodemeton | I | Ia | OP | |
| 51 | DNOC | I | Ib | NP | |
| 52 | Edifenphos | F | Ib | OP | |
| 53 | Eldrin /Endrin/ Nendrin | I | O | OC | (POP) |
| 54 | Endosultan | I | II | OC | |
| 55 | Endothion | I | O | | |
| 56 | EPN | I | Ia | OP | |
| 57 | Ethoprop / Ethoprophos | I | Ia | OP | |
| 53 | Ethylene dibromide | FM | | Org | |
| 59 | Ethylene dichloride | FM | | Org | |
| 60 | Ethylene Oxide | FM | | Org | |
| 61 | Fenamiphos | N | Ia | OP | |
| 62 | Fensulfothion | I | O | OP | |
| 63 | Fentin (fenbutatin oxide) | I | Un | OT | |
| 64 | Fluoro acetamide | R | Ib | Org | |
| 65 | Fonofos | I | Ia | OP | |
| 66 | Fosthietan | N | O | OP | |
| 67 | Heptachlor | I | II | OC | (POP) |
| 68 | Hexachlorobenzene | F | Ia | OC | (POP) |
| 69 | IPSP | I | O | | |
| 70 | Isobenzan | I | O | OC | |
| 71 | Isodrin (Isomer of Aldrin) | I | O | | |
| 72 | Isoxathion | I | Ib | OP | |
| 73 | Lead arsenate | I | Ib | AS | |
| 74 | Lead Compound (Pb) | | | Inorg | |
| 75 | Leptophos | I | O | OP | |
| 76 | MCPB | H | III | OC | |
| 77 | Medinoterb acetate | H | O | | |
| 78 | Mephospholan | I | O | OP | |
| 79 | Memaptophos | I | O | OP | |

| លរ | ឈ្មោះសារធាតុគីមី | ប្រើប្រាស់ | ចំណាត់ថ្នាក់ភាពពុល របស់អង្គការ WHO | ក្រុមគីមី | ផ្សេងៗ |
|---|---|---|---|---|---|
| 80 | *Mercury Compound (Hg)* | *F* | | | |
| 81 | *Methacarbate* | | *O* | | |
| 82 | *Methamidophos* | *I* | *Ib* | *OP* | |
| 83 | *Methidation* | *I* | *Ib* | *OP* | |
| 84 | *Methomyl* | *I* | *Ib* | *CA* | |
| 85 | *Mevinphos* | *I* | *Ia* | *OP* | |
| 86 | *Mirex* | *I* | *O* | *OC* | **(POP)** |
| 87 | *Monocrotophos* | *I* | *Ib* | *OP* | |
| 88 | *Nitrilacarb* | | *O* | | |
| 89 | *Nitrofen* | *H* | *O* | *Nitrophenols* | |
| 90 | *Oxamyl* | *I* | *Ib* | *CA* | |
| 91 | *Oxydeprofos (ESP)* | *I* | *O* | | |
| 92 | *Paraquat* | *H* | *II* | *BP* | |
| 93 | *Parathion (Parathion-ethyl)* | *I* | *Ia* | *OP* | |
| 94 | *Parathion-methyl* | *I* | *Ia* | *OP* | |
| 95 | *Pentachlorophenate de sodium* | *F* | *Ib* | *OC* | |
| 96 | *Pentachlorophenol / PCP* | *I, F, H* | *Ib* | *OC* | |
| 97 | *Phenothiol* | *H* | *III* | *OC* | |
| 98 | *Phorate* | *I* | *Ia* | *OP* | |
| 99 | *Phosfolan* | *I* | *O* | *OP* | |
| 100 | *Phoshamidon* | *I* | *Ia* | *OP* | |
| 101 | *Prothoate* | *I* | *O* | *OP* | |
| 102 | *Schradan* | *I* | *O* | *OP* | |
| 103 | *Scilliroside / red squill* | *R* | *O* | *Org* | |
| 104 | *Selenium Compound (Se)* | *F* | | | |
| 105 | *Sodium chlorate* | *H* | *III* | *OC* | |
| 106 | *Sodium Compound* | *F* | | | |
| 107 | *Sodium fluoroacetate* | *R* | *Ia* | *Org* | |
| 108 | *Strobane (Terpene polychlorinated)* | *I* | | | |
| 109 | *Sulfotep* | *I* | *Ia* | *OP* | |
| 110 | *Talinum compound* | *R* | *O* | *Inorg* | |
| 111 | *TEPP* | *I* | *O* | *OP* | |
| 112 | *Terbufos* | *I* | *Ia* | *OP* | |
| 113 | *Thionazin* | *I* | *O* | *OP* | |
| 114 | *Triamiphos* | *I, F, AC* | *O* | | |
| 115 | *Triazophos* | *I* | *Ib* | *OP* | |
| 116 | *Trichloronate* | *I* | *O* | *OP* | |

*ប្រភព* : ឧបសម្ព័ន្ធ ១ ប្រកាសលេខ ៥៩៨ ស្តីពី បញ្ជីរាយមុខថ្នាំកសិកម្មក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## កំណត់សំគាល់ :

| | |
|---|---|
| **AB** | Alkyl Bromide |
| **AC** | Acaricide |
| **AS** | Arsenic Compound |
| **BC** | Benzamide Compound |
| **BP** | Botane pesticide or Bipyridylium Derivative |
| **CA** | Carbamate |
| **CO** | Coumarin derivative or Coumarin Anticoagulant |
| **CU** | Copper compound |
| **DC** | Dithiocarbamates |
| **F** | Fungicide |
| **FM** | Fumigant |
| **H** | Herbicide |
| **I** | Insecticide |
| **IC** | Inorganochlorine Compound |
| **Inorg** | Inorganic Compound |
| **IP** | Inorganic Phosphide |
| **L** | Larvicide |
| **N** | Nematicide |
| **NP** | Nitrophenol derivate |
| **O** | Obsolete |
| **OC** | Organochlorine Compound |
| **ORG** | Organic Compound |
| **OP** | Organophosphorus Compound |
| **OT** | Organotin Compound |
| **PAA** | Phenoxyacetic Acid derivative |
| **PD** | Phtgalimide Derivative |
| **PGR** | Plant Growth Regulation |
| **PY** | Pyrathroid |
| **R** | Rodenticide |
| **SU** | Substituted Urea |
| **TC** | Thiadiazin Compound or Thiocarbamate |
| **TD** | Triazin derivative |
| **TU** | Thiourea Compound |
| **Un** | Unlikely to present acute hazard in normal use |

### ៤.៤.៤ បញ្ជីសារធាតុគីមីដែលស្ថិតក្រោមការដាក់កំរិតតឹងតែង

ក្នុងគោលបំណងទប់ស្កាត់ការផលិតគ្រឿងញៀន រដ្ឋាភិបាលកម្ពុជាបានដាក់កំរិតតឹងតែងលើសារធាតុគីមីមួយចំនួនដែលប្រើជាវត្ថុធាតុដើមសំរាប់ផលិតគ្រឿងញៀន តាមរយៈប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ២០០៤ ស្តីពី ការគ្រប់គ្រងនិងត្រួតពិនិត្យការនាំចេញ នាំចូល និងចែកចាយសារធាតុគីមីឧស្សាហកម្ម ដែលអាចយកទៅប្រើប្រាស់ធ្វើជាវត្ថុធាតុដើមផលិតថ្នាំញៀន ។ យោងតាមសេចក្តីប្រកាសនេះ រាល់ការនាំចូលនូវបណ្តាសារធាតុគីមីដែលមានចែងក្នុងតារាង ៤-៥ ខាងក្រោម ត្រូវតែមានការអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

តារាង ៤-៥: បញ្ជីសារធាតុគីមីឧស្សាហកម្មដែលស្ថិតក្រោមការត្រួតពិនិត្យតឹងតែងក្នុងការនាំចេញ នាំចូល និងចែកចាយ

| លរ | ឈ្មោះសារធាតុគីមី | លរ | ឈ្មោះសារធាតុគីមី |
|---|---|---|---|
| 1 | *1-phenyl-2-propanone* | 19 | *Methylene Chloride* |
| 2 | *3,4-methilenedioxy-pgenyl-2-propanone* | 20 | *N-acetylanthranilic Acid* |
| 3 | *Acetic Acid (Glacial)* | 21 | *Palladium* |
| 4 | *Acetic Anhydride* | 22 | *Phenylacetic Acid* |
| 5 | *Acetone* | 23 | *Phosphorus Pentachloride* |
| 6 | *Acetyl Chloride* | 24 | *Phosphorus Trichloride* |
| 7 | *Anthranilic Acid* | 25 | *Piperidine* |
| 8 | *Barium Sulphate* | 26 | *Piperonal* |
| 9 | *Caustic Soda* | 27 | *Potassium Permanganate* |
| 10 | *Chloroform* | 28 | *Safrole* |
| 11 | *Ethyl Acetate* | 29 | *Soda Ash* |
| 12 | *Ethyl Ether* | 30 | *Solvents* |
| 13 | *Ethylidence Diacetate* | 31 | *Sulfuric Acid* |
| 14 | *Formic Acid* | 32 | *Thinner* |
| 15 | *Hydrochloric Acid* | 33 | *Thionyl Chloride* |
| 16 | *Isosafrole* | 34 | *Toluene* |
| 17 | *Lysergic Acid* | 35 | *Xylene* |
| 18 | *Methyl Ethyl Kethone* | | |

*ប្រភព* : ប្រកាស ស្តីពី ការគ្រប់គ្រងនិងត្រួតពិនិត្យការនាំចេញ នាំចូល និងចែកចាយសារធាតុគីមីឧស្សាហកម្ម ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០០៤ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## ៤.៥ យន្តការដែលមិនស្ថិតក្នុងក្របខ័ណ្ឌច្បាប់ (Non-regulatory mechanism)

យន្តការដែលមិនស្ថិតក្នុងក្របខ័ណ្ឌច្បាប់នៅក្នុងបរិបទនេះ គឺសំដៅទៅលើសកម្មភាពចូលរួមដោយស្ម័គ្រចិត្ត របស់ផ្នែកឯកជនទូទៅ។ យន្តការនេះកំពុងត្រូវបាននិយមប្រើប្រាស់នៅតាមបណ្តាប្រទេសជឿនលឿន និងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកគ្រប់គ្រងសារធាតុគីមីជាមួយស្ថាប័នរដ្ឋ ។ យន្តការទាំងនោះត្រូវបានបង្កើតឡើង ក្រោមរូបភាពជាសមាគមឧស្សាហកម្ម ក្រុមសង្គ្រោះបន្ទាន់នានា សមាគមអាជីវករទេសចរណ៍ ។ល ។ ហើយយន្តការទាំងនោះមានគោលបំណងច្បាស់លាស់ក្នុងការគ្រប់គ្រងទៅលើប្រភេទ ឬក្រុមនៃសារធាតុគីមីជាក់លាក់ ព្រមទាំងបានកំណត់នូវវិសាលភាពនៃការអនុវត្តការងាររបស់គេ ។

ដោយឡែកនៅកម្ពុជា យន្តការដែលមិនស្ថិតក្នុងក្របខ័ណ្ឌច្បាប់ ដែលចូលរួមក្នុងការគ្រប់គ្រងសារធាតុគីមី គឺពុំទាន់មាននៅឡើយទេ។ ប៉ុន្តែ មានផ្នែកឯកជនមួយចំនួនបានចូលរួមជាសកម្មភាពស្ម័គ្រចិត្តជាមួយស្ថាប័នរដ្ឋ ក្នុងការលើកកំពស់ការយល់ដឹងរបស់សាធារណៈជននិងកិច្ចការពារបរិស្ថាន តាមរយៈការចូលរួមផ្តល់ជាមូលនិធិទាយជ្ជទានបរិស្ថាន និងជាវិភាគទានសំរាប់យុទ្ធនាការនានា។

## ៤.៦ យោបល់ និងការវិភាគ

- បរិធានច្បាប់ទាក់ទងទៅនឹងការគ្រប់គ្រងសារធាតុគីមី នៅមានការខ្វះខាតច្រើន ហើយបរិធានច្បាប់ដែលមានស្រាប់ក៏នៅមានការខ្វះចន្លោះច្រើនទាំងទិដ្ឋភាពគ្រប់គ្រងរួម និងតាមប្រភេទក្រុមនៃសារធាតុគីមី ។ ទន្ទឹមនេះ បរិធានច្បាប់ឬបទបញ្ញត្តិដែលមានស្រាប់ គឺពុំបានចែងលំអិតពីវិធានការដែលត្រូវគ្រប់គ្រងសារធាតុគីមីឱ្យមានសុវត្ថិភាពនៅតាមដំណាក់កាលនិមួយៗទេ ភាគច្រើនគឺចែងបទបញ្ញត្តិរួមៗ និងមិនច្បាស់លាស់ពីកាតព្វកិច្ចនិងការទទួលខុសត្រូវទាំងស្ថាប័នរដ្ឋ និងអ្នកពាក់ព័ន្ធ ។
- ប្រសិទ្ធិភាពនៃការអនុវត្តបរិធានច្បាប់ដែលមានស្រាប់ គឺនៅមានកំរិតនៅឡើយ។ មូលហេតុចំបង គឺដោយសារបញ្ញត្តិនៃច្បាប់ចែងមិនមានវិសាលភាពទូលាយ និងពុំបានល្អិតល្អន់ទៅលើទិដ្ឋភាពបច្ចេកទេសនិងការគ្រប់គ្រង ពោលគឺគ្រាន់តែចែងជាច្បាប់គោលតែប៉ុណ្ណោះ។ ទន្ទឹមនោះ ការខ្វះខាតនូវធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងសម្ភារៈបរិក្ខាក៏ជាមូលហេតុដែលធ្វើឱ្យការអនុវត្តបរិធានច្បាប់ពុំទទួលបានប្រសិទ្ធិភាពខ្ពស់។
- ចំពោះបរិធានច្បាប់ដែលមាន គឺមិនទាន់បានឆ្លើយតបទាំងស្រុងទៅនឹងបញ្ហាជាអាទិភាព ទាក់ទងទៅនឹងសារធាតុគីមីដែលបានរៀបរាប់នៅក្នុងជំពូក ២ នៃឯកសារនេះ។ បញ្ហាដែលបញ្ញត្តិច្បាប់ពុំទាន់បានគ្របដណ្តប់រួមមានៈ សារធាតុគីមីសំរាប់ប្រើប្រាស់តាមលំនៅឋាន សុវត្ថិភាពក្នុងការលើកដាក់ ដឹកជញ្ជូន ចែកចាយ ប្រើប្រាស់ និងបោះបង់ចោល និងកំរិតជាតិពុលអនុគ្រោះដែលមាននៅក្នុងម្ហូបអាហារ។
- ទន្ទឹមនឹងទិសដៅដែលត្រូវរៀបចំច្បាប់ថ្មីៗបន្ថែម និងការធ្វើវិសោធនកម្ម ដែលទាក់ទងនឹងការគ្រប់គ្រងសារធាតុគីមីកម្ពុជាបានចាប់ផ្តើមផ្តោតការយកចិត្តទុកដាក់ទៅលើការរៀបចំបរិធានច្បាប់ជំរុញការអនុវត្តអនុសញ្ញា និងពិធីសារអន្តរជាតិនានា ដែលកម្ពុជាបានចូលជាសមាជិករួច និងត្រៀមសុំចូលជាសមាជិកនាពេលអនាគត ។ បរិធានច្បាប់ដែលកំពុងរៀបចំរួមមាន :
    - ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រឧស្សាហកម្ម
    - ច្បាប់ស្តីពីការគ្រប់គ្រងសំណល់គ្រោះថ្នាក់ (ទាក់ទងអនុសញ្ញាបាសែល)
    - អនុក្រឹត្យស្តីពីការគ្រប់គ្រងសារធាតុគីមីបំផ្លាញស្រទាប់អូសូន (ទាក់ទងអនុសញ្ញាវីយែន)
    - ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម
    - ច្បាប់ស្តីពីស្តង់ដារនៃព្រះរាជាណាចក្រកម្ពុជា ។

# ជំពូកទី ៥
# ស្ថាប័នរដ្ឋពាក់ព័ន្ធក្នុងការគ្រប់គ្រងសារធាតុគីមី

ជំពូកនេះផ្តល់ពត៌មានពីតួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័នរដ្ឋក្នុងការគ្រប់គ្រងសារធាតុគីមីនៅកម្ពុជា ។ ដោយសារតែវដ្តនៃសារធាតុគីមីមានច្រើនដំណាក់កាល ដែលផ្តើមចេញពីការផលិត វេចខ្ចប់ ដឹកជញ្ជូន ចែកចាយ ស្តុក ប្រើប្រាស់ រហូតដល់បោះបង់ឬកំទេចចោលចុងក្រោយ រួមនឹងភាពផ្សេងៗគ្នានៃសារធាតុគីមីនិងប្រភេទនៃការប្រើប្រាស់ ចាំបាច់ត្រូវមានស្ថាប័នរដ្ឋជាច្រើនចូលរួមក្នុងការគ្រប់គ្រងសារធាតុគីមីប្រកបដោយសុវត្ថិភាព អនុលោមទៅតាមតួនាទីនិងការទទួលខុសត្រូវដែលកំណត់ដោយរាជរដ្ឋាភិបាល ។

## ៥.១ ស្ថាប័នរដ្ឋ និងការទទួលខុសត្រូវលើការគ្រប់គ្រងសារធាតុគីមី

យោងទៅតាមការអនុវត្តជាក់ស្តែងនៅកម្ពុជា ទាក់ទងទៅនឹងការងារគ្រប់គ្រងសារធាតុគីមី គឺមានស្ថាប័នរដ្ឋមួយចំនួនដែលចូលរួមអនុវត្តការងារនេះទៅតាមការកំណត់ភារកិច្ច និងការទទួលខុសត្រូវដែលបានចែងដោយច្បាប់ និងលិខិតបទដ្ឋានរបស់រាជរដ្ឋាភិបាល ។ ស្ថាប័នរដ្ឋទាំងនោះបានបំពេញភារកិច្ចរបស់ខ្លួនលើការងារគ្រប់គ្រងសារធាតុគីមី ក្នុងទិសដៅធ្វើឱ្យមានសុវត្ថិភាពនៅគ្រប់ដំណាក់កាល ឬសកម្មភាពនៃផលិតកម្ម ឬអាជីវកម្មសារធាតុគីមី ដើម្បីធានាទប់ស្កាត់និងកាត់បន្ថយផលប៉ះពាល់ទៅលើសុខភាពប្រជាពលរដ្ឋ ពិសេសសុខភាពអ្នកប្រើប្រាស់ផ្ទាល់ និងទប់ស្កាត់ឥទ្ធិពលគ្រោះថ្នាក់ទៅលើបរិស្ថាននិងជីវចំរុះ ។

ស្ថាប័នរដ្ឋដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសារធាតុគីមី រួមមាន:

១- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

២- ក្រសួងពាណិជ្ជកម្ម

៣- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៤- ក្រសួងបរិស្ថាន

៥- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

៦- ក្រសួងសុខាភិបាល និង

៧- ក្រសួងមហាផ្ទៃ ។

ការទទួលខុសត្រូវរបស់ស្ថាប័នរដ្ឋពាក់ព័ន្ធក្នុងការគ្រប់គ្រងសារធាតុគីមី (តាមដំណាក់កាលនៃវដ្តសារធាតុគីមី) មានបង្ហាញសង្ខេបនៅក្នុងតារាង ៥-១ ខាងក្រោម:

តារាង ៥-១: ការទទួលខុសត្រូវរបស់ស្ថាប័នរដ្ឋក្នុងដំណាក់កាលនៃវដ្តសារធាតុគីមី

| ស្ថាប័នរដ្ឋ | ដំណាក់កាលនៃវដ្តសារធាតុគីមី | | | | | | |
|---|---|---|---|---|---|---|---|
| | នាំចូល | ផលិត | ទុកដាក់ | ដឹកជញ្ជូន | ចែកចាយ | ប្រើប្រាស់ | បោះចោល |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | x | x | x | x | x | x | x |
| ក្រសួងពាណិជ្ជកម្ម | x | | | | x | | |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | x | | | | | | |
| ក្រសួងបរិស្ថាន | x | x | x | x | x | x | x |
| ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | x | x | x | | | x | x |
| ក្រសួងសុខាភិបាល | x | x | x | x | x | x | x |
| ក្រសួងមហាផ្ទៃ | x | x | x | x | x | x | x |

## ៥.២ ភារកិច្ចរបស់ស្ថាប័នរដ្ឋពាក់ទងនឹងការគ្រប់គ្រងសារធាតុគីមី

ស្ថាប័នរដ្ឋដែលមានការពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសារធាតុគីមី ដូចមានរៀបរាប់ខាងលើ គឺមានភារកិច្ចនិងការទទួលខុសត្រូវដោយឡែកពីគ្នា ដែលបានកំណត់ដោយរាជរដ្ឋាភិបាល ដូចមានសេចក្តីសង្ខេបខាងក្រោម :

### ៥.២.១ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសារធាតុគីមី ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ មានភារកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងសម្ភារៈកសិកម្ម រួមមានបីប្រភេទធំៗ គឺជីគីមី ថ្នាំកសិកម្ម និងឱសថសត្វ ដោយធ្វើការត្រួតពិនិត្យលើការនាំចូល ការធ្វើពាណិជ្ជកម្ម ការប្រើប្រាស់ និងការបោះបង់ចោលនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានកាតព្វកិច្ចរៀបចំគោលនយោបាយគ្រប់គ្រង រៀបចំក្របខ័ណ្ឌច្បាប់ លើកកំពស់ការយល់ដឹងជាសាធារណៈលើប្រសិទ្ធភាព និងសុវត្ថិភាពនៃការប្រើប្រាស់សារធាតុគីមីកសិកម្ម សំដៅលើកកំពស់ផលិតភាពកសិកម្ម សុវត្ថិភាពនិងសន្តិសុខស្បៀង និងសុខមាលភាពសាធារណៈ ។

### ៥.២.២ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលមានភារកិច្ចទទួលខុសត្រូវក្នុងការជំរុញសកម្មភាពអភិវឌ្ឍន៍ឧស្សាហកម្ម ផលិតកម្ម និងការប្រើប្រាស់សារធាតុគីមីឧស្សាហកម្មនៅកម្ពុជា ។ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលក៏ដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញសកម្មភាព ធ្វើការរុករកនិងការធ្វើអាជីវកម្មរ៉ែ និងការអភិវឌ្ឍន៍ថាមពលក្នុងប្រទេស ។ សំខាន់ជាងនេះទៀត ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលមានកាតព្វកិច្ចបង្កើតគោលនយោបាយ ច្បាប់ និងធ្វើផែនការដែលទាក់ទងនឹងទិដ្ឋភាពការងារឧស្សាហកម្ម ក៏ដូចជាទិដ្ឋភាពនៃការគ្រប់គ្រងសារធាតុគីមី ។

### ៥.២.៣ ក្រសួងពាណិជ្ជកម្ម

ទាក់ទងទៅនឹងការគ្រប់គ្រងសារធាតុគីមី ក្រសួងពាណិជ្ជកម្មតាមរយៈនាយកដ្ឋានកាំកុងត្រូល មានតួនាទីដ៏សំខាន់ក្នុងបញ្ហានេះដោយអនុលោមទៅលើភារកិច្ចក្នុងការត្រួតពិនិត្យលើគុណភាព សុវត្ថិភាព និងបរិមាណទំនិញនាំចេញ នាំចូល និងចរាចរលើទីផ្សារ ព្រមទាំងអនុវត្តវិធានការបង្ក្រាបការក្លែងបន្លំគុណភាពទំនិញលើទីផ្សារ លើកលែងតែផលិតផលឱសថនិងគ្រឿងសំអាង ។

### ៥.២.៤ ក្រសួងបរិស្ថាន

ក្រសួងបរិស្ថាន ដោយមានការចូលរួមសហការពីស្ថាប័នរដ្ឋនានា អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងផ្នែកឯកជន មានភារកិច្ចទទួលខុសត្រូវក្នុងការតាមដានគុណភាពបរិស្ថាន (ទឹក ដី ខ្យល់) និងធ្វើការត្រួតពិនិត្យលើប្រភពបង្កើត និងសាយភាយសារធាតុបំពុលបរិស្ថាន ព្រមទាំងប្រមូល ចងក្រង និងគ្រប់គ្រងទិន្នន័យសារធាតុគីមីពុល សារធាតុគីមីគ្រោះថ្នាក់ សំណល់គីមីពុល និងសំណល់គីមីគ្រោះថ្នាក់ និងការគ្រប់គ្រងសំណល់គ្រប់ប្រភេទប្រកបដោយសុវត្ថិភាពបរិស្ថាន ។

### ៥.២.៥ ក្រសួងសុខាភិបាល

ពាក់ព័ន្ធនឹងការគ្រប់គ្រងសារធាតុគីមី ក្រសួងសុខាភិបាលមានមុខងារ និងភារកិច្ចរៀបចំគោលនយោបាលសុខាភិបាលដោយផ្អែកលើមូលដ្ឋានកម្មវិធីរបស់រាជរដ្ឋាភិបាល សំដៅលើកកំពស់សុខមាលភាពរបស់ប្រជាពលរដ្ឋ គ្រប់គ្រងប្រព័ន្ធផលិតកម្មអាជីវកម្ម និងបែងចែកឱសថ បរិក្ខារអមវេជ្ជសាស្ត្រ និងសំភារៈវេជ្ជសាស្ត្រជូនដល់គ្រប់អង្គភាពនិងសាធារណៈជន ព្រមទាំងពិនិត្យតាមដានសុវត្ថិភាពចំណីអាហារ ។

### ៥.២.៦ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ទាក់ទងទៅនឹងតួនាទី និងការទទួលខុសត្រូវរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការងារគ្រប់គ្រងសារធាតុគីមី ទីចាត់ការគយនិងរដ្ឋាករដែលជាភ្នាក់ងាររបស់ក្រសួង មានភារកិច្ចគ្រប់គ្រងរាល់ទំនិញនាំចេញនិងនាំចូលគ្រប់ប្រភេទ ចាត់វិធានការរាំងខ្ទប់ និងចាប់ឃាត់ទំនិញគេចពន្ធគយ ព្រមទាំងត្រួតពិនិត្យនិងគ្រប់គ្រងការនាំចេញនិងនាំចូលទំនិញ ឥវ៉ាន់អ្នកដំណើរ រូបិយប័ណ្ណ លោហៈធាតុ ត្បូងថ្មមានតំលៃ បីតិកភ័ណ្ឌវប្បធម៌ កញ្ចប់ និងភណ្ឌិកាប្រៃសណីយ៍ ព្រមទាំងមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ ។

### ៥.២.៧ ក្រសួងមហាផ្ទៃ

ទាក់ទងទៅនឹងតួនាទី និងការទទួលខុសត្រូវរបស់ក្រសួងមហាផ្ទៃលើការងារគ្រប់គ្រងសារធាតុគីមី គឺបានស្តែងចេញតាមរយៈតួនាទីរបស់អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលមានតួនាទីដ៏សំខាន់ក្នុងការប្រមូលពត៌មាន និងក្នុងប្រតិបត្តិការប្រឆាំងនឹងការដាំដុះ ការផលិត និងការធ្វើជំនួញគ្រឿងញៀន និងសំរបសំរួលរាល់សកម្មភាពត្រួតពិនិត្យគ្រឿងញៀនរបស់ភ្នាក់ងារប្រតិបត្តិដទៃទៀត ដើម្បីធានាឱ្យបាននូវប្រសិទ្ធិភាព និងសុវត្ថិភាពនៃការបង្ក្រាបគ្រឿងញៀននៅកម្ពុជា ។

## ៥.៣ កម្មវិធីការងារពាក់ព័ន្ធការគ្រប់គ្រងសារធាតុគីមីរបស់ស្ថាប័នរដ្ឋ

រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ថា រាល់សកម្មភាពដែលទាក់ទងនឹងសារធាតុគីមី ដូចជា ការធ្វើអាជីវកម្ម ការធ្វើពាណិជ្ជកម្ម ការដឹកជញ្ជូន ការស្តុក ការវេចខ្ចប់ ការចែកចាយ និងប្រើប្រាស់សារធាតុគីមី គឺបានបង្កឱ្យមានការប៉ះពាល់ទៅលើសុខភាព និងបរិស្ថាន ។ ដើម្បីកាត់បន្ថយនូវផលប៉ះពាល់ជាអវិជ្ជមានទាំងនោះ ស្ថាប័នរដ្ឋបានកំណត់និងអនុវត្តនូវកម្មវិធីការងារមួយចំនួនដែលស្ថិតក្នុងក្របខ័ណ្ឌសមត្ថកិច្ច និងការទទួលខុសត្រូវរបស់ខ្លួន ដែលទាក់ទងទៅនឹងការគ្រប់គ្រងសារធាតុគីមី ។ ខាងក្រោមនេះ គឺជាកម្មវិធីការងារពាក់ព័ន្ធនឹងការគ្រប់គ្រងសារធាតុគីមី ដែលស្ថាប័នរដ្ឋបាននិងកំពុងប្រតិបត្តិ ។

តារាង ៥-២: កម្មវិធីការងារដែលអនុវត្តដោយរដ្ឋាភិបាលក្នុងការគ្រប់គ្រងសារធាតុគីមី

| ឈ្មោះស្ថាប័នរដ្ឋ | កម្មវិធី | អាសយដ្ឋានទំនាក់ទំនង |
|---|---|---|
| *ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ* | ១-គំរោងបង្កើនផលិតភាពកសិកម្ម<br>• ការពារដំណាំ ( អនុគំរោង) | • **ការិយាល័យការពារដំណាំ នៃនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**<br>អាគារលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ<br>ទូរស័ព្ទ: (៨៥៥) ២៣ ២១១ ៣៥១ /១២ ៨៩៨ ០៤៩<br>អ៊ីម៉ែល: simonabuntoun@hotmail.com |
| | ២-គំរោងបង្កើនផលិតភាពកសិកម្ម<br>• IPM ( អនុគំរោង) | • **ផ្នែកវិធានការជាតិការពារដំណាំ (IPM) នៃនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**<br>អាគារលេខ ១៤ ផ្លូវមុន្នីរ៉េត ខ័ណ្ឌចំការមន ក្រុងភ្នំពេញ<br>ទូរស័ព្ទ: (៨៥៥)២៣ ២១១ ៣៥១ /១២ ៨២៦ ១៩៩<br>អ៊ីម៉ែល: apipipm@online.com.kh |
| | ៣-ស្តង់ដារសំភារ:កសិកម្ម | • **ការិយាល័យបមាណីយ នៃនាយកដ្ឋាននិតិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**<br>អាគារលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ<br>ទូរស័ព្ទ: (៨៥៥)២៣ ២១១ ៣៥១ /១២ ៨៤១ ៨៦៧<br>អ៊ីមែល: 012841867@mobitel.com.kh |
| *ក្រសួងពាណិជ្ជកម្ម* | ១-ការបង្កើតកម្មវិធីអធិការកិច្ច និងការពង្រឹងការអនុវត្តចំនុចច្រកព្រំដែន និងការឃ្លាំមើលតាមទីផ្សារដោយផ្តោតការយកចិត្តទុកដាក់ចំពោះសារធាតុគីមី | • **នាយកដ្ឋានកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម**<br>អាគារលេខ ៥០ ផ្លូវ១៤៤ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ<br>ទូរស័ព្ទ/ទូរសារ: (៨៥៥) ២៣ ៤២៦ ១៦៦<br>អ៊ីម៉ែល: camcontrol@camnet.com.kh |

| ឈ្មោះស្ថាប័នរដ្ឋ | កម្មវិធី | អាសយដ្ឋានទំនាក់ទំនង |
|---|---|---|
| *ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ* | ១-កម្មវិធីប្រមូលពន្ធ និងត្រួតពិនិត្យការនាំចេញ និងនាំចូល | • ទីចាត់ការគយ និងរដ្ឋាករ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>អាគារលេខ ១៣ ផ្លូវ១៤៦ សង្កាត់ផ្សារដេប៉ូ ២ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ<br>ទូរស័ព្ទ : (៨៥៥) ១២ ៨១១ ១១៨<br>ទូរសារ: (៨៥៥) ១២ ៨៤១ ១០០<br>អ៊ីមែល: 012811118l@mobitel.com.kh |
| *ក្រសួងបរិស្ថាន* | ១-កម្មវិធីជាតិគ្រប់គ្រងសំណល់រឹង-រាវ | • នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន នៃក្រសួងបរិស្ថាន<br>អាគារលេខ ៤៨ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ<br>ទូរស័ព្ទ (៨៥៥) ២៣ ២១០ ៤៩២ /១២ ៩២៦ ១០៨<br>អ៊ីមែល: moepcd@online.com.kh<br>heng.nareth@online.com.kh |
| | ២-កម្មវិធីជាតិអូសូន | • ផ្នែកអនុសញ្ញា អូសូន នៃនាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន នៃក្រសួងបរិស្ថាន<br>អាគារលេខ ៤៨ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ<br>ទូរស័ព្ទ (៨៥៥) ២៣ ២១០ ៤៩២/១២ ៩៦២ ១០៣<br>អ៊ីមែល: moepcd@online.com.kh<br>sokharavuth@online.com.kh |
| | ៣-កម្មវិធីជាតិគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់ | • ផ្នែកអនុសញ្ញា បាសែល នៃនាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន នៃក្រសួងបរិស្ថាន<br>អាគារលេខ ៤៨ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ<br>ទូរស័ព្ទ (៨៥៥) ២៣ ២១០ ៤៩២/១២ ៨៥៦ ៨១៨<br>អ៊ីមែល: moepcd@online.com.kh<br>choviran@hotmail.com |
| | ៤-កម្មវិធីជាតិគ្រប់គ្រងសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ | • ផ្នែកអនុសញ្ញា ស្តុកខូម នៃនាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន នៃក្រសួងបរិស្ថាន<br>អាគារលេខ ៤៨ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ<br>ទូរស័ព្ទ (៨៥៥) ២៣ ២២០ ៣៩២/១២ ៩១៥ ៧៩២<br>អ៊ីមែល: moepcd@online.com.kh<br>nip_pops@online.com.kh |

| ឈ្មោះស្ថាប័នរដ្ឋ | កម្មវិធី | អាសយដ្ឋានទំនាក់ទំនង |
|---|---|---|
| *ក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល* | ១-ពង្រាងគោលការណ៍ណែនាំ ស្តីពី ការគ្រប់គ្រងសារធាតុគីមីឧស្សាហកម្ម<br>• បង្កើតប្រព័ន្ធគ្រប់គ្រងហានិភ័យ<br>• ការបង្កើតស្តង់ដារសំរាប់សារធាតុប្រកបដោយគ្រោះថ្នាក់<br>• ការបង្កើតវិធីសាស្ត្រវាយតំលៃការខូចខាតបរិស្ថាន | • ការិយាល័យបរិស្ថានឧស្សាហកម្ម នៃនាយកដ្ឋានបច្ចេកទេសឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>អាគារលេខ ៤៥ មហាវិថីព្រះនរោត្តម ក្រុងភ្នំពេញ<br>ទូរស័ព្ទ (៨៥៥) ២៣ ២១១ ១៤១ |
| | ២-គំរោងផលិតកម្មស្អាតក្នុងវិស័យឧស្សាហកម្ម<br>SECO/SWISS/UNIDO | • នាយកដ្ឋានបច្ចេកទេសឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>អាគារលេខ ៤៥ មហាវិថីព្រះនរោត្តម ក្រុងភ្នំពេញ<br>ទូរស័ព្ទ/ទូរសារ: (៨៥៥) ២៣ ៤២៨ ២៦៣ |
| | ៣-គំរោងគ្រប់គ្រងសហគ្រាសខ្នាតតូច និងមធ្យម | • នាយកដ្ឋានឧស្សាហកម្មធុនស្រាល និងសិប្បកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>អាគារលេខ ៤៥ មហាវិថីព្រះនរោត្តម ក្រុងភ្នំពេញ<br>ទូរស័ព្ទ/ទូរសារ: (៨៥៥)២៣ ៤២៨ ២៦៣ |
| | ៤-គំរោងផ្គត់ផ្គង់ទឹកស្អាតខេត្ត-ក្រុង | • នាយកដ្ឋានទឹកស្អាត នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>អាគារលេខ ៤៥ មហាវិថីព្រះនរោត្តម ក្រុងភ្នំពេញ |
| | ៥-គំរោងស្តង់ដារឧស្សាហកម្ម | • នាយកដ្ឋានស្តង់ដារឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>អាគារលេខ ៤៥ មហាវិថីព្រះនរោត្តម ក្រុងភ្នំពេញ<br>ទូរស័ព្ទ/ទូរសារ: (៨៥៥) ២៣ ២១៦ ០៨៦ |
| *ក្រសួងសុខាភិបាល* | ១-កម្មវិធីគ្រប់គ្រងឱសថ | • នាយកដ្ឋានឱសថ និងអាហារ នៃក្រសួងសុខាភិបាល<br>អាគារលេខ០៨ ផ្លូវអ៊ុងប៊ុគុណ សង្កាត់មិត្តភាព ខ័ណ្ឌ៧មករា ក្រុងភ្នំពេញ<br>ទូរស័ព្ទ/ទូរសារ: (៨៥៥)២៣ ៨៨០ ២៤៨<br>អ៊ីម៉ែល: moh-cpn@forum.org.kh |
| | ២-កម្មវិធីគ្រប់គ្រងសំណល់មន្ទីរពេទ្យ | • ការិយាល័យសេវាកម្មមន្ទីរពេទ្យ នាយកដ្ឋានមន្ទីរពេទ្យ នៃក្រសួងសុខាភិបាល<br>អាគារលេខ១៥១-១៥៣ ផ្លូវកម្ពុជាក្រោម សង្កាត់មិត្តភាព ខ័ណ្ឌ៧មករា ក្រុងភ្នំពេញ<br>ទូរស័ព្ទ: (៨៥៥) ២៣ ៤២៦ ០៣៤/១២ ៩១២ ១២២ |

| ឈ្មោះស្ថាប័នរដ្ឋ | កម្មវិធី | អាសយដ្ឋានទំនាក់ទំនង |
| --- | --- | --- |
| | ៣-កម្មវិធីគ្រប់គ្រងឱសថខ្វះគុណភាព | • **នាយកដ្ឋានឱសថ និង អាហារ ក្រសួងសុខាភិបាល**<br>អាគារលេខ០៨ ផ្លូវអ៊ុងប៉ូគុណ សង្កាត់មិត្តភាព ខ័ណ្ឌ៧មករា ក្រុងភ្នំពេញ<br>ទូរស័ព្ទ/ទូរសារ: (៨៥៥)២៣ ៨៨០ ២៤៨<br>អ៊ីម៉ែល: moh-cpn@forum.org.kh |

## ៥.៤ យោបល់ និងការវិភាគ

តួនាទី និងភារកិច្ចទទួលខុសត្រូវរបស់ស្ថាប័នរដ្ឋដែលរៀបរាប់ខាងលើ បានបញ្ជាក់យ៉ាងច្បាស់ថា មិនមានត្រួតគ្នាទេលើការងារបច្ចេកទេសគ្រប់គ្រងសារធាតុគីមី ដោយសារស្ថាប័នរដ្ឋនិមួយៗ មានកាតព្វកិច្ចទទួលខុសត្រូវលើវិស័យផ្សេងៗគ្នា។ ប៉ុន្តែប្រសិទ្ធិភាពនៃការអនុវត្តការងាររបស់ស្ថាប័នរដ្ឋនិមួយៗ ដែលមានភារកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងសារធាតុគីមី គឺនៅមានកំរិតដោយសារការខ្វះខាតនូវធនធានមនុស្សនិងមូលដ្ឋានសំភារៈអនុវត្តការងារ ។ ទន្ទឹមនោះ បញ្ហាប្រាក់ចំណូលរបស់មន្ត្រីរាជការមានកំរិតទាបជាងជីវភាពរស់នៅ គឺជាមូលហេតុមួយដែលធ្វើឱ្យការអនុវត្តតួនាទីភារកិច្ចរបស់ស្ថាប័នរដ្ឋក្នុងការគ្រប់គ្រងសារធាតុគីមីមិនមានប្រសិទ្ធិភាពខ្ពស់។

# ជំពូកទី ៦
# សកម្មភាពពាក់ព័ន្ធរបស់ផ្នែកឯកជន អង្គការមិនមែនរដ្ឋាភិបាល និងក្រុមស្រាវជ្រាវ

ជំពូកនេះនឹងបង្ហាញពីសកម្មភាពការងាររបស់ផ្នែកឯកជន អង្គការមិនមែនរដ្ឋាភិបាលនិងក្រុមស្រាវជ្រាវ ដែលគាំទ្រសកម្មភាពនិងកម្មវិធីជាតិក្នុងការគ្រប់គ្រងសារធាតុគីមី ក្នុងគោលបំណងធ្វើឱ្យមានភាពប្រសើរនិងប្រកបដោយសុវត្ថិភាពក្នុងការប្រើប្រាស់ និងបោះបង់ចោលនូវសារធាតុគីមី សំដៅការពារសុខភាពនិងបរិស្ថានឱ្យជៀសផុតពីឥទ្ធិពលគ្រោះថ្នាក់នៃសារធាតុគីមីដែលកំពុងប្រើប្រាស់នៅកម្ពុជា ។

## ៦.១ ការចូលរួមរបស់សង្គមស៊ីវិលក្នុងសកម្មភាពគ្រប់គ្រងសារធាតុគីមី

ការចូលរួមរបស់សហគមន៍ សង្គមស៊ីវិល និងភ្នាក់ងារដទៃទៀតនៅក្នុងសកម្មភាពគ្រប់គ្រងសារធាតុគីមី គឺមានសារៈសំខាន់ណាស់ ដែលអាចជួយជំរុញឱ្យការអនុវត្តច្បាប់ លិខិតបទដ្ឋាន និងគោលនយោបាយគ្រប់គ្រងប្រកបដោយសុវត្ថិភាពឱ្យកាន់តែមានប្រសិទ្ធិភាព។ ប៉ុន្តែ បច្ចុប្បន្ននេះសកម្មភាពចូលរួមពីសហគមន៍ សង្គមស៊ីវិល និងភ្នាក់ងារដទៃទៀតក្នុងការងារគ្រប់គ្រងសារធាតុគីមី គឺមានក្នុងកំរិតតិចតួចណាស់នៅកម្ពុជា ហើយដែលការចូលរួមនោះ គឺបានផ្តោតតែទៅលើការគ្រប់គ្រងសំរាមលំនៅឋានក្នុងសហគមន៍តែប៉ុណ្ណោះ។ ភាពអវត្តមានបែបនេះមិនមែនមានន័យថា បញ្ហាគ្រោះថ្នាក់នៃសារធាតុគីមីនៅកម្ពុជាពុំកើតមាននោះទេ ផ្ទុយទៅវិញភាពពេញនិយមនៃការប្រើប្រាស់សារធាតុគីមី និងការប្រើប្រាស់សារធាតុគីមីដោយខុសលក្ខណៈបច្ចេកទេស គឺមានការកើនឡើងជាលំដាប់ ហើយកង្វល់ពីគ្រោះថ្នាក់នៃការប្រើប្រាស់សារធាតុគីមីកាន់តែបានយល់ច្បាស់នៅក្នុងចំណោមពលរដ្ឋកម្ពុជា ។

ពិនិត្យជារួម ភាពខ្វះការចូលរួមពីសង្គមស៊ីវិល សហគមន៍ និងភ្នាក់ងារដទៃទៀត គឺដោយសារការខ្វះនូវយន្តការសំរបសំរួលដល់ការចូលរួម និងកង្វះខាតនូវធនធានមនុស្សនិងហិរញ្ញវត្ថុ ។

### ៦.១.១ កម្មវិធីការងាររបស់ផ្នែកឯកជនដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសារធាតុគីមី

ក្នុងការអនុវត្តកម្មវិធី ឬគោលនយោបាយជាតិក្នុងការគ្រប់គ្រងសារធាតុគីមីប្រកបដោយសុវត្ថិភាព ក៏មានការចូលរួមជាសកម្មភាពគាំទ្រពីផ្នែកឯកជនតាមរូបភាពស្ម័គ្រចិត្ត ដូចជាការចូលរួមជាវិភាគទានក្នុងការរៀបចំទិវាលើកកំពស់ការយល់ដឹងរបស់សាធារណជនលើបញ្ហាបរិស្ថាន (ទិវាបរិស្ថានជាតិនិងពិភពលោក ទិវាអនាម័យបរិស្ថានជាតិ ទិវាអូសូនជាតិ ។ល។) ។ ប៉ុន្តែចំពោះការចូលរួមជាសកម្មភាពស្ម័គ្រចិត្តជាប្រចាំ លើការងារពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសារធាតុគីមី គឺពុំទាន់មានជាសកម្មភាពនៅឡើយទេ។ ដោយឡែកបច្ចុប្បន្ននេះ មានតែក្រុមហ៊ុនចំនួន ២ ដែលកំពុងធ្វើអាជីវកម្មពាក់ព័ន្ធទៅនឹងការប្រមូលនិងទុកដាក់សំណល់ទីក្រុង សំណល់គ្រោះថ្នាក់ និងសំណល់រោងចក្រ ។

តារាង ៦-១: កម្មវិធីការងាររបស់ផ្នែកឯកជនដែលទាក់ទងនឹងការគ្រប់គ្រងសារធាតុគីមី

| ក្រុមសាធារណៈដែលចាប់អារម្មណ៍ | កម្មវិធី | អាស័យដ្ឋានទំនាក់ទំនង |
|---|---|---|
| *ក្រុមហ៊ុន ស៊ីនទ្រី* | សេវាកម្មប្រមូល និងដឹកជញ្ជូនសំណល់រឹងនៅរាជធានីភ្នំពេញ | អាគារលេខ៤៤២ D មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ<br>ទូរស័ព្ទ: (៨៥៥) ១២ ៩៩៤ ៩៩៥ |
| *ក្រុមហ៊ុន សារ៉ុមត្រេឌីង* | ការប្រមូលសំណល់ឧស្សាហកម្ម ការដឹកជញ្ជូន និងទីលានចាក់សំរាម | សារ៉ុមត្រេឌីង ទទួលខុសត្រូវមានកំរិត ផ្ទះលេខ១២២ ផ្លូវ៤៣០ សង្កាត់ទួលទំពូង២ ខណ្ឌចំការមន ក្រុងភ្នំពេញ<br>ទូរស័ព្ទ: (៨៥៥) ១១ ៩៣៨ ៩៦៧<br>អ៊ីមែល: saromtrading@hotmail.com |

## ៦.១.២ កម្មវិធីការងាររបស់អង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធការគ្រប់គ្រងសារធាតុគីមី

ដើម្បីធ្វើឱ្យសំរេចបាននូវផែនការគ្រប់គ្រងសារធាតុគីមីប្រកបដោយសុវត្ថិភាព រាជរដ្ឋាភិបាលកម្ពុជាបានបើកផ្លូវ និងបង្កលក្ខណៈសំរាប់ឱ្យមានការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាល តាមរយៈសកម្មភាពរបស់ពួកគេដែលមានការពាក់ព័ន្ធនឹងការគ្រប់គ្រងសារធាតុគីមី។ ជាការពិតណាស់ ការចូលរួមជាសកម្មភាពការងាររបស់អង្គការមិនមែនរដ្ឋាភិបាល គឺជាមូលដ្ឋាននៃការធ្វើឱ្យសំរេចបាននូវប្រសិទ្ធិភាពការងារ និងផែនការគ្រប់គ្រងសារធាតុគីមី ដែលរដ្ឋាភិបាលបានដាក់ចេញសំដៅធ្វើឱ្យការប្រើប្រាស់សារធាតុគីមីមានប្រសិទ្ធិភាព និងមិនមានគ្រោះថ្នាក់ទៅលើសុខភាពនិងបរិស្ថាន ។ ខាងក្រោមនេះ គឺជាកម្មវិធីការងាររបស់អង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសារធាតុគីមីនៅកម្ពុជា ។

តារាង ៦-២: កម្មវិធីការងាររបស់អង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធការគ្រប់គ្រងសារធាតុគីមី

| ឈ្មោះអង្គការមិនមែនរដ្ឋាភិបាល | កម្មវិធី | អាស័យដ្ឋានទំនាក់ទំនង |
|---|---|---|
| *វេទិការអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum on Cambodia)* | គំរោងកាត់បន្ថយថ្នាំកសិកម្មនៅកម្ពុជា តាមរយៈការជំរុញការយល់ដឹងអំពីបញ្ហាថ្នាំកសិកម្ម ការកាត់បន្ថយការប្រើថ្នាំកសិកម្ម និងការប្រើដោយសុវត្ថិភាព | អាគារលេខ ៩-១១ ផ្លូវ ៤៧៦ សង្កាត់ទួលទំពូង ១ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ<br>ទូរស័ព្ទ/ទូរសារ: (៨៥៥) ២៣ ២១៤ ៤២៩<br>អ៊ីមែល: ngoforum@ngoforum.org.kh |
| *មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CEDAC)* | គំរោងកាត់បន្ថយថ្នាំកសិកម្មនៅតំបន់ទន្លេមេគង្គកម្ពុជា តាមរយៈសកម្មភាពស្រាវជ្រាវអភិវឌ្ឍន៍កសិកម្ម ការអប់រំ ការបោះពុម្ពផ្សាយ សេវាកម្ម អភិវឌ្ឍន៍ទូទៅ និងចូលរួមក្នុងបណ្តាញកាត់បន្ថយថ្នាំកសិកម្មកម្ពុជា | អាគារលេខ ៣៩ ផ្លូវ៥២៨ សង្កាត់បឹងកក់១ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ<br>ប្រអប់សំបុត្រ: ១១១៨<br>ទូរស័ព្ទ/ទូរសារ: (៨៥៥) ២៣ ៨៨០ ៩១៦<br>អ៊ីមែល: cedac@camnet.com.kh |

| ឈ្មោះអង្គការ<br>មិនមែនរដ្ឋាភិបាល | កម្មវិធី | អាសយដ្ឋានទំនាក់ទំនង |
|---|---|---|
| *គំរោងការផ្សព្វផ្សាយកសិកម្មកម្ពុជា-អូស្ត្រាលី*<br>(CAAEP) | • គាំទ្រប្រព័ន្ធកសិកម្ម ឋានប្រព័ន្ធកសិកម្ម និងវិភាគសហគមន៍<br>• ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធត្រួតពិនិត្យនិងវាយតំលៃ<br>• គាំទ្រការអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្តុះបណ្តាល | អាគារលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ<br>ទូរស័ព្ទ: (៨៥៥) ១២ ៥០៣ ០៨៨<br>ទូរសារ: (៨៥៥) ២៣ ២១៣ ០១១<br>អ៊ីមែល: caaep@online.com.kh |
| *អង្គការស្រែខ្មែរ*<br>*Sre Khmer Organization* | គាំទ្រកសិករខ្មែរក្នុងផលិតកម្មបន្លែសរីរាង្គ | អាគារលេខ ១១បេ ផ្លូវ១០១ សង្កាត់បឹងត្របែក ខ័ណ្ឌចំការមន ភ្នំពេញ<br>ទូរស័ព្ទ/ទូរសារ: (៨៥៥) ២៣ ២១០ ២១៧ |
| *អង្គការអភិវឌ្ឍន៍ធនធានអន្តរជាតិ*<br>*Resource Development International (RDI)* | អង្កេត និងស្រាវជ្រាវសារធាតុអាសេនិចក្នុងទឹកអណ្តូងនៅខេត្តកណ្តាល | ផ្លូវឡុតដ្ឋរ៉ីយ៉ាល់ ស្រុកគៀនស្វាយ ខេត្តកណ្តាល<br>ទូរស័ព្ទ/ទូរសារ:(៨៥៥) ២៣ ៣៦៥ ៥៧៧<br>អ៊ីម៉ែល: rdi.bus@.rdic.org |
| *អង្គការស្តារូ (CSARO)* | អនាម័យសហគមន៍ និងការកែច្នៃសំរាម | អាគារលេខ ៧១ ផ្លូវ៣៦៨-១៦៣ សង្កាត់ទួលស្វាយព្រៃ១ ខ័ណ្ឌចំការមន ភ្នំពេញ<br>ប្រអប់សំបុត្រ: ២០១៥<br>ទូរស័ព្ទ/ទូរសារ:(៨៥៥) ២៣ ២១១ ១១៦<br>ទូរស័ព្ទចល័ត: (៨៥៥) ១២ ៥៥៧ ២៥៥<br>អ៊ីមែល csaro@online.com.kh<br>www.online.com.kh/users/csaro |
| *អង្គការអប់រំ និងគ្រប់គ្រងសំណល់កម្ពុជា*<br>Cambodian Education and Waste Management Organization | ផលិតកម្មជីកំប៉ុស្ត | សង្កាត់ជើងឯក ខ័ណ្ឌដង្កោ ក្រុងភ្នំពេញ<br>ប្រអប់សំបុត្រ: ៩៥៥<br>ទូរស័ព្ទចល័ត: (៨៥៥) ១២ ៨៤២ ៣៨៧<br>អ៊ីមែល: comped@forum.org.kh |

## ៦.១.៣ សេវាកម្មជំនាញនៅក្រៅស្ថាប័នរដ្ឋ

ក្រៅពីលទ្ធភាពរបស់រដ្ឋាភិបាល គេអាចស្វែងរកអ្នកជំនាញពីខាងក្រៅបាន ដើម្បីគាំទ្រកម្មវិធី និងគោលនយោបាយជាតិដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសារធាតុគីមី នៅតាមគ្រឹះស្ថានអប់រំ ផ្នែកឧស្សាហកម្ម ផ្នែកឯកជន សហជីព អង្គការវិជ្ជាជីវៈ ។ល។ ប៉ុន្តែ សេវាកម្មរបស់ផ្នែកទាំងនោះ គឺនៅមានកំរិតដោយពាក់ព័ន្ធទៅនឹងធនធាន សមត្ថភាពនិងមធ្យោបាយ ។ សេវាកម្មដែលអាចទទួលបានពីផ្នែកជំនាញទាំងនោះ មានសង្ខេបបង្ហាញជូននៅក្នុងតារាងខាងក្រោម ។

តារាង ៦-៣: សេវាកម្មជំនាញនៅក្រៅស្ថាប័នរដ្ឋ

| សេវាកម្មជំនាញ | អង្គភាពផ្តល់សេវាកម្មជំនាញនៅក្រៅស្ថាប័នរដ្ឋ | | | | | | |
|---|---|---|---|---|---|---|---|
| | វិទ្យាស្ថានស្រាវជ្រាវ | សាកលវិទ្យាល័យ | ឧស្សាហកម្ម | សេវាបរិស្ថាន | សហជីពកម្មករ | សហជីពពាណិជ្ជកម្ម | អង្គការវិជ្ជាជីវៈ |
| ការប្រមូលពត៌មាន | X | X | X | X | X | X | X |
| ការវិភាគគីមី | X | X | X | | | | |
| ការវាយតំលៃភាពគ្រោះថ្នាក់ | X | X | | X | | | X |
| ការកាត់បន្ថយភាពគ្រោះថ្នាក់ | | | X | | | | X |
| ការវិភាគគោលនយោបាយ | | | | | | | X |
| ការបណ្តុះបណ្តាល និងការអប់រំ | X | X | | X | | | X |
| ការស្រាវជ្រាវពីជំរើសផ្សេងៗ | X | X | | | | | X |
| ការត្រួតពិនិត្យតាមដាន | X | | | | | | X |
| ការជំរុញការអនុវត្តច្បាប់ | | | | X | X | X | |
| ការផ្តល់ពត៌មានដល់កម្មករ | | | | | X | X | |
| ការផ្តល់ពត៌មានដល់សាធារណជន | | | | X | | | |

## ៦.២ យោបល់ និងការវិភាគ

គោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលទាក់ទិនទៅនឹងការផ្តល់ឱកាសដល់សង្គមស៊ីវិល ដើម្បីទទួលនូវពត៌មានពីស្ថាប័នរដ្ឋនិងផ្តល់ត្រឡប់មកស្ថាប័នរដ្ឋវិញ ដែលទាក់ទងទៅនឹងការគ្រប់គ្រងសារធាតុគីមី គឺពុំទាន់បានកំណត់នៅឡើយទេ ។ ប៉ុន្តែចំពោះការអនុវត្តវិញ ការទទួលនិងការផ្តល់ពត៌មានទៅវិញទៅមករវាងស្ថាប័នរដ្ឋនិងសង្គមស៊ីវិល ត្រូវបានអនុវត្តយ៉ាងទូលំទូលាយយោងទៅតាមការស្នើសុំ លើកលែងតែពត៌មានផ្ទៃក្នុងរបស់ស្ថាប័ន។

ម្យ៉ាងវិញទៀតកម្ពុជានៅពុំទាន់មានច្បាប់ស្តីពីការបង្កើតសមាគមន៍ សហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល នៅឡើយទេ ប៉ុន្តែរដ្ឋាភិបាលបានបង្កលក្ខណៈងាយស្រួល និងភាពអនុគ្រោះដល់ការបង្កើត និងដំណើការរបស់សង្គមស៊ីវិលនៅក្នុងការចូលរួមចំណែកកសាងប្រទេស និងនៅក្នុងការគ្រប់គ្រងសារធាតុគីមី។ ការចូលរួមនេះអាចប្រព្រឹត្តទៅដោយមានការផ្តល់ប្រឹក្សាតាមរយៈមុខងារសហគ្រប់គ្រងអនុស្សារណៈយោគយល់ កិច្ចព្រមព្រៀងភាពជាដៃគូ ការចុះកិច្ចសន្យា ការយល់ស្របជាមួយគ្នា។ល។ ជាមួយគ្នានេះដែរ សង្គមស៊ីវិលបានធ្វើសកម្មភាពការងារផ្ទាល់ជាមួយសាធារណជន ក្នុងការផ្តល់ពត៌មានពីភាពគ្រោះថ្នាក់និងកង្វល់ពីសារធាតុគីមី និងបង្ហាញពីសកម្មភាពរបស់ស្ថាប័នរដ្ឋដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់សារធាតុគីមី។ ឧទាហរណ៍លទ្ធផលនៃការស្រាវជ្រាវពីវិធានការចំរុះការពារដំណាំ ត្រូវបានផ្តល់ជូនដល់សាធារណជនតាមរយៈសិក្ខាសាលាប្រព័ន្ធឃោសនាស្រែបង្ហាញ។ល។

# ជំពូកទី ៧
# គណៈកម្មការអន្តរក្រសួង

ជំពូកនេះផ្ដល់នូវការអធិប្បាយពីគណៈកម្មការអន្តរក្រសួង ដែលមាននាទីសំរបសំរួលកិច្ចសហការ និងសហប្រតិបត្តិការក្នុងចំណោមស្ថាប័នរដ្ឋ សង្គមស៊ីវិល និងភាគីពាក់ព័ន្ធមានផលប្រយោជន៍រួម ក្នុងការងារគ្រប់គ្រងសារធាតុគីមី។ ជំពូកនេះ ក៏នឹងផ្ដល់នូវពត៌មានពីទិសដៅ និងភារកិច្ចការងាររបស់គណៈកម្មការអន្តរក្រសួងផងដែរ ។

## ៧.១ គណៈកម្មការអន្តរក្រសួង

យោងទៅលើពត៌មានក្នុងជំពូក ៤ ជំពូក ៥ និងជំពូក ៦ នៃឯកសារនេះបានបង្ហាញថា នៅកម្ពុជាមានស្ថាប័នជាច្រើនដែលមានការពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលទៅនឹងការគ្រប់គ្រងសារធាតុគីមី រួមមាន : ស្ថាប័នរដ្ឋ សង្គមស៊ីវិល ផ្នែកឯកជន ភាគីពាក់ព័ន្ធផលប្រយោជន៍រួម។ល។ ថ្វីត្បិតតែស្ថាប័ននិមួយៗមានតួនាទី និងភារកិច្ចច្បាស់លាស់ឬដោយឡែកពីគ្នាក៏ដោយ ប៉ុន្តែនៅក្នុងការអនុវត្តតួនាទីនិងភារកិច្ចពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសារធាតុគីមីរបស់ស្ថាប័នទាំងនោះ គឺនៅមានការខ្វះចន្លោះខ្លះដោយបញ្ហាមួយចំនួនគឺមិនអាចធ្វើការដោះស្រាយដោយស្ថាប័នតែមួយបានឡើយ ដូចជា ការអនុវត្តគោលនយោបាយជាតិ ការអនុវត្តអនុសញ្ញាឬពិធីសារអន្តរជាតិ ការអនុវត្តកិច្ចព្រមព្រៀងក្នុងតំបន់ ការសិក្សាស្រាវជ្រាវ ការដោះស្រាយទំនាស់ ឬវិវាទជាដើម ។

ដើម្បីដោះស្រាយនូវបញ្ហាខាងលើ ពិសេសការជំរុញការអនុវត្តគោលនយោបាយ និងបច្ចេកទេសគ្រប់គ្រងសារធាតុគីមីឱ្យមានប្រសិទ្ធិភាព យន្តការសំរបសំរួលការគ្រប់គ្រងសារធាតុគីមីត្រូវបានបង្កើតឡើងក្រោមរូបភាពជាគណៈកម្មការអន្តរក្រសួង និងជាក្រុមការងារបច្ចេកទេស ។

គណៈកម្មការអន្តរក្រសួងដែលបានបង្កើតឡើង ដើម្បីជំរុញកិច្ចសំរបសំរួលនិងសហប្រតិបត្តិការរវាងស្ថាប័នរដ្ឋនិងស្ថាប័នរដ្ឋ រវាងស្ថាប័នរដ្ឋនិងសង្គមស៊ីវិលនិងភាគីពាក់ព័ន្ធផលប្រយោជន៍រួម សំដៅជំរុញការគ្រប់គ្រងសារធាតុគីមី ឱ្យមានប្រសិទ្ធិភាព និងសុវត្ថិភាព។ ដើម្បីសំរបសំរួលកិច្ចសហប្រតិបត្តិការខាងលើគណៈកម្មការអន្តរក្រសួងមានមុខងារ ៣ សំខាន់គឺ :

ក. សំរបសំរួលការងារពាក់ព័ន្ធរបស់សាមីស្ថាប័នទាក់ទងនឹងការគ្រប់គ្រងសារធាតុគីមី និងនិតិវិធីផ្សេងៗ

ខ. សំរបសំរួល ពិនិត្យ និងផ្ដល់យោបល់លើការរៀបចំផែនការជាតិសំរាប់គ្រប់គ្រងសារធាតុគីមីរបស់សាមីស្ថាប័នពាក់ព័ន្ធ

គ. សំរបសំរួលការងារផ្លាស់ប្ដូរពត៌មាន និងបច្ចេកវិទ្យាទាក់ទងនឹងការគ្រប់គ្រងសារធាតុគីមី រវាងស្ថាប័នរដ្ឋ សង្គមស៊ីវិល និងភាគីពាក់ព័ន្ធផលប្រយោជន៍រួម ។

ពាក់ព័ន្ធនឹងការងារគ្រប់គ្រងសារធាតុគីមី រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគណៈកម្មការអន្តរក្រសួងចំនួន ៣ ដើម្បីសំរបសំរួលការងាររួមមាន :

- គណៈកម្មការអន្តរក្រសួងសំរបសំរួលការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពផលិតផល និងសេវាកម្ម ។
- គណៈកម្មការបច្ចេកទេសសំរាប់ស្តង់ដារឧស្សាហកម្ម។
- ក្រុមប្រឹក្សាភិបាលអន្តរក្រសួងទទួលបន្ទុកសំរបសំរួលការអនុវត្តអនុសញ្ញា បាសែល រ៉ូតែរដាំ និងអនុសញ្ញាស្តុកខូម ។

សមាសភាព និងភារកិច្ចទទួលខុសត្រូវពាក់ព័ន្ធនឹងការងារគ្រប់គ្រងសារធាតុគីមី របស់គណៈកម្មការខាងលើមានបរិយាយសង្ខេបនៅក្នុងតារាង ៧-១ ខាងក្រោម ។

តារាង ៧-១: គណៈកម្មការអន្តរក្រសួងពាក់ព័ន្ធនឹងការគ្រប់គ្រងសារធាតុគីមី

| ឈ្មោះយន្តការ | ភារកិច្ចទទួលខុសត្រូវសង្ខេប | លេខាធិការដ្ឋាន | ស្ថាប័នជាសមាជិក | នីតិវិធីការងារ | ប្រសិទ្ធិភាពអនុវត្ត |
|---|---|---|---|---|---|
| ១-គណៈកម្មការអន្តរក្រសួងសំរបសំរួលការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពផលិតផល និងសេវាកម្ម (៨ ឧសភា ១៩៩៨) | គណៈកម្មការមានភារៈកិច្ចៈ<br>▷ រៀបចំ បែងចែក និងសំរបសំរួលភារកិច្ចអនុវត្តរបស់ស្ថាប័នជាសមាជិក<br>▷ រៀបចំគោលនយោបាយជាតិស្តីពីគុណភាព និងសុវត្ថិភាពនៃផលិតផល និងសេវាកម្ម កិច្ចការពារផលប្រយោជន៍អ្នកប្រើប្រាស់ និងភាពស្មោះត្រង់នៃកិច្ចការជំនួញ ។<br>▷ ជាគណៈកម្មការ Codex ជាតិ ដើម្បីបំពេញរាល់ការងារបច្ចេកទេស និងការងារដទៃទៀត ដែលទាក់ទងនឹងគោលនយោបាយស្តង់ដារអន្តរជាតិលើផលិតផលម្ហូបអាហារ ។<br>▷ ទទួលភារកិច្ចដទៃទៀតដែលត្រូវបានប្រគល់ឱ្យដោយរាជរដ្ឋាភិបាល ។ | ក្រសួងពាណិជ្ជកម្ម | ១. ក្រសួងពាណិជ្ជកម្ម<br>២. ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>៣. ទីស្តីការគណៈរដ្ឋមន្ត្រី<br>៤. ក្រសួងបរិស្ថាន<br>៥. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>៦. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>៧. ក្រសួងមហាផ្ទៃ<br>៨. ក្រសួងសុខាភិបាល | សំរបសំរួល និងជួយដល់ក្រសួងនានាក្នុងការធ្វើសេចក្តីសំរេចចិត្តចំពោះការគ្រប់គ្រងគុណភាព និងសុវត្ថិភាពផលិតផល និងសេវាកម្ម | (២) |
| ២.-គណៈកម្មការបច្ចេកទេសសំរាប់ស្តង់ដារឧស្សាហកម្ម (០១ សីហា ២០០១) | ភារកិច្ចចំបងរបស់គណៈកម្មការរួមមានៈ<br>▷ ផ្តល់ពត៌មានបច្ចេកទេសអំពីស្តង់ដារូបនីយកម្ម ។<br>▷ បង្កើតវិធានការប្រឆាំងទៅនឹងការផលិត ឬលក់ទំនិញអន់គុណភាពគ្មានសុវត្ថិភាព ដែលអាចបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាព<br>▷ ធ្វើឱ្យមានការចុះសំរុងគ្នាអំពីស្តង់ដារឧស្សាហកម្មកម្ពុជា<br>▷ ពិនិត្យ កែសំរួល និងផ្តល់យោបល់លើសេចក្តីព្រាងស្តង់ដារឧស្សាហកម្មកម្ពុជា ដើម្បីដាក់ជូនរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពលសំរេច<br>▷ ធ្វើការបកស្រាយ និងពន្យល់រាល់ទំនាស់ពាក់ព័ន្ធនឹងស្តង់ដារូបនីយកម្ម | ក្រសួងឧស្សាហកម្ម | ១. ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>២. ក្រសួងពាណិជ្ជកម្ម<br>៣. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>៤. ក្រសួងសុខាភិបាល<br>៥. ក្រសួងបរិស្ថាន<br>៦. ក្រសួងសាធារណៈការ និងដឹកជញ្ជូន<br>៧. ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់<br>៨. រាជបណ្ឌិតសភាកម្ពុជា<br>១០.សាកលវិទ្យាល័យភ្នំពេញ | សំរបសំរួល ពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងស្តង់ដារឧស្សាហកម្មជាតិ និងជំរុញការអនុវត្ត | (២) |

| ឈ្មោះយន្តការ | ភារកិច្ចទទួលខុសត្រូវសង្ខេប | លេខាធិការដ្ឋាន | ស្ថាប័នជាសមាជិក | នីតិវិធីការងារ | ប្រសិទ្ធិភាពអនុវត្ត |
| --- | --- | --- | --- | --- | --- |
| | | | ១១. សាកលវិទ្យាល័យភូមិន្ទកសិកម្ម<br>១២. សាកលវិទ្យាល័យ វិទ្យាសាស្ត្រ សុខាភិបាល<br>១៣. សាកលវិទ្យាល័យបច្ចេកវិទ្យាកម្ពុជា<br>១៤.សភាពាណិជ្ជកម្មកម្ពុជា<br>១៥. វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីការអភិវឌ្ឍន៍កម្ពុជា<br>១៦. សមាគមអ្នកប្រើប្រាស់<br>១៧. សមាគមអ្នកផលិត | | |
| ៣-ក្រុមប្រឹក្សាភិបាលអន្តរក្រសួងទទួលបន្ទុកសំរបសំរួលការអនុវត្តអនុសញ្ញា បាសែល រ៉ូតែរ៉ាំ និងអនុសញ្ញាស្តុកខុម (១១/០៦/ ២០០៣) | ក្រុមប្រឹក្សាភិបាលអន្តរក្រសួង មានភារកិច្ចសំខាន់ដូចតទៅ:<br>› រៀបចំសំណើគោលនយោបាយ ច្បាប់ និងផែនការជាតិដែលទាក់ទងទៅនឹងការជំរុញការអនុវត្តអនុសញ្ញាបាសែល អនុសញ្ញារ៉ូតែរ៉ាំ និងអនុសញ្ញាស្តុកខុម ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យនិងសំរេច ។<br>› សំរបសំរួលក្នុងការជំរុញការអនុវត្តអនុសញ្ញាទាំងបី ព្រមទាំងគោលនយោបាយ ច្បាប់ និងផែនការជាតិ ដែលពាក់ព័ន្ធនឹងអនុសញ្ញាទាំងបីនោះឱ្យមានប្រសិទ្ធិភាព ។<br>› ពិនិត្យ វាយតំលៃ និងធានាថាគោលនយោបាយ និងផែនការជាតិដែលទាក់ទងទៅនឹងការជំរុញការអនុវត្តអនុសញ្ញាទាំង ៣ ឆ្លើយតបទៅនឹងបណ្តាអាទិភាព និងគោលដៅអភិវឌ្ឍន៍របស់ជាតិ ។<br>› សំរបសំរួល និងជំរុញការចូលរួមយ៉ាងទូលំទូលាយពីភាគីពាក់ពន្ធ័ទាំងអស់ក្នុងការរៀបចំគោលនយោបាយ ច្បាប់ និងផែនការជាតិដែលពាក់ព័ន្ធនឹងអនុសញ្ញាទាំង ៣ ។ | ក្រសួងបរិស្ថាន | ១. ក្រសួងបរិស្ថាន<br>២. ក្រសួងការបរទេស<br>៤. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>៥. ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>៦. ក្រសួងសុខាភិបាល<br>៧. ក្រសួងសាធារណការ និងដឹកជញ្ជូន<br>៨. ក្រសួងពាណិជ្ជកម្ម<br>៩. ក្រសួងទេសចរណ៍<br>១០. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>១១. ទីចាត់ការគយ និងរដ្ឋាករ<br>១២. សាលាក្រុងភ្នំពេញ<br>១៣. ក្រសួងមហាផ្ទៃ<br>១៤. អាជ្ញាធរអគ្គិសនីកម្ពុជា | សំរបសំរួល និងជួយដល់បណ្តាក្រសួងក្នុងការអនុវត្តកាតព្វកិច្ចនៅក្រោមអនុសញ្ញា បាសែល រ៉ូតែរ៉ាំ និងស្តុកខុម | (២) |

| ឈ្មោះយន្តការ | ភារកិច្ចទទួលខុសត្រូវសង្ខេប | លេខាធិការដ្ឋាន | ស្ថាប័នជាសមាជិក | និតិវិធីការងារ | ប្រសិទ្ធិភាពអនុវត្ត |
| --- | --- | --- | --- | --- | --- |
| | ➤ កំណត់នូវគោលការណ៍ និងយុទ្ធសាស្ត្រ សំរាប់ដាក់ជូនរាជរដ្ឋាភិបាលធ្វើការចរចារនៅក្នុងកិច្ចប្រជុំអន្តរជាតិពាក់ព័ន្ធនឹងអនុសញ្ញាទាំង ៣ ។<br>➤ ស្វះស្វែងរកនូវធនធានដែលចាំបាច់សំរាប់ជំរុញការអនុវត្តផែនការជាតិដែលពាក់ព័ន្ធនឹងកាតព្វកិច្ចនៃភាគីជាសមាជិករបស់អនុសញ្ញាទាំង ៣ ។<br>➤ លើកកំពស់ការយល់ដឹង និងផ្សព្វផ្សាយពត៌មានជូនដល់ថ្នាក់ដឹកនាំស្ថាប័ន ក៏ដូចជាសាធារណជនទូទៅស្តីពីគោលការណ៍ និងកាតព្វកិច្ចដែលត្រូវបំពេញនៅក្រោមអនុសញ្ញាទាំង ៣ ។<br>➤ ចូលរួមកិច្ចប្រជុំ និងសិក្ខាសាលាថ្នាក់ជាតិ តំបន់ និងអន្តរជាតិ លើបញ្ហាដែលពាក់ពន្ធ័នឹងអនុសញ្ញាទាំង ៣ ។ ណែនាំនិងសំរបសំរួលបណ្តាគំរោងកម្មវិធីនិងសកម្មភាពស្រាវជ្រាវពាក់ព័ន្ធនឹងអនុសញ្ញាទាំង ៣ ។<br>➤ ត្រួតពិនិត្យ និងអនុមត័លើផែនការ និងរបាយការណ៍លទ្ធផលការងារគំរោង ឬកម្មវិធីនៅក្រោមបទបញ្ញត្តិនៃអនុសញ្ញាទាំង ៣ ។ | | ១៥. វិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍កសិកម្មកម្ពុជា<br>១៦. អង្គការមួបបៃតង | | |

*កំណត់សំគាល់* : (១) ល្អណាស់ (២) បង្គួរ (៣) អន់ខ្សោយ

គណៈកម្មការអន្តរក្រសួងដែលបានរៀបរាប់ខាងលើ ត្រូវបានបង្កើតឡើងក្រោមរូបភាពជាលក្ខណៈប្រមូលផ្តុំថ្នាក់ជាតិ ដែលសមាជិកនៃគណៈកម្មការអន្តរក្រសួង ឬយន្តការសំរបសំរួលត្រូវបានអញ្ជើញមកពីស្ថាប័នរដ្ឋពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល និងវិទ្យាស្ថានជាតិនានា ។ ចំពោះបេក្ខភាពប្រធាន ជាទូទៅត្រូវបានប្រគល់ជូនស្ថាប័នបង្គោលធ្វើជាអ្នកដឹកនាំ ។ គណៈកម្មការអន្តរក្រសួងមានអាណត្តិអចិន្ត្រៃយ៍ ហើយសមាជិកភាពរបស់សមាជិកនិមួយៗនៅក្នុងគណៈកម្មការ ក៏មានសុពលភាពជារៀងរហូតដែរ លើកលែងតែមានសំណើផ្លាស់ប្តូរពីសាមីអង្គភាព ឬពីគណៈកម្មការអន្តរក្រសួងនោះ ។

ក្រៅពីមានតួនាទីជាប្រធាន ស្ថាប័នបង្គោលត្រូវទទួលបន្ទុកជាលេខាធិការដ្ឋានសំរាប់គណៈកម្មការផងដែរ ។ លេខាធិការដ្ឋានមានតួនាទីសំខាន់ក្នុងការរៀបចំកិច្ចប្រជុំរបស់គណៈកម្មការអន្តរក្រសួង ឬសំរបសំរួល ព្រមទាំងចាត់ចែងរាល់ការងាររដ្ឋបាលទូទៅទៀតផង ។ លើសពីនេះទៀត ដើម្បីជួយការងាររបស់គណៈកម្មការអន្តរក្រសួងលើការងារបច្ចេកទេស ក្រុមការងារបច្ចេកទេសត្រូវបានបង្កើតឡើងទៅតាមតំរូវការជាក់ស្តែង ហើយដែលសមាជិកនៃក្រុមការងារត្រូវបានអញ្ជើញមកពីស្ថាប័នពាក់ព័ន្ធតាមសំណើរបស់ប្រធានគណៈកម្មការ ។

ទាក់ទងទៅនឹងតួនាទី និងភារកិច្ចលំអិតរបស់គណៈកម្មការអន្តរក្រសួងលើការងារគ្រប់គ្រងសារធាតុគីមី ត្រូវបានកំណត់ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល ឬប្រកាសរបស់ស្ថាប័នបង្គោល ។

ទោះបីជាយន្តការទាំង ៣ ខាងលើ មានភារកិច្ចសំរបសំរួលការងារគ្រប់គ្រងសារធាតុគីមី ដូចបានរៀបរាប់ខាងលើក្តី ក៏ការអនុវត្តភារកិច្ចសំរបសំរួលទាំងនោះនៅមានភាពខ្វះចន្លោះមួយចំនួន ដែលទាក់ទងទៅនឹងការខ្វះយន្តការទទួលយកមតិយោបល់ពីសាធារណជន ក៏ដូចជាបណ្តាភាគីពាក់ព័ន្ធផលប្រយោជន៍រួម ក្នុងការរៀបចំគោលនយោបាយឬសេចក្តីសំរេចផ្សេងៗដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសារធាតុគីមី ។ យោងតាមបទពិសោធន៍បានបង្ហាញឱ្យឃើញថា លុះត្រាតែអ្នកនាំចូល និងអ្នកប្រើប្រាស់សារធាតុគីមីបានចូលជាសមាជិកគណៈកម្មការ ទើបពួកគេអាចមានសិទ្ធក្នុងការជំទាស់នូវគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលដែលមិនសមស្រប ។

## ៧.២ យន្តការសំរាប់ទទួលមតិយោបល់ពីសង្គមស៊ីវិល

ទាក់ទងនឹងគណៈកម្មការអន្តរក្រសួងទាំង ៣ ខាងលើ កម្ពុជាបានបើកទូលាយឱ្យមានការចូលរួមជាសាធារណៈរួមមាន :

### ៧.២.១ ការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាល

មានអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន បានធ្វើការងារពាក់ព័ន្ធលើវិស័យគ្រប់គ្រងសារធាតុគីមី ដែលសេវាកម្មរបស់គេភាគច្រើនផ្តោតទៅលើការតាមដានការអនុវត្តគោលនយោបាយគ្រប់គ្រងសារធាតុគីមីរបស់រដ្ឋាភិបាល និងប្រមូលពត៌មានពីការប្រើប្រាស់សារធាតុគីមីដែលបង្កឱ្យមានផលប៉ះពាល់ទៅលើសុខភាព និងបរិស្ថាន ដើម្បីផ្តល់ជាអនុសាសន៍ដល់ស្ថាប័នរដ្ឋពាក់ព័ន្ធសំរាប់ពិចារណានិងចាត់វិធានការដោះស្រាយ ។ ទន្ទឹមនោះ សេវាកម្មល្អរបស់អង្គការទាំងនោះ គឺការផ្តល់ចំណេះដឹងជាមូលដ្ឋានដល់កសិករពីសុវត្ថិភាពនៃការប្រើប្រាស់ថ្នាំសំលាប់សត្វល្អិត និងជីគីមី ។ ជារួម យើងសង្កេតឃើញថាការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសារធាតុគីមី គឺនៅមិនទាន់សកម្មខ្លាំងក្លានិងស្ថិតក្នុងទ្រង់ទ្រាយតូច ទាំងក្នុងកិច្ចសហគមន៍ និងក្នុងតួនាទីតស៊ូមតិរបស់សាធារណជនអំពីសារធាតុគីមី ។

### ៧.២.២ ការចូលរួមរបស់សាធារណជន

កម្ពុជាក៏បានផ្តល់ឱកាសផងដែរឱ្យសាធារណជនចូលរួមក្នុងការបញ្ចេញមតិ និងការផ្តល់ព័ត៌មានដែលទាក់ទងនឹងការប្រើប្រាស់ និងគ្រោះថ្នាក់បង្កដោយសារធាតុគីមី ប៉ុន្តែការចូលរួមនៅមានកំរិត ។ បច្ចុប្បន្ន សាធារណជនកាន់តែមានការចាប់អារម្មណ៍ច្រើនពីផលប៉ះពាល់ទៅលើសុខភាព ។

## ៧.៣ យោបល់ និងការវិភាគ

ការអនុវត្តនូវភារកិច្ចរបស់គណៈកម្មការដែលមាន គឺពុំទាន់បានទទួលប្រសិទ្ធភាពខ្ពស់នៅឡើយ ដោយសារមានកង្វះខាតនូវបទពិសោធន៍ ប្រភពធនធានថវិកា និងយន្តការសំរាប់គាំទ្រដំណើរការរបស់គណៈកម្មការ ពោលគឺប្រតិបត្តិការងាររបស់លេខាធិការដ្ឋាន និងក្រុមការងារនៃគណៈកម្មការទាំងនោះមិនទាន់សកម្មនៅឡើយ ។ ម្យ៉ាងវិញទៀត ការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលទៅលើការងាររបស់គណៈកម្មការនៅមានកំរិត ។

ស្ថាប័នជាសមាជិករបស់គណៈកម្មការបានចូលរួមត្រឹមតែជាអ្នកផ្តល់នូវព័ត៌មាន ឬជាយោបល់តាមរយៈការប្រជុំឬការស្នើរបស់គណៈកម្មការតែប៉ុណ្ណោះ ហើយគណៈកម្មការទៀតសោតមិនបានធ្វើការប្រជុំ ឬធ្វើកិច្ចការប្រចាំថ្ងៃទៀងទាត់ទេ ពោលគឺធ្វើម្តងម្កាលតាមការចាំបាច់ ។

ជារួម ភារកិច្ចរបស់យន្តការដែលមានស្រាប់ មិនបានគ្របដណ្តប់ទៅលើរាល់បញ្ហាសារធាតុគីមីសំខាន់ៗទាំងស្រុងទេ ពោលគឺបានគ្របដណ្តប់ទៅលើសារធាតុគីមីដែលមាននៅក្នុងផលិតផលម្ហូបអាហារ លើបទដ្ឋាននៃកំរិតសារធាតុគីមីដែលមាននៅក្នុងផលិតផលឧស្សាហកម្ម និងសារធាតុគីមីដែលមានចែងនៅក្នុងអនុសញ្ញាអន្តរជាតិមួយចំនួនតែប៉ុណ្ណោះ ។ ដើម្បីបង្កើនការគ្រប់គ្រងសារធាតុគីមីទូទៅ កម្ពុជាគួរតែរៀបចំបង្កើតយន្តការសំរបសំរួលបន្ថែម ឬក៏ពង្រីកតួនាទីរបស់យន្តការដែលមានស្រាប់សំដៅធ្វើការគ្រប់គ្រងសារធាតុគីមីគ្រប់ប្រភេទ គ្រប់វដ្តទាំងអស់នៃសារធាតុគីមី ចាប់ពីការផលិត នាំចូល ចែកចាយ ប្រើប្រាស់ និងបោះបង់ចោល ។ ហេតុផលដែលស្នើបង្កើតឡើងនូវយន្តការសំរបសំរួលបន្ថែម ឬពង្រីកតួនាទីរបស់យន្តការដែលមានស្រាប់ គឺដោយសារតែបច្ចុប្បន្ននេះ យន្តការដែលមានស្រាប់បានធ្វើការដាច់ដោយឡែកពីគ្នា និងមិនមានការផ្លាស់ប្តូរព័ត៌មាននឹងគ្នាឱ្យបានញឹកញាប់ទេ ។

ចំពោះការផ្លាស់ប្តូរព័ត៌មានរវាងយន្តការមួយទៅយន្តការមួយទៀត គឺមិនមានជាប្រចាំទេ តែមានលក្ខណៈសាមញ្ញតាមការស្នើសុំ តាមរយៈការផ្តល់ឯកសារឱ្យគ្នាទៅវិញទៅមក ដែលភាគច្រើនជាឯកសារសំណេរ ដោយសារយន្តការនិមួយៗមិនមានទំនាក់ទំនងគ្នាជាបណ្តាញនៅក្នុងការបំពេញភារកិច្ច ក៏ដូចជាការផ្លាស់ប្តូរព័ត៌មាននិងបទពិសោធន៍ ។

# ជំពូកទី ៨
# ការទទួលបាន និងការប្រើប្រាស់ទិន្នន័យ

គោលបំណងសំខាន់នៅក្នុងជំពូកនេះ គឺផ្តល់ឱ្យនូវទស្សនៈទូទៅនៃលទ្ធភាពទិន្នន័យដែលមានសំរាប់ធ្វើការគ្រប់គ្រងសារធាតុគីមី រចនាសម្ព័ន្ធ និងវិភាគពីរបៀបដែលពត៌មានទាំងនោះត្រូវបានគេប្រើប្រាស់សំរាប់កាត់បន្ថយគ្រោះថ្នាក់ ដែលបណ្តាលមកពីសារធាតុគីមីនៅក្នុងក៏រិតជាតិ និងមូលដ្ឋាន។

## ៨.១ ទិន្នន័យដែលមានសំរាប់ការគ្រប់គ្រងសារធាតុគីមី

ការប្រមូល ចងក្រងពត៌មាន និងទិន្នន័យដែលទាក់ទងនឹងការគ្រប់គ្រងសារធាតុគីមី គឺមានការអនុវត្តតិចតួចណាស់ អាស្រ័យដោយកង្វះខាតធនធាន ការស្រាវជ្រាវ និងយុទ្ធសាស្ត្រគ្រប់គ្រងពត៌មាន។ ម្យ៉ាងវិញទៀត ការចងក្រងពត៌មាន និងទិន្នន័យលើវិស័យជំនាញរបស់ខ្លួនទាក់ទងនឹងការគ្រប់គ្រងសារធាតុគីមី នៅតាមបណ្តាស្ថាប័នរដ្ឋក៏មិនសូវនិយមអនុវត្ត ដែលជាហេតុធ្វើឱ្យមានកង្វះខាតពត៌មាន និងទិន្នន័យសំរាប់ការប្រើប្រាស់ទាំងបច្ចុប្បន្ននិងអនាគត។ ដោយឡែក ចំពោះពត៌មានដែលមានស្រាប់ គឺភាគច្រើនមិនសូវបានផ្សព្វផ្សាយឱ្យបានទូលំទូលាយទេ ហើយភាគច្រើនគឺស្ថិតនៅដោយឡែកៗតាមស្ថាប័នទទួលខុសត្រូវនិមួយៗ ។ ជាមួយគ្នានេះដែរ ការផ្លាស់ប្តូរពត៌មាននិងទិន្នន័យស្តីពីសារធាតុគីមី រវាងស្ថាប័នរដ្ឋនិងស្ថាប័នរដ្ឋ ឬស្ថាប័នរដ្ឋជាមួយសង្គមស៊ីវិល គឺច្រើនធ្វើឡើងតាមរយៈការស្នើសុំតែប៉ុណ្ណោះនិងក្នុងទំរង់ជាឯកសារសំណេរ ។

ឯកសារសំណេរដែលស្ថាប័នរដ្ឋបានបោះពុម្ពផ្សាយ គឺភាគច្រើនជារបាយការណ៍ប្រចាំឆ្នាំ របាយការណ៍អង្កេត និងអត្ថបទស្រាវជ្រាវ ។ រាល់ឯកសារសំណេរទាំងអស់ កម្រមានបរិយាយលំអិតពីបញ្ហាដែលពាក់ព័ន្ធទៅនឹងសារធាតុគីមីណាស់ ពោលគឺមានអធិប្បាយតែពីបញ្ហាបច្ចេកទេស ដែលទាក់ទងនឹងការងារបច្ចេកទេសរបស់ស្ថាប័នសាម៉ី។ ទោះជាយ៉ាងណាក៏ដោយទាក់ទិននឹងសារធាតុគីមី យើងអាចរកបានឯកសារសំណេរមួយចំនួនដូចមានរៀបរាប់នៅក្នុងតារាង ៨-១ ខាងក្រោម។

តារាង ៨-១: គុណភាព និងបរិមាណពត៌មានដែលអាចរកបាន

| ទិន្នន័យដែលត្រូវការដើម្បី | ថ្នាំសំលាប់សត្វល្អិត (សំរាប់កសិកម្ម សុខាភិបាល អ្នកប្រើ ) | សារធាតុគីមីឧស្សាហកម្ម | សារធាតុគីមីប្រើប្រាស់តាមផ្ទះ | សំណល់គីមី | សារធាតុគីមីដែលត្រូវហាមឃាត់ |
|---|---|---|---|---|---|
| ការកំណត់អាទិភាពនៃបញ្ហា | X | X | X | NA | FA |
| ការវាយតំលៃផលប៉ះពាល់ដោយសារធាតុគីមីតាមលក្ខខ័ណ្ឌក្នុងស្រុក | NA | NA | NA | NA | NA |
| ការវាយតំលៃភាពគ្រោះថ្នាក់ ( បរិស្ថាន /សុខភាព ) | NA | NA | NA | NA | NA |
| ការចាត់ថ្នាក់/ស្លាកសញ្ញា | X | NA | X | NA | X |
| ការចុះបញ្ជី | X | NA | NA | NA | X |
| ការផ្តល់អាជ្ញាប័ណ្ណ | X | NA | NA | NA | NA |

| ទិន្នន័យដែលត្រូវការដើម្បី | ថ្នាំសំលាប់សត្វល្អិត (សំរាប់កសិកម្ម សុខាភិបាល អ្នកប្រើ) | សារធាតុគីមីឧស្សាហកម្ម | សារធាតុគីមីប្រើប្រាស់តាមផ្ទះ | សំណល់គីមី | សារធាតុគីមីដែលត្រូវហាមឃាត់ |
|---|---|---|---|---|---|
| ការអនុញ្ញាត | X | X | NA | NA | NA |
| ការសំរេចចិត្តដើម្បីកាត់បន្ថយភាពគ្រោះថ្នាក់ | X | NA | NA | X | NA |
| ការចាត់វិធានការក្នុងពេលមានគ្រោះថ្នាក់ | NA | NA | NA | NA | NA |
| ការត្រួតពិនិត្យការពុល | NA | NA | NA | NA | NA |
| ការធ្វើសារពើភ័ណ្ឌការបញ្ចេញចោលទៅក្នុងខ្យល់ | NA | NA | NA | NA | NA |
| ការធ្វើអធិការកិច្ច និងសវនៈកម្ម (បរិស្ថាន និង សុខភាព) | NA | NA | NA | NA | NA |
| ការផ្តល់ពត៌មានដល់កម្មករ (រួមទាំងកសិករ) | X | NA | X | NA | NA |
| ការផ្តល់ពត៌មានដល់សាធារណជន | X | NA | X | X | X |

*សំគាល់*: FA : ដែលអាចរកបានទាំងស្រុង X : ដែលអាចរកបានតែមិនពេញលេញ NA : កម្រ ឬមិនអាចរកបាន

## ៨.២ ទីកន្លែងទិន្នន័យជាតិ

ទាក់ទងទៅនឹងទិន្នន័យជាតិពាក់ព័ន្ធសារធាតុគីមី កម្ពុជាពុំទាន់បានរៀបចំទីកន្លែងសំរាប់ទទួលទុកដាក់ជាប្រព័ន្ធជាតិ ដែលអាចផ្តល់ពត៌មានបានគ្រប់គ្រាន់ និងទាន់ពេលវេលានៅឡើយទេ។ ដូច្នេះហើយ ឯកសារទិន្នន័យសំណេរជាច្រើនត្រូវបានរក្សាទុកដោយឡែកៗនៅតាមស្ថាប័នពាក់ព័ន្ធ ហើយជាទូទៅគឺស្ថិតនៅតាមការិយាល័យជំនាញរបស់ស្ថាប័នទាំងនោះ។ មានន័យថា នៅពេលដែលឯកសារបច្ចេកទេសត្រូវបានបង្កើតដោយក្រសួង ឬការិយាល័យផ្នែកជំនាញណាមួយហើយ ឯកសារសំណេរទាំងនោះមិនត្រូវបានចែកចាយឱ្យទូលំទូលាយទៅកាន់ស្ថាប័នពាក់ព័ន្ធដទៃទេ ពោលគឺបានចែកចាយត្រឹមថ្នាក់ក្រសួងសាមីផ្ទាល់ ហើយជួនកាលបានផ្តល់ទៅស្ថាប័នរដ្ឋដទៃតាមការយល់ឃើញ ឬតាមការស្នើសុំពីស្ថាប័នដែលត្រូវការ។ លើសពីនេះទៀត ឯកសារមួយចំនួនដែលបានបោះពុម្ពរួចដោយស្ថាប័នរដ្ឋ ឬសង្គមស៊ីវិល ច្រើនតែទុកឯកសារសំណេរនៅក្នុងបណ្ណាល័យរបស់ស្ថាប័នខ្លួន គឺមិនបានផ្ញើរទៅដំកល់ទុកនៅបណ្ណាល័យជាតិ ឬបណ្ណាល័យណាមួយរបស់គ្រឹះស្ថានសិក្សាទេ ទោះបីជាកម្ពុជាមានបណ្ណាល័យជាតិមួយ និងបណ្ណាល័យគ្រឹះស្ថានសិក្សាតិចតួចក៏ដោយ ។

ម៉្យាងវិញទៀត រាល់ការទុកដាក់ឯកសារ គឺមិនសូវមានការធ្វើចំណាត់ថ្នាក់តាមលំដាប់កូដ ឬក្បួនបណ្ណាល័យទេ ដែលជាហេតុធ្វើឱ្យមានការលំបាកក្នុងការរកឯកសារសំណេរមកសិក្សា។ ជាមួយគ្នានេះដែរ ក៏មានកង្វះខាតក្នុងការធ្វើស្ថិតិអ្នកអាន ឬអ្នកស្រាវជ្រាវដែលបានយកឯកសារនេះមកសិក្សា ស្ថិតិប្រភេទឯកសារ និងស្ថិតិតំរូវការឯកសារជាដើម ។ល។

ចំពោះឯកសារជាអេឡិចត្រូនិចវិញ គឺមានតិចជាងឯកសារសំណេរ ឬឯកសារបោះពុម្ព ដោយសារនៅមានការខ្វះខាតកុំព្យូទ័រដែលសំរាប់ប្រើជាប្រព័ន្ធផ្ទុកនិងចែកចាយពត៌មានទិន្នន័យ និងជំនាញក្នុងការគ្រប់គ្រងឯកសារអេឡិចត្រូនិចនៅមានកំរិត។ រាល់ឯកសារអេឡិចត្រូនិចដែលមាន គឺច្រើនតែរក្សាទុកនៅក្នុងកុំព្យូទ័រផ្ទាល់របស់ស្ថាប័នជំនាញនិមួយៗ និងអាចរកបានតាមរយៈការស្នើសុំតែប៉ុណ្ណោះ។ លើសពីនេះទៀត ការទុកដាក់ពត៌មាននៅតាមគេហទំព័ររបស់ស្ថាប័នរដ្ឋ ក៏មិនសូវបានអនុវត្តឱ្យបានទូលំទូលាយនៅឡើយទេ។ ប៉ុន្តែ ទោះបីជាមានការខ្វះខាតខ្លះៗដូចមានរៀបរាប់ខាងលើ ក៏ពត៌មានទិន្នន័យទាក់ទងសារធាតុគីមីអាចរកបាននៅតាមទីកន្លែងដូចមានសង្ខេបបង្ហាញនៅក្នុងតារាង ៨-២ ខាងក្រោម។

តារាង ៨-២: ទីកន្លែងពត៌មាន និងទិន្នន័យជាតិ

| ប្រភេទទិន្នន័យ | ទីកន្លែង | ប្រភពទិន្នន័យ | អ្នកអាចទទួល | វិធីទទួលទិន្នន័យ | ទ្រង់ទ្រាយ |
|---|---|---|---|---|---|
| ស្ថិតិផលិតកម្ម | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ស្ថិតិនាំចូល | • ក្រសួងពាណិជ្ជកម្ម (នាយកដ្ឋានកាំកុងត្រូល) | • របាយការណ៍ប្រចាំឆ្នាំ<br>• របាយការណ៍សន្និបាតក្រសួង | • គ្រប់មជ្ឈដ្ឋាន | • សំណើសុំ | • ឯកសារពុម្ព |
| | • ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ទីចាត់ការគយ និងរដ្ឋាករ) | • របាយការណ៍ប្រចាំឆ្នាំ<br>• របាយការណ៍សន្និបាតក្រសួង | • គ្រប់មជ្ឈដ្ឋាន | • សំណើសុំ | • ឯកសារអេឡិចត្រូនិច |
| | • វិទ្យាស្ថានជាតិស្ថិតិ | • សៀវភៅស្ថិតិប្រចាំឆ្នាំ<br>• របាយការណ៍ប្រចាំឆ្នាំ | • គ្រប់មជ្ឈដ្ឋាន | • សំណើសុំ | • ឯកសារអេឡិចត្រូនិច<br>• ឯកសារពុម្ព |
| | • ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | • របាយការណ៍សន្និបាតក្រសួង | • គ្រប់មជ្ឈដ្ឋាន | • សំណើសុំ | • ឯកសារពុម្ព |
| | • ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | • របាយការណ៍ប្រចាំឆ្នាំ<br>• របាយការណ៍សន្និបាតក្រសួង | • គ្រប់មជ្ឈដ្ឋាន<br>• គ្រប់មជ្ឈដ្ឋាន | • សំណើសុំ | • ឯកសារពុម្ព<br>• ឯកសារពុម្ព |
| | • ក្រសួងសុខាភិបាល | • របាយការណ៍ប្រចាំឆ្នាំ | • គ្រប់មជ្ឈដ្ឋាន | • សំណើសុំ | • ឯកសារពុម្ព |
| ស្ថិតិនាំចេញ | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ស្ថិតិប្រើប្រាស់គីមី | • ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានកៀតសាស្ត្រ) | • របាយការណ៍ប្រចាំឆ្នាំ | • គ្រប់មជ្ឈដ្ឋាន | • សំណើសុំ | • ឯកសារពុម្ព |
| | • ក្រសួងសុខាភិបាល | • របាយការណ៍ប្រចាំឆ្នាំ | • គ្រប់មជ្ឈដ្ឋាន | • សំណើសុំ | • ឯកសារពុម្ព |
| របាយការណ៍គ្រោះថ្នាក់ផ្នែកឧស្សាហកម្ម | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |

| ប្រភេទទិន្នន័យ | ទីកន្លែង | ប្រភពទិន្នន័យ | អ្នកអាចទទួល | វិធីទទួលទិន្នន័យ | ទ្រង់ទ្រាយ |
|---|---|---|---|---|---|
| របាយការណ៍គ្រោះថ្នាក់ក្នុងការដឹកជញ្ជូន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ទិន្នន័យសុខភាពការងារ (កសិកម្ម) | • ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | • របាយការណ៍ប្រចាំឆ្នាំ | • គ្រប់មជ្ឈដ្ឋាន | • សំណើសុំ | • ឯកសារពុម្ព |
| | • វិទ្យាស្ថានជាតិស្ថិតិ | • របាយការណ៍សន្និបាតក្រសួង | • គ្រប់មជ្ឈដ្ឋាន | • សំណើសុំ | • ឯកសារអេឡិចត្រូនិច<br>• ឯកសារពុម្ព |
| | • ក្រសួងសុខាភិបាល | • សៀវភៅស្ថិតិប្រចាំឆ្នាំ<br>• កំនត់ត្រារបស់មន្ទីរពេទ្យ | • គ្រប់មជ្ឈដ្ឋាន | • សំណើសុំ<br>• ទិញ | • ឯកសារអេឡិចត្រូនិច<br>• ឯកសារពុម្ព |
| ទិន្នន័យសុខភាពការងារ (ឧស្សាហកម្ម) | • វិទ្យាស្ថានជាតិស្ថិតិ | • សៀវភៅស្ថិតិប្រចាំឆ្នាំ<br>• របាយការណ៍ប្រចាំឆ្នាំ | • គ្រប់មជ្ឈដ្ឋាន | • សំណើសុំ<br>• ទិញ | • ឯកសារអេឡិចត្រូនិច<br>• ឯកសារពុម្ព |
| | • ក្រសួងសុខាភិបាល | • របាយការណ៍សន្និបាតក្រសួង<br>• ផែនការសកម្មភាពជាតិ<br>• កំណត់ត្រារបស់មន្ទីរពេទ្យ | • គ្រប់មជ្ឈដ្ឋាន | • សំណើសុំ<br>• ទិញ | • ឯកសារអេឡិចត្រូនិច<br>• ឯកសារពុម្ព |
| ស្ថិតិការពុល | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ការបញ្ចេញសារធាតុពុល ការផ្ទេរ និងការចុះបញ្ជី | • ក្រសួងបរិស្ថាន | • របាយការណ៍ប្រចាំឆ្នាំ<br>• របាយការណ៍សន្និបាតក្រសួង<br>• ផែនការសកម្មភាពជាតិ<br>• សារពើភណ្ឌការបញ្ចេញសារធាតុពុល | • គ្រប់មជ្ឈដ្ឋាន | • សំណើសុំ<br>• ទិញ | • ឯកសារអេឡិចត្រូនិច<br>• ឯកសារពុម្ព |

| ប្រភេទទិន្នន័យ | ទីកន្លែង | ប្រភពទិន្នន័យ | អ្នកអាចទទួល | វិធីទទួលទិន្នន័យ | ទម្រង់ទ្រាយ |
|---|---|---|---|---|---|
| ទិន្នន័យសំណល់គ្រោះថ្នាក់ | • ក្រសួងបរិស្ថាន | • របាយការណ៍ប្រចាំឆ្នាំ<br>• របាយការណ៍សន្និបាតក្រសួង<br>• ផែនការសកម្មភាពជាតិ<br>• សារពើភណ្ឌការបញ្ចេញសារធាតុពុល | • គ្រប់មជ្ឈដ្ឋាន | • សំណើសុំ<br>• ទិញ | • ឯកសារអេឡិចត្រូនិច<br>• ឯកសារពុម្ព |
| ការចុះបញ្ជីថ្នាំកសិកម្ម | • ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | • របាយការណ៍ប្រចាំឆ្នាំ<br>• របាយការណ៍សន្និបាតក្រសួង | • គ្រប់មជ្ឈដ្ឋាន | • សំណើសុំ | • ឯកសារពុម្ព |
| ការចុះបញ្ជីសារធាតុគីមីពុល | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| សារពើភ័ណ្ឌសារធាតុគីមីដែលមានស្រាប់ | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ការចុះបញ្ជីការនាំចូល | • ក្រសួងពាណិជ្ជកម្ម នាយកដ្ឋានកាំកុងត្រូល<br>• ក្រសួងសុខាភិបាល<br>• ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | • របាយការណ៍ប្រចាំឆ្នាំ<br>• របាយការណ៍សន្និបាតក្រសួង<br>• របាយការណ៍សន្និបាតក្រសួង | • គ្រប់មជ្ឈដ្ឋាន<br>• គ្រប់មជ្ឈដ្ឋាន<br>• គ្រប់មជ្ឈដ្ឋាន | • សំណើសុំ | • ឯកសារពុម្ព<br>• ឯកសារពុម្ព<br>• ឯកសារពុម្ព |
| ការចុះបញ្ជីអ្នកផលិត | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ការសំរេចចិត្តរបស់PIC | • ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋាននីតិកម្មកសិកម្ម) | • ឯកសារអនុសញ្ញា<br>• របាយការណ៍ និងនិតិវិធី | • គ្រប់មជ្ឈដ្ឋាន | • ថតចំលង | • ឯកសារពុម្ព |
| ការសំរេចចិត្តរបស់ POPs | • ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>• ក្រសួងពាណិជ្ជកម្ម នាយកដ្ឋានកាំកុងត្រូល<br>• ក្រសួងបរិស្ថាន<br>• ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល<br>• ក្រសួងសុខាភិបាល | • របាយការណ៍ប្រចាំឆ្នាំ<br>• របាយការណ៍សន្និបាតក្រសួង<br>• ផែនការសកម្មភាពជាតិ<br>• បញ្ជីសារពើភ័ណ្ឌលែងមានការបំពុល<br>• កំនត់ហេតុនាំចូលជាតិគីមី | • គ្រប់មជ្ឈដ្ឋាន | • សំណើសុំ | • ឯកសារអេឡិចត្រូនិច<br>• ឯកសារពុម្ព |

សូមបញ្ជាក់ថា ពត៌មានទិន្នន័យទាក់ទងនឹងសារធាតុគីមីដែលបង្ហាញក្នុងតារាងខាងលើ គឺនៅមានការខ្វះខាតច្រើន ដូចជានៅក្នុងផ្នែកខ្លះនៃឯកសារទាំងនោះ មិនមានប្រធានបទដែលនិយាយចំៗពីការគ្រប់គ្រងសារធាតុគីមី ដោយសារតែការយល់ដឹង និងមធ្យោបាយសំរាប់ការរៀបចំនៅមានកំរិត ។

## ៨.៣ នីតិវិធីសំរាប់ប្រមូល និងចែកចាយទិន្នន័យជាតិ

កម្ពុជាមិនទាន់មានបទបញ្ញត្តិច្បាប់តំរូវឱ្យធ្វើការចងក្រង ឬចែកចាយទិន្នន័យ និងពត៌មានទាក់ទងនឹងការគ្រប់គ្រងសារធាតុគីមីនៅឡើយទេ ។ ជាទូទៅ ស្ថាប័នរដ្ឋនិមួយៗធ្វើការចងក្រងពត៌មាន ឬទិន្នន័យពាក់ព័ន្ធនឹងសារធាតុគីមីអាស្រ័យទៅតាមតំរូវការចាំបាច់របស់ស្ថាប័នខ្លួនតែប៉ុណ្ណោះ ហើយពត៌មាន និងទិន្នន័យនេះទៀតសោត ក៏មិនបានធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដែរ ។

លើសពីនេះទៀត កម្ពុជាក៏មិនបានធ្វើការប្រមូល ចងក្រង និងរក្សាទុកនូវពត៌មានទាក់ទងទៅនឹងឥទ្ធិពលនៃសារធាតុគីមីទៅលើសុខភាពមនុស្ស និងបរិស្ថានទេ ទោះបីកម្ពុជាបានជួបប្រទះនូវបញ្ហានេះក៏ដោយចុះ។ ឧទាហរណ៍ កន្លងមកមានករណីសន្លប់កម្មកររោងចក្រកាត់ដេររហូតដល់ច្រើននាក់ តែការសិក្សាលំអិតទៅលើការពុលឬគ្រោះថ្នាក់នេះមិនត្រូវបានធ្វើឱ្យបានស៊ីជំរៅទេ ពោលគឺគ្រាន់តែធ្វើរបាយការណ៍ ឬកំណត់ហេតុតែប៉ុណ្ណោះ ។ ស្ថាប័នរដ្ឋដែលជាអ្នកធ្វើកំណត់ត្រាឬរបាយការណ៍ លើការពុលនេះ ជាទូទៅមានមន្ត្រីនគរបាល មន្ត្រីក្រសួងសុខាភិបាល និងមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈប្រចាំខេត្ត-ក្រុង ។

ចំពោះវិធីសាស្ត្រក្នុងការប្រមូលពត៌មាន និងទិន្នន័យទាក់ទងនឹងការគ្រប់គ្រងសារធាតុគីមី គឺអាចអនុវត្តតាមវិធី ២ យ៉ាង : ជាផ្លូវការ និងមិនផ្លូវការ។ វិធីស្រាវជ្រាវពត៌មានសង្គមជាផ្លូវការរួមមានៈ ការស្រាវជ្រាវ ការសិក្សា ការអង្កេត ការត្រួតពិនិត្យ និងការពិសោធន៍ឬវិភាគ ។ ចំណែកនីតិវិធីយកពត៌មានដែលមិនផ្លូវការអាចទាក់ទិនទៅនឹងវិធីដូចខាងក្រោម :

- អង្កេតពត៌មានពីសមាជិកសហគមន៍ ឬពីសមាជិករដ្ឋាភិបាលណាដែលត្រូវចូលរួមក្នុងគំរោង ឬសកម្មភាពដែលពាក់ព័ន្ធ ។
- ធ្វើការសិក្សាស្រាវជ្រាវ និងកម្មសិក្សាផ្ទាល់ ។
- ប្រើប្រាស់មនុស្សដែលសំខាន់នៅក្នុងសហគមន៍ ឬក្នុងក្រសួងរបស់រដ្ឋាភិបាលដើម្បីផ្តល់ពត៌មាន ។
- ធ្វើការពិភាក្សាជាក្រុម ។
- ធ្វើបទសំភាសន៍ម្នាក់ៗ

## ៨.៤ លទ្ធភាពរកឯកសារពត៌មានអន្តរជាតិ

ការរកឯកសារពត៌មានអន្តរជាតិ គឺភាគច្រើនធ្វើឡើងតាមរយៈការសាកសួររកនៅតាមការិយាល័យអង្គការអន្តរជាតិដែលពាក់ព័ន្ធនឹងការងារនោះ ឬអាចរកនៅតាមបណ្ណាគារនិងតូបលក់សៀវភៅ។ ប៉ុន្តែការរកឯកសារពត៌មានរបៀបនេះ គឺទទួលបានផលប្រយោជន៍តិចតួច ។ ទោះជាយ៉ាងណាក៏ដោយ ចាប់តាំងពីកម្ពុជាមានលទ្ធភាពប្រើប្រាស់ប្រព័ន្ធអ៊ីនធើណែតមក ការរកឯកសារពត៌មានអន្តរជាតិ គឺច្រើនតែធ្វើតាមរយៈអ៊ីនធើណែត ឬចូលទៅគេហទំព័ររបស់ស្ថាប័នអន្តរជាតិទាំងនោះ។ តារាង ៨-៣ ខាងក្រោមនេះ គឺបង្ហាញពីលទ្ធភាពនៃការរកឯកសារពត៌មានអន្តរជាតិនៅកម្ពុជា។

តារាង ៨-៣: លទ្ធភាពឯកសារពត៌មានអន្តរជាតិ

| ឯកសារពត៌មាន | ទីកន្លែង | អ្នកអាចទទួល | វិធីសាស្ត្រទទួល |
|---|---|---|---|
| ឯកសារវិនិច្ឆ័យពីសុខភាព-បរិស្ថាន (Environmental Health Criteria Documents, WHO) | ការិយាល័យអង្គការសុខភាពពិភពលោកប្រចាំកម្ពុជា | សាធារណជនទូទៅ | ខ្ចីពីបណ្ណាល័យ<br>សំណើរសុំឬទិញ<br>អ៊ីនធឺណែត |
| គោលការណ៍ណែនាំពីសុខភាព និងសុវត្ថិភាព (Health and Safety Guides, WHO) | ការិយាល័យអង្គការសុខភាពពិភពលោកប្រចាំកម្ពុជា | សាធារណជនទូទៅ | ខ្ចីពីបណ្ណាល័យ<br>សំណើរសុំឬទិញ<br>អ៊ីនធឺណែត |
| ឯកសារទិន្នន័យសុវត្ថិភាពគីមីអន្តរជាតិ (International Chemical Safety Data Cards, IPCS / EC) | - | - | អ៊ីនធឺណែត |
| ឯកសារណែនាំធ្វើការសំរេចចិត្តក្នុងការជូនដំណឹងជាមុនពីចរាចរសារធាតុគីមី (Decision Guidance Document for PIC Chemicals (FAO/UNEP) | - ការិយាល័យអង្គការកសិកម្ម និងស្បៀងអាហារប្រចាំកម្ពុជា<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សាធារណជនទូទៅ | ខ្ចីពីបណ្ណាល័យ<br>សំណើរសុំឬទិញ<br>អ៊ីនធឺណែត |
| តារាងទិន្នន័យសុវត្ថិភាពថ្នាំសំលាប់សត្វល្អិតរបស់អង្គការ FAO/WHO (FAO/WHO Pesticides Safety Data Sheets) | - | - | អ៊ីនធឺណែត |
| ឯកសារនៃកិច្ចប្រជុំរួមរបស់អង្គការ FAO/WHO ពីសំណល់ថ្នាំកសិកម្ម (Documents from the FAO/WHO Joint Meeting on Pesticide Residues) | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សាធារណជនទូទៅ | ខ្ចីពីបណ្ណាល័យ<br>សំណើរសុំឬទិញ<br>អ៊ីនធឺណែត |
| តារាងទិន្នន័យសំភារៈការពារសុវត្ថិភាព (ឧស្សាហកម្ម) (Material Safety Data Sheets, Industry) | - | - | អ៊ីនធឺណែត |
| គោលការណ៍ណែនាំវិភាគសារធាតុគីមីរបស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD Guidelines for the Testing of Chemicals) | - | - | អ៊ីនធឺណែត |
| គោលការណ៍អនុវត្តប្រសើរសំរាប់មន្ទីរពិសោធន៍ (Good Laboratory Practice Principles) | - | - | អ៊ីនធឺណែត |
| គោលការណ៍អនុវត្តប្រសើរសំរាប់សហគ្រាសផលិត (Good Manufacturing Practice Principles) | អាស៊ាន ក្រសួងសុខាភិបាល នាយកដ្ឋានឱសថ និងម្ហូបអាហារ | សាធារណជនទូទៅ | ខ្ចីពីបណ្ណាល័យ<br>សំណើរសុំឬទិញ<br>អ៊ីនធឺណែត |
| បណ្តាញបណ្ណាល័យបរិស្ថានពិភពលោករបស់អង្គការ WHO/UNEP (WHO/UNEP Global Env. Library Network) | - | - | អ៊ីនធឺណែត |

## ៨.៥ លទ្ធភាពរកទិន្នន័យមូលដ្ឋានអន្តរជាតិ

នៅកម្ពុជា លទ្ធភាពរកទិន្នន័យមូលដ្ឋានអន្តរជាតិ គឺអាចរកបានតែតាមរយៈអ៊ីនធឺណែតតែប៉ុណ្ណោះ ។

តារាង ៨-៤ : លទ្ធភាពរកទិន្នន័យមូលដ្ឋានអន្តរជាតិ

| ទិន្នន័យមូលដ្ឋាន | ទីកន្លែង | អ្នកអាចទទួល | វិធីសាស្ត្រទទួល |
|---|---|---|---|
| អង្គការពលកម្មអន្តរជាតិ<br>(International Labor Organization, International Occupational Safety and Health Information Centre, ILO) | ប្រទេសស្វីស | អ្នកចាប់អារម្មណ៍ | អ៊ីនធឺណែត |
| កម្មវិធីអន្តរជាតិស្តីពីសុវត្ថិភាពគីមី<br>(International Program on Chemical Safety, Information on Toxic, INTOX) | មិនស្គាល់ | អ្នកចាប់អារម្មណ៍ | អ៊ីនធឺណែត |
| សេវាកម្មទិន្នន័យសង្ខេបនៃសារធាតុគីមី<br>(Chemical Abstract Services Database) | សហរដ្ឋអាមេរិក | អ្នកចាប់អារម្មណ៍ | អ៊ីនធឺណែត |
| បណ្តាញព័ត៌មានសកលស្តីពីសារធាតុគីមី<br>(Global Information Network on Chemicals) | ប្រទេសជប៉ុន | អ្នកចាប់អារម្មណ៍ | អ៊ីនធឺណែត |
| ទិន្នន័យពីបណ្តាញព័ត៌មានវិទ្យាសាស្ត្រ និងបច្ចេកទេស<br>(Scientific and Technical Information Network, STN Database) | មិនស្គាល់ | អ្នកចាប់អារម្មណ៍ | អ៊ីនធឺណែត |
| ទិន្នន័យពាក់ព័ន្ធដែលផ្លាស់ប្តូរជាមួយប្រទេសដទៃ<br>(Relevant Databases from Other Countries) | មិនស្គាល់ | អ្នកចាប់អារម្មណ៍ | អ៊ីនធឺណែត |

## ៨.៦ ប្រព័ន្ធផ្លាស់ប្តូរព័ត៌មានជាតិ

ថ្មីៗនេះរាជរដ្ឋាភិបាលកម្ពុជាបានបង្កើតបណ្តាញផ្លាស់ប្តូរព័ត៌មានតាមក្រសួង ហើយចាត់ទុកថាជាមធ្យោបាយបឋមនៃការប្រមូលផ្តុំ និងចែកចាយព័ត៌មានដែលជាទិសដៅឈានទៅមុខរបស់កម្ពុជា ។ បណ្តាញព័ត៌មាននេះ គ្រប់គ្រងដោយរាជរដ្ឋាភិបាលកម្ពុជាដែលគាំទ្រកម្មវិធីដោយអាជ្ញាធរជាតិសំរាប់ការអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មាន ហើយអាជ្ញាធរនេះបានបង្កើតឡើងដោយអនុក្រឹត្យ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០០ ។

រាជរដ្ឋាភិបាលកម្ពុជានឹងបន្តផ្តល់ព័ត៌មានទាំងឡាយដែលទាក់ទងការគ្រប់គ្រងសារធាតុគីមី ជូនដល់សាធារណជនតាមបណ្តាញព័ត៌មានដែលមាន ដោយបង្ហាញពីបច្ចេកទេសប្រើប្រាស់គីមី ពីព័ត៌មានខាងច្បាប់ តាមរយៈការប្រតិបត្តិ ការថែរក្សា និងការពង្រីកព័ត៌មានឱ្យសមស្របបន្ទាប់ពីបញ្ចប់ការរៀបចំទិន្នន័យមូលដ្ឋាន ស្តីពីសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុនេះទៅ។

គួរកត់សំគាល់ថា ការបញ្ចេញព័ត៌មានរវាងបណ្តាអង្គការអន្តរជាតិនានា និងដៃគូរបស់គេក្នុងប្រទេសកម្ពុជា គឺកើតឡើងដោយឯករាជ្យក្នុងស្ថាប័ននីមួយៗ អនុលោមទៅតាមកិច្ចព្រមព្រៀងសកម្មភាព និងសារៈប្រយោជន៍របស់ខ្លួន។ ទោះបីជារដ្ឋាភិបាលបានបង្កើតនូវបណ្តាញព័ត៌មានរួចហើយក្តី ប៉ុន្តែការផ្លាស់ប្តូរព័ត៌មានរវាងក្រសួងនានា ក្រុមសាធារណជនដែលចាប់អារម្មណ៍ និងបណ្តាអង្គការមិនមែនរដ្ឋាភិបាល មិនទាន់បានប្រព្រឹត្តទៅតាមរយៈបណ្តាញព័ត៌មាននេះទេ ។

ការផ្លាស់ប្តូរព័ត៌មានច្រើនតែធ្វើឡើងជាផ្លូវការ និងមិនផ្លូវការតាមការប្រជុំ សិក្ខាសិលា ការបណ្តុះបណ្តាល ការអនុវត្តគំរោងកម្មវិធីប្រព័ន្ធឃោសនាផ្សព្វផ្សាយ យន្តការសំរបសំរួល និងការបោះពុម្ពផ្សាយដែលទាក់ទិនព័ត៌មានទូទៅ ក៏ដូចជាការ

គ្រប់គ្រងសារធាតុគីមី ។ វិធីនេះមានគោលបំណងធ្វើការផ្លាស់ប្តូរពត៌មានគ្នាទៅវិញទៅមកដោយផ្ទាល់ ដើម្បីធ្វើឱ្យប្រសើរឡើងដល់កិច្ចសហប្រតិបត្តិការទាំងក្នុងចំណោមស្ថាប័នរដ្ឋាភិបាល និងសាធារណជនទូទៅ។ អ្នកធ្វើបវកថាជាឯកជន និងជាសាធារណៈកំពុងអភិវឌ្ឍន៍ផ្នែកអ៊ីនធឺណែត ដែលរួមមានពត៌មានទាក់ទងនឹងស្ថាប័នរដ្ឋាភិបាលនិងសាធារណៈ ។

រដ្ឋាភិបាលនឹងខិតខំប្រឹងប្រែងសំរបសំរួលព្រមទាំងផលិតពត៌មានឱ្យមានលក្ខណៈបច្ចេកទេស និងមានទ្រង់ទ្រាយដែលអាចទទួលយកបាន ដើម្បីបំពេញសេចក្តីត្រូវការជាសាធារណៈឱ្យបានទូលំទូលាយតាមលទ្ធភាពដែលមាន ។ រដ្ឋាភិបាលបាននឹងកំពុងពិចារណា និងត្រួតពិនិត្យតាមដាន វាយតំលៃ ប្រមូល និងធ្វើការកែលំអនូវពត៌មានស្តីពីការគ្រប់គ្រងសារធាតុគីមីឱ្យល្អប្រសើរ ។

## ៨.៧ យោបល់ និងការពិភាក្ស

- ពត៌មាន ស្តីពី ការគ្រប់គ្រងសារធាតុគីមីគឺត្រូវកំណត់ក្រោមកិច្ចសហប្រតិបត្តិការរវាងអន្តរក្រសួង និងមានផលប្រយោជន៍ទៅវិញទៅមក ប៉ុន្តែពត៌មានទាំងនោះនៅតែមានភាពខ្វះចន្លោះ ហើយមានការលំបាកក្នុងការប្រមូលដោយមូលហេតុមួយចំនួន ។
- តាមទំលាប់របស់ក្រសួងនិមួយៗ គឺមិនសូវចង់រួមចំណែកផ្តល់ពត៌មានទេ ។ ហេតុដូច្នេះហើយបានជាគេធ្វើការប្រមូលទិន្នន័យតាមក្រសួងតែរៀងៗខ្លួន ហើយរក្សាទុកឆ្ងាយពីផលប្រយោជន៍រួម ទន្ទឹមនោះការមិនបានឆ្លងកាត់ដំណើរការពិគ្រោះយោបល់លើពត៌មាន និងទិន្នន័យសារធាតុគីមីដែលប្រមូលបាន ដែលធ្វើឱ្យពត៌មានខ្លះនៅតែខ្វះខាត ហើយមួយចំនួនជាន់គ្នាដដែលៗ ។
- ប្រព័ន្ធផ្លាស់ប្តូរពត៌មានជាតិដូចដែលបានបង្ហាញគឺគ្រាន់តែជាបណ្តាញពត៌មានរដ្ឋទើបតែបង្កើត មិនទាន់បានបញ្ចូលប្រព័ន្ធទិន្នន័យមូលដ្ឋានស្តីពីការគ្រប់គ្រងសារធាតុគីមី ហើយក៏មិនអាចរកពត៌មានគីមីតាមរយៈបណ្តាញពត៌មានបានដែរ ។
- ពត៌មានគីមីដែលមានស្រាប់បានរក្សាទុកក្នុងក្រសួង ៦ សំខាន់ៗ : គឺក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងបរិស្ថាន ក្រសួងសុខាភិបាល និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។
- សំរាប់ទិសដៅរយៈពេលមធ្យមបណ្តាញពត៌មានរដ្ឋស្តីពីសារធាតុគីមីនេះ គឺបង្កើតឱ្យមានការផ្លាស់ប្តូរជាលក្ខណៈប្រព័ន្ធ ហើយសាធារណជនអាចទទួល និងផ្តល់មកវិញនូវបទពិសោធន៍ដែលជាមូលដ្ឋានសំខាន់សំរាប់ការអនុវត្តផែនការជាតិគ្រប់គ្រងគីមី សំរាប់វាយតំលៃផលប៉ះពាល់បណ្តាលមកពីសារធាតុគីមី និងសំរាប់ធ្វើឱ្យប្រសើរឡើងនូវការសំរបសំរួលគំរោងគ្រប់គ្រងសារធាតុគីមីទាំងឡាយដែលមាន ។
- សំរាប់ទស្សនៈរាជរដ្ឋាភិបាល ពត៌មានស្តីពី សារធាតុគីមីដែលប្រមូលបានក្នុងកំរងពត៌មានជាតិ និងពត៌មានដទៃទៀតដែលបានរក្សាទុកក្នុងក្រសួងពាក់ព័ន្ធ និងត្រូវបញ្ចូលទៅក្នុងកុំព្យូទ័របន្តទៅក្នុងបណ្តាញពត៌មានរបស់រដ្ឋាភិបាល ហើយគុណភាពនៃពត៌មានស្តីពីសារធាតុគីមី ក៏នឹងត្រូវគិតពិចារណាផងដែរ ។
- ការកសាងសមត្ថភាពសំរាប់ការគ្រប់គ្រងពត៌មានស្តីពី សារធាតុគីមីនិងបច្ចេកវិទ្យា គឺត្រូវបានចាត់ទុកជាអាទិភាពសំរាប់ឆ្ពោះទៅកាន់នយោបាយបើកទូលាយផ្នែកទិន្នន័យមូលដ្ឋានរបស់ជាតិនិងអន្តរជាតិ ។

# ជំពូកទី ៩
# របាយការណ៍សង្ខេបបច្ចេកទេស

ជំពូកនេះផ្តល់នូវព័ត៌មានទូទៅពីរចនាសម្ព័ន្ធបច្ចេកទេស ដែលទាក់ទងទៅនឹងការវិភាគសារធាតុគីមី និងផលិតផលរបស់វា ។ ជាមួយគ្នានេះដែរ ជំពូកនេះនឹងបង្ហាញពីប្រព័ន្ធព័ត៌មាននិងសមត្ថភាពកុំព្យូទ័រដែលមាននៅក្នុងមន្ទីរពិសោធន៍ជាតិ និងពីកម្មវិធីនិងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដែលទាក់ទងទៅនឹងសារធាតុគីមី ។

## ៩.១ រចនាសម្ព័ន្ធមន្ទីរពិសោធន៍សារធាតុគីមី

ពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធបច្ចេកទេស សំរាប់ការវិភាគសារធាតុគីមីនិងផលិតផលរបស់វា កម្ពុជាមានមន្ទីរពិសោធន៍រដ្ឋធំៗចំនួន ៦ ដែលស្ថិតនៅតាមស្ថាប័នរដ្ឋផ្សេងៗគ្នា រួមមាន : ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងពាណិជ្ជកម្ម ក្រសួងបរិស្ថាន ក្រសួងសុខាភិបាល ក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល និងក្រសួងធនធានទឹកនិងឧតុនិយម ដែលមានមុខងារនិងភារកិច្ចដោយឡែកពីគ្នាក្នុងការវិភាគសារធាតុគីមីនានា ។

បច្ចុប្បន្ន ប្រទេសកម្ពុជាបាននឹងកំពុងផ្តោតការយកចិត្តទុកដាក់លើការពង្រឹងសមត្ថភាពមន្ទីរពិសោធន៍ តាមរយៈការបំពាក់ឧបករណ៍និងសំភារៈផ្សេងៗទៀត និងការបណ្តុះបណ្តាលធនធានមនុស្ស សំដៅជំរុញសមត្ថភាពទទួលខុសត្រូវពាក់ព័ន្ធការវិភាគនិងការគ្រប់គ្រងសារធាតុគីមីឱ្យមានភាពកាន់តែសុក្រឹត្យ ។ ប៉ុន្តែ ទោះបីជាមានការខិតខំជួយគាំទ្រលើការងារពង្រឹងសមត្ថភាពមន្ទីរពិសោធន៍ពីសំណាក់រាជរដ្ឋាភិបាល ស្ថាប័នសាមី និងពីអង្គការផ្តល់ជំនួយនានាក៏ដោយ ក៏សមត្ថភាពមន្ទីរពិសោធន៍នៅកម្ពុជាទាំងនោះគឺនៅមានកំរិត ទាំងគ្រឿងបរិក្ខារ និងបច្ចេកទេសវិភាគ ហើយដែលការខ្វះខាតនេះចាំបាច់ត្រូវមានការយកចិត្តទុកដាក់និងដោះស្រាយជាបន្ទាន់ ប្រសិនបើមានឆន្ទៈក្នុងការជំរុញការត្រួតពិនិត្យនិងគ្រប់គ្រងសារធាតុគីមី ដែលធានាបាននូវសុវត្ថិភាពសុខភាពសាធារណៈ និងបរិស្ថាន ។

មុខងារ និងភារកិច្ចរបស់មន្ទីរពិសោធន៍សារធាតុគីមីនៃក្រសួងទាំង ៦ ក្នុងពេលបច្ចុប្បន្ន មានសង្ខេបបង្ហាញនៅក្នុងចំនុចខាងក្រោម ។

### ៩.១.១ មន្ទីរពិសោធន៍នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

មន្ទីរពិសោធន៍នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺស្ថិតនៅក្រោមការគ្រប់គ្រង និងប្រតិបត្តិដោយនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្ម និងនាយកដ្ឋាននីតិកម្មកសិកម្ម ដែលមានភារកិច្ចទទួលខុសត្រូវក្នុងការជួយលើកកំពស់ផលិតកម្មកសិកម្ម តាមរយៈការផ្តល់ឱ្យនូវសេវាកម្មបច្ចេកទេស និងសកម្មភាពប្រតិបត្តិក្នុងការវិភាគគុណភាពដីកសិកម្ម គុណភាពជីគីមីការជ្រើសនិងវេចខ្ចប់ថ្នាំសំលាប់សត្វល្អិត និងវិភាគសំណល់ ។ ការវិភាគថ្នាំកសិកម្មនិងជីគីមី គឺបានផ្តល់នូវទិន្នន័យបច្ចេកទេសដើម្បីគាំទ្រដល់ការត្រួតពិនិត្យនិងការចុះបញ្ជីថ្នាំកសិកម្មនិងជីគីមី ។ ទិន្នន័យទាំងនេះក៏មានសារៈប្រយោជន៍ផងដែរសំរាប់ការបណ្តុះបណ្តាលដល់កសិករ ដែលជាអ្នកប្រើប្រាស់ផ្ទាល់ជាមួយសារធាតុគីមីទាំងនោះ ។

### ៩.១.២ មន្ទីរពិសោធន៍នៃក្រសួងពាណិជ្ជកម្ម

មន្ទីរពិសោធន៍នៃក្រសួងពាណិជ្ជកម្ម គឺស្ថិតនៅក្រោមការគ្រប់គ្រង និងប្រតិបត្តិផ្ទាល់របស់នាយកដ្ឋានកាំកុងត្រូល ដែលមានភារកិច្ចទទួលខុសត្រូវក្នុងការជួយលើកកំពស់គុណភាពទំនិញនាំចេញនិងនាំចូល និងធ្វើចរាចរក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការវិភាគរកសារធាតុគីមីនៅក្នុងផលិតផលប្រើប្រាស់ និងផលិតផលម្ហូបអាហារ ដើម្បីធានាការអនុវត្តច្បាប់ បទដ្ឋានផលិតផល និងការផ្តល់សេវាកម្មប្រកបដោយប្រសិទ្ធិភាព ។

### ៩.១.៣ មន្ទីរពិសោធន៍នៃក្រសួងបរិស្ថាន

មន្ទីរពិសោធន៍នៃក្រសួងបរិស្ថាន គឺស្ថិតនៅក្រោមការគ្រប់គ្រង និងប្រតិបត្តិដោយនាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន ដែលមានភារកិច្ចទទួលខុសត្រូវក្នុងការគាំទ្រដល់សកម្មភាពត្រួតពិនិត្យគុណភាពបរិស្ថាន និងវាយតំលៃការបំពុល ដែលបង្កដោយប្រភពបញ្ចេញសំណល់ទូទៅ ពោលគឺមន្ទីរពិសោធន៍នេះដើរតួយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យសំណល់គីមី ត្រួតពិនិត្យគុណភាពបរិស្ថាន និងវិភាគលើសំណាកជីវសាស្ត្រសំរាប់គោលបំណងអភិរក្សជីវចំរុះ ។

### ៩.១.៤ មន្ទីរពិសោធន៍នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

មន្ទីរពិសោធន៍នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល គឺស្ថិតនៅក្រោមការគ្រប់គ្រង និងប្រតិបត្តិដោយនាយកដ្ឋានបច្ចេកទេសឧស្សាហកម្ម ដែលមានភារកិច្ចទទួលខុសត្រូវក្នុងការជួយត្រួតពិនិត្យនិងបង្កើនគុណភាពផលិតផលឧស្សាហកម្មក្នុងស្រុក ធ្វើអត្តសញ្ញាណសារធាតុគីមីដែលបំរើឱ្យផលិតកម្មក្នុងវិស័យឧស្សាហកម្ម ព្រមទាំងវិភាគសំណល់រាវឧស្សាហកម្ម។ មន្ទីរពិសោធន៍នេះធ្វើការយ៉ាងជិតស្និទ្ធជាមួយវិស័យឧស្សាហកម្ម សំដៅវិភាគគុណភាពផលិតផលឧស្សាហកម្ម និងចូលរួមក្នុងការត្រួតពិនិត្យស្តង់ដារឧស្សាហកម្មដោយផ្អែកលើច្បាប់ និងបទបញ្ញត្តិស្តីពីការគ្រប់គ្រងឧស្សាហកម្ម ។

### ៩.១.៥ មន្ទីរពិសោធន៍ជាតិត្រួតពិនិត្យគុណភាពឱសថនៃក្រសួងសុខាភិបាល

មន្ទីរពិសោធន៍ជាតិត្រួតពិនិត្យគុណភាពឱសថនៃក្រសួងសុខាភិបាល គឺស្ថិតនៅក្រោមការគ្រប់គ្រង និងប្រតិបត្តិដោយអគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល ដែលមានភារកិច្ចទទួលខុសត្រូវយ៉ាងជាក់លាក់ក្នុងការត្រួតពិនិត្យគុណភាពឱសថ សារធាតុគីមីសំរាប់ផលិតឱសថនិងវិភាគវេជ្ជសាស្ត្រ គ្រឿងសំអាង និងចំណីអាហារ ។

### ៩.១.៦ មន្ទីរពិសោធន៍នៃក្រសួងធនធានទឹកនិងឧតុនិយម

មន្ទីរពិសោធន៍របស់ក្រសួងធនធានទឹកនិងឧតុនិយម គឺស្ថិតនៅក្រោមការគ្រប់គ្រង និងប្រតិបត្តិដោយនាយកដ្ឋានជលសាស្ត្រ ដែលមានភារកិច្ចទទួលខុសត្រូវក្នុងការរកអត្តសញ្ញាណសារធាតុគីមី ដែលមាននៅក្នុងសំណាកទឹកនៅតាមប្រភពទឹកសាធារណៈ និងវិភាគគុណភាពដី ។ មន្ទីរពិសោធន៍នេះផ្តល់អាទិភាពចំពោះវិស័យពាក់ព័ន្ធនានាក្នុងប្រទេសកម្ពុជា ដើម្បីធ្វើការរួមគ្នាក្នុងដំណើរការវិភាគគុណភាពប្រភពទឹកសាធារណៈនិងដី។ មន្ទីរពិសោធន៍នេះផ្តល់នូវសេវាកម្មនិងគាំទ្រនូវសារៈសំខាន់នៃការរៀបចំយុទ្ធសាស្ត្រដើម្បីរុករកនិងគ្រប់គ្រងធនធានទឹកនិងដី ព្រមទាំងទទួលយកនូវរាល់សំណើផ្សេងៗពីវិស័យពាក់ព័ន្ធដើម្បីវិភាគគុណភាពធនធានទឹកនិងដី ។

ផ្អែកលើតួនាទី និងការទទួលខុសត្រូវរបស់បណ្តាមន្ទីរពិសោធន៍នៃស្ថាប័នរដ្ឋដូចបានរៀបរាប់ខាងលើ កម្ពុជាពុំទាន់មានមន្ទីរពិសោធន៍ដែលមានសមត្ថភាពវិភាគលើសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុឡើយ ។ បញ្ហាសំខាន់ៗ រួមមាន :

- ខ្វះកិច្ចសហប្រតិបត្តិការល្អរវាងមន្ទីរពិសោធន៍ និងមន្ទីរពិសោធន៍ និងជាមួយភាគីពាក់ព័ន្ធផលប្រយោជន៍រួមដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងប្រភពសាយភាយនៃសារធាតុគីមីទូទៅ និងជាពិសេសសារធាតុពុលមិនងាយបំបែកធាតុ (Persistent Toxic Substances, PTS) ។
- ខ្វះធនធានមនុស្សក្នុងដំណើរការមន្ទីរពិសោធន៍ និងខ្វះជំនាញបច្ចេកទេសក្នុងការវិភាគ ។
- ខ្វះឧបករណ៍ និងបរិក្ខារវិភាគ ដែលអាចគួរឱ្យទុកចិត្តបានទៅលើលទ្ធផលវិភាគ ។

រចនាសម្ព័ន្ធនៃមន្ទីពិសោធន៍របស់រដ្ឋសំខាន់ៗទាំង ៦ មានបង្ហាញសង្ខេបក្នុងតារាង៩-១ ខាងក្រោម ។

តារាង ៩-១: រចនាសម្ព័ន្ធមន្ទីរពិសោធន៍សំរាប់វិភាគសារធាតុគីមី

| ឈ្មោះ មន្ទីរពិសោធន៍ | អាសយដ្ឋាន | ឧបករណ៍វិភាគសំខាន់ៗ | វិញ្ញាបនប័ត្រទទួលស្គាល់សមត្ថភាព | វិញ្ញាបនប័ត្រការអនុវត្តន៍ល្អ GLP | គោលបំណង |
|---|---|---|---|---|---|
| មន្ទីរពិសោធន៍នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អាគារលេខ ១០ វិថីមុន្នីរ៉េត ខ័ណ្ឌចំការមន ក្រុងភ្នំពេញ<br>ទូរស័ព្ទ : (៨៥៥) ១២ ៨៧១ ៨៥៦<br>អាគារលេខ ២០០ មហាវិថីព្រះនរោត្តម...... | HPLC<br>SP<br>GC | គ្មាន | គ្មាន | វិភាគគុណភាពជីគីមី និងថ្នាំកសិកម្ម |
| មន្ទីរពិសោធន៍នៃក្រសួងពាណិជ្ជកម្ម | អាគារលេខ ៥០ ផ្លូវលេខ 144 ក្រុងភ្នំពេញ<br>ទូរស័ព្ទ/ទូរសារ:<br>(៨៥៥) ២៣ ៤២៦ ១៦៦ | AAS<br>UV/Vis<br>GC<br>HPLC | គ្មាន | គ្មាន | វិភាគផលិតផលប្រើប្រាស់ សារធាតុនិងផលិតផលគីមី និងម្ហូបអាហារ |
| មន្ទីរពិសោធន៍នៃក្រសួងបរិស្ថាន | អាគារលេខ ៤៨ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ទូរស័ព្ទ/ទូរសារ:<br>(៨៥៥) ២៣ ២១០ ៤៩២<br>Email: moelab@online.com.kh | AAS<br>SP | គ្មាន | គ្មាន | វិភាគសំណាកបរិស្ថាន (ទឹក ដី ខ្យល់ និងសំណាកជីវសាស្ត្រ) និងវិភាគសំណល់គ្រប់ប្រភេទ |
| មន្ទីរពិសោធន៍នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | អាគារលេខ ៤៥ វិថីព្រះនរោត្តម ខណ្ឌដូនពេញ ក្រុងភ្នំពេញ<br>ទូរស័ព្ទ/ទូរសារ:<br>(៨៥៥) ២៣ ៤២៨ ២៦៣<br>Email: hcscambodia@yahoo.com | SP | គ្មាន | គ្មាន | វិភាគគុណភាពផលិតផលរោងចក្រនិងសិប្បកម្ម ធ្វើអត្តសញ្ញាណសារធាតុគីមីដែលបំរើឱ្យផលិតកម្មក្នុងវិស័យឧស្សាហកម្ម និងវិភាគសំណល់រាវរោងចក្រ |

| ឈ្មោះ មន្ទីរពិសោធន៍ | អាសយដ្ឋាន | ឧបករណ៍ វិភាគ សំខាន់ៗ | វិញ្ញាបនប័ត្រ ទទួលស្គាល់ សមត្ថភាព | វិញ្ញាបនប័ត្រ ការអនុវត្តន៍ល្អ GLP | គោលបំណង |
|---|---|---|---|---|---|
| មន្ទីរពិសោធន៍ជាតិ ត្រួតពិនិត្យគុណភាព ឱសថនៃក្រសួង សុខាភិបាល | អាគារលេខ ៣៦ ផ្លូវហ្សកឌឺមីត្រូវ ក្រុងភ្នំពេញ<br>ទូរស័ព្ទ: (៨៥៥) ២៣ ៨៨០ ៧៣២<br>(៨៥៥) ១២ ៨១០ ៧២០ | HPLC<br>SP<br>TLC<br>UV<br>GC | គ្មាន | គ្មាន | វិភាគគុណភាពឱសថ សារធាតុគីមី និងចំណីអាហារ ដែលនាំចូល-ចេញ ផលិត និងកំពុងចរាចរ ក្នុងស្រុក |
| មន្ទីរពិសោធន៍នៃក្រសួង ធនធានទឹក និងឧតុនិយម | ផ្លូវជាតិលេខ២ សង្កាត់ចាក់អង្រែក្រោម ខ័ណ្ឌមានជ័យ<br>ទូរស័ព្ទ: (៨៥៥) ២៣ ៧២៤ ៣៨៩ | AAS<br>SP<br>FP | គ្មាន | គ្មាន | វិភាគគុណភាពប្រភពទឹក សាធារណៈ និងគុណភាពដី |

## ៩.២ ប្រព័ន្ធព័ត៌មាន និងសមត្ថភាពកុំព្យូទ័រ

ការប្រើប្រាស់បរិក្ខាបច្ចេកវិទ្យាព័ត៌មាន ដូចជាកុំព្យូទ័រ និងបណ្តាញព័ត៌មានតាមកុំព្យូទ័រ (Network) ទើបតែចាប់ផ្តើមជាលើកដំបូងនៅកម្ពុជានាចុងទសវត្សឆ្នាំ ១៩៩០ ដែលភាគច្រើននៃការប្រើប្រាស់ទាំងនេះ គឺទៅលើការងាររដ្ឋបាលតែប៉ុណ្ណោះ។ ចំពោះការទុកដាក់ឯកសារបច្ចេកទេសនៅក្នុងកុំព្យូទ័រ និងចែកចាយតាមបណ្តាញព័ត៌មានកុំព្យូទ័រវិញ គឺមានតែនៅផ្ទៃក្នុងរបស់ស្ថាប័នរដ្ឋនីមួយៗ និងមិនមានលក្ខណៈទូលាយទាំងស្រុងនៅឡើយ ។

នៅក្រោយឆ្នាំ ២០០០ រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមយុទ្ធនាការបំពាក់បរិក្ខាបច្ចេកវិទ្យាព័ត៌មាន (កុំព្យូទ័រ និងបណ្តាញព័ត៌មានតាមកុំព្យូទ័រ) និងបណ្តាញអ៊ីនធឺណែតដល់ស្ថាប័នរដ្ឋទូទៅ តែការបំពាក់នេះនៅមានកំរិតនៅឡើយទាំងផ្នែកបរិមាណនៃបរិក្ខា សេវាកម្ម បច្ចេកទេស និងសមត្ថភាពធនធានមនុស្ស ហើយដែលការបំពាក់នោះ គឺភាគច្រើនសំរាប់បំរើការងាររដ្ឋបាល។ កុំព្យូទ័រដែលបំពាក់ដោយរាជរដ្ឋាភិបាលត្រូវបានតភ្ជាប់ជាបណ្តាញ និងមានលទ្ធភាពប្រើប្រាស់សារអេឡិចត្រូនិកនិងអ៊ីនធឺណែតបាន។

ទោះជាយ៉ាងណាក៏ដោយ ការរក្សាព័ត៌មានបច្ចេកទេសនៅក្នុងកុំព្យូទ័រដែលតជាបណ្តាញនោះ នៅមិនទាន់អនុវត្តនៅឡើយទេ ដោយសារបញ្ហាកង្វះខាតប្រព័ន្ធចែកចាយព័ត៌មាន ខ្វះខាតបច្ចេកទេស ធនធានមនុស្សគ្រប់គ្រង។ល។ ដូច្នេះហើយ ព័ត៌មានបច្ចេកទេសជាទូទៅត្រូវបានរក្សាទុកនៅក្នុងកុំព្យូទ័រផ្ទាល់ខ្លួន (Personal Computer) នៅតាមស្ថាប័នបច្ចេកទេសនីមួយៗ។ តារាង ៩-២ ខាងក្រោមនេះ នឹងបង្ហាញពីបរិក្ខាបច្ចេកវិទ្យាព័ត៌មាននិងប្រភេទនៃកម្មវិធី (Software) ដែលមាននៅតាមស្ថាប័នរដ្ឋនីមួយៗ។

តារាង ៩-២: សមត្ថភាពប្រើប្រាស់កុំព្យូទ័រ

| ប្រព័ន្ធ និងកម្មវិធី ទិន្នន័យសំរាប់កុំព្យូទ័រ | ទីកន្លែង | សេរី (សមត្ថភាព) | ការប្រើប្រាស់បច្ចុប្បន្ន |
|---|---|---|---|
| Window XP<br>Office XP | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | Desktop Pentium IV | • បញ្ចូល និងរក្សាទុកទិន្នន័យ<br>• ភ្ជាប់បណ្តាញអ៊ីនធឺណែត |

| ប្រព័ន្ធ និងកម្មវិធី ទិន្នន័យសំរាប់កុំព្យូទ័រ | ទីកន្លែង | សេរី (សមត្ថភាព) | ការប្រើប្រាស់បច្ចុប្បន្ន |
|---|---|---|---|
| Window 2000 Office 2000 | ក្រសួងពាណិជ្ជកម្ម | Desktop Pentium II and III | • បញ្ចូល និងរក្សាទុកទិន្នន័យ<br>• ភ្ជាប់បណ្តាញអ៊ីនធឺណែត |
| Window 2000 Office 2000 | ក្រសួងបរិស្ថាន | Desktop Pentium II and III | • បញ្ចូល និងរក្សាទុកទិន្នន័យ<br>• ភ្ជាប់បណ្តាញអ៊ីនធឺណែត |
| Window 2000 Office 2000 | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | Desktop Pentium II and III | • បញ្ចូល និងរក្សាទុកទិន្នន័យ<br>• ភ្ជាប់បណ្តាញអ៊ីនធឺណែត |
| Window 2000 Office 2000 | ក្រសួងសុខាភិបាល | Desktop Pentium II and III | • បញ្ចូល និងរក្សាទុកទិន្នន័យ<br>• ភ្ជាប់បណ្តាញអ៊ីនធឺណែត |

## ៩.៣ កម្មវិធីអប់រំ និងការបណ្តុះបណ្តាលបច្ចេកទេស

ទាក់ទងទៅនឹងកម្មវិធីអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈពាក់ព័ន្ធលើវិស័យគីមី ក្នុងគោលបំណងឱ្យមានអ្នកឯកទេសក្នុងស្រុកដើម្បីអនុវត្តនូវកម្មវិធី ឬគោលនយោបាយរបស់រាជរដ្ឋាភិបាលលើការគ្រប់គ្រងសារធាតុគីមី មកទល់បច្ចុប្បន្ននេះ គឺបានរៀបចំបង្កើតឱ្យមាន និងដំណើរការនៅតាមវិទ្យាស្ថានឯកទេសនានា ដូចជា :

- សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ផ្តល់ការបណ្តុះបណ្តាលលើមុខវិជ្ជាគីមីសាស្ត្រ និងវិទ្យាសាស្ត្របរិស្ថាន
- សាកលវិទ្យាល័យភូមិន្ទកសិកម្មចំការដូង ផ្តល់ការបណ្តុះបណ្តាលលើមុខវិជ្ជាក្សេត្រសាស្ត្រ និងផលិតកម្មបសុព្យាបាល
- វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ផ្តល់ការបណ្តុះបណ្តាលលើឯកទេសបច្ចេកវិជ្ជាគីមី និងចំណីអាហារ
- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ផ្តល់ការបណ្តុះបណ្តាលលើមុខវិជ្ជាឱសថសាស្ត្រ
- សាលាជាតិកសិកម្មព្រែកលាប ផ្តល់ការបណ្តុះបណ្តាលលើមុខវិជ្ជាក្សេត្រសាស្ត្រ និងផលិតកម្មបសុព្យាបាល
- រាជបណ្ឌិតសភាកម្ពុជា ផ្តល់ការបណ្តុះបណ្តាលលើមុខវិជ្ជាគីមី និងចំណីអាហារ

ក្រៅពីការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈខាងលើ ការបណ្តុះបណ្តាលជំនាញឯកទេសទាក់ទងនឹងសារធាតុគីមី ត្រូវបានរៀបចំដោយស្ថាប័នរដ្ឋ ក្នុងគោលបំណងបង្កើនចំណេះដឹងនិងសមត្ថភាពដល់មន្ត្រីរាជការដែលពាក់ព័ន្ធនៅក្នុងការអនុវត្តកម្មវិធី និងគោលនយោបាយរាជរដ្ឋាភិបាលដែលទាក់ទងទៅនឹងការគ្រប់គ្រងសារធាតុគីមី ពិសេសសំរាប់មន្ត្រីនៅតាមមូលដ្ឋានដែលជាអ្នកអនុវត្តផ្ទាល់លើគោលនយោបាយ និងកម្មវិធីជាតិ។ ជាទូទៅ ការបណ្តុះបណ្តាលត្រូវបានរៀបចំទៅតាមតំរូវការនិងការចាំបាច់របស់ស្ថាប័នរដ្ឋនិមួយៗ ហើយដែលការរៀបចំនោះ គឺត្រូវបានអនុវត្តតាមរបៀបធ្វើការបណ្តើររៀនសូត្របណ្តើរហើយការបណ្តុះបណ្តាលនេះត្រូវបានសំរបសំរួលដោយអ្នកឯកទេសជាតិនិងអន្តរជាតិ ។

ទន្ទឹមនឹងនេះ ក៏មានការចាត់បញ្ជូនមន្ត្រីឱ្យទៅចូលរួមវគ្គបណ្តុះបណ្តាលជំនាញឯកទេសសំរាប់រយៈពេលខ្លី និងមធ្យមនៅបរទេស ហើយក៏មានបញ្ជូនមន្ត្រីឱ្យទៅបន្តការសិក្សាថ្នាក់ក្រោយឧត្តមលើជំនាញពាក់ព័ន្ធការគ្រប់គ្រងសារធាតុគីមី និងវិទ្យាសាស្ត្របរិស្ថាន ។ ប៉ុន្តែ ការបណ្តុះបណ្តាលខាងលើមិនមានរូបភាពទូលំទូលាយទេ ដោយសារកង្វះខាតនូវធនធានបច្ចេកទេស ហិរញ្ញវត្ថុ និងបញ្ហាភាសាបរទេស ។

## ៩.៤ យោបល់ និងការវិភាគ

ជារួម មន្ទីរពិសោធន៍ធំៗទាំង ៦ ចំណុះឱ្យស្ថាប័នរដ្ឋដែលបានរៀបរាប់ខាងលើ គឺបានដើរតួយ៉ាងសំខាន់ក្នុងការតាមដានការប្រើប្រាស់សារធាតុគីមីគ្រប់ប្រភេទនៅកម្ពុជា ចាប់តាំងពីពេលនាំចូល ចែកចាយ ប្រើប្រាស់ រហូតដល់ការបោះបង់ចោល។ល។ ដែលមានលក្ខណៈគ្រប់គ្រាន់ក្នុងការវិភាគ សំរាប់បំរើឱ្យការងារតាមដាននិងគ្រប់គ្រងសារធាតុគីមីនៅកម្ពុជា ឱ្យដំណើរការទៅបានល្អ។ ក្រៅពីមន្ទីរពិសោធន៍របស់ក្រសួងទាំង ៦ នៃស្ថាប័នរដ្ឋ កម្ពុជានៅមានមន្ទីរពិសោធន៍មួយចំនួនទៀត ដែលស្ថិតនៅតាមគ្រឹះស្ថានឧត្តមសិក្សា ។ មន្ទីរពិសោធន៍ទាំងនេះមានតួនាទីគាំទ្រការសិក្សាមុខវិជ្ជាគីមីរបស់និស្សិតនៅតាមគ្រឹះស្ថានសិក្សា ហើយក៏មានលទ្ធភាពក្នុងការវិភាគរកសារធាតុគីមីបានមួយចំនួនតាមការចាំបាច់។

ទោះជាយ៉ាងដូច្នេះក៏ដោយ កម្ពុជានៅមានកង្វះខាតមួយចំនួនខាងក្រោមដែលជះឥទ្ធិពលលើការបំពេញមុខងាររបស់មន្ទីរពិសោធន៍ ដូចជា:

- មន្ទីរពិសោធន៍នីមួយៗរបស់ក្រសួងទាំង ៦ នៅមានកង្វះខាតឧបករណ៍សំរាប់ធ្វើការវិភាគ ធាតុប្រតិករវិភាគ (Chemical Reagents) និងធនធានមនុស្សសំរាប់ធ្វើការវិភាគរកសារធាតុគីមីឱ្យបានគ្រប់ជ្រុងជ្រោយ។
- ទីតាំងរបស់មន្ទីរពិសោធន៍ទាំងអស់ស្ថិតនៅប្រមូលផ្តុំតែក្នុងទីក្រុង (រាជធានី) ដែលជាហេតុធ្វើឱ្យមានការលំបាកក្នុងការវិភាគសារធាតុគីមីនៅតាមខេត្ត-ក្រុងនានា ព្រោះថាសារធាតុគីមីមួយចំនួនទាមទារឱ្យមានការវិភាគភ្លាមៗក្រោយពេលយកសំណាករួច។
- មន្ទីរពិសោធន៍នីមួយៗនៅមិនទាន់បានចងសម្ព័ន្ធជាបណ្តាញការងារនៅឡើយទេ ក្នុងការផ្លាស់ប្តូរពត៌មាននិងទិន្នន័យដែលវិភាគបាន ក៏ដូចជាការជួយចែករំលែកការងារវិភាគរបស់គ្នាទៅវិញទៅមក។
- មិនមានមន្ទីរពិសោធន៍ណាមួយនៅកម្ពុជាមានការទទួលស្គាល់ពីមន្ទីរពិសោធន៍អន្តរជាតិ លើគុណភាពនៃការវិភាគ ឬការផ្លាស់ប្តូរវិភាគសំណាកទៅវិញទៅមកនៅឡើយទេ។

ដើម្បីបំពេញមុខងារក្នុងការតាមដានវិភាគរកសារធាតុគីមីដែលមាននៅក្នុងផលិតផលនានា មន្ទីរពិសោធន៍កម្ពុជាទាំងអស់គួរតែចងសម្ព័ន្ធគ្នាជាបណ្តាញការងារ ដើម្បីជួយចែករំលែកការវិភាគរកសារធាតុគីមី ក៏ដូចជាការចែករំលែកពត៌មាន និងទិន្នន័យនៃការវិភាគ សំដៅធានាការគ្រប់គ្រងសារធាតុគីមីនៅកម្ពុជាប្រកបដោយសុវត្ថិភាព ដោយត្រូវធ្វើការពិចារណាទៅលើកត្តាមួយចំនួនដូចខាងក្រោម:

- បង្កើតសាខាមន្ទីរពិសោធន៍មួយចំនួននៅតាមខេត្ត-ក្រុង ព្រមទាំងអភិវឌ្ឍន៍សមត្ថភាពមន្ទីរពិសោធន៍ដែលមានស្រាប់តាមរយៈការពង្រឹងសមត្ថភាពមន្ត្រី-បុគ្គលិក បំពាក់នូវឧបករណ៍សំភារៈវិភាគថ្មីៗ និងផ្គត់ផ្គង់ធាតុប្រតិករវិភាគឱ្យបានគ្រប់គ្រាន់តាមតំរូវការ ព្រមទាំងពង្រីកទំហំនៃការវិភាគគុណភាពសំរាប់មន្ទីរពិសោធន៍ដែលមានស្រាប់។
- បង្កើតបណ្តាញការងារមន្ទីរពិសោធន៍ និងកែលំអហេដ្ឋារចនាសម្ព័ន្ធពត៌មាន ដើម្បីគ្រប់គ្រងសារធាតុគីមីនៅកម្ពុជាឱ្យមានប្រសិទ្ធភាព ។
- ពង្រឹង និងលើកកំពស់សមត្ថភាពមន្ទីរពិសោធន៍របស់កម្ពុជា ឱ្យមានសមត្ថភាពពេញលេញដើម្បីឱ្យមានការទទួលស្គាល់ពីមន្ទីរពិសោធន៍អន្តរជាតិលើសមត្ថភាព និងលទ្ធភាពវិភាគ។
- ជំរុញការរួមចំណែករបស់មន្ទីរពិសោធន៍ឯកជនក្នុងការគ្រប់គ្រងសារធាតុគីមីឱ្យបានត្រឹមត្រូវ។

# ជំពូកទី ១០
# ការយល់ដឹងរបស់កម្មករ កសិករ និងសាធារណជន

ជំពូកនេះផ្តល់នូវទិដ្ឋភាពរួមស្តីពីយន្តការសំរាប់អប់រំ ផ្សព្វផ្សាយ និងផ្តល់ពត៌មានដល់កម្មករ កសិករ និងសាធារណជនទូទៅ ទាក់ទងទៅនឹងក្តីកង្វល់នៃបញ្ហាគ្រោះថ្នាក់ដែលបណ្តាលមកពីការនាំចូល និងប្រើប្រាស់សារធាតុគីមីនៅកម្ពុជា ដោយចែកចេញជា ៣ ផ្នែកសំខាន់ៗ រួមមាន : ពត៌មានសំរាប់កម្មករ ពត៌មានសំរាប់សាធារណជន និងការលើកកំពស់ចំណេះដឹងរបស់សាធារណជន ។

## ១០.១ ពត៌មានសំរាប់កម្មករ និងកសិករ

កម្ពុជានៅមិនទាន់មានបញ្ញត្តិច្បាប់ដែលចែងតំរូវឱ្យកម្មករ ដែលធ្វើការផ្ទាល់ជាមួយការលើកដាក់ និងប្រើប្រាស់សារធាតុគីមី ត្រូវមានចំណេះដឹងពីសុវត្ថិភាពនៃការធ្វើការងារជាមួយសារធាតុគីមីទេ ។ ដោយឡែកចំពោះការផ្សព្វផ្សាយពីបញ្ញត្តិច្បាប់ និងបរិធានច្បាប់ដែលមានស្រាប់ពាក់ព័ន្ធនឹងការគ្រប់គ្រង និងសុវត្ថិភាពនៃការលើកដាក់ និងប្រើប្រាស់សារធាតុគីមីដល់ប្រជាកសិករ កម្មករ និងសាធារណជនទូទៅ គឺគេធ្វើតិចតួចណាស់តាមរយៈទូរទស្សន៍ វិទ្យុ សារពត៌មាន ទស្សនាវដ្តី រូបភាពផ្សព្វផ្សាយ និងកំរងអត្ថបទផ្សព្វផ្សាយផ្សេងៗ ចំនែកពត៌មានដែលជាលទ្ធផលនៃការស្រាវជ្រាវពាក់ព័ន្ធនឹងសារធាតុគីមីរបស់រដ្ឋ និងបណ្តាអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនានាច្រើនធ្វើការអប់រំដល់ប្រជាកសិករ កម្មករ និងសាធារណជនទូទៅតាមរយៈវែស្របង្ហាញ ការប្រជុំជាសាធារណៈ សិក្ខាសាលា ហើយម្តងម្កាលក៏ធ្វើឡើងតាមរយៈប្រព័ន្ធឃោសនាដែរ ប៉ុន្តែមិនបានទូលំទូលាយទេ ភាគច្រើនតែតំបន់ប្រជុំជនប៉ុណ្ណោះ ។

## ១០.២ ពត៌មានសំរាប់សាធារណជន

ពត៌មានស្តីពីការប្រើប្រាស់សារធាតុគីមី ជាពិសេសការប្រើប្រាស់ថ្នាំកសិកម្មនិងជីគីមីប្រកបដោយសុវត្ថិភាព ក៏ដូចជាពត៌មានស្តីពីភាពគ្រោះថ្នាក់ត្រូវបានផ្សព្វផ្សាយដល់សាធារណជនតាមរយៈប្រព័ន្ធឃោសនា ជាពិសេសទូទស្សន៍ វិទ្យុ និងកាសែត ។ ខ្លឹមសារសំខាន់ៗដែលផ្សព្វផ្សាយដល់សាធារណជនទាក់ទងទៅនឹងការប្រើប្រាស់សារធាតុគីមី គឺពាក់ព័ន្ធទៅនឹងសុវត្ថិភាពនៃការប្រើប្រាស់ រួមមានវិធានការការពារសុខភាពអ្នកប្រើប្រាស់ និងអ្នកជិតខាង បញ្ហាជំងឺដែលអាចបណ្តាលមកពីសារធាតុគីមី គ្រោះថ្នាក់បណ្តាលមកពីសារធាតុគីមីទៅលើមនុស្ស និងបរិស្ថាន ។ល ។ បន្ថែមលើសពីនេះទៀត ស្ថាប័នពាក់ព័ន្ធនឹងការគ្រប់គ្រងសារធាតុគីមីក៏បានបោះពុម្ពផ្សាយពីការអនុវត្តកម្មវិធីនានាមួយចំនួន និងឯកសារស្រាវជ្រាវរបស់គេ តែមិនបានសង្កត់ធ្ងន់លើបញ្ហាជាតិគីមីដែលបង្កគ្រោះថ្នាក់ដល់បរិស្ថាន និងដល់សុខមាលភាពប្រជាពលរដ្ឋនោះទេ ។ ឯកសារទាំងនេះច្រើនបរិយាយពីសកម្មភាពវិវត្តរបស់គំរោង ឬកម្មវិធីរបស់គេតែប៉ុណ្ណោះ ។ យើងក៏សង្កេតឃើញមានការពន្យល់ណែនាំតិចតួចណាស់ដែលទាក់ទងដល់ការប្រើប្រាស់សារធាតុគីមីដែលនាំមកនូវភាពគ្រោះថ្នាក់ដល់បរិស្ថាននិងដល់សុខភាព ។ មកដល់បច្ចុប្បន្ននេះមានបណ្តាស្ថាប័នរដ្ឋ អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនានាកំពុងផ្តល់ការអប់រំជាទូទៅ រួមទាំងបញ្ហាពាក់ព័ន្ធនឹងសារធាតុគីមី រួមមាន :

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមជាមួយបណ្តាអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនានាផ្តល់ការអប់រំដល់កសិករ និងសាធារណជនទូទៅអំពីរបៀបប្រើជីគីមី ថ្នាំកសិកម្ម និងឱសថសត្វ ព្រមទាំងរបៀប

ការពារសុខភាពរបស់កសិករតាមរយៈកម្មវិធីស្រែបង្ហាញកម្មវិធីវិធានការចំរុះការពារដំណាំ និងគំរោងបង្កើនផលិតភាពកសិកម្ម។

- ក្រសួងពាណិជ្ជកម្មផ្តល់ការអប់រំដល់កសិករ កម្មករ និងសាធារណជនទូទៅ អំពីការប្រើប្រាស់ផលិតផលប្រកបដោយសុវត្ថិភាពតាមរយៈការអប់រំតាមទូរទស្សន៍ វិទ្យុ សារពត៌មាន និងតាមឯកសារផ្សព្វផ្សាយ។
- ក្រសួងបរិស្ថានរួមជាមួយបណ្តាអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនានា ផ្តល់ការអប់រំដល់កសិករ កម្មករ និងសាធារណជនទូទៅ អំពីបរិធានច្បាប់ដែលទាក់ទងការបំពុលបរិស្ថាន កម្មវិធីជាតិសំរាប់ទប់ស្កាត់ការបំពុលបរិស្ថាន ការថែរក្សាសុខភាពសាធារណៈ និងការយល់ដឹងពីសារធាតុពុល តាមរយៈទូរទស្សន៍ វិទ្យុ សារពត៌មាន រូបភាព និងឯកសារផ្សព្វផ្សាយនៃសិក្ខាសាលា និងការប្រជុំ ។
- ក្រសួងសុខាភិបាលរួមជាមួយបណ្តាអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនានា ផ្តល់ការអប់រំដល់កសិករ កម្មករ និងសាធារណជនទូទៅអំពីការថែរក្សាសុខភាព និងការប្រើប្រាស់ផលិតផលគីមីឱសថដោយសុវត្ថិភាពតាមរយៈទូរទស្សន៍ វិទ្យុ សារពត៌មាន រូបភាព និងឯកសារផ្សព្វផ្សាយ ។
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រួមជាមួយបណ្តាអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនានា ផ្តល់ការអប់រំដល់កម្មករ និងសាធារណជនទូទៅអំពីផលិតកម្មស្អាត និងសុវត្ថិភាពកម្មករក្នុងរោងចក្រសហគ្រាស តាមរយៈទូរទស្សន៍ វិទ្យុ សារពត៌មាន រូបភាព និងឯកសារផ្សព្វផ្សាយដល់ទីកន្លែង ។
- ដោយឡែកក្រសួងមហាផ្ទៃរួមជាមួយបណ្តាអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនានា ផ្តល់ការអប់រំដល់កសិករ កម្មករ និងសាធារណជនទូទៅ អំពីគ្រោះថ្នាក់នៃការប្រើប្រាស់សារធាតុគីមីសំរាប់ផលិតគ្រឿងញៀន និងគ្រឿងញៀន តាមរយៈទូរទស្សន៍ វិទ្យុ និងសារពត៌មាន រូបភាពនិងឯកសារផ្សព្វផ្សាយ ។

## ១០.៣ ការលើកកំពស់ចំណេះដឹងរបស់សាធារណជន

ការបង្កើនចំណេះដឹងជាសាធារណៈក្នុងប្រទេសកម្ពុជា គឺច្រើនធ្វើឡើងតាមរយៈសារពត៌មាន ទស្សនាវដ្តី ទូរទស្សន៍ និងវិទ្យុ។ល។ ទោះជាយ៉ាងណាក្តី ការធានាប្រសិទ្ធិភាព គុណភាពពត៌មាន និងយុទ្ធនាការផ្តល់ពត៌មានអំពីសារធាតុគីមីទូទៅ និងការអប់រំពិសេសអំពីថ្នាំកសិកម្ម និងជីគីមីដល់កសិករ គឺនៅមិនទាន់គ្រប់គ្រាន់ទេ។ ក្នុងអំឡុងពេលប៉ុន្មានឆ្នាំកន្លងទៅនេះ កម្ពុជាមានកង្វះខាតក្នុងការលើកកំពស់កម្មវិធីអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធដែលទាក់ទងទៅនឹងបញ្ហាសារធាតុគីមី។ ចំពោះកម្មវិធីអប់រំក្នុងប្រព័ន្ធសំរាប់សាលាចំណេះទូទៅវិញ គឺមិនមានបញ្ចូលចំណេះដឹងពីសុវត្ថិភាពនៃការប្រើប្រាស់សារធាតុគីមីទេ ទោះបីជាកម្មវិធីសិក្សាមានមុខវិជ្ជាគីមីក៏ដោយ។ ចំណែកកម្មវិធីអប់រំក្រៅប្រព័ន្ធ ត្រូវបានអនុវត្តដោយស្ថាប័នរដ្ឋ និងសង្គមស៊ីវិល ដោយផ្តោតសំខាន់ទៅលើការផ្តល់ចំណេះដឹង ស្តីពីភាពគ្រោះថ្នាក់និងសុវត្ថិភាពនៃការប្រើប្រាស់សារធាតុគីមី ជាពិសេសថ្នាំកសិកម្ម ជីគីមី និងសារធាតុគីមីនៅក្នុងផលិតផលម្ហូបអាហារ។ ទោះជាយ៉ាងនេះក៏ដោយ ក៏ការយល់ដឹងរបស់សាធារណជនលើសុវត្ថិភាពនៃការប្រើប្រាស់សារធាតុគីមី និងផលប៉ះពាល់របស់វាមកលើសុខភាពនិងបរិស្ថាននៅមានកំរិតទាប។ គេក៏បានមើលឃើញផងដែរថា ស្ថាប័នរដ្ឋមួយចំនួននៅមិនទាន់មានការយល់ដឹងឱ្យបានទូលំទូលាយពីសារធាតុគីមី និងគ្រោះថ្នាក់របស់វាមកលើបរិស្ថាន និងសុខភាព ហើយក៏មិនបានជំរុញសាធារណជនឱ្យយល់ដឹងពីសុវត្ថិភាពនៃការប្រើប្រាស់សារធាតុគីមីឱ្យមានភាពទូលំទូលាយដែរ។ មកដល់បច្ចុប្បន្ននេះ គឺកំរឃើញមានឯកសារបណ្តុះបណ្តាលណាត្រូវបានគេបោះពុម្ពជាថ្មី និងផ្សព្វផ្សាយពីសុវត្ថិភាពនៃការទុកដាក់

និងប្រើប្រាស់សារធាតុគីមីដល់សាធារណជន។ ឯកសារនិងពត៌មានដែលបានបោះពុម្ពរួច និងដែលបានផ្សព្វផ្សាយទាក់ទងទៅនឹងការគ្រប់គ្រងសារធាតុគីមី រួមមាន :

១- សៀវភៅ "បរិស្ថាន : ឯកសារជំនួយស្មារតី ដោយផ្តោតលើប្រទេសកម្ពុជា" បោះពុម្ពដោយក្រសួងបរិស្ថាន ១៩៩៩ ឧបត្ថម្ភដោយ UNDP/ETAP ។

២- ព្រឹត្តប័ត្រពត៌មានស្តីពីឱសថ ( ក្រសួងសុខាភិបាល ឆ្នាំ ២០០១) ។

៣- ឯកសារស្រាវជ្រាវស្តីពីសារធាតុអាសេនិចក្នុងទឹកអណ្តូង ( ក្រសួងអភិវឌ្ឍន៍ជនបទបានសហការជាមួយអង្គការ UNICEF ២០០៣) ។

៤- សៀវភៅ "ណែនាំសំរាប់គ្រូ : ការអប់រំបរិស្ថានសំរាប់កំរិតបឋមសិក្សា" ( ក្រសួងបរិស្ថាន/ ETAP/UNDP, ១៩៩៨ ) ។

៥- ពង្រាងសៀវភៅ "ណែនាំសំរាប់គ្រូ : ការអប់រំបរិស្ថានសំរាប់ពុទ្ធិកបឋមសិក្សា" ( ក្រសួងបរិស្ថាន, ETAP/UNDP, ១៩៩៨ ) ។

៦- សៀវភៅបង្ហាញពីសារធាតុគីមីដែលបានប្រើប្រាស់ក្នុងការផលិតថ្នាំញៀនដោយខុសច្បាប់ ( បោះពុម្ពផ្សាយដោយអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ) ។

៧- សារធាតុគីមីបំពុលសរីរាង្គមិនងាយបំបែកធាតុ និងកង្វល់របស់សហគមន៍អន្តរជាតិ (បោះពុម្ពដោយគំរោងពង្រឹងសមត្ថភាពរៀបចំផែនការជាតិសំរាប់អនុវត្តអនុសញ្ញា ស្តុកខូម ក្រសួងបរិស្ថាន ខែឧសភា ឆ្នាំ២០០៤ ) ។

៨- សៀវភៅស្តីពីថ្នាំកសិកម្ម ការពារដំណាំ និងបញ្ហារបស់វា (បោះពុម្ពដោយអង្គការ CEDAC 2003 ) ។

## ១០.៤ សកម្មភាពអប់រំពីសារធាតុគីមីនាពេលអនាគត

ដើម្បីឆ្លើយតបចំពោះតំរូវការខាងស្មារតី និងបង្កើនការយល់ដឹងអំពីសារធាតុគីមីឱ្យកាន់តែទូលំទូលាយក្នុងចំណោមកសិករ កម្មករ និងសាធារណជនទូទៅ ស្ថាប័នរដ្ឋដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសារធាតុគីមី បានដាក់ចេញនូវគំរោងការមួយចំនួនដើម្បីលើកកំពស់ការយល់ដឹងពីភាពគ្រោះថ្នាក់ និងសុវត្ថិភាពនៃការទុកដាក់ និងប្រើប្រាស់សារធាតុគីមី។ តារាង ១០-១ ខាងក្រោមបានសង្ខេបពីសកម្មភាពអប់រំលើសុវត្ថិភាពនៃការប្រើប្រាស់សារធាតុគីមីដល់ប្រជាកសិករ កម្មករ និងសាធារណជនទូទៅ ហើយតារាងនេះ ក៏បានបញ្ជាក់ផងដែរនូវក្រុមគោលដៅដែលត្រូវទទួលបានការអប់រំ និងកាលបរិច្ឆេទជាក់លាក់សំរាប់ការរៀបចំឯកសារ និងដំណើរការអប់រំនៅកម្ពុជានាពេលខាងមុខ ។

**តារាង ១០-១:** សកម្មភាពអប់រំពីសារធាតុគីមីក្នុងពេលអនាគត

| សកម្មភាពអប់រំពីសារធាតុគីមី | អ្នកដែលត្រូវអប់រំ | កាលវិភាគ | អ្នកទទួលខុសត្រូវ |
|---|---|---|---|
| • ការបណ្តុះបណ្តាលសុវត្ថិភាពចំណីអាហារ<br>• ការប្រើប្រាស់សារធាតុគីមីសំរាប់ការពារម្ហូបអាហារ និងគីមីបន្ថែមលើម្ហូបអាហារ | សិស្សានុសិស្ស គ្រប់មជ្ឈដ្ឋានសង្គម | ២០០៤-២០០៨ | នាយកដ្ឋានកាំកុងត្រូល |
| • កម្មវិធីធ្វើជីកំប៉ុស្ត | អាជ្ញាធរជាតិ និងខេត្ត និង ប្រជាកសិករ | | អង្គការបណ្តុះបណ្តាល និងគ្រប់គ្រងសំណល់កម្ពុជា |

| សកម្មភាពអប់រំពីសារធាតុគីមី | អ្នកដែលត្រូវអប់រំ | កាលវិភាគ | អ្នកទទួលខុសត្រូវ |
|---|---|---|---|
| • កម្មវិធីវិធានការចំរុះគ្រប់គ្រងដំណាំ ( កាត់បន្ថយគីមីដោយថ្នាំកសិកម្មយកចេញពីរុក្ខជាតិ សំរាប់ប្រឆាំងនឹងសត្រូវធម្មជាតិ ) | កសិករ | ២០០០-២០០៥ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| • សុវត្ថិភាពការប្រើប្រាស់ថ្នាំកសិកម្មប្រកបដោយប្រសិទ្ធិភាព | កសិករ | ២០០០-២០០៦ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| • ការផ្សព្វផ្សាយស្តីពីសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ តាមរយៈព្រឹត្តប័ត្រពត៌មានបច្ចេកទេស | សិស្សានុសិស្ស អាជ្ញាធរគ្រប់មជ្ឈដ្ឋានសង្គម | ២០០៣-២០០៥ | ក្រសួងបរិស្ថាន |
| • កម្មវិធីបណ្តុះបណ្តាលភ្នាក់ងារគយក្នុងការត្រួតពិនិត្យសារធាតុគីមីបំផ្លាញស្រទាប់អូសូន | មន្ត្រីគយ មន្ត្រីកាំកុងត្រូល និងស្ថាប័នពាក់ពន្ធ័ | ២០០៤-២០០៧ | ក្រសួងបរិស្ថាន |
| • ការផ្សព្វផ្សាយជាសាធារណៈ និងកម្មវិធីលើកទឹកចិត្តចំពោះម៉ាស៊ីនត្រជាក់រថយន្ត | ផ្នែកឯកជន ស្ថាប័នរដ្ឋាភិបាល គ្រប់មជ្ឈដ្ឋានសង្គម | ២០០៤-២០០៧ | ក្រសួងបរិស្ថាន |
| • កម្មវិធីបណ្តុះបណ្តាលអ្នកបច្ចេកទេស ម៉ាស៊ីនត្រជាក់ និងទូរទឹកកក | អ្នកបច្ចេកទេសម៉ាស៊ីនត្រជាក់ និងទូរទឹកកក | ២០០៤-២០០៧ | ក្រសួងបរិស្ថាន |
| • ជំរុញផលិតកម្មស្អាតក្នុងវិស័យឧស្សាហកម្ម ប្រើប្រាស់វត្ថុធាតុដើមឱ្យមានប្រសិទ្ធិភាព លើកកំពស់គុណភាពផលិតផល និងកាត់បន្ថយបរិមាណ សំណល់ (UNIDO) | វិនិយោគិនឧស្សាហកម្ម | ២០០៤-២០០៩ | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |

## ១០.៥ យោបល់ និងការពិភាក្សា

តាំងពីឆ្នាំ ១៩៨០ រហូតដល់បច្ចុប្បន្ន ការអប់រំពីសារធាតុគីមីក្នុងប្រទេសកម្ពុជា គឺបញ្ជ្រាបចូលដោយមានកំរិតទៅក្នុងកម្មវិធីអប់រំក្នុងប្រព័ន្ធ រួមមានបឋមសិក្សា និងមធ្យមសិក្សា ( អនុវិទ្យាល័យ និងវិទ្យាល័យ ) ។ ពិសេស នៅក្រោយឆ្នាំ ១៩៩៣ ការអប់រំពីការយល់ដឹងលើសុវត្ថិភាពទុកដាក់ និងប្រើប្រាស់សារធាតុគីមី បានក្លាយទៅជាប្រធានបទមួយដ៏មានសារៈសំខាន់នៅក្នុងកម្មវិធីអប់រំបរិស្ថានទូទៅ ជាពិសេស ទៅក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធ។ ការយល់ដឹងពីគ្រោះថ្នាក់សារធាតុគីមីក៏ត្រូវបានផ្តល់ជូនផងដែរដល់មន្ត្រីស្ថាប័នរដ្ឋ ជាពិសេសដល់មន្ត្រីក្រសួងបរិស្ថានគ្រប់លំដាប់ថ្នាក់ ។

ពេលបច្ចុប្បន្ននេះ កម្ពុជាបានអភិវឌ្ឍន៍កម្មវិធីអប់រំទាក់ទិននឹងការគ្រប់គ្រងសារធាតុគីមីនៅតាមស្ថាប័នរដ្ឋដោយឡែកៗពីគ្នា ដើម្បីបង្កើនសមត្ថភាពរបស់មន្ត្រីស្ថាប័នរដ្ឋផង និងដើម្បីលើកកំពស់ការយល់ដឹងរបស់ប្រជាកសិករ កម្មករ និងសង្គមជាតិទាំងមូលផងលើសុវត្ថិភាពនៃការទុកដាក់ ប្រើប្រាស់ និងបោះបង់ចោលសារធាតុគីមី និងបញ្ហាដែលទាក់ទងដូចមានក្នុងតារាង ១០-១ ។

ជាក្តីសង្ឃឹមទៅអនាគត គ្រូបង្គោល គ្រូឧទ្ទេសមួយចំនួននឹងត្រូវបានបណ្តុះបណ្តាល ដើម្បីឱ្យពួកគេមានលទ្ធភាពផ្សព្វផ្សាយចំណេះដឹងបន្តដល់ប្រជាកសិករ កម្មករ តាមរយៈការអប់រំក្រៅប្រព័ន្ធ អំពីសុវត្ថិភាពនៃការទុកដាក់ និងប្រើប្រាស់សារធាតុគីមី ដើម្បីការពារសុខភាពសាធារណៈ និងបរិស្ថានឱ្យចៀសផុតពីភាពគ្រោះថ្នាក់នៃឥទ្ធិពលសារធាតុគីមី ។

# ជំពូកទី ១១

# ទំនាក់ទំនងអន្តរជាតិ

ជំពូកនេះនឹងបង្ហាញពីពត៌មាននៃការចូលរួមចំណែក និងទំនាក់ទំនងក្នុងកិច្ចជាតិជាមួយនឹងអង្គការអន្តរជាតិ និងកិច្ចព្រមព្រៀងនានាដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសារធាតុគីមី សំដៅកំណត់នូវបញ្ហានិងវិធានការដំណោះស្រាយលើបញ្ហាទាក់ទងទៅនឹងសារធាតុគីមី តាមរយៈកម្មវិធីឬគំរោងជំនួយរបស់អង្គការអន្តរជាតិ និងភ្នាក់ងារផ្តល់ជំនួយនានា ។

## ១១.១ កិច្ចសហប្រតិបត្តិការ និងការចូលរួមជាមួយអង្គការអន្តរជាតិ និងកិច្ចព្រមព្រៀងនានា

យោងទៅលើការទទួលស្គាល់នូវភាពគ្រោះថ្នាក់ដែលអាចបង្កដោយសារធាតុគីមី និងក្នុងគោលបំណងរួមចំណែកជាមួយសហគមន៍អន្តរជាតិ ដើម្បីការពារសុខភាពសាធារណៈ និងគុណភាពបរិស្ថានឱ្យជៀសផុតពីឥទ្ធិពលគ្រោះថ្នាក់នៃសារធាតុគីមីពិសេសពពួកសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំទៅតាមលទ្ធភាព និងសមត្ថភាពរបស់ខ្លួនធ្វើកិច្ចសហប្រតិបត្តិការជាមួយសហគមន៍អន្តរជាតិ តាមរយៈការចូលរួមក្នុងកម្មវិធីការងារអន្តរជាតិ និងអនុសញ្ញាអន្តរជាតិនានាដែលទាក់ទងទៅនឹងការគ្រប់គ្រងសារធាតុគីមី ។

ប៉ុន្តែ ការចូលរួមរបស់កម្ពុជាក្នុងកិច្ចសហប្រតិបត្តិការជាមួយសហគមន៍អន្តរជាតិ ពាក់ព័ន្ធទៅនឹងការងារគ្រប់គ្រងសារធាតុគីមី គឺនៅពុំទាន់បានគ្រប់ផ្នែកនៅឡើយទេ ។ ដោយឡែក សកម្មភាពរបស់កម្ពុជាក្នុងកិច្ចសហប្រតិបត្តិការទាក់ទងទៅនឹងការចាត់វិធានការនានានៅក្រោមកាតព្វកិច្ចនៃអនុសញ្ញា ឬកិច្ចព្រមព្រៀង គឺពុំទាន់ដំណើរការបានល្អទេ ដោយសារការខ្វះខាតនូវធនធានមនុស្ស បទពិសោធន៍ និងមធ្យោបាយសំរាប់អនុវត្តន៍ ។

ខាងក្រោមនេះ គឺជាសកម្មភាពចូលរួមរបស់រាជរដ្ឋាភិបាលកម្ពុជាទៅក្នុងកម្មវិធី ឬសកម្មភាពរបស់អង្គការអន្តរជាតិនានាដូចមានសង្ខេបបង្ហាញក្នុងតារាង ១១-១ និងការផ្តល់សច្ចាប័នរបស់កម្ពុជាលើអនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិដែលទាក់ទងទៅនឹងការគ្រប់គ្រងសារធាតុគីមី ដូចមានសង្ខេបបង្ហាញក្នុងតារាង ១១-២ ខាងក្រោម ។

**តារាង ១១-១ :** សមាជិកភាពក្នុងអង្គការអន្តរជាតិ និងកម្មវិធីនានាពាក់ព័ន្ធនឹងការគ្រប់គ្រងសារធាតុគីមី

| អង្គការអន្តរជាតិ / កម្មវិធី | ស្ថាប័នជាតិទទួលបន្ទុកសំរបសំរួល | ស្ថាប័នពាក់ព័ន្ធចូលរួម | សកម្មភាពជាតិពាក់ព័ន្ធ |
|---|---|---|---|
| វេទិកាអន្តររដ្ឋាភិបាល ស្តីពី សុវត្ថិភាពគីមី (Inter-governmental Forum on Chemical Safety - IFCS) | ក្រសួងសុខាភិបាល (មិនទាន់ចូលជាសមាជិក) | ➢ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>➢ ក្រសួងបរិស្ថាន<br>➢ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | គ្មាន |
| កម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP)<br>➢ ការចុះបញ្ជីការអន្តរជាតិនូវសារធាតុគីមីពុលធ្ងន់ធ្ងរ (International Register of Potentially Toxic Chemicals) (National Correspondent) | មិនទាន់ចូលជាសមាជិក | មិនទាន់កំណត់ | គ្មាន |

| អង្គការអន្តរជាតិ / កម្មវិធី | ស្ថាប័នជាតិទទួលបន្ទុកសំរបសំរួល | ស្ថាប័នពាក់ព័ន្ធចូលរួម | សកម្មភាពជាតិពាក់ព័ន្ធ |
|---|---|---|---|
| ➢ ឧស្សាហកម្ម និងបរិស្ថាន<br>មជ្ឈមណ្ឌលកម្មវិធីសកម្មភាព<br>(មជ្ឈមណ្ឌល ផលិតកម្មស្អាត)<br>(Industry and Environment / Program Activity Centre) Cleaner Production Center | មិនទាន់ចូលជាសមាជិក | មិនទាន់កំណត់ | គ្មាន |
| កម្មវិធីអន្តរជាតិសំរាប់សុវត្ថិភាពគីមី<br>(International Program on Chemical Safety) | មិនទាន់ចូលជាសមាជិក | មិនទាន់កំណត់ | គ្មាន |
| អង្គការសុខភាពពិភពលោក<br>(WHO) | ➢ ក្រសួងសុខាភិបាល | ➢ ក្រសួងបរិស្ថាន<br>➢ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>➢ ក្រសួងពាណិជ្ជកម្ម<br>➢ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ➢ កម្មវិធីសុវត្ថិភាពចំណីអាហារ<br>➢ កម្មវិធីគ្រប់គ្រង សំណល់មន្ទីរពេទ្យ |
| អង្គការស្បៀង<br>និងកសិកម្មសហប្រជាជាតិ(FAO) | ➢ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>➢ ក្រសួងពាណិជ្ជកម្ម | ➢ ក្រសួងបរិស្ថាន<br>➢ ក្រសួងសុខាភិបាល | ➢ កម្មវិធីសុវត្ថិភាពចំណីអាហារ<br>➢ កម្មវិធីចំរុះគ្រប់គ្រងដំណាំ<br>➢ Codex Contact Point<br>➢ រៀបចំគណៈកម្មាធិការកូដិចជាតិ<br>➢ សំរបសំរួលបទបញ្ញត្តិបច្ចេកទេសទាក់ទងស្តង់ដារម្ហូបអាហារ សំភារៈវេចខ្ចប់ ..... |
| អង្គការអភិវឌ្ឍន៍ឧស្សាហកម្ម<br>សហប្រជាជាតិ (UNIDO) | ➢ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ➢ ក្រសួងពាណិជ្ជកម្ម<br>➢ ក្រសួងបរិស្ថាន<br>➢ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ➢ កម្មវិធីស្តង់ដារឧស្សាហកម្មកម្ពុជា និងមាត្រសាស្ត្រ<br>➢ បង្កើនការយល់ដឹងពីផលិតកម្មស្អាត និងជំរុញការអនុវត្តផលិតកម្មស្អាតនៅតាមសហគ្រាសផលិតកម្ម |
| អង្គការពលកម្មអន្តរជាតិ<br>(ILO) | ➢ ក្រសួងការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈ | ➢ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>➢ ក្រសួងពាណិជ្ជកម្ម<br>➢ ក្រសួងសុខាភិបាល<br>➢ ក្រសួងកិច្ចការនារី | ➢ កម្មវិធីទប់ស្កាត់ការប្រើប្រាស់កំលាំងអនិតិជន |
| ធនាគារពិភពលោក<br>(World Bank) | ➢ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ➢ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>➢ ក្រសួងបរិស្ថាន<br>➢ ក្រសួងសុខាភិបាល<br>➢ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ➢ កម្មវិធីផ្តល់ សេវាសុខាភិបាល<br>➢ គំរោងបង្កើនផលិតភាពកសិកម្ម<br>➢ គំរោងផលិតកម្មទឹកស្អាត |

| អង្គការអន្តរជាតិ / កម្មវិធី | ស្ថាប័នជាតិទទួលបន្ទុកសំរបសំរួល | ស្ថាប័នពាក់ព័ន្ធចូលរួម | សកម្មភាពជាតិពាក់ព័ន្ធ |
|---|---|---|---|
| ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) | ➢ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>➢ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ➢ ក្រសួងបរិស្ថាន<br>➢ ក្រសួងសុខាភិបាល<br>➢ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ➢ កម្មវិធីផ្តល់សេវាសុខាភិបាល |

តារាង ១១-២ : អនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិទាក់ទងនឹងសារធាតុគីមី

| កិច្ចព្រមព្រៀងអន្តរជាតិ | ស្ថានភាព | ស្ថាប័នជាតិទទួលបន្ទុកសំរបសំរួល | សកម្មភាពអនុវត្តន៍ថ្នាក់ជាតិ |
|---|---|---|---|
| របៀបវារៈ២១ - គណៈកម្មការសំរាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព (Agenda 21 Commission for Sustainable Development) | មិនទាន់រៀបចំ | គ្មាន | គ្មាន |
| គោលការណ៍ណែនាំក្រុងឡុងនៃកម្មវិធីបរិស្ថានអង្គការសហប្រជាជាតិ (នីតិវិធីស្ម័គ្រចិត្ត) (UNEP London Guidelines) | មិនទាន់អនុវត្ត | គ្មាន | គ្មាន |
| ការណែនាំបទបញ្ជានៃអង្គការស្បៀង និងកសិកម្ម (នីតិវិធីស្ម័គ្រចិត្ត) (FAO Code of Conduct) -GCP/RAC/191/AUL -FNPP/GLO/002/NET | ជាភាគីសមាជិក | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ➢ រៀបចំបង្កើតសាលារៀនស្រែកសិករ ស្តីពីកម្មវិធីវិធានការចំរុះគ្រប់គ្រងដំណាំ (IPM) |
| ពិធីសារម៉ុងរេអាល់ (Montreal Protocol) | ជាភាគីសមាជិក | ក្រសួងបរិស្ថាន | ➢ ទិវាអូសូន<br>➢ រៀបចំផែនការជាតិសំរាប់គ្រប់គ្រងសារធាតុត្រជាក់<br>➢ ផ្សព្វផ្សាយជាសាធារណៈពីឥទ្ធិពលបំផ្លាញស្រទាប់អូសូន និងសុខភាពមនុស្ស |
| អនុសញ្ញាអង្គការពលកម្មអន្តរជាតិ ១៧០ (ILO Convention 170) | គ្មានពត៌មាន | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | |
| អនុសាសន៍របស់សហប្រជាជាតិសំរាប់ការដឹកជញ្ជូន ទំនិញគ្រោះថ្នាក់ (UN Recommendation for the Transport of Dangerous Goods) | គ្មានពត៌មាន | | |
| អនុសញ្ញា បាសែល (Basel Convention) | ជាភាគីសមាជិក | ក្រសួងបរិស្ថាន | ➢ ធ្វើសារពើភ័ណ្ឌសំណល់អាគុយ<br>➢ រៀបចំផែនការយុទ្ធសាស្ត្រជាតិក្នុងការគ្រប់គ្រងសំណល់អាគុយ<br>➢ រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងសំណល់អាគុយប្រកបដោយសុវត្ថិភាព |

| កិច្ចព្រមព្រៀងអន្តរជាតិ | ស្ថានភាព | ស្ថាប័នជាតិទទួលបន្ទុកសំរបសំរួល | សកម្មភាពអនុវត្តន៍ថ្នាក់ជាតិ |
|---|---|---|---|
| អនុសញ្ញា ក្រុងឡុង<br>(London Convention) | គ្មានពត៌មាន | | |
| កិច្ចព្រមព្រៀងទូទៅស្តីពីតារាងពន្ធគយ និងពាណិជ្ជកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោក (ដែលទាក់ទងការធ្វើពាណិជ្ជកម្មសារធាតុគីមី GATT/WTO agreement) | ជាភាគីសមាជិក | ក្រសួងពាណិជ្ជកម្ម | ➢ រៀបចំចងក្រងពន្ធគយលើមុខទំនិញទាំង ៩៧ ដោយរួមបញ្ចូលទាំងមុខទំនិញជាសារធាតុគីមី |
| អនុសញ្ញាអាវុធគីមី<br>(Chemicals Weapons Convention) | បានចុះហត្ថលេខាលើអនុសញ្ញា ១៩៩៣ និង ត្រៀមធ្វើសច្ចាប័ន) | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>ក្រសួងការពារជាតិ<br>ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | |
| ក្រុមការងារអាស៊ានស្តីពីគីមីឧស្សាហកម្ម (កិច្ចព្រមព្រៀងតំបន់/អនុតំបន់) | គ្មានពត៌មាន | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | |
| អនុសញ្ញា រ៉ូតើដាំ (PIC Convention) | មិនទាន់ចូលជាភាគីសមាជិក | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | |
| អនុសញ្ញា ស្តុកខូម<br>(Stockholm Convention) | មិនទាន់ចូលជាភាគីសមាជិក | ក្រសួងបរិស្ថាន | ➢ រៀបចំគំរោងពត៌មានជាតិ ស្តីពី ការគ្រប់គ្រងសារធាតុគីមី<br>➢ ធ្វើសារពើភ័ណ្ឌលើកទី ១ នៃសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ (POPs)<br>➢ រៀបចំការបណ្តុះបណ្តាល និងផ្សព្វផ្សាយពីបញ្ហាសារធាតុ (POPs)<br>➢ រៀបចំផែនការជាតិសំរាប់អនុវត្តអនុសញ្ញាស្តុកខូម |

## ១១.២ ការចូលរួមក្នុងគំរោងជំនួយបច្ចេកទេសដែលពាក់ព័ន្ធ

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កម្ពុជាបានទទួលជំនួយឧបត្ថម្ភពីសហគមន៍អន្តរជាតិមួយចំនួន លើផ្នែកជំនួយបច្ចេកទេសនិងហិរញ្ញវត្ថុ សំរាប់ជួយដល់កម្ពុជាក្នុងការអនុវត្តកម្មវិធីអន្តរជាតិ កិច្ចព្រមព្រាងនិងអនុសញ្ញាអន្តរជាតិនានា និងផែនការសកម្មភាពជាតិដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសារធាតុគីមី ។ ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបពីគំរោងទាក់ទងការគ្រប់គ្រងសារធាតុគីមី ដែលកម្ពុជាបាននឹងកំពុងអនុវត្តក្រោមគំរោងជំនួយរបស់សហគមន៍អន្តរជាតិ ដូចមានសង្ខេបក្នុងតារាង ១១-៣ ខាងក្រោម ។

តារាង ១១ -៣: សកម្មភាពគំរោងរបស់កម្ពុជាពាក់ព័ន្ធសារធាតុគីមី ផ្នែកកសិកម្ម និងផ្នែកឧស្សាហកម្មក្រោមគំរោងជំនួយរបស់អង្គការអន្តរជាតិ

| ឈ្មោះគំរោង និងពេលវេលាអនុវត្តន៍ | ភ្នាក់ងារផ្តល់ជំនួយ | គោលបំណង | អង្គភាព/ស្ថាប័នទទួលបន្ទុកអនុវត្តន៍គំរោងផ្ទាល់ | អង្គភាព/ស្ថាប័នចូលរួមសហការអនុវត្តន៍គំរោង | សកម្មភាពពាក់ព័ន្ធក្នុងគំរោង |
|---|---|---|---|---|---|
| កសាងសមត្ថភាពសំរាប់យន្តការអភិវឌ្ឍន៍ស្អាត (២០០៣-២០០៥) (Capacity Development for the Clean Development Mechanism) | Dutch / UNEP | ធ្វើឱ្យយល់ដឹងទូលំទូលាយពីយន្តការអភិវឌ្ឍន៍ស្អាតនិងជំរុញការអនុវត្តយន្តការនៃការអភិវឌ្ឍន៍ស្អាត | > នាយកដ្ឋានផែនការ និងកិច្ចការច្បាប់នៃក្រសួងបរិស្ថាន អាគារលេខ ៤៨ វិថីសម្តេចព្រះសីហនុ ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ២១៨ ៣៧០ អ៊ីម៉ែល : cccap@online.com.kh | > ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>> ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>> ក្រសួងសាធារណការ និងដឹកជញ្ជូន<br>> សាកលវិទ្យាល័យភូមិន្ទកសិកម្មចំការដូង | > បង្កើនការយល់ដឹងឱ្យបានទូលំទូលាយនិងអភិវឌ្ឍន៍ស្ថាបន័ និងសមត្ថភាពមនុស្ស ដើម្បីចូលរួមឱ្យពេញលេញក្នុងយន្តការអភិវឌ្ឍន៍ស្អាត<br>> រៀបចំឱ្យមានការចូលរួមរបស់ស្ថាប័នសំខាន់ក្នុងការរៀបចំ និងអនុវត្តន៍យន្តការអភិវឌ្ឍន៍ស្អាត<br>> រៀបចំគំរោងស្នើសុំសំរាប់យន្តការអភិវឌ្ឍន៍ស្អាត |
| កម្មវិធីសកម្មភាពជាតិដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ (២០០៣-២០០៤) (Formulation for National Adaptation Program of Action for Climate Change) | UNDP / GEF | រៀបចំផែនការសកម្មភាពអាទិភាពជាតិក្នុងការបន្សាំទៅនឹងឥទ្ធិពលអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យកសិកម្ម ធនធានទឹក តំបន់ឆ្នេរ ព្រៃឈើ និងសុខភាពមនុស្ស | > នាយកដ្ឋានផែនការ និងកិច្ចការច្បាប់នៃក្រសួងបរិស្ថាន អាគារលេខ ៤៨ វិថីសម្តេចព្រះសីហនុ ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ២១៨ ៣៧០ អ៊ីម៉ែល: ETAP@online.com.kh | > ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>> ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>> ក្រសួងធនធានទឹក និងឧតុនិយម<br>> ក្រសួងផែនការ និងស្ថិតិ<br>> សាកលវិទ្យាល័យភូមិន្ទកសិកម្មចំការដូង | > រៀបចំកម្មវិធីសកម្មភាពជាតិដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ<br>> សំយោគពត៌មានដែលអាចរកបាននៅក្នុងប្រទេសស្តីពីភាពងាយរងគ្រោះ និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ<br>> សំរបសំរួលការពិនិត្យផ្តល់យោបល់លើផែនការសកម្មភាពជាតិ ដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុដោយសាធារណជន និងរដ្ឋាភិបាល |
| គំរោងអភិវឌ្ឍន៍សមត្ថភាពជាតិ (២០០១-២០០៥) (National Capacity Development Project) | DANIDA | | > នាយកដ្ឋានសំរបសំរួលជំនួយអឺរ៉ុបនៃគណៈកម្មការនិតិសម្បទា និងអភិវឌ្ឍន៍ (ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា) | > ក្រសួងបរិស្ថាន<br>> ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | > ពង្រឹងសមត្ថភាពមន្ទីរពិសោធន៍<br>> ពង្រឹងសមត្ថភាពផលិតកម្មស្អាត |

| ឈ្មោះគំរោង និងពេលវេលាអនុវត្តន៏ | ភ្នាក់ងារផ្តល់ជំនួយ | គោលបំណង | អង្គភាព/ស្ថាប័នទទួលបន្ទុកអនុវត្តន៏គំរោងផ្ទាល់ | អង្គភាព/ស្ថាប័នចូលរួមសហការអនុវត្តន៏គំរោង | សកម្មភាពពាក់ព័ន្ធក្នុងគំរោង |
|---|---|---|---|---|---|
| | | | វិមានរដ្ឋាភិបាល វិថីព្រះស៊ីសុវត្ថិ វត្តភ្នំ ក្រុងភ្នំពេញ<br>ទូរសព្ទ: (៨៥៥) ២៣ ៩៩១ ១៤៥<br>ទូរសារ: (៨៥៥) ២៣ ៩៨១ ១៧៧<br>អ៊ីម៉ែល: crdb.rith@online.com.kh | > ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>> ក្រសួងធនធានទឹក និងឧតុនិយម<br>> ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ | > ពង្រឹងសមត្ថភាពរៀបចំរបាយការណ៍ស្ថានភាពបរិស្ថានជាតិ<br>> បណ្តុះបណ្តាលធនធានមនុស្ស |
| ការធ្វើបញ្ជីសារពើភ័ណ្ឌសំណល់អាគុយផ្ទុកសំណ និងអាស៊ីត (២០០៣-២០០៤)<br>(Inventory of Used Lead-Acid Battery) | BASEL | រៀបចំផែនការយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងសំណល់អាគុយដែលផ្ទុកសំណ និងអាស៊ីតប្រកបដោយសុវត្ថិភាពបរិស្ថាន | > នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន នៃក្រសួងបរិស្ថាន<br>អាគារលេខ ៤៨ វិថីសម្តេចព្រះសីហនុ/ ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ<br>ទូរសព្ទ : (៨៥៥) ២៣ ២១០ ៤៩២<br>អ៊ីម៉ែល : moepcd@online.com.kh | | > ធ្វើសារពើភ័ណ្ឌលើសំណល់អាគុយ ដែលផ្ទុកសំណ និងអាស៊ីត<br>> រៀបចំផែនការយុទ្ធសាស្ត្រជាតិ សំរាប់គ្រប់គ្រងសំណល់អាគុយដែលផ្ទុកសំណ និងអាស៊ីត<br>> រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងសំណល់អាគុយដែលផ្ទុកសំណ និងអាស៊ីតប្រកបដោយសុវត្ថិភាពបរិស្ថាន |
| កម្មវិធីជាតិក្នុងការគ្រប់គ្រងសារធាតុត្រជាក់ (២០០៤-២០០៧)<br>(Refrigerants Management Plan) | UNEP | កាត់បន្ថយ និងលុបបំបាត់ចោលសារធាតុបំផ្លាញស្រទាប់អូសូន | > នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន នៃក្រសួងបរិស្ថាន<br>អាគារលេខ ៤៨ វិថីសម្តេចព្រះសីហនុ/ ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ<br>ទូរសព្ទ : (៨៥៥) ២៣ ២១០ ៤៩២<br>អ៊ីម៉ែល : moepcd@online.com.kh | | > រៀបចំផែនការសកម្មភាពជាតិ ដើម្បីលុបបំបាត់សារធាតុបំផ្លាញស្រទាប់អូសូន<br>> ផ្សព្វផ្សាយជាសាធារណៈអំពីឥទ្ធិពលបំផ្លាញស្រទាប់អូសូន និងសុខភាពមនុស្ស |
| គំរោងពង្រឹងសមត្ថភាពរៀបចំផែនការជាតិអនុវត្តន៏អនុសញ្ញា ស្តុកខូម | UNEP/ GEF | រៀបចំផែនការជាតិសំរាប់អនុវត្តន៏អនុសញ្ញា ស្តុកខូម | > នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន នៃក្រសួងបរិស្ថាន | > ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>> ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | > រៀបចំកំរងពត៌មានជាតិ ស្តីពី ការគ្រប់គ្រងសារធាតុគីមី<br>> ធ្វើសារពើភ័ណ្ឌលើកទី ១ នៃសារធាតុ (POPs) |

| ឈ្មោះគំរោង និងពេលវេលាអនុវត្តន៍ | ភ្នាក់ងារផ្តល់ជំនួយ | គោលបំណង | អង្គភាព/ស្ថាប័នទទួលបន្ទុកអនុវត្តន៍គំរោងផ្ទាល់ | អង្គភាព/ស្ថាប័នចូលរួមសហការអនុវត្តន៍គំរោង | សកម្មភាពពាក់ព័ន្ធក្នុងគំរោង |
|---|---|---|---|---|---|
| (២០០៣-២០០៥)<br>(Enabling Activities for the Development of a National Plan for Implementation of the Stockholm Convention on POPs) | | | អាគារលេខ ៤៨ វិថីសម្តេចព្រះសីហនុ/ ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ<br>ទូរស័ព្ទ : (៨៥៥) ២៣ ២១០ ៤៩២<br>អ៊ីម៉ែល : moepcd@online.com.kh | > ក្រសួងពាណិជ្ជកម្ម<br>> ក្រសួងសុខាភិបាល<br>> ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | > រៀបចំការបណ្តុះបណ្តាល និងផ្សព្វផ្សាយពីបញ្ហាសារធាតុ (POPs)<br>> រៀបចំផែនការជាតិសំរាប់អនុវត្តអនុសញ្ញា ស្តុកខូម |
| គំរោងគ្រប់គ្រងសំណល់-សេដ្ឋកិច្ច | CIDA | | > ដេប៉ាតឺម៉ង់វិទ្យាសាស្ត្របរិស្ថាន នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ខណ្ឌទួលគោក ក្រុងភ្នំពេញ<br>ទូរស័ព្ទ: (៨៥៥) ១១ ៩៩៣ ៥០៥<br>អ៊ីម៉ែល: environment.rupp@everyday.com.kh | | > ធ្វើការស្រាវជ្រាវពីបញ្ហាសំណល់សំរាម<br>> កសាងសមត្ថភាព<br>> អភិវឌ្ឍន៍កម្មវិធីសិក្សា<br>> រៀបចំវគ្គបណ្តុះបណ្តាលសំរាប់មន្ត្រីស្ថាប័នរដ្ឋពាក់ព័ន្ធនឹងការងារគ្រប់គ្រងសំណល់ |
| កម្មវិធីសុខភាពបន្តពូជ ២០០៤-២០០៦ | KFW | លើកកំពស់សុខភាពមាតាតាមរយៈការពន្យាកំណើត | > នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យនិងគ្រឿងសំអាង នៃក្រសួងសុខាភិបាល<br>អាគារលេខ៨ ផ្លូវអ៊ុងប៉ូគុណ (លេខ ១០៥)<br>សង្កាត់មិត្តភាព ខ័ណ្ឌ៧មករា<br>ទូរស័ព្ទ: ០២៣ ៨៨០ ២៤៨<br>អ៊ីមែល: moh_cpn@forum.org.kh | | > ផ្គត់ផ្គង់ថ្នាំពន្យាកំណើត<br>> បង្កើនចំណេះដឹងអំពីការប្រើប្រាស់ថ្នាំពន្យាកំណើត |
| កម្មវិធីឱសថក្លែងក្លាយ | WHO | កាត់បន្ថយឱសថក្លែងក្លាយលើទីផ្សារ | > នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យនិងគ្រឿងសំអាង នៃក្រសួងសុខាភិបាល<br>អាគារលេខ៨ ផ្លូវអ៊ុងប៉ូគុណ (លេខ ១០៥) | > ក្រសួងសុខាភិបាល<br>> ថ្នៃកឯកជន | > ចុះប្រមូលសំណាកឱសថ<br>> កំណត់អត្តសញ្ញាណ និងត្រួតពិនិត្យគុណភាព |

| ឈ្មោះគំរោង និងពេលវេលាអនុវត្តន៍ | ភ្នាក់ងារផ្តល់ជំនួយ | គោលបំណង | អង្គភាព/ស្ថាប័នទទួលបន្ទុកអនុវត្តន៍គំរោងផ្ទាល់ | អង្គភាព/ស្ថាប័នចូលរួមសហការអនុវត្តន៍គំរោង | សកម្មភាពពាក់ព័ន្ធក្នុងគំរោង |
|---|---|---|---|---|---|
| | | | សង្កាត់មិត្តភាព ខ័ណ្ឌ៧មករា<br>ទូរស័ព្ទ: ០២៣ ៨៨០ ២៤៨<br>អ៊ីមែល: moh_cpn@forum.org.kh | | |
| តំរូវការឱសថសារវន្តសំរាប់សុខភាពមាតា និងទារក | UNICEF | លើកកំពស់សុខភាពមាតា និងទារកតាមរយៈការផ្តល់ឱសថគាំពា | ➢ នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខាពេទ្យនិងគ្រឿងសំអាង នៃក្រសួងសុខាភិបាល<br>អាគារលេខ៨ ផ្លូវអ៊ុងប៊ុំគុណ (លេខ ១០៩)<br>សង្កាត់មិត្តភាព ខ័ណ្ឌ៧មករា<br>ទូរស័ព្ទ: ០២៣ ៨៨០ ២៤៨<br>អ៊ីមែល: moh_cpn@forum.org.kh | | ➢ អភិបាលកិច្ចលើការគ្រប់គ្រងឱសថ និងបរិក្ខារ |
| កម្មវិធីវិធានការចំរុះគ្រប់គ្រងដំណាំ<br>១៩៩៣ – ២០០៥ | DANIDA<br>FAO<br>APIP<br>WB | បណ្តុះបណ្តាលកសិករអំពីបច្ចេកទេស IPM ក្នុងទិសដៅកាត់បន្ថយការប្រើប្រាស់ថ្នាំកសិកម្ម | ➢ នាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>អាគារលេខ ១៤ វិថីមុន្នីរ៉េត សង្កាត់ទួលស្វាយព្រៃ២ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ<br>ទូរស័ព្ទ : (៨៥៥) ២៣ ២១៨ ៧៩២<br>(៨៥៥) ២៣ ៧២០ ៤៨៥<br>អ៊ីម៉ែល : ipm.apip@online.com.kh | ➢ មន្ទីរកសិកម្មខេត្ត-ក្រុង<br>➢ អង្គការតាមបណ្តាខេត្ត | ➢ ដំណើរការសាលារៀនស្រែកសិករ<br>➢ រៀបចំក្លិបកសិករ (IPM)<br>➢ ចងក្រងសហគមន៍កសិករ |

| ឈ្មោះគំរោង និងពេលវេលាអនុវត្តន៍ | ភ្នាក់ងារផ្តល់ជំនួយ | គោលបំណង | អង្គភាព/ស្ថាប័នទទួលបន្ទុកអនុវត្តន៍គំរោងផ្ទាល់ | អង្គភាព/ស្ថាប័នចូលរួមសហការអនុវត្តន៍គំរោង | សកម្មភាពពាក់ព័ន្ធក្នុងគំរោង |
|---|---|---|---|---|---|
| ផែនការវិនិយោគអាហាររូបត្ថម្ភ ២០០៣-២០០៧ | UNDP<br>GEF | លុបបំបាត់បញ្ហាកង្វះជាតិអ៊ីយ៉ូតនៅកម្ពុជា | ក្រសួងផែនការ | > ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>> ក្រសួងពាណិជ្ជកម្ម<br>> ក្រសួងអប់រំ យុវជន និងកីឡា<br>> ក្រសួងអភិវឌ្ឍន៍ជនបទ | > ត្រួតពិនិត្យកិរិតអ៊ីយ៉ូដក្នុងអំបិល |
| គំរោងបង្កើនផលិតភាពកសិកម្ម (APIP) ១៩៩៩ - ២០០៤ | WB | កសាងធនធានមនុស្ស រចនាសម្ព័ន្ធ និងរៀបចំបទដ្ឋានបច្ចេកទេស និងបទដ្ឋានច្បាប់ | > នាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាគារលេខ ១៤ វិថីមុន្នីវ៉េត សង្កាត់ទូលស្វាយព្រៃ២ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ<br>ទូរស័ព្ទ : (៨៥៥) ២៣ ២២០ ៨៨៦<br>អ៊ីម៉ែល : agronomy@bigpond.com.kh | > មន្ទីរកសិកម្មខេត្ត-ក្រុង | > ធ្វើការអង្កេតថ្នាំកសិកម្មដែលកំពុងចរាចរនៅតាមទីផ្សារ<br>> វិភាគថ្នាំកសិកម្មរកភាពសុទ្ធនៃសារធាតុរបស់វា<br>> កំណត់នូវថ្នាំកសិកម្មមួយចំនួនដែលមិនអនុញ្ញាតឱ្យប្រើប្រាស់<br>> ធ្វើពិសោធន៍បង្ហាញពីប្រសិទ្ធភាពនៃថ្នាំកសិកម្មដើម្បីកំចាត់សត្វល្អិត និងជំងឺនៅតាមស្រែកសិករ<br>> ផ្សព្វផ្សាយវិធីប្រើថ្នាំកសិកម្មប្រកបដោយប្រសិទ្ធភាពដល់មន្ត្រីកសិកម្មថ្នាក់ខេត្ត និងកសិករ |
| គំរោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យទីប្រជុំជន ខេត្ត-ក្រុង (២០០៣-២០០៨) | WB | ផ្តល់ទឹកស្អាតជូនប្រជាជនក្រីក្រតាមទីជនបទ ខេត្ត-ក្រុង | > នាយកដ្ឋានទឹកស្អាត នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អាគារលេខ ៤៥ វិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ<br>ទូរស័ព្ទ : (៨៥៥) ២៣ ២១០ ២៧២<br>អ៊ីម៉ែល : Watersector@bigpond.com.kh | > រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ | > កំពុងសិក្សា និងដាក់ដេញថ្លៃសាងសង់ជាជំហាន១ |

| ឈ្មោះគំរោង និងពេលវេលាអនុវត្តន៍ | ភ្នាក់ងារផ្តល់ជំនួយ | គោលបំណង | អង្គភាព/ស្ថាប័នទទួលបន្ទុកអនុវត្តន៍គំរោងផ្ទាល់ | អង្គភាព/ស្ថាប័នចូលរួមសហការអនុវត្តន៍គំរោង | សកម្មភាពពាក់ព័ន្ធក្នុងគំរោង |
|---|---|---|---|---|---|
| អភិវឌ្ឍន៍វិស័យទឹកស្អាតនៅខេត្ត-ក្រុង (២០០០ - ២០០៥) | ADB | បង្កើនការផ្គត់ផ្គង់ទឹកស្អាតតាមខេត្ត-ក្រុង | > នាយកដ្ឋានទឹកស្អាត នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អាគារលេខ ៤៥ វិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ<br>ទូរស័ព្ទ : (៨៥៥) ២៣ ២១០ ២៧២<br>អ៊ីម៉ែល : Watersector@bigpond.com.kh | > រដ្ឋាករទឹកស្វ័យតខេត្ត-ក្រុង | > បានអនុវត្តនៅតាមខេត្ត-ក្រុងជាជំហាន១ |
| បង្កើនផលិតកម្មស្អាតក្នុងវិស័យឧស្សាហកម្មនៅកម្ពុជា (២០០៤-២០០៧)<br>(Promotion of Cleaner Industrial Production in the Kingdom of Cambodia) | UNIDO | ធ្វើឱ្យមានការយល់ដឹងពីផលិតកម្មស្អាត និងជំរុញការអនុវត្តផលិតកម្មស្អាតនៅតាមបណ្តារោងចក្រ និងសហគ្រាសនៅកម្ពុជា | > នាយកដ្ឋានបច្ចេកទេសឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អាគារលេខ ៤៥ វិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ | > ក្រសួងបរិស្ថាន | > កំពុងរៀបចំដំណើរការ |
| គំរោងរៀបចំច្បាប់ស្តង់ដារឧស្សាហកម្ម (២០០៣-២០០៤) | UNIDO | រៀបចំច្បាប់ស្តីពីស្តង់ដារនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីមាត្រសាស្ត្រជាតិ | > នាយកដ្ឋានស្តង់ដារឧស្សាហកម្មឧស្សាហកម្មកម្ពុជា នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អាគារលេខ ៤៥ វិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ<br>ទូរស័ព្ទ : (៨៥៥) ២៣ ២១៦ ០៨៦<br>អ៊ីម៉ែល : discinfo@camnet.com.kh | | > សេចក្តីព្រាងច្បាប់ស្តង់ដារកម្ពុជាបានបញ្ចប់ នឹងកំពុងរង់ចាំការអនុម័ត |

បច្ចុប្បន្ននេះកម្ពុជាពុំមានគោលនយោបាយជាក់លាក់ណាមួយដើម្បីកំណត់លក្ខខ័ណ្ឌ ឬដាក់វិធានការទៅលើគំរោងជំនួយដែលអាចមានផលប៉ះពាល់ដល់ការគ្រប់គ្រងសារធាតុគីមីឡើយ ។ រាល់គំរោងជំនួយឥតសំណងទាំងអស់ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់លទ្ធភាពខ្ពស់ជាងគេដើម្បីសំរួលដល់ការអនុវត្តគំរោង ។ រាជរដ្ឋាភិបាលធ្វើការត្រួតពិនិត្យត្រឹមតែលទ្ធផលដែលទទួលបាន ថាតើវាសមស្របតាមកិច្ចព្រមព្រៀង ឬអនុស្សារណៈយោគយល់ដែរឬទេ ហើយបន្ទាប់មកធ្វើជាអនុសាសន៍ដើម្បីកែលំអរហូតដល់ទទួលជោគជ័យស្របតាមកម្មវត្ថុដែលបានកំណត់ ។ រដ្ឋាភិបាលនឹងមិនធ្វើសវនកម្មហិរញ្ញវត្ថុចំពោះគំរោងជំនួយឥតសំណងទេ ។

ដូចដែលបានបញ្ជាក់ក្នុងជំពូកទី ៦ រួចមកហើយថា រដ្ឋាភិបាលមិនបានកំណត់ជានីតិវិធីសំរាប់ការសំរបសំរួលគំរោងជំនួយឥតសំណងទេ តែការសំរបសំរួលនានាធ្វើឡើងតាមរយៈមុខងារសហគ្រប់គ្រង ការចុះអនុស្សរណៈយោគយល់ កិច្ចព្រមព្រៀងភាពជាដៃគូ ការចុះកិច្ចសន្យានិងការយល់ស្របជាមួយគ្នាជាលាយល័ក្ខអក្សរ គឺសំដៅមិនឱ្យមានការជាន់សកម្មភាពគ្នាឡើយ ។

ចំពោះគំរោងជំនួយជាប្រាក់កម្ចី រដ្ឋាភិបាលមានកំណត់នីតិវិធីច្បាស់លាស់ណាស់ ។ គំរោងខ្ចីប្រាក់ពីបរទេសអាចធ្វើទៅបានទាល់តែមានការអនុមតិពីសភាជាតិជាមុនសិន ។ ការធ្វើសវនកម្មហិរញ្ញវត្ថុ និងការត្រួតពិនិត្យលទ្ធផលនៃការអនុវត្តគំរោង គឺជាភារកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃប្រទេសកម្ពុជា ។ បច្ចុប្បន្ននេះ កម្ពុជាមិនទាន់មានគំរោងខ្ចីប្រាក់សំរាប់ការងារគ្រប់គ្រងសារធាតុគីមីទេ ។

## ១១.៣ យោបល់ និងការវិភាគ

ពិនិត្យជារួម សកម្មភាពអនុវត្តការងាររបស់កម្ពុជា គឺពុំទាន់ឆ្លើយតបទៅនឹងសេចក្តីតំរូវរបស់កិច្ចព្រមព្រៀងអន្តរជាតិទាំងស្រុងនៅឡើយទេ ។ មូលហេតុសំខាន់ត្រង់ថា កម្ពុជានៅមានកង្វះខាតរចនាសម្ព័ន្ធគ្រប់គ្រងសារធាតុគីមី ព្រមទាំងការខ្វះខាតនូវធនធានមនុស្សយ៉ាងច្រើនក្នុងវិស័យគីមី ។ ទាំងមន្ត្រីរដ្ឋាភិបាលនិងប្រជាពលរដ្ឋ ជាទូទៅមិនទាន់មានការយល់ដឹងឱ្យស៊ីជំរៅពីបញ្ហានិងការគ្រប់គ្រងសារធាតុគីមី ។ ហេតុដូចនេះហើយ កម្ពុជាបានទទួលស្គាល់ថាការកសាងសមត្ថភាពជាតិនាពេលបច្ចុប្បន្នសំរាប់ការគ្រប់គ្រងសារធាតុគីមី ជាដំណោះស្រាយយ៉ាងសំខាន់និងបន្ទាន់ដើម្បីធានាឱ្យមានការគ្រប់គ្រងមួយដែលមានប្រសិទ្ធភាពនិងសុវត្ថិភាព និងឆ្លើយតបទៅនឹងកិច្ចព្រមព្រៀងអន្តរជាតិនានា ។

កម្ពុជាបានបង្កលក្ខណៈងាយស្រួល និងសំរបសំរួលបានល្អនូវកិច្ចព្រមព្រៀង និងសកម្មភាពអន្តរជាតិនានា ស្តីពីការគ្រប់គ្រងសារធាតុគីមីក៏ដូចជាកម្មវិធីការងារផ្សេងទៀតដែរ ។ម្យ៉ាងទៀតរាជរដ្ឋាភិបាលកម្ពុជាក៏បានគាំទ្រយ៉ាងខ្លាំងក្លា និងបានយកចិត្តទុកដាក់ក្នុងការបញ្ចូលកម្មវិធីការងាររបស់បណ្តាអង្គការអន្តរជាតិនានាទៅក្នុងកម្មវិធីជាតិ ក្នុងគោលដៅនៃការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនិងការកាត់បន្ថយភាពក្រីក្រ ព្រមទាំងការធ្វើឱ្យប្រសើរឡើងដល់សុខភាពប្រជាជន និងសុវត្ថិភាពបរិស្ថាន ។ ដោយឡែកនៅតាមស្ថាប័នរដ្ឋដែលមានទំនាក់ទំនងផ្ទាល់ជាមួយបណ្តាអង្គការអន្តរជាតិនានា គណៈកម្មការសំរបសំរួលថ្នាក់ជាតិដែលបានបង្កើតឡើងមានការសំរបសំរួលបានល្អ ហើយរួមគ្នាកំណត់បញ្ហាដែលទាក់ទងគីមី ព្រមទាំងដាក់ចេញនូវវិធានការជាក់លាក់មួយក្នុងការកសាងសមត្ថភាពស្ថាប័នរដ្ឋាភិបាល និងភាគីពាក់ព័ន្ធផលប្រយោជន៍នានាសំរាប់អនុវត្តន៍គំរោងគ្រប់គ្រងសារធាតុគីមី ក្រោមការគាំទ្រពីភ្នាក់ងារអ្នកផ្តល់ជំនួយអន្តរជាតិឱ្យទទួលបានជោគជ័យ ។

សំរាប់ជាគោលគំនិតទូទៅ កម្ពុជាបានរៀបចំជាគណៈកម្មការសំរបសំរួលអន្តរក្រសួងមួយចំនួន ដើម្បីអនុវត្តរាល់ជំនួយអន្តរជាតិដែលពាក់ព័ន្ធ នេះជានីតិវិធីដែលកម្ពុជាបានរៀបចំ ។ ការទទួលខុសត្រូវរបស់គណៈកម្មការទាំងនោះ អាចជាការធានារួមគ្នាមួយរបស់គ្រប់ភាគីពាក់ព័ន្ធមានលក្ខណៈជាបរិធានច្បាប់សំរាប់ការការពារសុខភាព និងសុវត្ថិភាពបរិស្ថាន ។

ដើម្បីលើកកំពស់ប្រសិទ្ធិភាពនៃកម្មវិធីជំនួយអន្តរជាតិនាពេលបច្ចុប្បន្ន កម្ពុជាមានអនុសាសន៍មួយចំនួនដូចខាងក្រោម:

- ជំរុញដំណើរការធ្វើផែនការដោយមានការចូលរួមក្នុងចំណោមកម្មវិធីជំនួយអន្តរជាតិ ជាពិសេសរួមជាមួយស្ថាប័នរដ្ឋ ។
- លើកកំពស់សមត្ថភាពក្នុងស្រុកក្នុងការចូលរួមអនុវត្តន៍ផែនការ ។
- យកចិត្តទុកដាក់បន្ថែមទៀតក្នុងការចូលរួមធ្វើការងារជាមួយយន្តការសំរបសំរួលដែលមានស្រាប់ ។
- ចែករំលែកនូវបទពិសោធន៍ និងពត៌មានដែលទទួលបានពីកម្មវិធីនានា ដែលបាននឹងកំពុងអនុវត្តន៍ ។
- កម្មវិធីជំនួយអន្តរជាតិនានាត្រូវចូលរួមផ្តល់យោបល់ឱ្យស្ថាប័នរដ្ឋក្នុងការអនុវត្តច្បាប់ ឃ្លាំមើលពីខាងក្រៅ និងចូលរួមក្នុងការវាយតំលៃផលប៉ះពាល់ពីសារធាតុគីមី និងសកម្មភាពអភិបាលកិច្ច ។
- កម្មវិធីជំនួយអន្តរជាតិនានាដែលមកធ្វើការក្នុងប្រទេសកម្ពុជា ត្រូវចេះសំរបសំរួលតាមកាលៈទេសៈ និងលក្ខខ័ណ្ឌក្នុងស្រុក ។
- ផ្តល់ឱកាសដល់បុគ្គលិកបច្ចេកទេសរដ្ឋាភិបាលឱ្យធ្វើការជាមួយកម្មវិធីនានាដែលពាក់ព័ន្ធ គឺអាចសំរួលឱ្យ :
  - ការប្រាស្រ័យទាក់ទងគ្នាមានភាពល្អប្រសើរ ។
  - ការកំណត់អាទិភាពនៃបញ្ហាបានត្រឹមត្រូវ ។
  - ការសំរេចនូវគោលបំណងរួមក្នុងការការពារសុខមាលភាពប្រជាជន និងធានាដល់សុវត្ថិភាពបរិស្ថាន ។
  - ការកសាងសមត្ថភាពដល់បុគ្គលិកក្នុងស្រុកឱ្យមានសមត្ថភាពធ្វើការងារជាមួយកំរិតអន្តរជាតិ ។

រាជរដ្ឋាភិបាលយល់ឃើញថា បើអាចដោះស្រាយនិងអនុវត្តតាមអនុសាសន៍ដែលលើកឡើងខាងលើបាន នោះនឹងគ្មានឧបសគ្គអ្វីជាសំខាន់ក្នុងការអនុវត្តនូវកម្មវិធីជំនួយ ឬកិច្ចព្រមព្រៀងអន្តរជាតិនានានៅកម្ពុជាឡើយ ។

# ឯកសារយោង

១- របាយការណ៍សន្និបាតសុខាភិបាលឆ្នាំ ២០០១ របស់ក្រសួងសុខាភិបាល

២- ស្ថិតិកសិកម្មឆ្នាំ ២០០០-២០០១ របស់នាយកដ្ឋានផែនការស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៣- ស្ថិតិកសិកម្មឆ្នាំ ១៩៨០-២០០០ របស់នាយកដ្ឋានផែនការស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៤- របាយការណ៍សន្និបាតស្តីពីកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ ២០០៣ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៥- របាយការណ៍បូកសរុបការងារឧស្សាហកម្ម រ៉ែ និងថាមពលប្រចាំឆ្នាំ ២០០១ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

៦- របាយការណ៍បូកសរុបការងារបរិស្ថានប្រចាំឆ្នាំ ២០០២ នៃក្រសួងបរិស្ថាន

៧- របាយការណ៍បូកសរុបការងារឧស្សាហកម្ម រ៉ែ និងថាមពលប្រចាំឆ្នាំ ២០០៣ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

៨- ទស្សនទានមូលដ្ឋានសំរាប់ការស្តារឡើងវិញ និងការអភិវឌ្ឍន៍នៃវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទពីឆ្នាំ ១៩៩៦-២០០០ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៩- ការធ្វើអង្កេតផ្នែកសុខភាព និងប្រជាសាស្ត្រនៅកម្ពុជាឆ្នាំ ២០០០ នៃក្រសួងសុខាភិបាល

១០- យុទ្ធសាស្ត្រផ្នែកថាមពលកម្ពុជាឆ្នាំ ១៩៩៩ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

១១- សារាចរណែនាំរបស់អគ្គនាយកដ្ឋានថាមពលឆ្នាំ ២០០២ ស្តីពីទិសដៅសំរាប់ការអភិវឌ្ឍន៍វិស័យថាមពល នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

១២- ការវាយតំលៃផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ៥ ឆ្នាំលើកទី ១ (១៩៩៦-២០០០) និងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ៥ ឆ្នាំលើកទី ២ (២០០១-២០០៥) នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

១៣- ការចុះបញ្ជីរោងចក្រឆ្នាំ២០០២ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

១៤- ស្ថិតិជលផលឆ្នាំ ១៩៨០-២០០០ របស់នាយកដ្ឋានជលផល ឆ្នាំ២០០១

១៥- ផែនការវិស័យសុខាភិបាលឆ្នាំ ២០០២ នៃក្រសួងសុខាភិបាល

១៦- ការអង្កេតលើកំលាំងពលកម្មនៅកម្ពុជាឆ្នាំ ២០០១ របស់វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ

១៧- ឯកសារបមាណី និងការគ្រប់គ្រងសំភារកសិកម្ម ឆ្នាំ ២០០១ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

១៨- ផលិតផលក្នុងស្រុកឆ្នាំ ២០០៣ នៃក្រសួងសុខាភិបាល

១៩- របាយការណ៍ស្ថិតិជាតិលើវិស័យសុខាភិបាលឆ្នាំ ២០០០ របស់នាយកដ្ឋានផែនការ និងពត៌មានសុខាភិបាល នៃក្រសួងសុខាភិបាល

២០- ថ្នាំកសិកម្ម និងបញ្ហារបស់វាឆ្នាំ ២០០០ គោលការណ៍ណែនាំសំរាប់កសិករ និងអ្នកផ្សព្វផ្សាយ ស៊ីដាក់

២១- របាយការណ៍ការគ្រប់គ្រងសំណល់មន្ទីរពេទ្យរាជធានីភ្នំពេញឆ្នាំ ២០០១ នៃក្រសួងបរិស្ថាន

២២- ព្រឹត្តប័ត្រប្រចាំឆ្នាំស្តីពីតំលៃផលិតផលកសិកម្មលេខ ៤ ឆ្នាំ ២០០១ របស់ការិយាល័យទីផ្សារកសិកម្ម នាយកដ្ឋានផែនការស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

២៣- ការផលិតថាមពលអគ្គិសនីខេត្ត-ក្រុងឆ្នាំ ២០០២ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

២៤- របាយការណ៍ការអង្កេតលើសេដ្ឋកិច្ច-សង្គមនៅកម្ពុជាឆ្នាំ ១៩៩៩ របស់វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ

២៥- ស្ថិតិប្រចាំឆ្នាំ ២០០៣ របស់វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ

២៦- កម្មវិធីគ្រប់គ្រងសំណល់នៅកម្ពុជាឆ្នាំ ២០០២-២០០៦ នាយកដ្ឋានត្រួតពិនិត្យការបំពុល នៃក្រសួងបរិស្ថាន

២៧- Guidance Document on Preparing a National Profile to Assess the National Infrastructure for Management of Chemicals, UNITAR

២៨- Guidance Note on Preparing/Updating a National Profile as Part of a Stockholm Convention National Implementation Plan, UNITAR, January 2003




**ក្រសួងបរិស្ថាន**
**នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន**

អាគារ៤៨ វិថីសម្តេចព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ : (855) 23 210 493
ទូរសារ : (855) 23 220 392
អ៊ីម៉ែល : moepcd@online.com.kh
: nip_pops@online.com.kh
គេហទំព័រ : www.moe.gov.kh/cambodia-sc